# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា
### គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ

# ឯកសារណែនាំ
# ស្តីពី
# វិធីសាស្ត្រនៃការវាយតម្លៃនិងការទទួលស្គាល់
# សាលាបឋមសិក្សានិងអនុវិទ្យាល័យគំរូ ឆ្នាំ២០២៥

"សាលារៀនរដ្ឋផ្តល់សេវាជូនប្រជាជនកាន់តែប្រសើរឡើង"

**ឆ្នាំ ២០២៥**

# អារម្ភកថា

រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ស្វាហាប់ និងឈ្លាសវៃ ប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលជាអគ្គមគ្គុទេសក៍វ័យក្មេងដ៏ឆ្នើម ពោរពេញដោយសមត្ថភាព និងថាមពល បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដើម្បី «កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព» ស្របតាមអភិក្រម «ជីវភាពនៃប្រព័ន្ធតួអង្គតែមួយ» ដើម្បីកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា «ក្លាយជាប្រទេសមានចំណូលខ្ពស់» ត្រឹមឆ្នាំ២០៥០។

ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវកម្មវិធីកែទម្រង់ជាបន្តបន្ទាប់ ដែលក្នុងនោះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាការដ្ឋានកែទម្រង់ស្នូលមួយរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុសាធារណៈឱ្យដើរតួនាទីដ៏សំខាន់ សំដៅចូលរួមធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងថវិកា ព្រមទាំងការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន។ កម្មវិធីនេះ បានរួមចំណែកបង្កើតសមិទ្ធផលជាប្រវត្តិសាស្ត្រជាច្រើននៅកម្ពុជា ទាំងសមិទ្ធផលក្នុងការកែលម្អអភិបាលកិច្ចនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផ្ទាល់ និងទាំងសមិទ្ធផលក្នុងទិដ្ឋភាពនៃការរីកចម្រើនផ្នែកសង្គម-សេដ្ឋកិច្ចរបស់កម្ពុជា ជាពិសេស ការបន្តរក្សានូវសន្តិភាព សន្តិសុខ ស្ថិរភាពនយោបាយ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រឹងមាំ, ដែលទាំងអស់នេះ គឺជាមូលដ្ឋានមិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍប្រទេស។

ទន្ទឹមនឹងការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលនៅតែបន្តផ្តល់អាទិភាពខ្ពស់លើការវិនិយោគក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល។ ជាក់ស្តែង, វិស័យអប់រំនៅតែជាវិស័យគន្លឹះនៅក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល ក្នុងនីតិកាលទី៧ នៃរដ្ឋសភា ដោយផ្តោតជាសំខាន់ទៅលើការពង្រឹងគុណភាពវិស័យអបរំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា តាមរយៈការបង្កើតបរិយាកាសល្អសម្រាប់ការអប់រំ និងការបណ្តុះបណ្តាលប្រកបដោយគុណភាព និងជំនាញខ្ពស់។

កន្លងមក រាជរដ្ឋាភិបាលបានដាក់ចេញនូវយន្តការគណៈកម្មការវាយតម្លៃអង្គភាពសេវាសាធារណៈថ្នាក់ជាតិក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ដើម្បីចូលរួមជំរុញ និងលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវាសាធារណៈរបស់អង្គភាព តាមរយៈការផ្តល់ការលើកទឹកចិត្ត ព្រមទាំងការទទួលស្គាល់ពីរាជរដ្ឋាភិបាល។ លទ្ធផលពីការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈគំរូនេះ ផ្តល់នូវធាតុចូលសំខាន់ៗ ក្នុងការកែលម្អអភិបាលកិច្ច ក្នុងគោលបំណងលើកកម្ពស់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ព្រមទាំងបង្កើនជំនឿទុកចិត្តពីប្រជាជនកម្ពុជា។ ក្នុងស្មារតី

ខាងលើនេះ ខ្ញុំពិតជាមានក្តីរំភើប និងសូមកោតសរសើរដោយស្មោះចំពោះគំនិត ក្នុងការរៀបចំឱ្យមានជាឯកសារណែនាំស្តីពីវិធីសាស្ត្រនៃការវាយតម្លៃ និងការទទួលស្គាល់អនុវិទ្យាល័យនេះ។

ខ្ញុំជឿជាក់ថា ឯកសារណែនាំស្តីពីវិធីសាស្ត្រនៃការវាយតម្លៃនិងការទទួលស្គាល់អនុវិទ្យាល័យ ដោយបង្ហាញនិងពន្យល់លម្អិតអំពីលក្ខណៈវិនិច្ឆ័យតាមសូចនាករនីមួយៗ នឹងរួមចំណែកបង្កើនគុណភាព និងភាពទាន់ពេលនៃការផ្តល់សេវាសាធារណៈនៅមូលដ្ឋាន ដែលសបញ្ជាក់ឱ្យឃើញនូវការខិតខំរបស់ស្ថាប័នរាជរដ្ឋាភិបាល, អង្គភាពពាក់ព័ន្ធ និងសហគមន៍មូលដ្ឋាន ក្នុងការគាំទ្រការផ្តល់គុណភាពសេវាសាធារណៈ ជូនប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរ។ ទន្ទឹមនេះ ឯកសារនេះនឹងក្លាយជាមគ្គុទេសក៍អភិបាលកិច្ចសាធារណៈដ៏មានគុណប្រយោជន៍មួយសម្រាប់អង្គភាពផ្តល់សេវាអប់រំ និងសេវាសុខាភិបាល ព្រមទាំងអង្គភាពផ្តល់សេវាសាធារណៈផ្សេងទៀត ដើម្បីអាចដកស្រង់ជាបទពិសោធន៍ និងជាធាតុចូលនៃការគ្រប់គ្រងអង្គភាព និងការផ្តល់សេវាសាធារណៈ។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មីនា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយភាពស្វាហាប់ ឈ្លាសវៃនិងចក្ខុវិស័យដ៏វែងឆ្ងាយរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ជាផែនទីចង្អុលផ្លូវលើការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព សំដៅកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចគោលដៅឆ្នាំ២០៣០ ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ និងចក្ខុវិស័យឆ្នាំ២០៥០ ជាប្រទេសមានចំណូលខ្ពស់។ ដើម្បីសម្រេច ចក្ខុវិស័យប្រកបដោយមហិច្ឆតានេះ រាជរដ្ឋាភិបាល បានសម្រេចឆន្ទៈយ៉ាងមោះមុតបន្តអនុវត្តការកែទម្រង់គ្រប់ផ្នែកគ្រប់វិស័យឱ្យកាន់តែមានលក្ខណៈទូលំទូលាយ និងស៊ីជម្រៅ ក្នុងគោលដៅធ្វើឱ្យកម្ពុជាមានភាពសុខដុម និងការអភិវឌ្ឍប្រកបដោយចីរភាព។ ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់វិស័យអប់រំ និងការកែទម្រង់វិស័យសុខាភិបាល ត្រូវបានកំណត់ជាវិធានការគន្លឹះ សម្រាប់គាំទ្រដល់ការអនុវត្ត និងការសម្រេចបាននូវកម្មវិធីនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល។

ដើម្បីចូលរួមអនុវត្ត និងសម្រេចឱ្យបាននូវវិធានការគន្លឹះសំខាន់ទាំងបីខាងលើរបស់រាជរដ្ឋាភិបាល គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ(គ.វ.ជ.) បាននិងកំពុងបំពេញការងារយ៉ាងសកម្មក្នុងការពង្រឹងនិងលើកកម្ពស់អភិបាលកិច្ចនិងគុណភាពសេវារបស់អង្គភាពផ្តល់សេវាអប់រំ និងសុខាភិបាលមូលដ្ឋាន រួមមានសាលាមត្តេយ្យសិក្សា រហូតដល់វិទ្យាល័យសម្រាប់វិស័យអប់រំ និងមណ្ឌលសុខភាពរហូតដល់មន្ទីរពេទ្យបង្អែកផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត៣ សម្រាប់វិស័យសុខាភិបាល តាមរយៈការអនុវត្តអនុក្រឹត្យស្តីពីការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល។

ការរៀបចំ និងដាក់ឱ្យអនុវត្តឯកសារណែនាំស្តីពីវិធីសាស្ត្រនៃការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូ គឺជាកិច្ចការចាំបាច់មួយសម្រាប់គាំទ្រដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាពសុក្រឹតភាព និងយុត្តិធម៌ ក្នុងការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល។ ឯកសារនេះ អាចប្រើប្រាស់សម្រាប់អង្គភាពជាគោលដៅនៃការវាយតម្លៃ និងអ្នកពាក់ព័ន្ធជាផែនទីបង្ហាញផ្លូវក្នុងការកែលម្អការគ្រប់គ្រង និងការផ្តល់សេវានៃអង្គភាពរបស់ខ្លួន ត្រៀមលក្ខណៈបានល្អប្រសើរសម្រាប់ចូលរួមការប្រឡងប្រណាំងអង្គភាពផ្តល់សេវាសាធារណៈគំរូ ព្រមទាំងឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាជន និងការរួមចំណែកសម្រេចបាននូវបញ្ចកោណទី១ **"ការអភិវឌ្ឍមូលធនមនុស្ស"** នៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា។

ខ្ញុំសង្ឃឹម និងជឿជាក់ថា ឯកសារណែនាំនេះ នឹងត្រូវប្រើប្រាស់យ៉ាងទូលំទូលាយ ជាមគ្គុទ្ទេសក៍គោលដ៏សំខាន់សម្រាប់ការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល និងកិច្ចការនានាដែលរួមចំណែកដល់ការអភិវឌ្ឍសាលារៀន និងមន្ទីរពេទ្យមូលដ្ឋានគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្នុងនាមគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ ខ្ញុំសូមអំពាវនាវដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសអង្គភាពគោលដៅសម្រាប់ការវាយតម្លៃ បន្តចូលរួមយ៉ាងសកម្មបន្ថែមទៀតក្នុងចលនាប្រឡងប្រណាំងអង្គភាពផ្តល់សេវាសាធារណៈគំរូនេះ និងប្រើប្រាស់ឯកសារនេះ តាមភារកិច្ចរៀងៗខ្លួន ដើម្បីចូលរួមចំណែកលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃសេវាអប់រំ និងសេវាសុខាភិបាលមូលដ្ឋានឱ្យកាន់តែប្រសើរជូនប្រជាជន ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា។

ថ្ងៃព្រហស្បតិ៍ ៤កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មីនា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**និងជាប្រធានគ.វ.ជ.**

**ហ៊ុន ម៉ានី**

# អារម្ភកថា

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ជាបន្តបន្ទាប់ក្នុងគោលបំណងពង្រឹងគុណភាពអប់រំ និងការផ្តល់សេវាអប់រំប្រកបដោយបរិយាបន្ន និងសមធម៌ ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលអាណត្តិទី៧ ក្នុងការបណ្តុះបណ្តាលនូវធនធានមនុស្ស មានគុណវុឌ្ឍិខ្ពស់ មានវិជ្ជាជីវៈច្បាស់លាស់ប្រកបដោយគំនិតច្នៃប្រឌិត ស្របទៅតាមការរីកចម្រើននៃបច្ចេកវិទ្យាឌីជីថល សេដ្ឋកិច្ចសង្គម និងការវិវត្តនៅក្នុងតំបន់ និងពិភពលោក។ ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់យកកំណែទម្រង់ជាអាទិភាពសំខាន់ៗចំនួនបី រួមមាន៖ ១)ការដាក់ឱ្យអនុវត្តនូវកម្មវិធីសិក្សាថ្មីនៅតាមសាលារៀន ២) កំណែទម្រង់នៃការបណ្តុះបណ្តាលគ្រូបង្រៀន និងពង្រឹងគុណវឌ្ឍិនៃការបណ្តុះបណ្តាលគ្រូបង្រៀន និង៣)ការអនុវត្តការគ្រប់គ្រងនៅតាមសាលារៀន ដើម្បីពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាអប់រំនៅកម្រិតសាលារៀន។

ជាមួយគ្នានេះផងដែរ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញឱ្យអនុវត្តស្តង់ដាសាលារៀនគំរូនៅគ្រប់ភូមិសិក្សាចាប់ពីកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅ ដោយផ្តោតលើស្តង់ដាសំខាន់ចំនួន៥ រួមមាន **ស្តង់ដាទី១៖** លទ្ធផលការសិក្សារបស់សិស្ស **ស្តង់ដាទី២៖** ការបង្រៀន និងរៀន **ស្តង់ដាទី៣៖** ការចូលរួមរបស់សហគមន៍ **ស្តង់ដាទី៤៖** ដំណើរការប្រតិបត្តិការ និងរដ្ឋបាលសាលារៀន និង**ស្តង់ដាទី៥៖** គណនេយ្យភាពសាលារៀន។

តាំងនាមឱ្យក្រសួងអប់រំ យុវជន និងកីឡា ខ្ញុំសូមគាំទ្រ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់រាជរដ្ឋាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ ដែលបានផ្តួចផ្តើមគំនិតបង្កើតឱ្យមានកម្មវិធីវាយតម្លៃ និងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ ដើម្បីជំរុញ ក៏ដូចជាលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពអប់រំ និងលើកទឹកចិត្តដល់ការខិតខំប្រឹងប្រែងរបស់គ្រឹះស្ថានសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា ជឿជាក់ និងសង្ឃឹមយ៉ាងមុតមាំថា ឯកសារណែនាំស្តីពីវិធីសាស្ត្រនៃការវាយតម្លៃ និងទទួលស្គាល់សាលាបឋមសិក្សា និងអនុវិទ្យាល័យ ជាអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនឹងចូលរួមចំណែកក្នុងការរៀបចំ និងកែលម្អគ្រឹះស្ថានសិក្សារបស់ខ្លួន ចូលរួមប្រកួតប្រជែងសាលាបឋមសិក្សា និងអនុវិទ្យាល័យ ជាអង្គភាពផ្តល់សេវាសាធារណៈគំរូ និងជាត្រីវិស័យដល់គ្រឹះស្ថានសិក្សាក្នុងការពង្រឹងការផ្តល់សេវាអប់រំ ការដឹកនាំ និងគ្រប់គ្រង ការបង្រៀន និងរៀន ការកែលម្អបរិស្ថានសិក្សា និងការចូលរួមចំណែកពីសំណាក់មាតាបិតា អាណាព្យាបាល និងសហគមន៍នៅតាមគ្រប់កម្រិតគ្រឹះស្ថានសិក្សា។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ[illegible] ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

# បញ្ជីរាយនាមសមាសភាពក្រុមការងារ

ក្រុមការងារដឹកនាំ តែងនិពន្ធ និងរៀបចំ **ឯកសារណែនាំស្តីពីវិធីសាស្ត្រនៃការវាយតម្លៃនិងការទទួលស្គាល់សាលាបឋមសិក្សា និងអនុវិទ្យាល័យគំរូ** មានសមាសភាពដូចខាងក្រោមៈ

**ក. ក្រុមការងារដឹកនាំនិងត្រួតពិនិត្យ**

| | | |
|---|---|---|
| ១. ឯកឧត្តម | **ហ៊ុន ម៉ានី** | រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈនិងជាប្រធាន គ.វ.ជ. |
| ២. ឯកឧត្តម | **យក់ ប៊ុនណា** | រដ្ឋលេខាធិការប្រចាំការក្រសួងមុខងារសាធារណៈនិងជាអនុប្រធានប្រចាំការនៃ គ.វ.ជ. |
| ៣. ឯកឧត្តម | **ចាន់ សុធី** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាអនុប្រធាននៃ គ.វ.ជ. |
| ៤. ឯកឧត្តម | **អ៊ុត សំអន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃនិងជាសមាជិកនៃ គ.វ.ជ. |
| ៥. ឯកឧត្តម | **អ៊ីន វីរជាតិ** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រីនិងជាសមាជិកនៃ គ.វ.ជ. |
| ៦. ឯកឧត្តម | **ស៊ិក ប៊ុណ្ណា** | រដ្ឋលេខាធិការក្រសួងសុខាភិបាលនិងជាសមាជិកនៃ គ.វ.ជ. |
| ៧. ឯកឧត្តម | **ចាយ សាមិត្ត** | រដ្ឋលេខាធិការក្រសួងបរិស្ថាននិងជាសមាជិកនៃ គ.វ.ជ. |
| ៨. ឯកឧត្តម | **ឆាយ ឆត្រាវុធ** | រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ |
| ៩. ឯកឧត្តម | **ចាន់ សុជា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនិងជាសមាជិកនៃ គ.វ.ជ. |
| ១០. ឯកឧត្តម | **ថោង ប៉ូវ៉ាន់** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា និងជាសមាជិកនៃ គ.វ.ជ. |
| ១១. ឯកឧត្តម | **យ៉េត វីណែល** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាអគ្គលេខាធិការរងនៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងជាសមាជិកនៃ គ.វ.ជ. |
| ១២. ឯកឧត្តមបណ្ឌិត | **ជ័យ សារិន** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា និងជាសមាជិកនៃគ.វ.ជ. |
| ១៣. ឯកឧត្តម | **ឈុន សុជាតិ** | អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈនៃក្រសួងមុខងារសាធារណៈ |
| ១៤. លោកវេជ្ជបណ្ឌិត | **កុំ សំសុង** | ប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិកក្រសួងសុខាភិបាលនិងជាសមាជិកនៃ គ.វ.ជ. |
| ១៥. ឯកឧត្តម | **សៀត វិចិត្រ** | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈនិងជាលេខាធិការនៃ គ.វ.ជ. |
| ១៦. ឯកឧត្តម | **ប្រាក់ ម៉ូវ** | អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈនៃក្រសួងមុខងារសាធារណៈ |

ខ. ក្រុមការងារនិពន្ធនិងរៀបចំអត្ថបទ

១. ឯកឧត្តមបណ្ឌិត **ជ័យ សារិន** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា

២. លោកជំទាវ **នាង លីណា** អនុរដ្ឋលេខាធិការនៃក្រសួងមុខងារសាធារណៈ

៣. ឯកឧត្តម **យន ម៉ាលីមឆេង** ទីប្រឹក្សានៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងជាជំនួយការសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី

៤. លោក **លន គឹមហេង** អគ្គនាយករងនៃអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈនៃក្រសួងមុខងារសាធារណៈ

៥. លោក **ព្រីង មរកត** អគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំនៃក្រសួងអប់រំ យុវជន និងកីឡា

៦. លោក **ហ៊ី ឌីណារក្ស** ប្រធាននាយកដ្ឋានអប់រំ ការងារ វប្បធម៌ ធម្មការ និងសាសនា នៃទីស្តីការគណៈរដ្ឋមន្ត្រី

៧. លោក **ប៉ូល អម្រិតកិត្យា** ប្រធាននាយកដ្ឋានគោលនយោបាយសេវាសាធារណៈនៃក្រសួងមុខងារសាធារណៈ

៨. លោក **ស្រី ម៉ារ៉ូណា** អនុប្រធាននាយកដ្ឋានរង្វាន់និងលើកទឹកចិត្តនៃក្រសួងបរិស្ថាន

៩. លោក **តូច ថុន** អនុប្រធាននាយកដ្ឋានមុខងារនិងធនធាននៃក្រសួងមហាផ្ទៃ

១០. លោក **ជា ម៉េង** ប្រធានការិយាល័យថវិកាវិស័យសង្គមកិច្ចទី១ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

១១. លោកស្រី **ពៅ ជីតា** ប្រធានការិយាល័យនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

១២. លោក **ប៊ុនថន ប៊ុនឆៃ** ប្រធានការិយាល័យនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

១៣. លោក **ជ័យ រតនា** អនុប្រធានលេខាធិការដ្ឋាននៃអគ្គាធិការដ្ឋាន នៃក្រសួងអប់រំ យុវជន និងកីឡា

១៥. លោក **ប៊ុន ហៃ** អនុប្រធានការិយាល័យថវិកាវិស័យសង្គមកិច្ចទី១ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

១៦. លោក **យ៉ែម មករា** មន្ត្រីនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នៃក្រសួងអប់រំ យុវជន និងកីឡា

# មាតិកា


**អារម្ភកថាឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ............ I

**អារម្ភកថាឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ** ................. III

**អារម្ភកថាឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** .......... V

**បញ្ជីរាយនាមសមាសភាពក្រុមការងារ** ........................................ VI

**មាតិកា** ........................................ VIII

**សេចក្តីផ្តើម** ........................................ ១

**ផ្នែកទី១៖ ស្តង់ដាសេវាសាធារណៈ** ........................................ ២

១.១ គុណភាពព័ត៌មាន ........................................ ៣

១.២ ភាពងាយស្រួលក្នុងការទទួលយកសេវា ........................................ ១០

១.៣ ភាពយកចិត្តទុកដាក់ក្នុងការទទួលអ្នកប្រើប្រាស់សេវា ........................................ ១៥

១.៤ ការផ្តល់សេវាតាមគោលការណ៍កំណត់ និងអភិបាលកិច្ចល្អ ........................................ ១៩

**ផ្នែកទី២៖ ស្តង់ដាបទដ្ឋានសមិទ្ធិកម្មនៃការផ្តល់សេវាសាធារណៈក្នុងវិស័យអប់រំ** .................. ២២

២.១ ការដឹកនាំ និងការគ្រប់គ្រងសាលារៀន ........................................ ២៣

២.២ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាជានាឱ្យមានគុណភាព សមធម៌ និងបរិយាបន្ននៅក្នុងសាលារៀន .. ៤៥

២.៣ គុណវុឌ្ឍិ និងជំនាញវិជ្ជាជីវៈបុគ្គលិកអប់រំ ........................................ ៥០

**ផ្នែកទី៣៖ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងអង្គភាព** ................................ ៦២

៣.១ ភាពជឿទុកចិត្តនៃថវិកា និងការពង្រឹងស្វ័យភាពហិរញ្ញវត្ថុ ........................................ ៦៣

៣.២ ប្រព័ន្ធគ្រប់គ្រងគណនេយ្យ និងទ្រព្យសម្បត្តិរដ្ឋ ........................................ ៧២

៣.៣ ការតាមដាន និងការត្រួតពិនិត្យ ........................................ ៧៨

**ផ្នែកទី៤៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅក្នុងអង្គភាព** .................... ៨២

៤.១ ការគ្រប់គ្រងធនធានមនុស្ស ........................................ ៨៣

**ផ្នែកទី៥៖ ការរៀបចំ និងកែលម្អបរិស្ថានអង្គភាព** ........................................ ៩៤

៥.១ ការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន ភាពស្អាត សុខភាពនិងអនាម័យ ............................ ៩៥

៥.២ ការអនុវត្តដើម្បីសោភណភាពក្នុងបរិវេណសាលារៀន ........................................ ៩៧

៥.៣ ទីតាំងលេងកំសាន្ត និងគ្រប់គ្រងកាកសំណល់ ........................................ ១០៤

៥.៤ ការប្រើប្រាស់ទឹកស្អាត និងអនាម័យ ចំណីអាហារដែលលក់ដូរក្នុងបរិវេណសាលារៀន ...... ១០៨

**ផ្នែកទី៦៖ ទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍព្រមទាំងការចូលរួមវាយតម្លៃពីអ្នកប្រើប្រាស់សេវាសាធារណៈ** ........................................ ១១២

៦.១ ការពង្រឹងទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ អាជ្ញាធរ និងដៃគូអភិវឌ្ឍ ........... ១១៣

៦.២ ការអភិវឌ្ឍកុមារ/យុវជន ........................................ ១១៩
**ផ្នែកទី៧៖ ការដោះស្រាយបញ្ហាប្រឈមជាមួយប្រជាពលរដ្ឋ អាជ្ញាធរ និងសហគមន៍** ១២២
៧.១ យន្តការទទួលព័ត៌មានត្រឡប់ និងបណ្ដឹងតវ៉ា ........................................ ១២៣
៧.២ ការអនុវត្តវិធានការឆ្លើយតបទៅនឹងបញ្ហាប្រឈមនានា ស្របតាមស្ថានភាពជាក់ស្តែង ...... ១២៦
**ផ្នែកទី៨៖ ការផ្តួចផ្តើមគំនិតថ្មីៗ និងនវានុវត្តន៍ដើម្បីធ្វើឱ្យអភិបាលកិច្ចមានដំណើរការកាន់តែប្រសើរឡើង** ........................................ ១២៩
៨.១.ការបញ្ជ្រាបការយល់ដឹងនិងការអនុវត្តគំនិតនវានុវត្តន៍និងការច្នៃប្រឌិតក្នុងអង្គភាពផ្តល់សេវា ១៣០
៨.២. ការធ្វើឱ្យមាននិរន្តរភាពការអនុវត្ត គំនិតនវានុវត្តន៍ដែលទទួលបានជោគជ័យ និងចែករំលែកជាមួយអង្គភាពដទៃ ........................................ ១៣៤
**សេចក្តីសន្និដ្ឋាន** ........................................ ១៣៦
**គន្លនិទ្ទេស** ........................................ ១៣៧

# ឯកសារណែនាំស្តីពីវិធីសាស្ត្រនៃការវាយតម្លៃនិងការទទួលស្គាល់សាលាបឋមសិក្សានិងអនុវិទ្យាល័យគំរូ

## សេចក្តីផ្តើម

**អរគុណសន្តិភាព** សមិទ្ធផលគ្រប់វិស័យបានរីកដុះដាលនិងអភិវឌ្ឍឥតឈប់ឈរ ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**។ ក្រោមម្លប់សន្តិភាព កម្ពុជាបានឆ្លងកាត់ពីស្ថានភាពក្នុងឋានៈជាប្រទេសដែលមានចំណូលទាបមកជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ព្រមទាំងបាន និងកំពុងពង្រឹងសាមគ្គីភាពគ្រប់ផ្នែកនៃសង្គមជាតិឈានទៅកាន់ឋានៈជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍនិងមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងនីតិកាលទី៧នៃរដ្ឋសភា**។ វិស័យអប់រំដែលជាគ្រឹះនៃការបណ្តុះថ្នាលបញ្ញវន្តប្រកបដោយសមត្ថភាព មនសិការជាតិ និងសីលធម៌ ត្រូវបានកំណត់ជាវិស័យអាទិភាព និងយុទ្ធសាស្ត្រសម្រាប់ជំរុញល្បឿនក្នុងការនាំកម្ពុជាសម្រេចគោលដៅទាំងនេះ។ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តគាំទ្រដល់ការអប់រំ សមត្ថភាពនិងចំនួនបុគ្គលិកអប់រំ ប្រាក់បៀវត្ស វិធីសាស្ត្រនៃការបង្រៀននិងរៀន និងប្រព័ន្ធនៃការគ្រប់គ្រងការបណ្តុះបណ្តាលអប់រំនៅគ្រប់កម្រិតសិក្សាត្រូវបានកសាង និងកែលម្អជាបន្តបន្ទាប់ឆ្លើយតបនឹងតម្រូវការការរីកចម្រើននៃសង្គមជាតិ និងការវិវត្តផ្នែកបច្ចេកវិទ្យាក្នុងបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤។ សាលាបឋមសិក្សា និងអនុវិទ្យាល័យ ដែលជាគ្រឹះស្ថានសិក្សាមូលដ្ឋាន ក៏មានការរីកចម្រើននិងកំពុងផ្តល់សេវាកាន់តែប្រសើរឡើង ក្រោមការគាំទ្រពីប្រជាជន អាជ្ញាធរគ្រប់លំដាប់ថ្នាក់ សហគមន៍ អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ។

ដើម្បីរួមចំណែកក្នុងការលើកកម្ពស់គុណភាពអប់រំនៅកម្រិតសាលាបឋមសិក្សានិងអនុវិទ្យាល័យ គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ បានសម្រេចកំណត់យកភូមិសិក្សាទាំងពីរខាងលើជាគោលដៅនៃការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូ បន្ទាប់ពីវិទ្យាល័យ និងសាលាមត្តេយ្យសិក្សាដែលត្រូវបានអនុវត្តនៅឆ្នាំ២០២៤។ ការចូលរួមក្នុងចលនាប្រឡងប្រណាំងនេះ នឹងធ្វើឱ្យសាលាបឋមសិក្សានិងអនុវិទ្យាល័យនៅទូទាំងប្រទេស អភិវឌ្ឍខ្លួនកាន់តែលឿននិងធ្វើឱ្យប្រជាពលរដ្ឋកាន់តែពេញចិត្តនិងជឿទុកចិត្តលើសេវាសាធារណៈនេះ។

ឯកសារណែនាំស្តីពីវិធីសាស្ត្រនៃការវាយតម្លៃនិងការទទួលស្គាល់សាលាបឋមសិក្សានិងអនុវិទ្យាល័យគំរូត្រូវបានរៀបចំដើម្បីជួយដល់គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុវត្តតួនាទីវាយតម្លៃក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ជួយដល់អង្គភាពជាគោលដៅនៃការវាយតម្លៃក្នុងការរៀបចំខ្លួនចូលរួមដាក់ពាក្យប្រឡងប្រណាំង ព្រមទាំងជួយបង្ហាញផ្លូវជាមូលដ្ឋាននិងទិសដៅនៃការអភិវឌ្ឍសាលារៀននៅភូមិសិក្សាទាំងពីរទៅជាអង្គភាពផ្តល់សេវាអប់រំសាធារណៈគំរូផងដែរ។

ឯកសារណែនាំនេះ ត្រូវបានរៀបចំជាប្រាំបីផ្នែកស្របតាមលក្ខណៈវិនិច្ឆ័យគោលទាំងប្រាំបីនៃតារាងវាយតម្លៃនិងទទួលស្គាល់សាលាបឋមសិក្សា និងអនុវិទ្យាល័យគំរូ ព្រមទាំងផ្តល់នូវសេចក្តីពន្យល់នូវលក្ខណៈវិនិច្ឆ័យរងនីមួយៗ មធ្យោបាយសម្រាប់ប្រើជាមូលដ្ឋានក្នុងការវាយតម្លៃ និងវិធីសាស្ត្រក្នុងការវាយតម្លៃ ឬការដាក់ពិន្ទុក្នុងការវាយតម្លៃ។

# ផ្នែកទី១៖ ស្តង់ដាសេវាសាធារណៈ

## ១. ស្តង់ដាសេវាសាធារណៈ (១១៥ពិន្ទុ)

ស្តង់ដាសេវាសាធារណៈ គឺជាម៉ែត្រវាស់កម្រិតគុណភាព និងចរិតលក្ខណៈនៅក្នុងការផ្តល់សេវាសាធារណៈដើម្បីទទួលបាននូវការពេញចិត្តពីសំណាក់អ្នកប្រើប្រាស់សេវាតាមលក្ខខណ្ឌកំណត់(ដូចជានីតិវិធី ពេលវេលា តម្លៃ និងទីកន្លែង) និងឆ្លើយទៅនឹងតម្រូវការរបស់អ្នកប្រើប្រាស់សេវា[1]។ ការកំណត់ស្តង់ដាសេវាសាធារណៈជាលក្ខណៈវិនិច្ឆ័យគោលមួយនៃការវាយតម្លៃគឺដើម្បីជំរុញឱ្យសាលារៀនធានាភាពងាយស្រួលក្នុងការទទួលយកសេវា ផ្តល់សេវាដោយផ្តោតលើតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ លើកកម្ពស់តម្លាភាពនិងគណនេយ្យភាពក្នុងការផ្តល់សេវា និងជំរុញការលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការផ្តល់សេវាជាប្រចាំ។

នៅក្នុងផ្នែកស្តង់ដាសេវាសាធារណៈ មានពិន្ទុសរុបចំនួន ១១៥ ដែលមានលក្ខណៈវិនិច្ឆ័យរងចំនួន៤ គឺ៖

**១. គុណភាពព័ត៌មាន (៤០ពិន្ទុ)**

**២. ភាពងាយស្រួលក្នុងការទទួលយកសេវា (៣៥ពិន្ទុ)**

**៣. ភាពយកចិត្តទុកដាក់ក្នុងការទទួលអ្នកប្រើប្រាស់សេវា (២៥ពិន្ទុ)**

**៤. ការផ្តល់សេវាតាមគោលការណ៍កំណត់ និងអភិបាលកិច្ចល្អ (១៥ពិន្ទុ)**

---

[1] ឧបសម្ព័ន្ធទី២ នៃ អនុក្រឹត្យលេខ ៤៥៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិវាយតម្លៃសេវាសាធារណៈ

## ១.១ គុណភាពព័ត៌មាន (៤០ពិន្ទុ)

- ***សេចក្ដីពន្យល់៖*** គុណភាពព័ត៌មានរបស់សាលារៀនសំដៅដល់ការផ្ដល់ព័ត៌មានអំពីសេវាអប់រំ តាមរយៈការផ្សព្វផ្សាយផ្ដល់ជូនអ្នកប្រើប្រាស់សេវាប្រកបដោយលក្ខណៈងាយយល់ ងាយទទួលយក និងជឿទុកចិត្តបាន។

### ១.១.១ បទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសេវា (១០ពិន្ទុ)

➢ <u>មានរក្សាទុកបទដ្ឋានគតិយុត្តពាក់ព័ន្ធសម្រាប់អ្នកប្រើប្រាស់សេវាអាចពិនិត្យផ្ទៀងផ្ទាត់អំពីសេវា</u>

- ***សេចក្ដីពន្យល់៖*** សំដៅដល់បទដ្ឋានគតិយុត្តទាំងអស់ដែលពាក់ព័ន្ធនឹងសេវានិងការគ្រប់គ្រងសាលារៀន មានដូចជាច្បាប់ អនុក្រឹត្យ ប្រកាស សេចក្ដីណែនាំ និងបទបញ្ជាផ្ទៃក្នុង។ល។ ត្រូវបានរក្សាទុកដាក់ដោយមានសណ្ដាប់ធ្នាប់ ងាយស្រួលក្នុងការរកឃើញ និងអាចផ្ដល់ជូនអ្នកប្រើប្រាស់សេវាទាំងក្នុងសាលារៀន ទាំងអ្នកប្រើប្រាស់សេវាពីខាងក្រៅអាចពិនិត្យផ្ទៀងផ្ទាត់បាន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)បន្ទប់ ឬទូសម្រាប់ផ្ទុកឯកសារ ២)របៀប និងសណ្ដាប់ធ្នាប់នៃការរៀបចំនិងធ្វើចំណាត់ថ្នាក់និងប្រភេទឯកសារ ៣)ក្រូណូដាក់ឯកសារ និង ៤)របៀបនៃការរក្សាឯកសារបទដ្ឋានគតិយុត្តពាក់ព័ន្ធសេវាសាលា(ច្បាប់ស្ដីពីការអប់រំនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ច្បាប់ស្ដីពីការបង្កើតក្រសួង អនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា ផែនការយុទ្ធសាស្ត្រវិស័យអប់រំ គោលនយោបាយអប់រំ អនុក្រឹត្យស្ដីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន សេចក្ដីណែនាំ របាយការណ៍ផ្សេងៗរបស់សាលា)។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានបន្ទប់ ឬទូសមរម្យប្រកបដោយសុវត្ថិភាពសម្រាប់ទុកដាក់ឯកសារបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យអប់រំ និងសេវារបស់សាលារៀន |
| ពិន្ទុ ១ | មានឯកសារបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យអប់រំ និងសេវារបស់សាលារៀនរក្សាទុកនៅក្នុងបន្ទប់ ឬទូសម្រាប់ផ្ទុកឯកសារ |
| ពិន្ទុ ១ | មានការរៀបចំឯកសារបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យអប់រំ និងសេវារបស់សាលារៀនទៅតាមប្រភេទ កាលបរិច្ឆេទ(ដាក់ក្នុងក្រូណូ)និងប្រកបដោយសណ្ដាប់ធ្នាប់ |
| ពិន្ទុ ១ | មានការរៀបចំជាបញ្ជីកាឯកសារបទដ្ឋានគតិយុត្តប្រកបដោយបច្ចុប្បន្នភាព (ក្នុងក្រូណូនីមួយៗ) |
| ពិន្ទុ ១ | មានឯកសារបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសេវារបស់សាលារៀនរក្សាទុកនៅកន្លែងដែលមានភាពងាយស្រួលដល់អ្នកប្រើប្រាស់សេវាក្នុងការស្នើសុំពិនិត្យ និងមានមន្ត្រីទទួលបន្ទុកគ្រប់គ្រងឯកសារប្រចាំការ ឬបញ្ជីកាឯកសារបទដ្ឋានគតិយុត្តប្រកបដោយបច្ចុប្បន្នភាពរក្សាទុកក្នុងប្រព័ន្ធអេឡិកត្រូនិក |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** បទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសេវារបស់សាលា ទី១-ច្បាប់ស្តីពីការអប់រំ ឬព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ទី២-អនុក្រឹត្យលេខ១២៦ស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ទី៣-អនុក្រឹត្យលេខ១០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧ ស្តីពីការកម្រិតរបបម៉ោងកំណត់ ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែមសម្រាប់ការបង្រៀនក្នុងគ្រឹះស្ថានសិក្សាសាធារណៈ ទី៤-សេចក្តីណែនាំលេខ២៥៦ ស្តីពីនិយាមប្រើប្រាស់មន្ត្រីរាជការសម្រាប់សាលាមត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាចំណេះទូទៅនិងសាលាគរុកោសល្យ ទី៥-សេចក្តីណែនាំស្តីពីដំណើរការគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈតាមឆ្នាំសិក្សានីមួយៗ ទី៦-សេចក្តីណែនាំលេខ០៨ស្តីពីនីតិវិធីកែតម្រូវវិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាបឋមភូមិ ចំណេះទូទៅ និងបំពេញវិជ្ជា ទី៧-សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា ទី៨-ផែនទីបង្ហាញផ្លូវការអប់រំនៅកម្ពុជាឆ្នាំ២០៣០ ។ល។

➢ <u>បានរៀបចំស្តង់ដាផ្តល់សេវារដ្ឋបាល និងបទបញ្ជាផ្ទៃក្នុងរៀបចំដោយសាលារៀនតាមភាពជាក់ស្តែង និងប្រកបដោយប្រសិទ្ធភាព</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការរៀបចំឱ្យមានស្តង់ដាផ្តល់សេវារដ្ឋបាលរបស់សាលារៀន និងការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់សាលាសម្រាប់បុគ្គលិកអប់រំទាំងអស់(ទាំងគ្រូបង្រៀន បុគ្គលិកបំពេញការងាររដ្ឋបាល ព្រមទាំងសិស្ស) ដើម្បីបង្ហាញពីការប្តេជ្ញាចិត្តរបស់សាលារៀនក្នុងការផ្តល់សេវាប្រកបដោយគុណភាព។ ក្នុងករណីដែលសាលាមានអន្តេវាសិកដ្ឋាន ត្រូវមានបទបញ្ជាផ្ទៃក្នុងដោយឡែកសម្រាប់គ្រូ និងសិស្សស្នាក់នៅអន្តេវាសិកដ្ឋាន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ខិត្តប័ណ្ណ បណ្ណប្រកាស ឬឯកសារបញ្ជាក់អំពីស្តង់ដាផ្តល់សេវារដ្ឋបាល និងបទបញ្ជាផ្ទៃក្នុងរបស់សាលារៀន ២)របាយការណ៍នៃកិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកប្រើប្រាស់សេវា និងគណៈកម្មការគ្រប់គ្រងសាលារៀន/ក្រុមប្រឹក្សាភិបាល/គណៈកម្មការទ្រទ្រង់សាលារៀនស្តីពីការរៀបចំបទបញ្ជាផ្ទៃក្នុង និងស្តង់ដាសេវារដ្ឋបាលរបស់សាលារៀន ៣)ការអង្កេតពីលទ្ធផលនៃការអនុវត្តស្តង់ដា និងបទបញ្ជាផ្ទៃក្នុងរបស់សាលារៀន និង៤)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានការកំណត់ស្តង់ដាផ្តល់សេវារដ្ឋបាលដែលសាលារៀនផ្តល់ដោយផ្ទាល់ (ឧទាហរណ៍ និយាមនៃឥរិយាបថទទួលអ្នកប្រើប្រាស់សេវា រយៈពេលផ្តល់លិខិតបញ្ជាក់ការសិក្សា លិខិតបញ្ជាក់ការផ្ទេរចូល ការផ្ទេរចេញ) |
| ពិន្ទុ ២ | មានការកំណត់បទបញ្ជាផ្ទៃក្នុង រៀបចំដោយសាលាសម្រាប់បុគ្គលិកអប់រំ និងសិស្ស |

| | |
|---|---|
| ពិន្ទុ ១ | ស្តង់ដាផ្តល់សេវារដ្ឋបាលរបស់សាលារៀន និងបទបញ្ញាផ្ទៃក្នុងសម្រាប់បុគ្គលិកអប់រំនិងសិស្ស ត្រូវបានរៀបចំដោយមានការពិគ្រោះយោបល់ជាមួយអ្នកប្រើប្រាស់សេវា គ្រូបង្រៀន និងគណៈកម្មការគ្រប់គ្រងសាលារៀន/ក្រុមប្រឹក្សាភិបាល/គណៈកម្មការទ្រទ្រង់សាលារៀន |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ចំណុចដែលត្រូវពិនិត្យគឺបទបញ្ញាផ្ទៃក្នុង និងស្តង់ដាផ្តល់សេវារដ្ឋបាលដែលសាលារៀនបានរៀបចំឡើងសម្រាប់បុគ្គលិកអប់រំ និងសិស្ស អនុលោមតាមអនុក្រឹត្យ ប្រកាស សេចក្តីណែនាំ សេចក្តីសម្រេចរបស់ក្រសួងបានត្រឹមត្រូវ ហើយមិនផ្ទុយនឹងបទដ្ឋានគតិយុត្តជាធរមាន។

### ១.១.២ ការផ្សព្វផ្សាយព័ត៌មានអំពីសេវា (២០ពិន្ទុ)

➤ **បានផ្សព្វផ្សាយផែនការអភិវឌ្ឍរបស់សាលារៀន**

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបចំផែនការអភិវឌ្ឍសាលារៀន ឬផែនការកែលម្អសាលារៀនដោយមានការចូលរួមគាំទ្រពីគណៈកម្មការគ្រប់គ្រងសាលារៀន បុគ្គលិកអប់រំ មាតាបិតាឬអ្នកអាណាព្យាបាលសិស្ស សហគមន៍ និងអាជ្ញាធរមូលដ្ឋាន ព្រមទាំងមានការផ្សព្វផ្សាយទូលំទូលាយ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ផែនការអភិវឌ្ឍសាលារៀន ឬផែនការកែលម្អសាលារៀន ២)ទំហំក្តារខៀន ឬតារាង ឬផ្ទាំងព័ត៌មានអំពីផែនការអភិវឌ្ឍសាលារៀនឬផែនការកែលម្អសាលារៀន ឬសេចក្តីសង្ខេប ឬប្លង់នៃផែនការអភិវឌ្ឍសាលារៀន ៣)ទីកន្លែងបិទផ្សាយក្តារខៀន ឬតារាង ឬផ្ទាំងព័ត៌មានអំពីផែនការអភិវឌ្ឍសាលារៀនឬផែនការកែលម្អសាលារៀន ឬសេចក្តីសង្ខេប ឬប្លង់នៃផែនការអភិវឌ្ឍសាលារៀន និង៤)របាយការណ៍ស្តីពីកិច្ចប្រជុំពិភាក្សាលើគម្រោងផែនការអភិវឌ្ឍ ឬផែនការកែលម្អសាលារៀនដែលមានសមាសភាពចូលរួមពីតំណាងពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានការបិទផ្សាយព័ត៌មានអំពីផែនការអភិវឌ្ឍសាលារៀនឬផែនការកែលម្អសាលារៀនក្នុងទម្រង់ជាក្រដាសA4 ឬរបាយការណ៍ស្តីពីកិច្ចប្រជុំពិភាក្សាលើគម្រោងផែនការអភិវឌ្ឍ ឬផែនការកែលម្អសាលារៀនដែលមានសមាសភាពចូលរួមពីអ្នកពាក់ព័ន្ធ |
| ពិន្ទុ ១ | មានការបិទផ្សាយព័ត៌មានអំពីផែនការអភិវឌ្ឍសាលារៀនឬផែនការកែលម្អសាលារៀននៅផ្នែកជួរមុខឬមុខទីចាត់ការ ឬនៅកន្លែងដទៃក្នុងបរិវេណសាលារៀន |
| ពិន្ទុ ១ | មានការដាក់បង្ហាញផ្ទាំងព័ត៌មានអំពីផែនការអភិវឌ្ឍសាលារៀនឬផែនការកែលម្អសាលារៀនក្នុងទំហំធំសមរម្យ អក្សរច្បាស់ងាយដល់អ្នកប្រើប្រាស់សេវាពិនិត្យផ្ទៀងផ្ទាត់បិទផ្សាយនៅក្រៅបរិវេណសាលារៀន (សាលាឃុំ/សាលាក្រុង-ស្រុក-ខណ្ឌ ។ល។) |

| | |
|---|---|
| ពិន្ទុ ២ | មានការបិទឬផ្សព្វផ្សាយខ្លឹមសារសង្ខេបនៃផែនការអភិវឌ្ឍសាលារៀន ឬផែនការកែលម្អសាលារៀន (ជាខិត្តប័ណ្ណ ឬក្រដាសបត់ ឬបណ្ណប្រកាស) |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ <u>បានផ្សព្វផ្សាយព័ត៌មានអំពីប្រភេទសេវា ឯកសារតម្រូវ និងលក្ខខណ្ឌក្នុងការទទួលបានសេវាសាលារៀន</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបចំឱ្យមានការផ្សព្វផ្សាយព័ត៌មានអំពីប្រភេទសេវា ឯកសារតម្រូវ ទម្រង់ពាក្យស្នើសុំសេវា និងលក្ខខណ្ឌនានាដែលអ្នកប្រើប្រាស់សេវាត្រូវបំពេញ ដើម្បីទទួលបានសេវានីមួយៗ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ក្តារខៀន ឬតារាង ឬផ្ទាំងព័ត៌មានអំពីប្រភេទសេវា ឯកសារតម្រូវ ទម្រង់ពាក្យស្នើសុំសេវា និងលក្ខខណ្ឌក្នុងការទទួលសេវា ២)ទំហំក្តារខៀន ឬតារាង ឬផ្ទាំងព័ត៌មាន ៣)ទីកន្លែងបិទផ្សាយក្តារខៀន ឬតារាង ឬផ្ទាំងព័ត៌មានអំពីប្រភេទសេវា ឯកសារតម្រូវ ទម្រង់ពាក្យស្នើសុំសេវា និងលក្ខខណ្ឌក្នុងការទទួលសេវា។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានការបិទផ្សាយព័ត៌មានអំពីប្រភេទសេវាទាំងអស់ និងឯកសារតម្រូវក្នុងទម្រង់ជាក្រដាស A4 |
| ពិន្ទុ ១ | មានការបិទផ្សាយព័ត៌មានអំពីទម្រង់ពាក្យស្នើសុំសេវាទាំងអស់ និងលក្ខខណ្ឌដើម្បីទទួលបានសេវានីមួយៗ(ឈ្មោះ/វាយមុខសេវា កម្រៃសេវា និងលក្ខខណ្ឌផ្សេងៗ)នៅផ្នែកជួរមុខឬមុខទីចាត់ការ ឬនិងនៅកន្លែងដទៃក្នុងបរិវេណសាលារៀន |
| ពិន្ទុ ១ | មានការបិទផ្សាយព័ត៌មានអំពីប្រភេទសេវាទាំងអស់ ឯកសារតម្រូវ ទម្រង់ពាក្យស្នើសុំសេវា និងលក្ខខណ្ឌដើម្បីទទួលបានសេវានីមួយៗ ក្នុងទំហំធំសមរម្យ អក្សរច្បាស់ ងាយដល់អ្នកប្រើប្រាស់សេវាពិនិត្យផ្ទៀងផ្ទាត់ (ជាផ្ទាំងព័ត៌មាន ឬបដា) |
| ពិន្ទុ ១ | មានការបិទផ្សាយព័ត៌មានអំពីប្រភេទសេវាទាំងអស់ ឯកសារតម្រូវ ទម្រង់ពាក្យស្នើសុំសេវានិងលក្ខខណ្ឌដើម្បីទទួលបានសេវានីមួយៗនៅក្រៅបរិវេណសាលារៀន (សាលាឃុំ/សាលាក្រុង-ស្រុក-ខណ្ឌ ។ល។) |
| ពិន្ទុ ១ | មានការបិទឬផ្សព្វផ្សាយព័ត៌មានអំពីប្រភេទសេវា ឯកសារតម្រូវ ទម្រង់ពាក្យស្នើសុំសេវា និងលក្ខខណ្ឌដើម្បីទទួលបានសេវា(ជាខិត្តប័ណ្ណ ឬក្រដាសបត់ ឬបណ្ណប្រកាសដែលអាចចែកជូនអ្នកប្រើប្រាស់សេវា) |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** សេវារបស់សាលារៀនមានដូចជា៖ ការចុះឈ្មោះចូលរៀន ប្រឡងឡើងថ្នាក់ ប្រឡងឡើងវិញ លិខិតបញ្ជាក់ការសិក្សា លិខិតបញ្ជាក់ការផ្ទេរចូល ការផ្ទេរចេញ លក្ខខណ្ឌនិងវិធានការដោះស្រាយចំពោះសិស្សមករៀនយឺតឬអវត្តមានហួសចំនួនពេលកំណត់ លក្ខខណ្ឌសិស្សក្រីក្រឬពិការ ដើម្បីទទួលបានការបំពាក់បំប៉នបន្ថែម ឬស្នាក់នៅអន្តេវាសិកដ្ឋានជាដើម។

- បានផ្សព្វផ្សាយព័ត៌មានអំពីម៉ោងបំពេញការងារ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលរបស់សាលារៀន

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបចំឱ្យមានការផ្សព្វផ្សាយនូវព័ត៌មានអំពីម៉ោងបំពេញការងាររបស់បុគ្គលិកអប់រំ និងនីតិវិធី ឬចរន្ត ឬរំហូរនៃការផ្តល់សេវារដ្ឋបាលរបស់សាលារៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ក្តារខៀន ឬតារាង ឬផ្ទាំងព័ត៌មានអំពីម៉ោងបំពេញការងាររបស់បុគ្គលិកអប់រំ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាល ២)ទំហំក្តារខៀន ឬតារាង ឬផ្ទាំងព័ត៌មាន និង៣)ទីកន្លែងបិទផ្សាយក្តារខៀន ឬតារាង ឬផ្ទាំងព័ត៌មានអំពីម៉ោងបំពេញការងាររបស់បុគ្គលិកអប់រំ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាល។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានការបិទផ្សាយព័ត៌មានអំពីម៉ោងបំពេញការងាររបស់បុគ្គលិកអប់រំក្នុងទម្រង់ជាក្រដាស A4 |
| ពិន្ទុ ១ | មានការបិទផ្សាយព័ត៌មានអំពីនីតិវិធី (មានបង្ហាញនូវរំហូរ ឬចរន្ត) នៃដំណើរការផ្តល់សេវារដ្ឋបាលរបស់សាលារៀននៅផ្នែកជួរមុខឬមុខទីចាត់ការ ឬនៅកន្លែងដទៃក្នុងបរិវេណសាលារៀន |
| ពិន្ទុ ១ | មានការបិទផ្សាយព័ត៌មានអំពីម៉ោងបំពេញការងាររបស់បុគ្គលិកអប់រំ និងនីតិវិធី (មានបង្ហាញនូវរំហូរ ឬចរន្ត) នៃដំណើរការផ្តល់សេវារដ្ឋបាលរបស់សាលារៀនក្នុងទំហំធំសមរម្យ អក្សរច្បាស់ងាយដល់អ្នកប្រើសេវាពិនិត្យផ្ទៀងផ្ទាត់(ជាផ្ទាំងព័ត៌មាន ឬបដា) |
| ពិន្ទុ ១ | មានការបិទផ្សាយព័ត៌មានអំពីម៉ោងបំពេញការងាររបស់បុគ្គលិកអប់រំ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលនៅក្រៅបរិវេណសាលារៀន(សាលាឃុំ/សាលាក្រុង-ស្រុក-ខណ្ឌ។ល។) |
| ពិន្ទុ ១ | មានការបិទឬផ្សព្វផ្សាយព័ត៌មានអំពីម៉ោងបំពេញការងាររបស់បុគ្គលិកអប់រំ និងនីតិវិធី (មានបង្ហាញនូវរំហូរ ឬចរន្ត)នៃដំណើរការផ្តល់សេវារដ្ឋបាល(ជាខិត្តប័ណ្ណ ឬក្រដាសបត់ ឬបណ្ណប្រកាសដែលអាចចែកជូនអ្នកប្រើប្រាស់សេវា) |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** សាលារៀនអាចបិទផ្សាយព័ត៌មានអំពីម៉ោងពេលបំពេញការងាររបស់បុគ្គលិកអប់រំ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលក្នុងផ្ទាំងតែមួយឬដាច់ដោយឡែកពីគ្នា ស្របទៅតាមស្ថានភាពជាក់ស្តែងនៃកន្លែងបិទផ្សាយ។

- បានផ្សព្វផ្សាយព័ត៌មានអំពីមធ្យោបាយទំនាក់ទំនងរបស់សាលារៀន

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបចំឱ្យមានការផ្សព្វផ្សាយព័ត៌មានអំពីមធ្យោបាយទំនាក់ទំនងនានារបស់ខ្លួន ដើម្បីផ្តល់ឱកាសឱ្យអ្នកប្រើប្រាស់សេវា(សិស្ស មាតាបិតា អ្នកអាណាព្យាបាល ឬអ្នកពាក់ព័ន្ធ) អាចធ្វើទំនាក់ទំនងជាមួយសាលារៀន តាមរយៈមធ្យោបាយមួយចំនួនដូចជា ទំនាក់ទំនងដោយផ្ទាល់ជាមួយបុគ្គលិកប្រចាំការ សៀវភៅតាមដានការសិក្សារបស់សិស្ស កិច្ចប្រជុំឬវេទិកាសាធារណៈ ទូរសព្ទ គេហទំព័រ បណ្តាញទំនាក់ទំនងសង្គមជាដើម។

- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ផ្ទាំងព័ត៌មានអំពីមធ្យោបាយទំនាក់ទំនងរបស់សាលារៀនមានដូចជាលេខទូរសព្ទរបស់បុគ្គលិកប្រចាំការ ទូរសព្ទ គេហទំព័រ ឬបណ្តាញទំនាក់ទំនងសង្គមរបស់សាលារៀន ២)ទំហំផ្ទាំងព័ត៌មាន ៣)ទីកន្លែងបិទផ្សាយផ្ទាំងព័ត៌មានអំពីមធ្យោបាយទំនាក់ទំនងរបស់សាលារៀន និង៤)សៀវភៅតាមដានការសិក្សារបស់សិស្ស។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានការបិទផ្សាយព័ត៌មានអំពីមធ្យោបាយទំនាក់ទំនងរបស់សាលារៀនក្នុងទម្រង់ជាក្រដាស A4 នៅផ្នែកជួរមុខឬមុខទីចាត់ការនិងនៅកន្លែងដទៃក្នុងបរិវេណសាលារៀន |
| ពិន្ទុ ១ | មានការបិទផ្សាយព័ត៌មានអំពីមធ្យោបាយទំនាក់ទំនងរបស់សាលារៀននៅក្រៅបរិវេណសាលារៀន (សាលាឃុំ/សាលាក្រុង-ស្រុក-ខណ្ឌ។ល។) |
| ពិន្ទុ ១ | បានបិទផ្សាយព័ត៌មានអំពីមធ្យោបាយទំនាក់ទំនងរបស់សាលារៀន បានគ្រប់មធ្យោបាយទំនាក់ទំនងរបស់សាលារៀន(ដូចជាលេខទូរសព្ទរបស់បុគ្គលិកប្រចាំការ ទូរសព្ទ គេហទំព័រ ឬបណ្តាញទំនាក់ទំនងសង្គមរបស់សាលារៀន(ជាខិត្តប័ណ្ណ ឬក្រដាសបត់ ឬបណ្ណប្រកាសដែលអាចចែកជូនអ្នកប្រើប្រាស់សេវា) |
| ពិន្ទុ ១ | មានការដាក់បង្ហាញផ្ទាំងព័ត៌មានអំពីមធ្យោបាយទំនាក់ទំនងរបស់សាលារៀនក្នុងទំហំធំសមរម្យ អក្សរច្បាស់ងាយដល់អ្នកប្រើប្រាស់សេវាពិនិត្យផ្ទៀងផ្ទាត់(ជាផ្ទាំងព័ត៌មាន ឬបដា) |
| ពិន្ទុ ១ | សៀវភៅតាមដានរបស់សិស្សមានដាក់លេខទូរសព្ទទំនាក់ទំនងរបស់សាលារៀន (គណៈគ្រប់គ្រងសាលារៀន គ្រូប្រចាំថ្នាក់ ឬមន្ត្រីទទួលបន្ទុករដ្ឋបាលសាលារៀន និងអ្នកអាណាព្យាបាលសិស្ស) |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** សាលារៀនគួរកំណត់ឱ្យមានលេខទូរសព្ទសម្រាប់ទំនាក់ទំនងជាមួយគ្រូបន្ទុកថ្នាក់ និងគណៈគ្រប់គ្រងសាលារៀន ដើម្បីបង្កភាពងាយស្រួលដល់មាតាបិតា ឬអ្នកអាណាព្យាបាលសិស្សក្នុងការទំនាក់ទំនងជាមួយសាលារៀន។

### ១.១.៣ មធ្យោបាយផ្សព្វផ្សាយព័ត៌មានអំពីសេវា (១០ពិន្ទុ)

➢ <u>បានផ្សព្វផ្សាយព័ត៌មានតាមប្រព័ន្ធមិនមែនអេឡិចត្រូនិក(ឧគ្ឃោសនសព្ទ កម្រងព័ត៌មានស្តីពីសេវាសាធារណៈ ព្រឹត្តិបត្រព័ត៌មាន សារព័ត៌មាន ផ្សព្វផ្សាយតាមសហគមន៍ ខិត្តប័ណ្ណ និងការផ្សាយនៅហ្នឹងកន្លែងជាដើម)</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានប្រើប្រាស់មធ្យោបាយមិនមែនជាអេឡិចត្រូនិកផ្សេងៗ ដើម្បីផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការផ្តល់សេវារបស់ខ្លួនជូនអ្នកប្រើប្រាស់សេវា ប្រជាពលរដ្ឋ សហគមន៍ ដៃគូអភិវឌ្ឍ និងអាជ្ញាធរដែនដី។ មធ្យោបាយនៃការផ្សព្វផ្សាយមិនមែនជាអេឡិចត្រូនិកមានដូចជាកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ ឧគ្ឃោសនសព្ទ កម្រងព័ត៌មានស្តីពីសេវាសាធារណៈ

ព្រឹត្តិបត្រព័ត៌មាន សារព័ត៌មាន ខិត្តប័ណ្ណ បណ្ណប្រកាស ក្ដារខៀនព័ត៌មានឬបិទផ្សាយនៅតាមទីតាំងក្នុងសាលា ការដង្ហែក្បួន ឬក្រុមការងារស្ម័គ្រចិត្តរបស់សាលា។

- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ មធ្យោបាយនៃការផ្សព្វផ្សាយមិនមែនជាអេឡិចត្រូនិក ដែលសាលារៀនបានប្រើប្រាស់ដូចជាកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ ឧគ្ឃោសនសព្ទ កម្រងព័ត៌មានស្ដីពីសេវាសាធារណៈ ព្រឹត្តិបត្រព័ត៌មាន សារព័ត៌មាន ខិត្តប័ណ្ណ បណ្ណប្រកាស ក្ដារខៀនព័ត៌មានឬបិទផ្សាយនៅតាមទីតាំងក្នុងសាលា ការដង្ហែក្បួន ឬក្រុមការងារស្ម័គ្រចិត្តរបស់សាលា។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានការផ្សព្វផ្សាយព័ត៌មានសេវាតាមរយៈកម្រងព័ត៌មានស្ដីពីសេវាសាធារណៈ ឬតាមក្រុមការងារស្ម័គ្រចិត្តរបស់សាលា |
| ពិន្ទុ ១ | មានការផ្សព្វផ្សាយព័ត៌មានសេវាតាមរយៈកិច្ចប្រជុំជាមួយអ្នកប្រើប្រាស់សេវា(ពីខាងក្រៅនិងខាងក្នុងសាលា) ឬតាមរយៈវេទិកាសាធារណៈ ឬភាគីពាក់ព័ន្ធ |
| ពិន្ទុ ១ | មានការផ្សព្វផ្សាយព័ត៌មានសេវាតាមរយៈព្រឹត្តិបត្រព័ត៌មាន ឬខិត្តប័ណ្ណ ឬក្រដាសបត់ ឬបណ្ណប្រកាសដែលអាចចែកជូនអ្នកប្រើប្រាស់សេវា |
| ពិន្ទុ ១ | មានការផ្សព្វផ្សាយព័ត៌មានសេវាតាមរយៈឧគ្ឃោសនសព្ទ ឬការដង្ហែក្បួន |
| ពិន្ទុ ១ | មានការផ្សព្វផ្សាយព័ត៌មានសេវាតាមរយៈការបិទផ្សាយនៅលើជញ្ជាំង ឬផ្ទាំងក្រដាស ឬបដា ឬក្ដារខៀនព័ត៌មាននៅក្នុងបរិវេណសាលារៀន និងទីប្រជុំជន ឬសាលាឃុំ/សាលាក្រុង-ស្រុក-ខណ្ឌ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ <u>បានផ្សព្វផ្សាយព័ត៌មានតាមប្រព័ន្ធអេឡិចត្រូនិក និងឌីជីថល (ដូចជា Facebook, Telegram, Tweeter ជាដើម)</u>

- ***សេចក្ដីពន្យល់៖*** សំដៅដល់សាលារៀនបានប្រើប្រាស់មធ្យោបាយក្នុងទម្រង់ជាអេឡិចត្រូនិកផ្សេងៗ ដើម្បីផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការផ្ដល់សេវារបស់ខ្លួនជូនអ្នកប្រើប្រាស់សេវា ប្រជាពលរដ្ឋ សហគមន៍ ដៃគូអភិវឌ្ឍ និងអាជ្ញាធរដែនដី។ មធ្យោបាយផ្សព្វផ្សាយក្នុងទម្រង់ជាអេឡិចត្រូនិកមានដូចជាវិទ្យុ ទូរទស្សន៍ ទូរសព្ទ គេហទំព័ររបស់សាលារៀន ឬបណ្ដាញទំនាក់ទំនងសង្គមនានា (Facebook, Telegram...)។ល។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ មធ្យោបាយនៃការផ្សព្វផ្សាយក្នុងទម្រង់ជាអេឡិចត្រូនិក ដែលសាលារៀនបានប្រើប្រាស់ដូចជាវិទ្យុ ទូរទស្សន៍ ទូរសព្ទ គេហទំព័ររបស់សាលារៀន ឬបណ្ដាញទំនាក់ទំនងសង្គមនានា (Facebook, telegram...)។ល។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥(គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានការផ្សព្វផ្សាយព័ត៌មានសេវាតាមរយៈវិទ្យុ ឬទូរទស្សន៍ |
| ពិន្ទុ ១ | មានការផ្សព្វផ្សាយព័ត៌មានសេវាតាមរយៈគេហទំព័រសាលារៀន ឬទូរសព្ទ ឬអ៊ីម៉ែល |
| ពិន្ទុ ២ | មានការផ្សព្វផ្សាយព័ត៌មានសេវាតាមរយៈបណ្តាញទំនាក់ទំនងសង្គមរបស់សាលារៀន (Facebook, telegram...) |
| ពិន្ទុ ១ | ព័ត៌មានស្តីពីសេវារបស់សាលារៀនដែលដាក់ឱ្យផ្សព្វផ្សាយនៅក្នុងគេហទំព័រឬបណ្តាញទំនាក់ទំនងសង្គមរបស់សាលារៀនត្រូវបានធ្វើបច្ចុប្បន្នកម្មជាប្រចាំ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## ១.២ ភាពងាយស្រួលក្នុងការទទួលយកសេវា (៣៥ពិន្ទុ)

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបចំហេដ្ឋារចនាសម្ព័ន្ធឱ្យមានលក្ខណៈងាយស្រួលរកឃើញ មានផ្លូវចេញ-ចូលប្រកបដោយសុវត្ថិភាព កន្លែងផ្តល់សេវាប្រកបដោយផាសុកភាព នីតិវិធី បែបបទនិងលក្ខខណ្ឌនៃការទទួលយកសេវាមានភាពសាមញ្ញ និងឆាប់រហ័ស។

### ១.២.១ ទីតាំង និងហេដ្ឋារចនាសម្ព័ន្ធ (១៥ពិន្ទុ)

➢ <u>មានហេដ្ឋារចនាសម្ព័ន្ធក្នុងបរិវេណសាលារៀនប្រកបដោយភាពងាយស្រួលក្នុងការស្វែងរកនិងទទួលយកសេវា</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបចំហេដ្ឋារចនាសម្ព័ន្ធដូចជាផ្លូវចេញចូល របងព័ទ្ធជុំវិញ ខ្លោងទ្វារ(មានសរសេរឈ្មោះនិងអាសយដ្ឋានសាលារៀននៅខ្លោងទ្វារ ឬជិតខ្លោងទ្វារ ឬក្នុងបរិវេណសាលា) អគារសិក្សា(មានឈ្មោះអគារ) ទីចាត់ការ និងផ្លូវឆ្ពោះទៅអគារនិងអង្គភាពឬកន្លែងនីមួយៗក្នុងបរិវេណសាលារៀនរៀបចំបានល្អប្រសើរ ដើម្បីបង្កលក្ខណៈងាយស្រួលដល់អ្នកប្រើប្រាស់សេវា។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ស្ថានភាពហេដ្ឋារចនាសម្ព័ន្ធក្នុងបរិវេណសាលារៀនដូចជាផ្លូវចេញចូល របងព័ទ្ធជុំវិញ មានសរសេរឈ្មោះនិងអាសយដ្ឋានសាលារៀននៅខ្លោងទ្វារ ឬមានបិទនៅជិតខ្លោងទ្វារ ឬរបងសាលារៀន អគារសិក្សា(មានឈ្មោះអគារ) ទីចាត់ការ និងផ្លូវឆ្ពោះទៅអគារនិងអង្គភាពឬកន្លែងនីមួយៗ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥(គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានខ្លោងទ្វារដែលមានឈ្មោះសាលារៀន និងអាសយដ្ឋាន(ភូមិ ឃុំ-សង្កាត់ ក្រុង-ស្រុក-ខណ្ឌ ខេត្ត-រាជធានី) ឬឈ្មោះនិងអាសយដ្ឋានសាលារៀនមានបិទនៅជិតខ្លោងទ្វារ ឬរបងសាលារៀន |
| ពិន្ទុ ១ | មានរបងព័ទ្ធជុំវិញសាលារៀន |

| | |
|---|---|
| ពិន្ទុ ១ | មានផ្លូវចេញចូលសាលារៀនដែលមានលក្ខណៈងាយស្រួលធ្វើដំណើរ មិនមានការរំខាន និងប្រកបដោយសុវត្ថិភាព( ឧទាហរណ៍ គ្មានភក់ជ្រាំ ស្លែកាន់ អេិល ដើមឈើរលំ ខ្សែភ្លើងធ្លាក់ ។ល។) |
| ពិន្ទុ ១ | ផ្លូវទៅកាន់អគារ ឬកន្លែងផ្សេងៗក្នុងបរិវេណសាលារៀនមានភាពងាយស្រួលធ្វើដំណើរ មិនមានការរំខាន និងប្រកបដោយសុវត្ថិភាព( ឧទាហរណ៍ គ្មានភក់ជ្រាំ ស្លែកាន់ អេិល ដើមឈើរលំ ខ្សែភ្លើងធ្លាក់ និងជម្រាលសម្រាប់អ្នកដែលមានពិការភាព) |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ មានបិទបង្ហាញប្លង់ទីតាំងសាលារៀន និងស្លាកសញ្ញាប្រាប់ពីឈ្មោះអង្គភាពទទួលបន្ទុកការងារនីមួយៗច្បាស់លាស់

- ***សេចក្តីពន្យល់៖*** សំដៅដល់ការបិទបង្ហាញប្លង់សាលារៀនដែលបង្ហាញអំពីទីតាំងសាលារៀន (អាសយដ្ឋាន ព្រំប្រទល់ ទំហំ ទីតាំងអគារ សួន។ល។) គំនូសព្រួញបង្ហាញផ្លូវទៅកាន់ទីតាំងអគារឬអង្គភាព និងស្លាកសញ្ញាប្រាប់ពីឈ្មោះអង្គភាពទទួលបន្ទុកការងារនីមួយៗ ដោយមានការសរសេរបង្ហាញឈ្មោះច្បាស់លាស់។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ប្លង់សាលារៀនដែលបង្ហាញអាសយដ្ឋាន ព្រំប្រទល់ ទំហំ ទីតាំងអគារ សួន។ល។ ២)គំនូសបង្ហាញអំពីប្លង់អគារនិងអង្គភាពទាំងអស់ និង ៣)ស្លាកសញ្ញាប្រាប់ពីឈ្មោះអង្គភាពទទួលបន្ទុកការងារនីមួយៗ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥(គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានការបិទបង្ហាញប្លង់សាលារៀន ដែលមានបញ្ជាក់អាសយដ្ឋាន ព្រំប្រទល់ ទំហំផ្ទៃដីរបស់សាលារៀន និងសញ្ញាបង្ហាញទិសច្បាស់លាស់ |
| ពិន្ទុ ១ | មានបិទបង្ហាញគំនូសបង្ហាញផ្លូវទៅកាន់អគារនិងអង្គភាពទាំងអស់ក្នុងបរិវេណសាលារៀន |
| ពិន្ទុ ១ | គ្រប់អគារនិងអង្គភាពទាំងអស់មានការកំណត់ឈ្មោះនិងសរសេរស្លាកសញ្ញាបង្ហាញឈ្មោះច្បាស់លាស់ |
| ពិន្ទុ ១ | ប្លង់សាលារៀន និងគំនូសបង្ហាញផ្លូវទៅកាន់អគារនិងកន្លែងផ្សេងៗក្នុងបរិវេណសាលារៀនត្រូវបានបិទនៅខាងមុខសាលាឬផ្នែកខាងមុខក្នុងបរិវេណសាលារៀនដែលងាយមើលឃើញ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ <u>មានចំណតសម្រាប់ចតយានជំនិះ ព្រមទាំងមានការបែងចែករវាងចំណតសម្រាប់បុគ្គលិកអប់រំ សិស្ស និងភ្ញៀវប្រកបដោយសណ្តាប់ធ្នាប់ និងមានអនាម័យស្អាតជាប្រចាំ</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនរៀបចំឱ្យមានចំណតយានជំនិះ(រថយន្ត ម៉ូតូ កង់) ដោយមានការបែងចែកសម្រាប់បុគ្គលិកអប់រំ ភ្ញៀវ និងសិស្ស និងរក្សាបាននូវសណ្តាប់ធ្នាប់ សុវត្ថិភាពនិងអនាម័យស្អាតជាប្រចាំ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ការបែងចែកចំណតយានជំនិះតាមប្រភេទ(រថយន្ត ម៉ូតូ កង់) និងសម្រាប់បុគ្គលិកអប់រំ ភ្ញៀវ និងសិស្ស ២)គំនូសចំណត ៣)សណ្តាប់ធ្នាប់ និងសុវត្ថិភាពនៃទីតាំងចំណត និង៤)អនាម័យនៃទីតាំងចំណត។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានកំណត់កន្លែងចំណតយានជំនិះ(រថយន្ត និងម៉ូតូ/កង់) |
| ពិន្ទុ ១ | មានការបែងចែកចំណតយានជំនិះសម្រាប់បុគ្គលិកអប់រំ ភ្ញៀវ និងសិស្ស |
| ពិន្ទុ ១ | ទីតាំងចំណតមានគំនូស(គូសជាបន្ទាត់ ចងខ្សែជាបន្ទាត់ ឬការខណ្ឌជាគំនូសសម្រាប់ចតតាមមធ្យោបាយផ្សេងទៀត) ដើម្បីសម្រួលដល់ការចត |
| ពិន្ទុ ១ | ចំណតយានជំនិះមានសណ្តាប់ធ្នាប់ និងសុវត្ថិភាព |
| ពិន្ទុ ១ | ចំណតយានជំនិះមានអនាម័យ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

### ១.២.២ ទីតាំងផ្តល់សេវាប្រកបដោយផាសុកភាព (១០ពិន្ទុ)

➢ <u>បានរៀបចំបរិស្ថាននៅក្នុងថ្នាក់រៀនប្រកបដោយផាសុកភាព</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបចំបរិស្ថាននៅថ្នាក់រៀនឱ្យមានតុកៅអីគ្រប់គ្រាន់(មិនប្រជៀតគ្នា) មានខ្យល់ចេញចូល មានពន្លឺគ្រប់គ្រាន់ ដើម្បីឱ្យថ្នាក់រៀនមានផាសុកភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ថ្នាក់រៀននីមួយៗ(ការរៀបចំតុកៅអី បង្អួច កង្ហារ ពន្លឺ ខ្យល់ចេញចូល និងបរិយាកាសក្នុងបន្ទប់រៀន)។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥(គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | ថ្នាក់រៀននីមួយៗមានតុកៅអីគ្រប់គ្រាន់សម្រាប់សិស្ស និងគ្រូ |
| ពិន្ទុ ១ | ការរៀបចំតុកៅអី មានរក្សាគម្លាតសមរម្យមិនប្រជៀតគ្នា |
| ពិន្ទុ ១ | ថ្នាក់រៀនមានខ្យល់ចេញចូលគ្រប់គ្រាន់ |
| ពិន្ទុ ១ | ថ្នាក់រៀនមានពន្លឺគ្រប់គ្រាន់ |
| ពិន្ទុ ១ | ថ្នាក់រៀនមានសីតុណ្ហភាពសមស្រប |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ បានរៀបចំបរិស្ថាននៅក្នុងបណ្ណាល័យ បន្ទប់ពិសោធន៍ បន្ទប់ផ្តល់សេវាផ្សេងៗប្រកបដោយសុវត្ថិភាព និងផាសុកភាព

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបចំបរិស្ថាននៅក្នុងបណ្ណាល័យ បន្ទប់ពិសោធន៍ បន្ទប់ផ្តល់សេវាផ្សេងៗប្រកបដោយសុវត្ថិភាព ផាសុកភាព មានតុកៅអីគ្រប់គ្រាន់ មានខ្យល់ចេញចូល មានពន្លឺគ្រប់គ្រាន់ មិនមានធូលី សំបុកពីងពាង ឬប្រឡាក់កខ្វក់ និងមិនមានក្លិនអាក្រក់។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ បណ្ណាល័យ បន្ទប់ពិសោធន៍ បន្ទប់ផ្តល់សេវាផ្សេងៗ( ការរៀបចំតុកៅអី បង្អួច កង្ហារ អនាម័យ បរិយាកាស និងសោភណភាព )។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | ក្នុងបណ្ណាល័យ បន្ទប់ពិសោធន៍ បន្ទប់ផ្តល់សេវាផ្សេងៗមានតុកៅអីគ្រប់គ្រាន់សម្រាប់អ្នកចូលអាន ប្រកបដោយរបៀបរៀបរយនិងមានសណ្តាប់ធ្នាប់ និងសុវត្ថិភាព |
| ពិន្ទុ ១ | ក្នុងបណ្ណាល័យ បន្ទប់ពិសោធន៍ បន្ទប់ផ្តល់សេវាផ្សេងៗមានខ្យល់ចេញចូលគ្រប់គ្រាន់ |
| ពិន្ទុ ១ | ក្នុងបណ្ណាល័យ បន្ទប់ពិសោធន៍ បន្ទប់ផ្តល់សេវាផ្សេងៗមានពន្លឺគ្រប់គ្រាន់ |
| ពិន្ទុ ១ | ក្នុងបណ្ណាល័យ បន្ទប់ពិសោធន៍ បន្ទប់ផ្តល់សេវាផ្សេងៗមិនមានធូលី សំបុកពីងពាង ឬប្រឡាក់ (កម្រាល ជញ្ជាំង ដំបូល តុ កៅអី ។ល។) |
| ពិន្ទុ ១ | ក្នុងបណ្ណាល័យ បន្ទប់ពិសោធន៍ បន្ទប់ផ្តល់សេវាផ្សេងៗមានសោភណភាព (មានលម្អដោយការបិទរូបភាព ពាក្យពេចន៍ ឬពាក្យស្លោកអប់រំ ឬតាំងផើងផ្កា។ល។) និងមិនមានក្លិនអាក្រក់ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

### ១.២.៣ បែបបទនិងលក្ខខណ្ឌនៃការទទួលយកសេវា (១០ពិន្ទុ)

➢ បានរៀបចំ និងអនុវត្តការទទួលយកឯកសារតម្រូវសម្រាប់ទទួលសេវាឱ្យមានចំនួនតិច និងទម្រង់នៃពាក្យស្នើសុំសេវាមានលក្ខណៈងាយយល់និងងាយបំពេញ

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានសិក្សានិងកាត់បន្ថយចំនួនឯកសារតម្រូវ(មិនចាំបាច់) សម្រាប់ភ្ជាប់ជាមួយពាក្យស្នើសុំសេវាតាមស្ថានភាពជាក់ស្តែងនៃសេវានីមួយៗ និងបានកែសម្រួលទម្រង់នៃពាក្យស្នើសុំសេវារដ្ឋបាលនានាឱ្យមានលក្ខណៈងាយយល់និងងាយបំពេញ ដើម្បីធ្វើឱ្យលក្ខខណ្ឌនៃការផ្តល់សេវាកាន់តែមានភាពសាមញ្ញ និងងាយទទួលយកបាន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ឯកសារតម្រូវសម្រាប់ទទួលបានសេវានានារបស់សាលារៀន( ការវិវត្តក្នុងរយៈពេល៣ឆ្នាំចុងក្រោយ) ២)ទម្រង់នៃពាក្យស្នើសុំសេវារដ្ឋបាលនានារបស់សាលារៀន( ការវិវត្តក្នុងរយៈពេល៣ឆ្នាំចុងក្រោយ) ៣)ផែនការកាត់បន្ថយឯកសារតម្រូវ ឬកែសម្រួលទម្រង់នៃពាក្យស្នើសុំសេវា (មានភាពទន់ភ្លន់ឬបត់បែនទៅតាមស្ថានភាពជាក់ស្តែង) ៤)របាយការណ៍ស្វ័យវាយតម្លៃរបស់សាលារៀន និង៥)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានការសិក្សា ឬរៀបចំសកម្មភាពកាត់បន្ថយឯកសារតម្រូវមិនចាំបាច់ ឬកែសម្រួលទម្រង់នៃពាក្យស្នើសុំសេវាឱ្យមានចំនួនតិចនិងសាមញ្ញតាមស្ថានភាពជាក់ស្តែងនៃសេវានីមួយៗ |
| ពិន្ទុ ២ | បានអនុវត្តការកាត់បន្ថយឯកសារតម្រូវមិនចាំបាច់ដើម្បីទទួលបានសេវាឱ្យមានចំនួនតិចតាមស្ថានភាពជាក់ស្តែង |
| ពិន្ទុ ១ | បានអនុវត្តការកែសម្រួលទម្រង់នៃពាក្យស្នើសុំសេវាឱ្យមានភាពសាមញ្ញ និងមានភាពទន់ភ្លន់ឬបត់បែនទៅតាមស្ថានភាពជាក់ស្តែង |
| ពិន្ទុ ១ | ពាក្យស្នើសុំសេវាទាំងអស់របស់សាលារៀន(ពាក្យពេចន៍ ឃ្លាប្រយោគ)មានលក្ខណៈងាយយល់និងងាយបំពេញ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ <u>បានសិក្សានិងរៀបចំនីតិវិធីនៃការទទួលយកសេវាមានលក្ខណៈសាមញ្ញ និងឆាប់រហ័ស</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបចំកែសម្រួលនីតិវិធីនៃការផ្តល់សេវារដ្ឋបាល(សេវាផ្តល់លិខិតបញ្ជាក់ការសិក្សា ព្រឹត្តិបត្រពិន្ទុ លិខិតផ្ទេរចេញផ្ទេរចូល។ល។) ឱ្យមានលក្ខណៈខ្លីសាមញ្ញមិនស្មុគស្មាញនិងឆាប់រហ័ស។ សាលារៀនអាចបង្កើតឲ្យមានជម្រើសសម្រាប់ការទទួលយកសេវាសម្រេចចុងក្រោយ ដូចជាការទទួលយកនៅហ្នឹងកន្លែងផ្តល់សេវា ឬនៅទីកន្លែងផ្សេងស្របច្បាប់ដែលនៅជិតអ្នកប្រើសេវា តាមរយៈក្រុមការងារទទួលបន្ទុកផ្តល់សេវាតាមមធ្យោបាយចល័ត។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ចរន្តឬរំហូរឬនីតិវិធីនៃការផ្តល់សេវា ២)របាយការណ៍ស្តីពីការកែលម្អនីតិវិធីនៃការផ្តល់សេវារដ្ឋបាលរបស់សាលារៀន ៣)របាយការណ៍ស្វ័យវាយតម្លៃរបស់សាលារៀន ៤)ជម្រើសនៃការទទួលយកសេវា និង៥)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានការសិក្សានិងកែលម្អនីតិវិធីនៃការផ្តល់សេវាជាប្រចាំ ឬនីតិវិធីនៃការស្នើសុំ និងទទួលយកសេវាសម្រេចចុងក្រោយ(លទ្ធផល)ត្រូវបានផ្តល់នូវជម្រើស (នៅហ្នឹងកន្លែងផ្តល់សេវា ឬនៅទីកន្លែងផ្សេងស្របច្បាប់ដែលនៅជិតអ្នកប្រើប្រាស់សេវា) |
| ពិន្ទុ ២ | នីតិវិធីនៃការផ្តល់សេវាមានលក្ខណៈខ្លី ឆាប់រហ័ស សាមញ្ញមិនស្មុគស្មាញ (ឧទាហរណ៍មានយន្តការច្រកចេញ ចូលតែមួយ) |
| ពិន្ទុ ១ | សេវាដែលផ្តល់ដោយសាលារៀនមានភាពឆាប់រហ័ស(មុនកាលកំណត់) |
| ពិន្ទុ ១ | មានបង្កើតក្រុមការងារទទួលបន្ទុកផ្តល់សេវាតាមមធ្យោបាយចល័ត |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

### ១.៣ ភាពយកចិត្តទុកដាក់ក្នុងការទទួលអ្នកប្រើប្រាស់សេវា (២៥ពិន្ទុ)

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបចំឱ្យមានស្តង់ដានៃបដិសណ្ឋារកិច្ច និងយន្តការសម្របសម្រួលការលំបាករបស់អ្នកប្រើប្រាស់សេវាតាមទិដ្ឋភាពជាក់ស្តែង។ ឧទាហរណ៍៖ ស្តង់ដានៃបដិសណ្ឋារកិច្ច ដូចជាការប្រើប្រាស់ពាក្យពេចន៍ ឥរិយាបថនិងអាកប្បកិរិយានៃការទទួលស្វាគមន៍ (ការសំពះ ការទទួលរាក់ទាក់...)។

#### ១.៣.១ ការរៀបចំបដិសណ្ឋារកិច្ច (២០ពិន្ទុ)

➢ <u>បានរៀបចំឱ្យបុគ្គលិកអប់រំមានឯកសណ្ឋានឬសម្លៀកបំពាក់សមរម្យ និងពាក់ស្លាកឈ្មោះឬបណ្ណសម្គាល់ខ្លួនជាប្រចាំក្នុងពេលបំពេញការងារក្នុងសាលារៀន</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានកំណត់ឱ្យបុគ្គលិកអប់រំ មានសម្លៀកបំពាក់សមរម្យឬមានឯកសណ្ឋាន ដោយមានពាក់ស្លាកឈ្មោះឬបណ្ណសម្គាល់ខ្លួនជាប្រចាំក្នុងពេលបំពេញការងារ។ សាលាមានការកំណត់ឯកសណ្ឋាន ឬស្លាកឈ្មោះ ឬបណ្ណសម្គាល់ខ្លួនខុសគ្នា(ទ្រង់ទ្រាយ ទំហំស្លាកឬបណ្ណពណ៌) រវាងបុគ្គលិកអប់រំទទួលបន្ទុកការងាររដ្ឋបាលនិងគ្រូបង្រៀន រវាងគ្រូបង្រៀនតាមកម្រិតថ្នាក់នីមួយៗ និងរវាងគ្រូបង្រៀនតាមមុខវិជ្ជានីមួយៗ ឬពណ៌ទៅតាមថ្ងៃបំពេញការងារ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)សម្លៀកបំពាក់ឬឯកសណ្ឋានរបស់បុគ្គលិកអប់រំ ២)ឯកសណ្ឋានប្រចាំថ្ងៃរបស់បុគ្គលិកអប់រំ និង៣)ស្លាកឈ្មោះឬបណ្ណសម្គាល់ខ្លួន(ពណ៌ខៀវ)របស់បុគ្គលិកអប់រំ (គ្រូបង្រៀននិងបុគ្គលិករដ្ឋបាល)។
- ***របៀបនៃការដាក់ពិន្ទុពី0 ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | បុគ្គលិកអប់រំទាំងអស់មានសម្លៀកបំពាក់សមរម្យឬឯកសណ្ឋានក្នុងពេលបំពេញការងារ |
| ពិន្ទុ ១ | បុគ្គលិកអប់រំទាំងអស់មានពាក់ស្លាកឈ្មោះសម្គាល់ខ្លួនជាប្រចាំក្នុងពេលបំពេញការងារ |
| ពិន្ទុ ១ | មានការកំណត់ឯកសណ្ឋានឬស្លាកឈ្មោះខុសគ្នា(ពណ៌ខៀវ) រវាងគ្រូបង្រៀននិងបុគ្គលិករដ្ឋបាល ឬគ្រូបង្រៀនតាមកម្រិតថ្នាក់ ឬតាមមុខវិជ្ជានីមួយៗ |
| ពិន្ទុ ២ | មានការកំណត់ឯកសណ្ឋានតាមតម្រូវការងារនិងព្រឹត្តិការណ៍ឬសកម្មភាពផ្សេងៗក្នុងសាលារៀន |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ <u>បានរៀបចំឱ្យសិស្សមានឯកសណ្ឋាន(សម្លៀកបំពាក់សមរម្យ និងមានស្លាកឈ្មោះឬបណ្ណសម្គាល់ខ្លួនជាប្រចាំក្នុងសាលារៀន) និងមានសីលធម៌/សុជីវធម៌ និងភាពរួសរាយរាក់ទាក់</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានកំណត់ឱ្យសិស្សមានសម្លៀកបំពាក់សមរម្យ ឬមានឯកសណ្ឋាន ដោយមានពាក់ស្លាកឈ្មោះឬបណ្ណសម្គាល់ខ្លួនជាប្រចាំក្នុងថ្នាក់រៀន។ សាលារៀនបានបង្ហាត់បង្រៀនសិស្សឱ្យមានភាពរួសរាយរាក់ទាក់ និងប្រកាន់ខ្ជាប់នូវអាកប្បកិរិយា ពាក្យសម្តី និងសីលធម៌ល្អក្នុងសាលារៀន។ ដើម្បីឱ្យសិស្សប្រកាន់ខ្ជាប់នូវឥរិយាបថទាំងនេះ សាលារៀនអាចរៀបចំឱ្យមានស្តង់ដានៃការប្រើប្រាស់ពាក្យទទួលស្វាគមន៍ ការសំពះ និងអប់រំផ្សព្វផ្សាយបទបញ្ជាផ្ទៃក្នុងគោលការណ៍សាលារៀននិងគោលការណ៍ថ្នាក់រៀនសម្រាប់សិស្សជាប្រចាំ។

- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)សម្លៀកបំពាក់ឬឯកសណ្ឋានរបស់សិស្ស ២)ស្លាកឈ្មោះឬបណ្ណសម្គាល់ខ្លួនរបស់សិស្ស ៣)ភាពរួសរាយរាក់ទាក់ អាកប្បកិរិយា ពាក្យសម្តី និងសីលធម៌របស់សិស្ស ៤)ស្តង់ដា ឬបែបបទនៃការធ្វើបដិសណ្ឋារកិច្ច និង៥)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | សិស្សទាំងអស់មានសម្លៀកបំពាក់សមរម្យ ឬឯកសណ្ឋានក្នុងសាលារៀន |
| ពិន្ទុ ១ | សិស្សទាំងអស់មានពាក់ស្លាកឈ្មោះសម្គាល់ខ្លួនជាប្រចាំក្នុងសាលារៀន |
| ពិន្ទុ ១ | មានកំណត់ស្តង់ដាឬបែបបទនៃការធ្វើបដិសណ្ឋារកិច្ច ឬការសំដែងរបាំប្រពៃណី (សម្រាប់សិស្ស) |
| ពិន្ទុ ១ | មានការអប់រំណែនាំដល់សិស្សអំពីការធ្វើបដិសណ្ឋារកិច្ច សុជីវធម៌ និងសីលធម៌ក្នុងសាលារៀន |
| ពិន្ទុ ១ | សិស្សមានពាក្យសម្តីសមរម្យ មានភាពរួសរាយរាក់ទាក់ អាកប្បកិរិយាល្អ និងសាមគ្គីភាពក្នុងសាលារៀន |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ចំពោះការអប់រំណែនាំដល់សិស្សអំពីការធ្វើបដិសណ្ឋារកិច្ច សុជីវធម៌ និងសីលធម៌ល្អក្នុងពេលបំពេញការងារសាលារៀនអាចរៀបចំឱ្យមាន៖ ការផ្សព្វផ្សាយជាវីដេអូខ្លីឬអត្ថបទស្តីពីការធ្វើបដិសណ្ឋារកិច្ច និងការអនុវត្តសុជីវធម៌និងសីលធម៌ល្អក្នុងពេលសិក្សា ការផ្តល់ការលើកទឹកចិត្តដល់សិស្សដែលបានប្រកាន់ខ្ជាប់នូវសុជីវធម៌និងសីលធម៌ល្អ។

## ➢ បុគ្គលិកអប់រំមានភាពរួសរាយរាក់ទាក់ និងមានសីលធម៌/សុជីវធម៌

- ***សេចក្តីពន្យល់៖*** សំដៅដល់បុគ្គលិកអប់រំរបស់សាលារៀនមានភាពរួសរាយរាក់ទាក់ និងប្រកាន់ខ្ជាប់នូវអាកប្បកិរិយា ពាក្យសម្តី និងសីលធម៌ល្អក្នុងពេលបំពេញការងារ។ ដើម្បីឱ្យបុគ្គលិកអប់រំប្រកាន់ខ្ជាប់នូវឥរិយាបថទាំងនេះ សាលារៀនអាចរៀបចំឱ្យមានស្តង់ដានៃការប្រើប្រាស់ពាក្យទទួលស្វាគមន៍ ការសំពះ និងអប់រំផ្សព្វផ្សាយក្រមសីលធម៌នៃបុគ្គលិកអប់រំជាប្រចាំ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ភាពរួសរាយរាក់ទាក់ អាកប្បកិរិយា ពាក្យសម្តី និងសីលធម៌របស់បុគ្គលិកអប់រំក្នុងការផ្តល់សេវា ២)ស្តង់ដាឬបែបបទនៃការធ្វើបដិសណ្ឋារកិច្ច និង៣)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។

- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ២ | បង្កើតឱ្យមានស្តង់ដារឬបែបបទនៃការធ្វើបដិសណ្ឋារកិច្ចនិងផ្តល់ព័ត៌មាន(សម្រាប់បុគ្គលិកអប់រំ) ដល់អ្នកប្រើប្រាស់សេវានៅកន្លែងផ្តល់ព័ត៌មាន |
| ពិន្ទុ ១ | មានការបណ្តុះបណ្តាល ឬណែនាំដល់អ្នកផ្តល់សេវានៅកន្លែងផ្តល់ព័ត៌មាន និងបុគ្គលិកអប់រំទាំងអស់អំពីការធ្វើបដិសណ្ឋារកិច្ច សុជីវធម៌ និងសីលធម៌ល្អក្នុងពេលបំពេញការងារ |
| ពិន្ទុ ២ | បុគ្គលិកអប់រំទាំងអស់មានភាពរួសរាយរាក់ទាក់ និងប្រកាន់ខ្ជាប់អាកប្បកិរិយា ពាក្យសម្តី និងសីលធម៌ល្អក្នុងពេលបំពេញការងារ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ចំពោះការបណ្តុះបណ្តាល ឬណែនាំដល់អ្នកផ្តល់សេវានៅកន្លែងផ្តល់ព័ត៌មាន និងបុគ្គលិកអប់រំទាំងអស់អំពីការធ្វើបដិសណ្ឋារកិច្ច សុជីវធម៌ និងសីលធម៌ល្អក្នុងពេលបំពេញការងារ សាលារៀនអាចរៀបចំឱ្យមាន៖ ការផ្សព្វផ្សាយជាវីដេអូខ្លីឬអត្ថបទស្តីពីការធ្វើបដិសណ្ឋារកិច្ច និងការអនុវត្តសុជីវធម៌និងសីលធម៌ល្អក្នុងពេលបំពេញការងារ ការផ្តល់ការលើកទឹកចិត្តដល់មន្ត្រីដែលបានអនុវត្តការងារដោយប្រកាន់ខ្ជាប់នូវសុជីវធម៌និងសីលធម៌ល្អ។

➢ <u>បានរៀបចំឱ្យមានទីកន្លែង(ផ្នែក តុ ឬទីតាំង) សម្រាប់ផ្តល់ព័ត៌មាន និងផ្តល់ការបំភ្លឺផ្សេងៗពាក់ព័ន្ធនឹងសេវារបស់សាលារៀន</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនរៀបចំឱ្យមានផ្នែក កន្លែង ឬតុផ្តល់ព័ត៌មាន ដែលមានកន្លែងអង្គុយរង់ចាំប្រកបដោយផាសុកភាព និងមានការចាត់តាំងមន្ត្រីប្រចាំការសម្រាប់ការផ្តល់ព័ត៌មាន ឬឆ្លើយតបសំណួរពាក់ព័ន្ធនឹងសេវានានារបស់សាលារៀនក្នុងពេលបំពេញការងារ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)កន្លែងផ្តល់ព័ត៌មាន ២)កន្លែងអង្គុយរង់ចាំ ៣)លិខិតបង្គាប់ការ និងការបែងចែកវេនប្រចាំការនៅកន្លែងផ្តល់ព័ត៌មានអំពីសេវារបស់សាលារៀន ៤)វត្តមានរបស់មន្ត្រីប្រចាំការនៅកន្លែងផ្តល់ព័ត៌មានអំពីសេវារបស់សាលារៀន និង ៥)ការសម្ភាសកំណត់ការយល់ដឹងរបស់មន្ត្រីប្រចាំការអំពីសមត្ថភាពផ្តល់ព័ត៌មាន ការបំភ្លឺ ឬឆ្លើយតបសំណួរពាក់ព័ន្ធនឹងសេវានានារបស់សាលារៀន។
- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ១ | មានកន្លែងផ្តល់ព័ត៌មាន និងកន្លែងអង្គុយរង់ចាំប្រកបដោយផាសុកភាព |
| ពិន្ទុ ១ | មានលិខិតបង្គាប់ការ និងការបែងចែកវេនប្រចាំការនៅកន្លែងផ្តល់ព័ត៌មានអំពីសេវារបស់សាលារៀន |
| ពិន្ទុ ១ | មានមន្ត្រីប្រចាំការនៅកន្លែងផ្តល់ព័ត៌មានក្នុងម៉ោងបំពេញការងារតាមការកំណត់របស់សាលារៀន |

| | |
|---|---|
| ពិន្ទុ ១ | មន្ត្រីបម្រើការនៅកន្លែងផ្តល់ព័ត៌មាន មានការយល់ដឹងទូលំទូលាយអំពីសេវារបស់សាលារៀន និងអាចផ្តល់ការបំភ្លឺផ្សេងៗពាក់ព័ន្ធនឹងសេវារបស់សាលារៀន |
| ពិន្ទុ ១ | មន្ត្រីប្រចាំការនៅកន្លែងផ្តល់ព័ត៌មានបានទទួលការបណ្តុះបណ្តាលពាក់ព័ន្ធនឹងការងារផ្តល់ព័ត៌មាន និងការបំភ្លឺឬឆ្លើយតបផ្សេងៗពាក់ព័ន្ធនឹងសេវារបស់សាលារៀន |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

### ១.៣.២ យន្តការសម្របសម្រួល (៥ពិន្ទុ)

➢ <u>មានការយកចិត្តទុកដាក់និងសម្របសម្រួលដោះស្រាយការលំបាករបស់អ្នកប្រើសេវាតាមទិដ្ឋភាពជាក់ស្តែង</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការយកចិត្តទុកដាក់របស់បុគ្គលិកអប់រំចំពោះអ្នកប្រើសេវាមិនមែនជាសិស្ស តាមរយៈការផ្តល់ព័ត៌មាន និងសម្រួលការលំបាករបស់អ្នកប្រើសេវា ជាពិសេស(ជនមានពិការភាព ចាស់ជរា អនក្ខរជន កុមារ ស្ត្រីមានកូនតូចឬមានផ្ទៃពោះ និងព្រះសង្ឃជាដើម) តាមទិដ្ឋភាពជាក់ស្តែង។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ឯកសារចាត់តាំងមន្ត្រី ឬក្រុមការងារសម្រួលដល់ការទទួលសេវារបស់អ្នកដែលត្រូវការជំនួយ ២)មធ្យោបាយនិងហេដ្ឋារចនាសម្ព័ន្ធសម្រាប់សម្រួលការលំបាករបស់អ្នកប្រើសេវាដែលជាជនងាយរងគ្រោះដូចជាជនមានពិការភាព ចាស់ជរា អនក្ខរជន កុមារ ស្ត្រីមានកូនតូចឬមានផ្ទៃពោះ និងព្រះសង្ឃជាដើម និង៣)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានលិខិតបង្គាប់ការ និងការបែងចែកវេនប្រចាំការរបស់មន្ត្រីសម្រាប់ជួយនិងសម្រួលការលំបាកដល់អ្នកត្រូវការជំនួយដូចជាជនមានពិការភាព ចាស់ជរា អនក្ខរជន កុមារ ស្ត្រីមានកូនតូច ឬមានផ្ទៃពោះ និងព្រះសង្ឃជាដើម |
| ពិន្ទុ ២ | មានមន្ត្រីប្រចាំការតាមវេនសម្រាប់ជួយនិងសម្រួលការលំបាកដល់អ្នកត្រូវការជំនួយដូចជាជនមានពិការភាព ចាស់ជរា អនក្ខរជន កុមារ ស្ត្រីមានកូនតូចឬមានផ្ទៃពោះ និងព្រះសង្ឃជាដើម |
| ពិន្ទុ ១ | មានមធ្យោបាយសម្រាប់សម្រួលការលំបាករបស់អ្នកប្រើសេវាជាជនមានពិការភាព ចាស់ជរា កុមារ ស្ត្រីមានកូនតូច និងស្ត្រីមានផ្ទៃពោះ (កង់រុញ កន្លែងអង្គុយរង់ចាំ មានកៅអី បន្ទប់ទឹក ជម្រាលសម្រាប់អ្នកដែលមានពិការភាព) |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## ១.៤ ការផ្តល់សេវាតាមគោលការណ៍កំណត់ និងអភិបាលកិច្ចល្អ (១៥ពិន្ទុ)

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានអនុវត្តការផ្តល់សេវាតាមគោលការណ៍ដែលមានកំណត់ក្នុងបទដ្ឋានគតិយុត្តជាធរមាន និងបានផ្តល់សេវាប្រកបដោយសមធម៌ និងបរិយាបន្ន ដូចជាជួយដល់សិស្សដែលមានពិការភាព និងសិស្សក្រីក្រដើម្បីទទួលបានការសិក្សាដោយគ្មានការរើសអើង។

### ១.៤.១ ការផ្តល់សេវាតាមគោលការណ៍កំណត់ (១០ពិន្ទុ)

➢ <u>បានផ្តល់សេវាស្របតាមការកំណត់(ដូចជាតម្លៃ រយះពេល សុពលភាព...)</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានអនុវត្តការផ្តល់សេវាតាមគោលការណ៍ដែលមានកំណត់ក្នុងបទដ្ឋានគតិយុត្តជាធរមាន ទាំងតម្លៃ រយៈពេល ឯកសារតម្រូវ និងលក្ខខណ្ឌក្នុងការទទួលយកសេវា។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)បទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការផ្តល់សេវារបស់សាលារៀន ២)ការអនុវត្តការផ្តល់សេវារបស់សាលារៀន ៣)ពាក្យបណ្តឹងឬព័ត៌មានត្រឡប់ពាក់ព័ន្ធនឹងការផ្តល់សេវា ៤)របាយការណ៍នៃការដោះស្រាយនិងឆ្លើយតបចំពោះព័ត៌មានត្រឡប់និងបណ្តឹងតវ៉ា និង៥)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | បានអនុវត្តការយកតម្លៃសេវាតាមគោលការណ៍កំណត់(មិនមានការយកកម្រៃបន្ថែមខុសពីគោលការណ៍កំណត់) |
| ពិន្ទុ ១ | បានអនុវត្តការផ្តល់សេវាតាមពេលវេលាកំណត់ក្នុងការផ្តល់សេវាតាមករណីនីមួយៗ |
| ពិន្ទុ ១ | បានអនុវត្តការផ្តល់សេវាដោយមិនមានតម្រូវឱ្យផ្តល់ឯកសារតម្រូវលើសពីគោលការណ៍កំណត់ |
| ពិន្ទុ ១ | បានអនុវត្តការផ្តល់សេវាដោយមិនតម្រូវឱ្យមានការអនុវត្តលក្ខខណ្ឌនៃការផ្តល់សេវាខុសពីលក្ខខណ្ឌដែលបានកំណត់ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ <u>សាលារៀនទទួលបានវិញ្ញាបនបត្រ/បណ្ណសរសើរ/លិខិតសរសើរ/ពានរង្វាន់នៃការផ្តល់សេវា(ដៃគូអភិវឌ្ឍ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត មន្ទីរ ថ្នាក់ជាតិ តំបន់ និង/ឬ អន្តរជាតិ)</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀន បានទទួលវិញ្ញាបនបត្រ ឬបណ្ណសរសើរ ឬលិខិតសរសើរ ឬពានរង្វាន់នៃការផ្តល់សេវារបស់សាលារៀន ឬបុគ្គលិកអប់រំរបស់សាលាទទួលបានបណ្ណសរសើរ ឬលិខិតសរសើរ ឬពានរង្វាន់ពីសំណាក់ស្ថាប័នមានសមត្ថកិច្ចដូចជាអាជ្ញាធរដែនដី មន្ទីរជំនាញ ក្រសួង ស្ថាប័នថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ វិញ្ញាបនបត្រ ឬបណ្ណសរសើរ ឬលិខិតសរសើរ ឬពានរង្វាន់នៃការផ្តល់សេវារបស់សាលារៀននិងបុគ្គលិកអប់រំ ឬក្រុមការងារដែលបម្រើការងារក្នុងនាមសាលារៀន។

- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ១ | សាលារៀន ឬបុគ្គលិកអប់រំរបស់សាលា ឬក្រុមការងារដែលបម្រើការងារក្នុងនាមសាលារៀនទទួលបានវិញ្ញាបនបត្រ ឬបណ្ណសរសើរ ឬលិខិតសរសើរ ឬពានរង្វាន់នៃការផ្ដល់សេវា ពីស្ថាប័នមានសមត្ថកិច្ចកម្រិតថ្នាក់ក្រុង ស្រុក ខណ្ឌ |
| ពិន្ទុ ១ | សាលារៀន ឬបុគ្គលិកអប់រំរបស់សាលា ឬក្រុមការងារដែលបម្រើការងារក្នុងនាមសាលារៀនទទួលបានវិញ្ញាបនបត្រ ឬបណ្ណសរសើរ ឬលិខិតសរសើរ ឬពានរង្វាន់នៃការផ្ដល់សេវា ពីស្ថាប័នមានសមត្ថកិច្ចកម្រិតថ្នាក់រាជធានី ខេត្ត |
| ពិន្ទុ ២ | សាលារៀន ឬបុគ្គលិកអប់រំរបស់សាលា ឬក្រុមការងារដែលបម្រើការងារក្នុងនាមសាលារៀនទទួលបានវិញ្ញាបនបត្រ ឬបណ្ណសរសើរ ឬលិខិតសរសើរ ឬពានរង្វាន់នៃការផ្ដល់សេវា ពីស្ថាប័នមានសមត្ថកិច្ចកម្រិតថ្នាក់ក្រសួងឬថ្នាក់ជាតិ (វិញ្ញាបនបត្រ ឬបណ្ណសរសើរ ឬលិខិតសរសើរ ឬពានរង្វាន់ច្រើនជាងមួយ បាន២ពិន្ទុ បើមានតែមួយ បាន១ពិន្ទុ) |
| ពិន្ទុ ១ | សាលារៀន ឬបុគ្គលិកអប់រំរបស់សាលា ឬក្រុមការងារដែលបម្រើការងារក្នុងនាមសាលារៀនទទួលបានវិញ្ញាបនបត្រ ឬបណ្ណសរសើរ ឬលិខិតសរសើរ ឬពានរង្វាន់ ពីស្ថាប័នមានសមត្ថកិច្ចកម្រិតថ្នាក់តំបន់ឬអន្តរជាតិ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

### ១.៤.២ ការផ្ដល់សេវាប្រកបដោយសមធម៌ និងបរិយាបន្ន (៥ពិន្ទុ)

➢ បានផ្ដល់សេវាប្រកបដោយសមធម៌ និងបរិយាបន្ន(ជួយដល់សិស្សដែលមានពិការភាព និងសិស្សក្រីក្រដោយមានជម្រាល បន្ទប់ស្នាក់នៅ ឧបករណ៍សម្ភារៈជំនួយសិស្សដែលមានពិការភាព និងអាហារូបករណ៍ជាដើម)

- ***សេចក្ដីពន្យល់៖*** សំដៅដល់សាលារៀនបានអនុវត្តការជួយតាមលទ្ធភាពជាក់ស្ដែងដល់សិស្សដែលមានពិការភាព សិស្សក្រីក្រ សិស្សស្រី តាមរយៈការរៀបចំហេដ្ឋារចនាសម្ព័ន្ធ(ជម្រាលសម្រាប់សិស្សដែលមានពិការភាព បន្ទប់ស្នាក់នៅសម្រាប់សិស្សក្រីក្រ...) ការផ្ដល់អាហារូបករណ៍ ការប្រើប្រាស់សម្ភារៈជំនួយ និងការរៀបចំកម្មវិធីសិក្សាដោយឡែក/ពិសេស(សិស្សដែលត្រូវការជំនួយ និងសិស្សដែលមានបញ្ញាខ្ពស់) ដើម្បីឱ្យពួកគេទទួលបានសេវាអប់រំប្រកបដោយសមធម៌ និងបរិយាបន្ន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)កម្មវិធីអាហារូបករណ៍របស់សាលារៀន ២)ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារៈឧបករណ៍សម្រាប់សម្រួលដល់សិស្សដែលមានពិការភាព សិស្សក្រីក្រ និងសិស្សស្រី ៣)កម្មវិធីសិក្សាដោយឡែក/ពិសេសសម្រាប់សិស្សដែលមានពិការភាព និងសិស្សដែលមានបញ្ញាខ្ពស់ ៤)កម្រងរូបភាព ឬឯកសារបញ្ជាក់ពីការគាំទ្ររបស់សាលារៀនចំពោះសិស្សដែលមានពិការភាព និងសិស្សក្រីក្រ និង៥)ការសម្ភាសជាមួយសិស្សនិងអ្នកអាណាព្យាបាលសិស្ស សហគមន៍អំពីការទទួលសេវា លក្ខខណ្ឌអាហារូបករណ៍ ការផ្ដល់កន្លែងស្នាក់នៅនិងអន្តេវាសិកដ្ឋាន។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានកម្មវិធីអាហារូបករណ៍ជួយដល់សិស្សក្រីក្រ សិស្សដែលមានពិការភាព និងសិស្សដែលមានបញ្ហាខ្ពស់ តាមស្ថានភាពជាក់ស្តែង |
| ពិន្ទុ ១ | មានហេដ្ឋារចនាសម្ព័ន្ធនិងសម្ភារៈឧបករណ៍(កៅអីរុញ មានជម្រាលជនមានពិការភាពជាដើម) សម្រាប់សម្រួលដល់សិស្សដែលមានពិការភាព(សិស្សមានបញ្ហាភ្នែក ត្រចៀក) សិស្សក្រីក្រ សិស្សស្រី និងសិស្សដែលមានបញ្ហាខ្ពស់ |
| ពិន្ទុ ១ | មានកម្មវិធីសិក្សា ឬកម្មវិធីដោយឡែក/ពិសេសសម្រាប់សិស្សដែលមានពិការភាព សិស្សក្រីក្រ និង សិស្សដែលមានបញ្ហាខ្ពស់ |
| ពិន្ទុ ១ | មានគ្រូដែលទទួលបានការបណ្តុះបណ្តាលសម្រាប់បង្រៀនដល់សិស្សដែលមានពិការភាព សិស្សក្រីក្រ និងសិស្សដែលមានបញ្ហាខ្ពស់ |
| ពិន្ទុ ១ | មានលិខិតបង្គាប់ការចាត់តាំងគ្រូបង្រៀនសម្រាប់រៀបចំកម្មវិធីបង្រៀន និងបង្រៀនដល់សិស្សដែលមានពិការភាព សិស្សក្រីក្រ និងសិស្សដែលមានបញ្ហាខ្ពស់ ឬការផ្តល់កន្លែងស្នាក់នៅ ឬអន្តេវាសិកដ្ឋាន |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ចំពោះសិស្សមានបញ្ហាភ្នែកឬត្រចៀក គឺមានការយកចិត្តទុកដាក់រៀបចំតុកៅអីអង្គុយនៅជួរមុខ និងផ្តល់ជាកៅអីរុញដល់សិស្សពិការ។ ចំពោះសិស្សស្រីសាលារៀនបានផ្តល់នូវសំឡីអនាម័យ និងមានការអប់រំ។

# ផ្នែកទី២៖ ស្តង់ដាឬនិយាមនៃការផ្តល់សេវាសាធារណៈក្នុងវិស័យអប់រំ

## ២. ស្តង់ដា ឬនិយាមនៃការផ្តល់សេវាសាធារណៈក្នុងវិស័យអប់រំ

ស្តង់ដា ឬនិយាមនៃការផ្តល់សេវាសាធារណៈក្នុងវិស័យអប់រំ គឺជាឧបករណ៍កំណត់ និងវាស់វែងអំពីការរៀបចំហេដ្ឋារចនាសម្ព័ន្ធអប់រំ ការដឹកនាំ និងការគ្រប់គ្រងរបស់សាលារៀន ការបង្រៀន និងរៀនដើម្បីធានាបាននូវការផ្តល់សេវាអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន។ សេវាបង្រៀននិងរៀនគឺជាមូលដ្ឋានគ្រឹះនៃការអប់រំនៅកម្រិតសាលារៀនដើម្បីឱ្យសិស្សទទួលបាននូវលទ្ធផលនៃការសិក្សាល្អប្រកបដោយចំណេះដឹង បំណិន តម្លៃ មានសីលធម៌រស់នៅល្អ និងក្លាយជាពលរដ្ឋសកលដែលមានជំនាញ មនសិការវិជ្ជាជីវៈ និងស្មារតីទទួលខុសត្រូវខ្ពស់ក្នុងសង្គម។

ការកំណត់ និងវាយតម្លៃទៅលើស្តង់ដា ឬនិយាមនៃការផ្តល់សេវាសាធារណៈក្នុងវិស័យអប់រំមានគោលបំណងធានាឱ្យការផ្តល់សេវាអប់រំរបស់សាលារៀនប្រកបគុណភាព សមធម៌ និងបរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។

នៅក្នុងផ្នែកនៃស្តង់ដា ឬនិយាមនៃការផ្តល់សេវាសាធារណៈក្នុងវិស័យអប់រំ មានពិន្ទុសរុបចំនួន៣០០ (សាលាបឋមសិក្សាពិន្ទុសរុប ២៨៥) ដែលមានលក្ខណៈវិនិច្ឆ័យរងចំនួន៣ គឺ៖

**១. ការដឹកនាំ និងការគ្រប់គ្រងសាលារៀន** (១៦៥ពិន្ទុ) (សាលាបឋមសិក្សា ១៧០ពិន្ទុ)

**២. ហេដ្ឋារចនាសម្ព័ន្ធ និងសេវាធានាឱ្យមានគុណភាព សមធម៌ និងបរិយាបន្ននៅក្នុងសាលារៀន** (៤៥ពិន្ទុ) (សាលាបឋមសិក្សា ៣០ពិន្ទុ)

**៣. គុណវុឌ្ឍិ និងជំនាញវិជ្ជាជីវៈបុគ្គលិកអប់រំ** (៩០ពិន្ទុ) (សាលាបឋមសិក្សា ៨៥ពិន្ទុ)

## ២.១ ការដឹកនាំ និងការគ្រប់គ្រងសាលារៀន (១៦៥ពិន្ទុ) (សាលាបឋមសិក្សា ១៧០ពិន្ទុ)

### ២.១.១ ភាពជាអ្នកដឹកនាំសាលារៀន (៣៥ពិន្ទុ)

➢ <u>មានចក្ខុវិស័យសាលារៀនឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ/គោលនយោបាយអប់រំ</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបចំ និងកំណត់ចក្ខុវិស័យច្បាស់លាស់ដើម្បីជាត្រីវិស័យសម្រាប់អង្គភាពក្នុងការរៀបចំអភិវឌ្ឍរយៈពេលខ្លី មធ្យម និងវែង។ ចក្ខុវិស័យសំដៅដល់មហិច្ឆតារួមដ៏ខ្ពស់បំផុត ដែលសាលារៀនចង់ទៅដល់នាពេលអនាគត។ ចក្ខុវិស័យសាលារៀនត្រូវឆ្លើយតបទៅគោលនយោបាយអប់រំ ចក្ខុវិស័យអប់រំ និងជាអ្វីដែលសាលារៀនចង់ក្លាយទៅជា នាពេលអនាគត ដោយផ្អែកលើធនធានដែលខ្លួនមាន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ឯកសារដែលមានបញ្ជាក់អំពីចក្ខុវិស័យ និង២)ការសម្ភាសគណៈគ្រប់គ្រងសាលា បុគ្គលិកអប់រំ និងភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ១ | ចក្ខុវិស័យសាលារៀនត្រូវបានផ្សព្វផ្សាយ និងមានការយល់ដឹងពីបុគ្គលិកអប់រំ និងអ្នកពាក់ព័ន្ធ |
| ពិន្ទុ ១ | មានចក្ខុវិស័យសាលារៀនដែលអាចអនុវត្ត និងសម្រេចបាន |
| ពិន្ទុ ១ | ការកំណត់ចក្ខុវិស័យសាលារៀនស្របតាមគោលនយោបាយអប់រំ និងចក្ខុវិស័យអប់រំ |
| ពិន្ទុ ១ | ការកំណត់ចក្ខុវិស័យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ |
| ពិន្ទុ ១ | មានការកំណត់ចក្ខុវិស័យសាលារៀន |
| ពិន្ទុ ០ | មិនមានការកំណត់ចក្ខុវិស័យសាលារៀន |

➢ <u>មានបេសកកម្មឆ្លើយតបទៅនឹងចក្ខុវិស័យ</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សកម្មភាពស្នូលដែលសាលារៀនត្រូវអនុវត្តក្នុងការបំពេញមុខងារឈានទៅសម្រេចនូវចក្ខុវិស័យដែលបានកំណត់។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ឯកសារបញ្ជាក់អំពីបេសកកម្ម ២)ការសម្ភាសគណៈគ្រប់គ្រងសាលា បុគ្គលិកអប់រំ និងភាគីពាក់ព័ន្ធ និង៣)រចនាសម្ព័ន្ធដឹកនាំគ្រប់គ្រងសាលារៀន គណៈកម្មការនានា និងតួនាទីភារកិច្ច។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ១ | បេសកកម្មសាលារៀនត្រូវបានបញ្ជ្រាបឱ្យមានការយល់ដឹងដល់គណៈគ្រប់គ្រង បុគ្គលិកអប់រំ និងអ្នកពាក់ព័ន្ធ |
| ពិន្ទុ ១ | រៀបចំរចនាសម្ព័ន្ធដឹកនាំគ្រប់គ្រងសាលារៀន គណៈកម្មការនានា និងតួនាទីភារកិច្ចឆ្លើយតបទៅនឹងបេសកកម្មដែលបានកំណត់ |

| | |
|---|---|
| ពិន្ទុ ១ | មានបេសកកម្មដែលអាចធ្វើឱ្យសម្រេចនូវចក្ខុវិស័យសាលារៀន |
| ពិន្ទុ ១ | ការរៀបចំបេសកកម្មសាលារៀនមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ |
| ពិន្ទុ ១ | មានបេសកកម្មសាលារៀន |
| ពិន្ទុ ០ | មិនបានរៀបចំបេសកកម្មសាលារៀន |

➢ គុណតម្លៃ ឬបាវចនា ឬទស្សនៈរបស់សាលារៀន

- ***សេចក្តីពន្យល់៖*** សំដៅដល់តម្លៃស្នូល ឬបាវចនា ឬគោលការណ៍ ឬទស្សនៈដែលសាលារៀនបានប្រកាន់ភ្ជាប់ និងអនុវត្តយ៉ាងខ្ជាប់ខ្ជួនក្នុងពេលបំពេញការងារ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ឯកសារបញ្ជាក់អំពីគុណតម្លៃ ឬបាវចនា ឬទស្សនៈសាលារៀន ២)របាយការណ៍ប្រជុំរៀបចំឯកសារកំណត់គុណតម្លៃ ឬបាវចនា ឬទស្សនៈ ៣)ការសម្ភាសពីភាគីពាក់ព័ន្ធអំពីគុណតម្លៃ ឬបាវចនា ឬទស្សនវិទ្យារបស់សាលារៀន និង៤)ការសង្កេតឥរិយាបថការបំពេញការងារ និងការសិក្សារៀនសូត្ររបស់បុគ្គលិកអប់រំ គ្រូបង្រៀន និងសិស្សានុសិស្ស។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ១ | គណៈគ្រប់គ្រងសាលារៀន បុគ្គលិកអប់រំ គ្រូបង្រៀន និងសិស្សានុសិស្សប្រកាន់ភ្ជាប់នូវគុណតម្លៃ ឬបាវចនាឬទស្សនៈរបស់សាលារៀន |
| ពិន្ទុ ១ | មានការផ្សព្វផ្សាយនិងការយល់ដឹងអំពីគុណតម្លៃឬបាវចនា |
| ពិន្ទុ ១ | គុណតម្លៃ ឬបាវចនាសាលារៀនឆ្លើយតបទៅនឹងបេសកកម្ម និងចក្ខុវិស័យ |
| ពិន្ទុ ១ | មានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការកំណត់គុណតម្លៃ ឬបាវចនា (គណៈគ្រប់គ្រងសាលារៀន បុគ្គលិកអប់រំ គ្រូបង្រៀន អាជ្ញាធរដែនដី សហគមន៍ សិស្ស...) |
| ពិន្ទុ ១ | មានកំណត់ពីគុណតម្លៃ ឬបាវចនា ឬទស្សនៈ |
| ពិន្ទុ ០ | មិនមានកំណត់ពីគុណតម្លៃ ឬបាវចនា ឬទស្សនៈ |

➢ មានគណៈកម្មការទ្រទ្រង់សាលារៀន/ក្រុមប្រឹក្សាភិបាលសាលារៀន/គណៈកម្មការគ្រប់គ្រងសាលារៀន

- ***សេចក្តីពន្យល់៖*** គណៈកម្មការទ្រទ្រង់សាលារៀន/ក្រុមប្រឹក្សាភិបាលសាលារៀន/គណៈកម្មការគ្រប់គ្រងសាលារៀនគឺជាតំណាងសហគមន៍សាលារៀនដែលត្រូវបានជ្រើសរើសដោយការបោះឆ្នោតចេញពីអ្នកមានធនធាន(សម្ភារៈ ថវិកា ពេលវេលា សមត្ថភាព ឆន្ទៈ) អ្នកដែលគេគោរពស្រឡាញ់ និងមានឥទ្ធិពលក្នុងសហគមន៍ មន្ត្រីរាជការ សង្គមស៊ីវិល ក្រុមប្រឹក្សាឃុំ មេភូមិ មាតាបិតា និងអ្នកអាណាព្យាបាលសិស្ស ដែលមានសមាសភាពមួយចំនួនតាមការចាំបាច់ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានពីររូប មានអាណត្តិមួយឆ្នាំម្តង និងមានតួនាទីទទួលបន្ទុកមើលការខុសត្រូវប្រតិបត្តិរួមនៃការអភិវឌ្ឍសាលារៀន។

- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)រចនាសម្ព័ន្ធដឹកនាំនិងគ្រប់គ្រងគណៈកម្មការទ្រទ្រង់សាលារៀន/ក្រុមប្រឹក្សាភិបាលសាលារៀន/គណៈកម្មការគ្រប់គ្រងសាលារៀន ២) សេចក្តីសម្រេច/លិខិតបង្គាប់ការស្តីពីការបង្កើតគណៈកម្មការទ្រទ្រង់សាលារៀន/ក្រុមប្រឹក្សាភិបាលសាលារៀន /គណៈកម្មការគ្រប់គ្រងសាលារៀន ៣)បំណែងចែកតួនាទី និងភារកិច្ច ដែលមានចុះហត្ថលេខានិងបោះត្រា និង៤)របាយការណ៍កិច្ចប្រជុំប្រចាំត្រីមាសរបស់គណៈកម្មការទ្រទ្រង់សាលារៀន/ក្រុមប្រឹក្សាភិបាលសាលារៀន/គណៈកម្មការគ្រប់គ្រងសាលារៀន។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥(គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | រាល់ការសម្រេចចិត្តក្នុងការអភិវឌ្ឍសាលារៀន ត្រូវបានទទួលការយល់ព្រមពីគណៈកម្មការទ្រទ្រង់សាលារៀន/ក្រុមប្រឹក្សាភិបាលសាលារៀន/គណៈកម្មការគ្រប់គ្រងសាលារៀន |
| ពិន្ទុ ២ | គណៈកម្មការទ្រទ្រង់សាលារៀន/ក្រុមប្រឹក្សាភិបាលសាលារៀន/គណៈកម្មការគ្រប់គ្រងសាលារៀនបានអនុវត្តតួនាទី និងភារកិច្ច និងរៀបចំប្រជុំការងារប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំជាទៀងទាត់ |
| ពិន្ទុ ១ | គណៈកម្មការទ្រទ្រង់សាលារៀន/ក្រុមប្រឹក្សាភិបាលសាលារៀន/គណៈកម្មការគ្រប់គ្រងសាលារៀនមានរចនាសម្ព័ន្ធដឹកនាំ និងគ្រប់គ្រង និងបំណែងចែកតួនាទី និងភារកិច្ច |
| ពិន្ទុ ១ | មានការរៀបចំគណៈកម្មការទ្រទ្រង់សាលារៀន/ក្រុមប្រឹក្សាភិបាលសាលារៀន/គណៈកម្មការគ្រប់គ្រងសាលារៀន |
| ពិន្ទុ ០ | មិនបានរៀបចំ ឬធ្វើបច្ចុប្បន្នកម្មគណៈកម្មការទ្រទ្រង់សាលារៀន/ក្រុមប្រឹក្សាភិបាលសាលារៀន/ គណៈកម្មការគ្រប់គ្រងសាលារៀន |

➢ មានគណៈកម្មការគ្រប់គ្រងថ្នាក់រៀន(គគថ) តាមថ្នាក់រៀន និងកម្រិតថ្នាក់ ប្រចាំឆ្នាំសិក្សានីមួយៗ

- ***សេចក្តីពន្យល់៖*** គណៈកម្មការគ្រប់គ្រងថ្នាក់រៀនគឺជាតំណាងមាតាបិតា អ្នកអាណាព្យាបាលសិស្សត្រូវបានជ្រើសរើសដោយការបោះឆ្នោតចេញពីមាតាបិតា អ្នកអាណាព្យាបាលសិស្សនៅតាមថ្នាក់រៀននីមួយៗ និងមានសមាសភាពមួយចំនួនតាមការចាំបាច់ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានពីររូប មានអាណត្តិមួយឆ្នាំម្តង និងមានតួនាទីទទួលបន្ទុកមើលការខុសត្រូវប្រតិបត្តិរួមនៃថ្នាក់រៀន និងភ្ជាប់ទំនាក់ទំនងរវាងគ្រូបង្រៀនឈរថ្នាក់ និងមាតាបិតា អ្នកអាណាព្យាបាលសិស្ស។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)រចនាសម្ព័ន្ធដឹកនាំនិងគ្រប់គ្រងគណៈកម្មការគ្រប់គ្រងថ្នាក់រៀន ២)សេចក្តីសម្រេច/លិខិតបង្គាប់ការស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងថ្នាក់រៀន ៣)រចនាសម្ព័ន្ធ និងបំណែងចែកតួនាទី និងភារកិច្ច ដែលមានចុះហត្ថលេខានិងបោះត្រា និង៤)របាយការណ៍កិច្ចប្រជុំ។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥(គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | គណៈកម្មការគ្រប់គ្រងថ្នាក់រៀនបានដើរតួនាទី និងចូលរួមរៀបចំកែលម្អថ្នាក់រៀន ផ្តត់ផ្គង់ និង ឧបត្ថម្ភដល់សិស្សងាយរងគ្រោះ និងជួបការលំបាក តាមដាន និងវាយតម្លៃលទ្ធផលនៃការសិក្សារបស់សិស្ស និងផ្តល់ព័ត៌មានត្រឡប់ |
| ពិន្ទុ ១ | គណៈកម្មការគ្រប់គ្រងថ្នាក់រៀនបានអនុវត្តតួនាទី និងភារកិច្ច និងរៀបចំប្រជុំការងារប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ |
| ពិន្ទុ ១ | គណៈកម្មការគ្រប់គ្រងថ្នាក់រៀនមានរចនាសម្ព័ន្ធដឹកនាំ និងគ្រប់គ្រង និងបំណែងចែកតួនាទី និងភារកិច្ច |
| ពិន្ទុ ១ | មានការរៀបចំគណៈកម្មការគ្រប់គ្រងថ្នាក់រៀន |
| ពិន្ទុ ០ | មិនបានរៀបចំគណៈកម្មការគ្រប់គ្រងថ្នាក់រៀន |

➢ <u>ការរៀបចំសេវាគ្រូបង្រៀន និងបុគ្គលិកអប់រំបានស្របតាមកម្រិតជំនាញ កម្រិតវិជ្ជាជីវៈ និងនិយាម</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការរៀបចំសេវាបុគ្គលិកអប់រំ និងគ្រូបង្រៀននៅតាមសាលារៀនស្របតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា(និយាមនៃការប្រើប្រាស់បុគ្គលិកអប់រំ និងគ្រូបង្រៀននៅតាមសាលារៀន)។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)កាលវិភាគបង្រៀនរបស់គ្រូបង្រៀន និង២)កិច្ចព្រមព្រៀងបុគ្គលិកបង្រៀននិងមិនបង្រៀនប្រចាំឆមាស និងប្រចាំឆ្នាំ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | ការរៀបចំសេវាគ្រូបង្រៀនស្របតាមឯកទេសបង្រៀននិងកម្រិតថ្នាក់ និងបានបែងចែកភារកិច្ចសម្រាប់បុគ្គលិកមិនបង្រៀនត្រូវតាមឯកទេសជំនាញ និងគោរពតាមម៉ោងបំពេញការងារ |
| ពិន្ទុ ៤ | រៀបចំសេវាគ្រូបង្រៀនស្របតាមឯកទេសបង្រៀន និងកម្រិតថ្នាក់ និងបានបែងចែកភារកិច្ចសម្រាប់បុគ្គលិកអប់រំមិនបង្រៀនស្របតាមជំនាញ តែមិនគោរពតាមម៉ោងបំពេញការងារ |
| ពិន្ទុ ៣ | រៀបចំសេវាគ្រូបង្រៀនស្របតាមឯកទេសបង្រៀន និងបានបែងចែកភារកិច្ចសម្រាប់បុគ្គលិកមិនបង្រៀនស្របតាមឯកទេសជំនាញ |
| ពិន្ទុ ២ | បានរៀបចំទាំងសេវាគ្រូបង្រៀន និងបានបែងចែកភារកិច្ចសម្រាប់បុគ្គលិកមិនបង្រៀន |
| ពិន្ទុ ១ | បានរៀបចំតែសេវាគ្រូបង្រៀន ប៉ុន្តែមិនបានរៀបចំបែងចែកភារកិច្ចសម្រាប់បុគ្គលិកមិនបង្រៀន |
| ពិន្ទុ ០ | មិនបានរៀបចំសេវាគ្រូបង្រៀន និងបុគ្គលិកមិនបង្រៀន |

- ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងដំណើរការគ្រប់គ្រងសាលារៀន
  - ***សេចក្តីពន្យល់៖*** សំដៅដល់ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានគាំទ្រដល់ដំណើរការគ្រប់គ្រងសាលារៀន និងទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធ។
  - ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ឧបករណ៍ និងកម្មវិធីបច្ចេកវិទ្យាព័ត៌មាន (មានដូចជា កុំព្យូទ័រ ម៉ាស៊ីនបោះពុម្ព/ថតចម្លង អ៊ីនធើណេតក្នុងសាលា...) ២)ឯកសារបែងចែកភារកិច្ចមន្ត្រីទទួលបន្ទុកបច្ចេកវិទ្យាព័ត៌មាន និង៣)សម្ភាសជាមួយគណៈគ្រប់គ្រង និងភាគីពាក់ព័ន្ធ។
  - ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងទំនាក់ទំនងសាធារណៈ |
| ពិន្ទុ ២ | ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងទិន្នន័យសាលារៀន និងបំពេញកិច្ចការរដ្ឋបាលសាលារៀន |
| ពិន្ទុ ២ | ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងការរៀននិងបង្រៀនជាប្រចាំ |
| ពិន្ទុ ០ | មិនមានគ្រប់ចំណុចខាងលើ |

### ២.១.២ ការគ្រប់គ្រងសាលារៀន (២៥ពិន្ទុ)

- មានផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន(៥ឆ្នាំ)
  - ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀនសម្រាប់រយៈពេល ៥ឆ្នាំ ដោយមានការចូលរួមពិគ្រោះយោបល់ពីគ្រប់ភាគីពាក់ព័ន្ធ ដោយផ្អែកលើស្ថានភាពជាក់ស្តែង និងឆ្លើយតបទៅនឹងសូចនាករដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ភាគីពាក់ព័ន្ធរួមមាន គណៈគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស គ្រូបង្រៀន គណៈកម្មការគ្រប់គ្រងសាលារៀន/គណៈទ្រទ្រង់សាលារៀន/ក្រុមប្រឹក្សាភិបាលសាលារៀន និងដៃគូអភិវឌ្ឍ សហគមន៍ អាជ្ញាធរ មាតាបិតា អ្នកអាណាព្យាបាលសិស្ស។
  - ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)របាយការណ៍ប្រជុំធ្វើផែនការ ២)បញ្ជីវត្តមានអ្នកចូលរួមប្រជុំធ្វើផែនការ ៣)ផែនការអភិវឌ្ឍសាលារៀន និង៤)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។
  - ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥(គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន មានការចូលរួមពេញលេញពីគ្រប់ភាគីពាក់ព័ន្ធ |
| ពិន្ទុ ១ | ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀនដោយបានគិតគូរពីស្ថានភាពជាក់ស្តែង (តម្រូវការសាលារៀន លទ្ធភាពសាលារៀន និងសកម្មភាពដែលមិនទាន់បានអនុវត្តនៅឆ្នាំចាស់) |

| | |
|---|---|
| ពិន្ទុ ២ | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀនឆ្លើយតបទៅនឹងសូចនាករផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា |
| ពិន្ទុ ០ | មិនមានគ្រប់ចំណុចខាងលើ |

- <u>មានផែនការប្រតិបត្តិប្រចាំឆ្នាំ ឬផែនការកែលម្អសាលារៀន</u>

*សេចក្តីពន្យល់៖* សំដៅដល់សាលារៀនបានរៀបចំផែនការប្រតិបត្តិឬផែនការកែលម្អសាលារៀនសម្រាប់ឆ្នាំសិក្សានីមួយៗ ដោយមានការចូលរួមពិគ្រោះយោបល់ពីគ្រប់ភាគីពាក់ព័ន្ធ ដោយផ្អែកលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន។ ភាគីពាក់ព័ន្ធរួមមាន គណៈគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស គ្រូបង្រៀន គណៈកម្មការគ្រប់គ្រងសាលារៀន/គណៈទ្រទ្រង់សាលារៀន/ក្រុមប្រឹក្សាភិបាលសាលារៀន និងដៃគូអភិវឌ្ឍអប់រំ សហគមន៍ អាជ្ញាធរ មាតាបិតា អ្នកអាណាព្យាបាលសិស្ស។

- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ផែនការប្រតិបត្តិប្រចាំឆ្នាំ ២)ផែនការអភិវឌ្ឍសាលារៀន ៣)របាយការណ៍សមិទ្ធផលតាមកាល និង៤)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំឬផែនការកែលម្អសាលារៀន មានការចូលរួមពេញលេញពីគ្រប់ភាគីពាក់ព័ន្ធ |
| ពិន្ទុ ១ | ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំឬផែនការកែលម្អសាលារៀនដោយបានគិតគូរពីស្ថានភាពជាក់ស្តែង(តម្រូវការសាលារៀន លទ្ធភាពសាលារៀន និងសកម្មភាពដែលមិនទាន់បានអនុវត្តនៅឆ្នាំចាស់) |
| ពិន្ទុ ២ | ផែនការប្រតិបត្តិប្រចាំឆ្នាំឬផែនការកែលម្អសាលារៀន ផ្អែកលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន |
| ពិន្ទុ ០ | មិនមានគ្រប់ចំណុចខាងលើ |

- <u>មានប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តការងារជាប្រចាំ</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបចំផែនការសកម្មភាពតាមដានពិនិត្យនិងវាយតម្លៃការអនុវត្តការងារជាទៀងទាត់ ប្រព័ន្ធរបាយការណ៍តាមដានការអនុវត្តការងារ និងរបបប្រជុំវាយតម្លៃការអនុវត្តការងារជាប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆមាស ដើម្បីពិនិត្យវឌ្ឍនភាពនិងអនុវត្តវិធានការកែលម្អតាមដំណាក់កាលនីមួយៗ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ផែនការប្រតិបត្តិប្រចាំឆ្នាំ ២)ផែនការអភិវឌ្ឍសាលារៀន ៣)បញ្ជីសមាសភាពចូលរួមកិច្ចប្រជុំ និង៤)របាយការណ៍វឌ្ឍនភាពការងារប្រចាំខែ ត្រីមាស និងឆមាស។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានផែនការសកម្មភាពតាមដានពិនិត្យនិងវាយតម្លៃការអនុវត្តការងារ |
| ពិន្ទុ ១ | មានប្រព័ន្ធរបាយការណ៍តាមដានការអនុវត្តការងារ |
| ពិន្ទុ ២ | មានរបបប្រជុំវាយតម្លៃការអនុវត្តការងារជាប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆមាស |
| ពិន្ទុ ១ | មានការអនុវត្តសកម្មភាពកែលម្អផ្អែកលើលទ្ធផលនៃសកម្មភាពអនុវត្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃ |
| ពិន្ទុ ០ | មិនមានគ្រប់ចំណុចខាងលើ |

➢ **ស្វ័យវាយតម្លៃសាលារៀនប្រចាំឆ្នាំ ឆ្លុះបញ្ចាំងទៅនឹងផែនការប្រចាំឆ្នាំ**

- ***សេចក្តីពន្យល់៖*** សំដៅដល់ដំណើរការនៃការវាយតម្លៃការអនុវត្តការងាររបស់សាលារៀនដោយខ្លួនឯងក្នុងមួយឆ្នាំសិក្សាម្តងឆ្លុះបញ្ចាំងពីការអនុវត្តការងារធៀបទៅនឹងផែនការប្រចាំឆ្នាំ ឬផែនការប្រតិបត្តិដែលធ្វើឡើងដោយអធិការកិច្ចផ្ទៃក្នុង ដឹកនាំដោយនាយកសាលារៀនដែលមានការចូលរួមវាយតម្លៃពីគ្រប់ភាគីពាក់ព័ន្ធនៅក្នុងសាលារៀន (គណៈគ្រប់គ្រងសាលារៀន ប្រធាន/អនុប្រធានក្រុមបច្ចេកទេស គ្រូបង្រៀន សិស្សានុសិស្ស និងអ្នកពាក់ព័ន្ធផ្សេងៗទៀត)។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ផែនការអភិវឌ្ឍសាលារៀន ២)ឧបករណ៍ស្វ័យវាយតម្លៃ(ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើផលសម្រេច) និង៣)របាយការណ៍ស្វ័យវាយតម្លៃសាលារៀនប្រចាំឆ្នាំ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥(គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ៣ | ការអនុវត្តការស្វ័យវាយតម្លៃមានការចូលរួមពេញលេញពីគ្រប់ភាគីពាក់ព័ន្ធ |
| ពិន្ទុ ១ | បានផ្តល់របាយការណ៍ស្វ័យវាយតម្លៃដល់អង្គភាពពាក់ព័ន្ធទៀងទាត់និងទាន់ពេលវេលា |
| ពិន្ទុ ១ | បានកំណត់វិធានការកែលម្អផ្អែកលើលទ្ធផលនៃស្វ័យវាយតម្លៃសម្រាប់អនុវត្តនៅឆ្នាំបន្ទាប់ |
| ពិន្ទុ ០ | មិនបានធ្វើស្វ័យវាយតម្លៃសាលារៀន |

➢ **សមិទ្ធកម្មធៀបនឹងផែនការដែលបានកំណត់**

- ***សេចក្តីពន្យល់៖*** សំដៅដល់លទ្ធផលការងារដែលសាលារៀនសម្រេចបានធៀបទៅនឹងផែនការប្រតិបត្តិប្រចាំឆ្នាំ ឬផែនការកែលម្អសាលារៀនដែលបានកំណត់។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ផែនការប្រតិបត្តិប្រចាំឆ្នាំឬផែនការកែលម្អសាលារៀន និង២)របាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | សមិទ្ធកម្មសម្រេចបានតាមផែនការប្រតិបត្តិប្រចាំឆ្នាំ ដែលបានកំណត់ចាប់ពី ៨១ ភាគរយឡើងទៅ |
| ពិន្ទុ ៤ | សមិទ្ធកម្មសម្រេចបានតាមផែនការប្រតិបត្តិប្រចាំឆ្នាំ ដែលបានកំណត់ចន្លោះពី ៧១ ដល់៨០ភាគរយ |
| ពិន្ទុ ៣ | សមិទ្ធកម្មសម្រេចបានតាមផែនការប្រតិបត្តិប្រចាំឆ្នាំ ដែលបានកំណត់ចន្លោះពី ៦១ ដល់៧០ភាគរយ |
| ពិន្ទុ ២ | សមិទ្ធកម្មសម្រេចបានតាមផែនការប្រតិបត្តិប្រចាំឆ្នាំ ដែលបានកំណត់ចន្លោះពី ៥១ ដល់៦០ភាគរយ |
| ពិន្ទុ ១ | សមិទ្ធកម្មសម្រេចបានតាមផែនការប្រតិបត្តិប្រចាំឆ្នាំ ដែលបានកំណត់ចន្លោះពី ៣១ ដល់៥០ភាគរយ |
| ពិន្ទុ ០ | សមិទ្ធកម្មសម្រេចបានតាមផែនការប្រតិបត្តិប្រចាំឆ្នាំ ដែលបានកំណត់ក្រោម៣០ ភាគរយ |

### ២.១.៣ ការដឹកនាំការបង្រៀននិងរៀន (៤០ពិន្ទុ) (សាលាបឋមសិក្សា ៤៥ពិន្ទុ)

➢ <u>មានរចនាសម្ព័ន្ធដឹកនាំ និងគ្រប់គ្រងកម្មវិធីសិក្សា (នាយក នាយករងទទួលបន្ទុកបច្ចេកទេស និង ក្រុមបច្ចេកទេស)</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការរៀបចំឱ្យមានរចនាសម្ព័ន្ធ សមាសភាពដឹកនាំ និងការគ្រប់គ្រងការបែងចែកតួនាទីនិងភារកិច្ចច្បាស់លាស់ដល់គណៈគ្រប់គ្រងសាលារៀនទទួលបន្ទុកបច្ចេកទេស ក្រុមបច្ចេកទេសតាមមុខវិជ្ជា ក្នុងការងារដឹកនាំអនុវត្ត និងវាយតម្លៃការអនុវត្តកម្មវិធីសិក្សា និងការវាយតម្លៃលទ្ធផលការសិក្សា។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)បំណែងចែកតួនាទី និងភារកិច្ចគណៈគ្រប់គ្រងសាលារៀន ២)រចនាសម្ព័ន្ធក្រុមបច្ចេកទេស ៣)លិខិតបង្គាប់ការស្តីពីការបែងចែកតួនាទីនិងភារកិច្ចរបស់ក្រុមបច្ចេកទេសតាមមុខវិជ្ជានីមួយៗ ៤)ផែនការប្រចាំឆ្នាំរបស់ក្រុមបច្ចេកទេស និង៥)របាយការណ៍ប្រជុំក្រុមបច្ចេកទេសតាមមុខវិជ្ជានីមួយៗ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានបំណែងចែកតួនាទី និងភារកិច្ចនាយករងទទួលបន្ទុកបច្ចេកទេសច្បាស់លាស់ |
| ពិន្ទុ ១ | រចនាសម្ព័ន្ធគណៈគ្រប់គ្រងសាលារៀនមាននាយករងទទួលបន្ទុកបច្ចេកទេស |
| ពិន្ទុ ១ | មានបំណែងចែកតួនាទី និងភារកិច្ចក្រុមបច្ចេកទេសនីមួយៗ |
| ពិន្ទុ ២ | មានរៀបចំក្រុមបច្ចេកទេសតាមកម្រិតថ្នាក់ |
| ពិន្ទុ ០ | គ្មានក្រុមបច្ចេកទេសច្បាស់លាស់ |

- ដឹកនាំរៀបចំ និងអនុវត្តសកម្មភាពកម្មវិធីសិក្សាបន្ថែម (កម្មវិធីបំណិនជីវិតមូលដ្ឋាន អប់រំសីលធម៌ សុជីវធម៌...)

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបចំកម្មវិធីសិក្សាបន្ថែម ឬអនុវត្តសកម្មភាពកម្មវិធីសិក្សាបន្ថែមផ្សេងៗ ក្រៅពីកម្មវិធីសិក្សាថ្នាក់ជាតិ(កម្មវិធីបំណិនជីវិតមូលដ្ឋាន អប់រំសីលធម៌ សុជីវធម៌...) ឆ្លើយតបទៅតម្រូវការរបស់សេដ្ឋកិច្ចសង្គម សិស្ស និងសហគមន៍។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)កាលវិភាគកម្មវិធីសិក្សាបន្ថែម ឬការអនុវត្តសកម្មភាពបន្ថែម ២)កម្មវិធីសិក្សាបន្ថែម ឬការអនុវត្តសកម្មភាពបន្ថែម និង៣)សម្ភាសជាមួយគ្រូ និងសិស្ស។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥(គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានកម្មវិធីសិក្សាបន្ថែម ឬការអនុវត្តសកម្មភាពបន្ថែមបានអនុវត្តគ្រប់ថ្នាក់ |
| ពិន្ទុ ២ | មានកម្មវិធីសិក្សាបន្ថែម ឬការអនុវត្តសកម្មភាពបន្ថែម បានអនុវត្តគ្រប់កម្រិតថ្នាក់ |
| ពិន្ទុ ១ | មានកាលវិភាគកម្មវិធីសិក្សាបន្ថែម ឬការអនុវត្តសកម្មភាពបន្ថែមច្បាស់លាស់ |
| ពិន្ទុ ១ | មានកម្មវិធីសិក្សាបន្ថែម ឬការអនុវត្តសកម្មភាពបន្ថែម |
| ពិន្ទុ ០ | គ្មានកម្មវិធីសិក្សាបន្ថែម ឬការអនុវត្តសកម្មភាពបន្ថែម |

- អនុវត្តកម្មវិធីអំណានដំបូង និងគណិតវិទ្យាដំបូង (សម្រាប់តែសាលាបឋមសិក្សា)

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបឋមសិក្សាបានបញ្ចូល និងអនុវត្តកញ្ចប់កម្មវិធីអំណានដំបូង និងគណិតវិទ្យាដំបូងនៅក្នុងកម្មវិធីសិក្សាប្រចាំឆ្នាំ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)កញ្ចប់សម្ភារៈកម្មវិធីអំណានដំបូង គណិតវិទ្យាដំបូង ២)អង្កេត និងសម្ភាសន៍គ្រូបង្រៀនថ្នាក់ទី១ ទី២ និងទី៣ និង៣)សម្ភាសន៍គណៈគ្រប់គ្រងសាលារៀន និងកុមារថ្នាក់ទី១ ទី២ និងទី៣។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | បង្រៀនថ្នាក់ទី១ ទី២ និងទី៣ ចាប់ពី៩០ភាគរយឡើងទៅបានបញ្ចូល និងអនុវត្តកម្មវិធីកញ្ចប់អំណានដំបូង និងគណិតវិទ្យាដំបូងនៅក្នុងកម្មវិធីសិក្សា និងដំណើរការបង្រៀន និងរៀន |
| ពិន្ទុ ៤ | គ្រូបង្រៀនថ្នាក់ទី១ ទី២ និងទី៣ ចាប់ពី៨០ភាគរយឡើងទៅបានបញ្ចូល និងអនុវត្តកម្មវិធីកញ្ចប់អំណានដំបូង និងគណិតវិទ្យាដំបូងនៅក្នុងកម្មវិធីសិក្សា និងដំណើរការបង្រៀន និងរៀន |

| | |
|---|---|
| ពិន្ទុ ៣ | គ្រូបង្រៀនថ្នាក់ទី១ ទី២ និងទី៣ ចាប់ពី៧០ភាគរយឡើងទៅបានបញ្ចូល និងអនុវត្តកម្មវិធីកញ្ចប់អំណានដំបូង និងគណិតវិទ្យាដំបូង នៅក្នុងកម្មវិធីសិក្សា និងការបង្រៀន និងរៀនប្រចាំឆ្នាំ |
| ពិន្ទុ ២ | គ្រូបង្រៀនថ្នាក់ទី១ ទី២ និងទី៣ចាប់ពី៥០ភាគរយឡើងទៅ បានបញ្ចូល និងអនុវត្តកម្មវិធីកញ្ចប់សម្ភារៈអំណានដំបូង និងគណិតវិទ្យាដំបូង នៅក្នុងកម្មវិធីសិក្សា និងការបង្រៀន និងរៀនប្រចាំឆ្នាំ |
| ពិន្ទុ ១ | គ្រូបង្រៀនថ្នាក់ទី១ ទី២ និងទី៣ ក្រោម៥០ភាគរយ បានបញ្ចូល និងអនុវត្តកម្មវិធីកញ្ចប់សម្ភារៈអំណានដំបូង និងគណិតវិទ្យាដំបូង នៅក្នុងកម្មវិធីសិក្សា និងបង្រៀន និងរៀនប្រចាំឆ្នាំ |
| ពិន្ទុ ០ | គ្មានចំណុចទាំងអស់ខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** លក្ខណៈវិនិច្ឆ័យលម្អិតនេះ ពុំមាននៅតារាងលក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃអនុវិទ្យាល័យនោះទេ។

➢ មានសម្ភារៈសិក្សា និងសម្ភារៈឧបទេសតាមមុខវិជ្ជា និងតាមកម្រិតថ្នាក់

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបចំ បង្កើត(ផលិត) និងបំពាក់សម្ភារៈសិក្សា និងសម្ភារៈឧបទេសនានាសម្រាប់បម្រើដល់ការបង្រៀន និងរៀននៅតាមមុខវិជ្ជានីមួយៗ និងតាមកម្រិតថ្នាក់(សម្ភារៈឧបទេសសម្រាប់គ្រូបង្រៀន និងសម្ភារៈសិក្សាសម្រាប់សិស្ស)។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)កម្មវិធីសិក្សា ២)សៀវភៅសិក្សាគោល និង៣)សម្ភារៈឧបទេសសម្រាប់ដំណើរការបង្រៀន និងរៀន (សម្ភារៈឧបទេសដែលផ្តល់តាមរយៈថវិកាក្រសួង ឬច្នៃបង្កើតដោយបុគ្គលិកអប់រំរបស់សាលារៀន)។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥(គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | ថ្នាក់រៀនមានបំពាក់ក្តារខៀន តុ កៅអី ហ្វឹត ម៉ាស៊ីនបញ្ចាំងស្លាយសម្រាប់ដំណើរការបង្រៀន និងរៀន |
| ពិន្ទុ ១ | មានសម្ភារឧបទ្ទេសបំរើឱ្យការបង្រៀន និងរៀន |
| ពិន្ទុ ២ | មានសៀវភៅសិក្សាគោល កម្មវិធីសិក្សា និងឬសៀវភៅណែនាំគ្រូ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ មានរបបប្រជុំក្រុមបច្ចេកទេសតាមមុខវិជ្ជា(យ៉ាងតិច ៧ដងក្នុង១ឆ្នាំ) និងមានរបៀបវារៈច្បាស់លាស់តាមការណែនាំ/ការកំណត់

- ***សេចក្តីពន្យល់៖*** សំដៅដល់ការរៀបចំកិច្ចប្រជុំជាទៀងទាត់របស់ក្រុមបច្ចេកទេសតាមមុខវិជ្ជានីមួយៗក្នុងគោលបំណងចែករំលែក និងពង្រឹងវិធីសាស្ត្របង្រៀន ខ្លឹមសារបង្រៀន ឬការអភិវឌ្ឍចំណេះដឹង និងបំណិនទៅលើមុខវិជ្ជាបង្រៀន ការវាយតម្លៃការសិក្សារបស់សិស្ស ការរៀបចំ និងកែលម្អផែនការបង្រៀន និងរៀន និងថ្នាក់និទស្សន៍ជាដើម។

- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)របៀបវារៈកិច្ចប្រជុំ ២)បញ្ជីវត្តមានកិច្ចប្រជុំ ៣)របាយការណ៍កិច្ចប្រជុំក្រុមបច្ចេកទេស និង៤)ការសម្ភាសជាមួយអ្នកពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥(គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | ការប្រជុំបច្ចេកទេសមានប្រធានបទសម្បូរបែប និងជាកត្តាគន្លឹះក្នុងការពង្រឹងប្រសិទ្ធភាពបង្រៀន និងរៀនរួមមាន៖ ការចែករំលែក និងពង្រឹងវិធីសាស្ត្របង្រៀន ខ្លឹមសារបង្រៀន ឬការអភិវឌ្ឍចំណេះដឹង និងបំណិនទៅលើមុខវិជ្ជាបង្រៀន ការវាយតម្លៃការសិក្សារបស់សិស្ស ការរៀបចំ និងកែលម្អផែនការបង្រៀន និងរៀនជាដើម។ |
| ពិន្ទុ ១ | ការប្រជុំបច្ចេកទេស ផ្តោតលើការបង្រៀនថ្នាក់និទស្សន៍ |
| ពិន្ទុ ១ | ការប្រជុំក្រុមបច្ចេកទេសបានអនុវត្តជាទៀងទាត់ |
| ពិន្ទុ ១ | ការប្រជុំក្រុមបច្ចេកទេសមានរបៀបវារៈច្បាស់លាស់ |
| ពិន្ទុ ០ | គ្មានការប្រជុំក្រុមបច្ចេកទេស |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ការប្រជុំដែលយកជាផ្លូវការបាន(កម្មវត្ថុនៃការដាក់ពិន្ទុ) សំដៅដល់ការប្រជុំដែលផ្តោតលើប្រធានបទកែលម្អវិធីសាស្ត្របង្រៀន ខ្លឹមសារមេរៀន ឬការអភិវឌ្ឍចំណេះដឹង និងបំណិនទៅលើមុខវិជ្ជាដែលត្រូវបង្រៀន ការវាយតម្លៃការសិក្សារបស់សិស្ស និងការកែលម្អផែនការបង្រៀន និងរៀន។

### ➢ <u>មានផែនការ និងអនុវត្តអធិការកិច្ចផ្ទៃក្នុងលើការបង្រៀននិងរៀនជាប្រចាំ</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនរៀបចំផែនការ និងការចុះអធិការកិច្ចលើការបង្រៀននិងរៀនតាមថ្នាក់រៀននីមួយៗរបស់ក្រុមអធិការកិច្ចផ្ទៃក្នុង(នាយកសាលា នាយករងទទួលបន្ទុកបច្ចេកទេស ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនពាក់ព័ន្ធមួយចំនួនទៀត) ក្នុងគោលបំណងកែលម្អ និងពង្រឹងប្រសិទ្ធភាពការបង្រៀន និងរៀនរបស់គ្រូបង្រៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ផែនការអធិការកិច្ចប្រចាំឆ្នាំ ២)បញ្ជីថ្នាក់រៀនដែលរងអធិការកិច្ច ៣)បញ្ជីវត្តមានក្រុមអធិការកិច្ច និង៤)របាយការណ៍អធិការកិច្ច។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥(គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ៣ | បានអនុវត្តអធិការកិច្ចអប់រំនៅតាមថ្នាក់រៀនស្របតាមផែនការអធិការកិច្ច |
| ពិន្ទុ ១ | មានរៀបចំក្រុមការងារអធិការកិច្ចអប់រំផ្ទៃក្នុង សមាសភាពនាយករងទទួលបន្ទុកបច្ចេកទេស ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន...... |
| ពិន្ទុ ១ | មានផែនការអធិការកិច្ចតាមថ្នាក់រៀន |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចទាំងអស់ខាងលើ |

## ➢ មានការលើកទឹកចិត្ត និងចេះធ្វើការជាក្រុមដើម្បីបង្កើតវប្បធម៌ចែករំលែក

- ***សេចក្តីពន្យល់៖*** សំដៅដល់ការផ្តល់តម្លៃគ្នាទៅវិញទៅមក សាមគ្គីភាព ការលើកទឹកចិត្តគ្នាទៅវិញទៅមក ការប្រាស្រ័យទាក់ទង ការចែករំលែក ការចេះជួយពន្យល់ និងបង្ហាត់បង្ហាញគ្នាទៅវិញទៅមកនូវចំណេះដឹង ជំនាញ និងបទពិសោធការងារល្អ ក្នុងចំណោមបុគ្គលិកអប់រំ និងគ្រូបង្រៀននៅក្នុងសាលារៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ការសម្ភាសគណៈគ្រប់គ្រង គ្រូបង្រៀន សហគមន៍ អំពីសាមគ្គីភាព ការលើកទឹកចិត្តគ្នាទៅវិញទៅមក ការប្រាស្រ័យទាក់ទង ការចែករំលែក ការចេះជួយពន្យល់ និងបង្ហាត់បង្ហាញគ្នាទៅវិញទៅមកនូវចំណេះដឹង ជំនាញ និងបទពិសោធការងារល្អ ២)ការរៀបចំឱ្យមានបន្ទប់គ្រូបង្រៀន ៣)ការរៀបចំឱ្យមានវេទិកា ឬកម្មវិធីដែលអនុញ្ញាតឱ្យលោកគ្រូ អ្នកគ្រូចែករំលែកចំណេះដឹងថ្មីៗ និងបទពិសោធ និង៤)របាយការណ៍ ឬកំណត់ហេតុនៃកិច្ចប្រជុំបច្ចេកទេស ឬប្រជុំប្រចាំខែ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | សាលារៀនមានវប្បធម៌នៃការផ្តល់តម្លៃគ្នាទៅវិញទៅមក សាមគ្គីភាពផ្ទៃក្នុង ការចែករំលែក ការសហការ និងការធ្វើការជាក្រុមក្នុងចំណោមគណៈគ្រប់គ្រង គ្រូបង្រៀន និងបុគ្គលិកអប់រំ |
| ពិន្ទុ ៤ | គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងបុគ្គលិកអប់រំទាំងអស់មានការសហការ ការប្រាស្រ័យទាក់ទងល្អ ការធ្វើការងារជាក្រុម ការជួយគាំទ្រគ្នាទៅវិញទៅមក ការចែករំលែកចំណេះដឹងជំនាញ និងបទពិសោធការងារ |
| ពិន្ទុ ៣ | គណៈគ្រប់គ្រង និងគ្រូបង្រៀនមានការចែករំលែកចំណេះដឹង ជំនាញ និងបទពិសោធការងារដឹកនាំ និងគ្រប់គ្រងដល់គ្នាទៅវិញទៅមក |
| ពិន្ទុ ២ | គ្រូបង្រៀនមានការចែករំលែកចំណេះដឹង ជំនាញ និងបទពិសោធការងារបង្រៀននិងរៀនដល់គ្នាទៅវិញទៅមក |
| ពិន្ទុ ១ | គណៈគ្រប់គ្រង បុគ្គលិកអប់រំ និងគ្រូបង្រៀនមានការរាប់អានគ្នា និងការផ្តល់តម្លៃគ្នាទៅវិញទៅមក |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** សាមគ្គីភាពផ្ទៃក្នុងសំដៅដល់ការធ្វើការងារជាក្រុម មិនមើលបំណាំគ្នា ចេះជួយគ្នាទៅវិញទៅមក មានការទទួលខុសត្រូវលើភារកិច្ចរៀងៗខ្លួន និងរួមគ្នាទទួលខុសត្រូវ។

## ➢ មានការវាយតម្លៃលទ្ធផលការសិក្សារបស់សិស្សជាប្រចាំ(ការធ្វើតេស្តស្តង់ដា)

- ***សេចក្តីពន្យល់៖*** សំដៅដល់ការប្រឡងវាស់ស្ទង់សមត្ថភាពសិស្សប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំដែលត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមកម្មវិធីសិក្សា សៀវភៅសិក្សាគោលរបស់ក្រសួងអប់រំ យុវជន និងកីឡា និងត្រូវបានរៀបចំឡើងនៅតាមក្រុមបច្ចេកទេស ឬដោយសាលារៀន។

- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)តេស្តវង្វាយតម្លៃស្តង់ដាប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំ ២)បញ្ជីវត្តមានគ្រូបង្រៀន សិស្ស និងអ្នកចូលរួម និង៣)ក្តារខៀនបិទលទ្ធផលការសិក្សារបស់សិស្ស(នៅក្នុងបរិវេណសាលា និងទីសាធារណៈ)។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | មានការរៀបចំការធ្វើតេស្តវាយតម្លៃការសិក្សាស្តង់ដាវាស់ស្ទង់សមត្ថភាពរបស់សិស្សមុនពេលចូលរៀន និងធ្វើតេស្តវាយតម្លៃជាប្រចាំដោយប្រើវិញ្ញាសាស្តង់ដារួម ស្របតាមស្តង់ដាកម្មវិធីសិក្សា |
| ពិន្ទុ ៤ | មានការរៀបចំការធ្វើតេស្តវាយតម្លៃការសិក្សាស្តង់ដាវាស់ស្ទង់សមត្ថភាពរបស់សិស្សមុនពេលចូលរៀន និងធ្វើតេស្តវាយតម្លៃជាប្រចាំដោយប្រើវិញ្ញាសាស្តង់ដារួម |
| ពិន្ទុ ៣ | មានការរៀបចំការធ្វើតេស្តវាយតម្លៃជាប្រចាំ និងមានការរៀបចំតាក់តែងវិញ្ញាសាស្តង់ដារួម |
| ពិន្ទុ ២ | មានការវាយតម្លៃការសិក្សារបស់សិស្សពីគ្រូបង្រៀនម្នាក់ៗជាប្រចាំ (ប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំ) ប៉ុន្តែវិញ្ញាសារៀបចំដោយគ្រូបង្រៀនម្នាក់ៗដាច់ដោយឡែក |
| ពិន្ទុ ១ | មានការវាយតម្លៃការសិក្សារបស់សិស្សពីគ្រូបង្រៀនម្នាក់ៗ តែមិនទៀងទាត់ |
| ពិន្ទុ ០ | មិនមានការវាយតម្លៃការសិក្សារបស់សិស្ស |

➢ <u>មានការផ្តល់និងទទួលព័ត៌មានត្រឡប់អំពីលទ្ធផលសិក្សារបស់សិស្ស(សៀវភៅតាមដានការសិក្សាតាមលិខិតអញ្ជើញ...)ជាមួយមាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស សហគមន៍ និងអ្នកពាក់ព័ន្ធជាប្រចាំ</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនមានការរៀបចំយន្តការផ្តល់ដំណឹងដល់មាតាបិតា និងអ្នកអាណាព្យាបាល សហគមន៍និងអ្នកពាក់ព័ន្ធនានាអំពីការសិក្សារបស់សិស្ស ដូចជាលទ្ធផលនៃការសិក្សា វត្តមានប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំជាដើម។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)បញ្ជីសំរង់ពិន្ទុរបស់គ្រូម្នាក់ៗតាមមុខវិជ្ជា ២)សៀវភៅតាមដានការសិក្សា ៣)របាយការណ៍ទំនាក់ទំនងជាមួយមាតាបិតា អ្នកអាណាព្យាបាល សហគមន៍ និង អាជ្ញាធរដែនដី ៤)បញ្ជីវត្តមានសិស្ស និង៥)របាយការណ៍និងឯកសារពាក់ព័ន្ធនឹងកិច្ចប្រជុំរវាងគណៈគ្រប់គ្រងជាមួយអ្នកអាណាព្យាបាលសិស្ស។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | មានការផ្តល់ព័ត៌មានពីការសិក្សានិងវត្តមានរបស់សិស្សជាប្រចាំ(ប្រចាំខែ) និងមានការអញ្ជើញជួបប្រជុំជាមួយមាតាបិតាសិស្ស អាជ្ញាធរដែនដី និងសហគមន៍ដើម្បីកំណត់បញ្ហានៃការសិក្សា ទទួលសំណូមពរ និងស្វែងរកដំណោះស្រាយ |
| ពិន្ទុ ៤ | មានការផ្តល់ព័ត៌មានពីការសិក្សានិងវត្តមានរបស់សិស្សជាប្រចាំ(ប្រចាំខែ) និងមានការអញ្ជើញជួបប្រជុំជាមួយមាតាបិតាសិស្សដើម្បីកំណត់បញ្ហានៃការសិក្សា ទទួលសំណូមពរ និងស្វែងរកដំណោះស្រាយ |

| | |
|---|---|
| ពិន្ទុ ៣ | មានការផ្តល់ព័ត៌មានពីការសិក្សានិងវត្តមានរបស់សិស្សជាប្រចាំ(ប្រចាំខែ) |
| ពិន្ទុ ២ | មានការផ្តល់ព័ត៌មានពីការសិក្សា និងវត្តមានរបស់សិស្ស តែអនុវត្តមិនបានជាប់លាប់ |
| ពិន្ទុ ១ | មានសៀវភៅតាមដានការសិក្សា និងវត្តមានរបស់សិស្ស តែមិនបានយកទៅអនុវត្ត |
| ពិន្ទុ ០ | មិនមានសៀវភៅតាមដានការសិក្សា និងវត្តមានរបស់សិស្ស |

### ២.១.៤ ការធានាគណនេយ្យភាព (១០ពិន្ទុ)

➢ <u>ការគ្រប់គ្រងរដ្ឋបាល និងប្រព័ន្ធរាយការណ៍</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការគ្រប់គ្រងរដ្ឋបាលសាលារៀន(ដូចជា ចរន្តឯកសារ និងការរៀបចំ និងបែងចែកកាលវិភាគបង្រៀនជាដើម) និងការរៀបចំប្រព័ន្ធរាយការណ៍តាមឋានានុក្រមការងារនៅក្នុងសាលារៀន ក្នុងទិសដៅលើកកម្ពស់ប្រសិទ្ធភាព និងគណនេយ្យភាពការងាររបស់បុគ្គលិកអប់រំម្នាក់ៗ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)បំណែងចែកតួនាទីភារកិច្ចរបស់គណៈគ្រប់គ្រង និងបុគ្គលិករដ្ឋបាលរបស់សាលារៀន ២)កន្លែងបំពេញការងាររដ្ឋបាល និងអ្នកទទួលខុសត្រូវរដ្ឋបាលរបស់សាលារៀន និង៣)ការសម្ភាសជាមួយគណៈគ្រប់គ្រង និងអ្នកពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានបំណែងចែកភារកិច្ច និងការទទួលខុសត្រូវផ្នែករដ្ឋបាល |
| ពិន្ទុ ១ | មានកន្លែងធ្វើការ ការរៀបចំទុកដាក់ឯកសារ និងរបាយការណ៍ |
| ពិន្ទុ ១ | មានអ្នកទទួលខុសត្រូវលើការងារគ្រប់គ្រងរដ្ឋបាលច្បាស់លាស់ |
| ពិន្ទុ ២ | មានការកំណត់ចរន្តការងាររដ្ឋបាលក្នុងសាលារៀន |
| ពិន្ទុ ០ | មិនមានគ្រប់ចំណុចខាងលើ |

➢ <u>ការបិទផ្សាយលទ្ធផលសិក្សារបស់សិស្សដោយតម្លាភាព</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការបិទផ្សាយលទ្ធផលនៃការសិក្សារបស់សិស្សនៅលើក្តារខៀនព័ត៌មាន (នៅក្នុងបរិវេណសាលារៀន និងទីសាធារណៈ) និងនៅតាមថ្នាក់រៀន(លទ្ធផលនៃការសិក្សារបស់សិស្សប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំ)។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ការបិទផ្សាយលទ្ធផលការសិក្សារបស់សិស្សនៅតាមថ្នាក់រៀន និងតាមក្តារខៀនព័ត៌មាន(ក្នុងបរិវេណសាលារៀន និងទីសាធារណៈ)។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | មានការបិទផ្សាយលទ្ធផលនៃការសិក្សារបស់សិស្សក្នុងថ្នាក់រៀនគ្រប់ខែ គ្រប់ថ្នាក់ និងទៀងទាត់ និងបានបិទផ្សាយជាសាធារណៈ |
| ពិន្ទុ ៤ | មានការបិទផ្សាយលទ្ធផលនៃការសិក្សារបស់សិស្សក្នុងថ្នាក់រៀនគ្រប់ខែ គ្រប់ថ្នាក់ និងទៀងទាត់ តែមិនបានបិទផ្សាយជាសាធារណៈ(ក្នុងបរិវេណសាលារៀននិងទីសាធារណៈ) |
| ពិន្ទុ ៣ | មានការបិទផ្សាយលទ្ធផលនៃការសិក្សារបស់សិស្សក្នុងថ្នាក់រៀនគ្រប់ខែ គ្រប់ថ្នាក់ តែមិនទៀងទាត់ |
| ពិន្ទុ ២ | មានការបិទផ្សាយលទ្ធផលនៃការសិក្សារបស់សិស្សក្នុងថ្នាក់រៀនគ្រប់ខែ តែមិនគ្រប់កម្រិតថ្នាក់និងថ្នាក់ |
| ពិន្ទុ ១ | មានការបិទផ្សាយលទ្ធផលការសិក្សារបស់សិស្សធ្វើឡើងមិនបានគ្រប់ខែក្នុងថ្នាក់រៀន |
| ពិន្ទុ ០ | មិនមានការបិទផ្សាយលទ្ធផលសិក្សារបស់សិស្ស |

### ២.១.៥ ការគ្រប់គ្រងប្រកបដោយសុចរិតភាព (២០ពិន្ទុ)

➢ **ការណែនាំ និងការផ្សព្វផ្សាយបញ្ញាបការយល់ដឹងពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងសុចរិតភាពយ៉ាងហោច១ដងក្នុង១ឆ្នាំ**

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានណែនាំ ផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងអំពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនដល់បុគ្គលិកអប់រំ នៅក្នុងសាលារៀនយ៉ាងហោចឱ្យបាន១ដងក្នុងមួយឆ្នាំសិក្សា។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យ ១)សៀវភៅក្រមសីលធម៌វិជ្ជាជីវៈ ២)របាយការណ៍និងបញ្ជីវត្តមានប្រជុំផ្សព្វផ្សាយសៀវភៅក្រមសីលធម៌វិជ្ជាជីវៈ និង៣)កិច្ចសម្ភាសអំពីការយល់ដឹងរបស់គណៈគ្រប់គ្រង បុគ្គលិកអប់រំ និងគ្រូបង្រៀនអំពីសៀវភៅក្រមសីលធម៌វិជ្ជាជីវៈ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | ភាគរយនៃការយល់ដឹងរបស់បុគ្គលិកអប់រំអំពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន លើសពី ៨៥ភាគរយ |
| ពិន្ទុ ៤ | ភាគរយនៃការយល់ដឹងរបស់បុគ្គលិកអប់រំអំពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ចន្លោះពី ៧១ទៅ៨៥ភាគរយ |
| ពិន្ទុ ៣ | ភាគរយនៃការយល់ដឹងរបស់បុគ្គលិកអប់រំអំពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ចន្លោះពី ៥០ទៅ៧០ភាគរយ |
| ពិន្ទុ ២ | មានសៀវភៅស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងបានផ្សព្វផ្សាយយ៉ាងហោចមួយដងក្នុងមួយឆ្នាំ |
| ពិន្ទុ ១ | មានឯកសារឬសៀវភៅស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន តែមិនបានផ្សព្វផ្សាយ |
| ពិន្ទុ ០ | មិនមានឯកសារឬសៀវភៅស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន |

## ➢ គោរពក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន

- ***សេចក្តីពន្យល់៖*** សំដៅដល់បុគ្គលិកអប់រំគោរពនិងប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ក្នុងពេលបំពេញការងារ។ ការកំណត់អំពីការគោរពក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ត្រូវផ្អែកលើការវាយតម្លៃពីអ្នកប្រើប្រាស់សេវា និងអ្នកពាក់ព័ន្ធដែលរួមមានសិស្ស មាតាបិតាឬអ្នកអាណាព្យាបាលសិស្ស តំណាងសហគមន៍ និងអាជ្ញាធរ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)កិច្ចសម្ភាសជាមួយភាគីពាក់ព័ន្ធអំពីការគោរពក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និង២)របាយការណ៍វាយតម្លៃរបស់ក្រុមប្រឹក្សាវិន័យ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | អ្នកប្រើប្រាស់សេវា និងអ្នកពាក់ព័ន្ធចំនួនចាប់ពី៨៥ភាគរយ វាយតម្លៃថា បុគ្គលិកអប់រំគោរពក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន |
| ពិន្ទុ ៤ | អ្នកប្រើប្រាស់សេវា និងអ្នកពាក់ព័ន្ធចំនួនចាប់ពី៧៥ភាគរយ វាយតម្លៃថា បុគ្គលិកអប់រំគោរពក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន |
| ពិន្ទុ ៣ | អ្នកប្រើប្រាស់សេវា និងអ្នកពាក់ព័ន្ធចំនួនចាប់ពី៦៥ភាគរយ វាយតម្លៃថា បុគ្គលិកអប់រំគោរពក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន |
| ពិន្ទុ ២ | អ្នកប្រើប្រាស់សេវា និងអ្នកពាក់ព័ន្ធចំនួនចាប់ពី៤៥ភាគរយ វាយតម្លៃថា បុគ្គលិកអប់រំគោរពក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន |
| ពិន្ទុ ១ | អ្នកប្រើប្រាស់សេវា និងអ្នកពាក់ព័ន្ធចំនួនចាប់ពី២៥ភាគរយ វាយតម្លៃថា បុគ្គលិកអប់រំគោរពក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន |
| ពិន្ទុ ០ | អ្នកប្រើប្រាស់សេវា និងអ្នកពាក់ព័ន្ធចំនួនតិចជាង២៥ភាគរយ វាយតម្លៃថា បុគ្គលិកអប់រំគោរពក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន |

## ➢ ផ្តល់ដំបូន្មាននិងការអប់រំណែនាំបទបញ្ញាផ្ទៃក្នុង វិន័យសាលា សីលធម៌និងសុជីវធម៌ដល់សិស្សជាប្រចាំ

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបចំសកម្មភាព និងកម្មវិធីផ្តល់ដំបូន្មាន និងការអប់រំណែនាំបទបញ្ញាផ្ទៃក្នុង វិន័យសាលារៀន សីលធម៌ និងសុជីវធម៌ដល់សិស្សជាប្រចាំនៅក្នុងថ្នាក់រៀន និងនៅក្នុងបរិវេណសាលារៀនក្នុងគោលបំណងឱ្យសិស្សមានវិន័យ មានរបៀបរៀបរយ ឥរិយាបថមានសីលធម៌ និងសុជីវធម៌រៀន និងរស់នៅល្អទាំងនៅក្នុងថ្នាក់រៀន ក្នុងបរិវេណសាលារៀន នៅក្នុងសហគមន៍ និងសង្គម។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)កម្មវិធីការអប់រំណែនាំ និងផ្តល់ដំបូន្មានដល់សិស្សរបស់សាលារៀន ២)ការសម្ភាសជាមួយសិស្ស គ្រូបង្រៀន គណៈគ្រប់គ្រងសាលា និងសហគមន៍ ៣)ការអង្កេតសកម្មភាពនានារបស់សិស្សក្នុងថ្នាក់រៀន និងនៅក្នុងបរិវេណសាលារៀន និង៤)ពាក្យស្លោកនានានៅក្នុងថ្នាក់រៀន និងបរិវេណសាលារៀន។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥(គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | សិស្សានុសិស្សមានសីលធម៌ និងសុជីវធម៌ល្អទាំងនៅក្នុងសាលារៀន និងក្នុងសហគមន៍ |
| ពិន្ទុ ១ | នៅក្នុងថ្នាក់រៀន និងបរិវេណសាលារៀនមានពាក្យស្លោកជាការផ្តល់ដំបូន្មាន និងការអប់រំណែនាំ បទបញ្ជាផ្ទៃក្នុង វិន័យសាលារៀន សីលធម៌ និងសុជីវធម៌ដល់សិស្ស |
| ពិន្ទុ ១ | សាលារៀនមានរៀបចំកម្មវិធី និងកាលវិភាគ ដោយមានការអញ្ជើញចាស់ព្រឹទ្ធាចារ្យ ឬព្រះសង្ឃផ្តល់ជាឱវាទ ដំបូន្មាន និងការអប់រំណែនាំ សីលធម៌ និងសុជីវធម៌ដល់សិស្ស |
| ពិន្ទុ ១ | សាលារៀន ឬថ្នាក់រៀននីមួយៗបានរៀបចំបទបញ្ជាផ្ទៃក្នុងដោយឡែករបស់ខ្លួនសម្រាប់អនុវត្តនៅសាលារៀន |
| ពិន្ទុ ១ | សាលារៀនមានកម្មវិធីផ្តល់ដំបូន្មាន និងការអប់រំណែនាំជាប្រចាំនៅពេលគោរពទង់ជាតិ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ <u>មានគណនេយ្យភាព ភាពត្រឹមត្រូវ តម្លាភាព និងយុត្តិធម៌ក្នុងការវិនិច្ឆ័យការសិក្សារបស់សិស្ស</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបចំយន្តការ បទបញ្ជាផ្ទៃក្នុង វិន័យសម្រាប់បុគ្គលិកអប់រំ និងគ្រូបង្រៀនក្នុងការអនុវត្តការងារ ការបង្រៀន និងរៀន និងការវាយតម្លៃការសិក្សារបស់សិស្សប្រកបដោយគណនេយ្យភាព ភាពត្រឹមត្រូវ តម្លាភាព និងយុត្តិធម៌។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំងឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)បទបញ្ជាផ្ទៃក្នុងសាលារៀន ២)យន្តការ ឬនីតិវិធីការប្រឡង និង៣)ការសម្ភាស ជាមួយសិស្ស គ្រូបង្រៀន គណៈគ្រប់គ្រងសាលា និងសហគមន៍។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥(គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | បុគ្គលិកអប់រំ និងគ្រូបង្រៀនបានវិនិច្ឆ័យការសិក្សាសិស្សប្រកបដោយភាពត្រឹមត្រូវ និងយុត្តិធម៌ |
| ពិន្ទុ ១ | បុគ្គលិកអប់រំ និងគ្រូបង្រៀនបានវិនិច្ឆ័យការសិក្សាសិស្សប្រកបដោយគណនេយ្យភាព និងតម្លាភាព |
| ពិន្ទុ១ | សាលារៀនបានរៀបចំយន្តការវាយតម្លៃ និងការផ្តល់ពិន្ទុសិស្សប្រកបដោយតម្លាភាព និងយុត្តិធម៌ |
| ពិន្ទុ១ | គណៈគ្រប់គ្រងសាលាបានប្រជុំណែនាំបទបញ្ជាផ្ទៃក្នុង និងវិន័យសម្រាប់បុគ្គលិកអប់រំ និងគ្រូបង្រៀនក្នុងការបំពេញការងារ និងការបង្រៀន និងរៀនជាប្រចាំ |
| ពិន្ទុ ១ | សាលារៀនបានរៀបចំយន្តការ បទបញ្ជាផ្ទៃក្នុង និងវិន័យសម្រាប់បុគ្គលិកអប់រំ និងគ្រូបង្រៀនក្នុងការបំពេញការងារ និងការបង្រៀន និងរៀន |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## ២.១.៦ លទ្ធផលនៃការសិក្សា (៣៥ពិន្ទុ)

➢ អត្រាសិស្សចុះឈ្មោះចូលរៀនខ្ពស់ជាង ឬស្មើថ្នាក់ជាតិ

- ***សេចក្តីពន្យល់៖*** សំដៅដល់ផលធៀបអត្រាសិស្សចុះឈ្មោះចូលរៀនរបស់សាលារៀនធៀបនឹងអត្រាថ្នាក់ជាតិ។ អត្រាចុះឈ្មោះចូលរៀនសំដៅដល់ផលធៀបនៃចំនួនសិស្សចុះឈ្មោះចូលរៀនជាក់ស្តែងធៀបនឹងចំនួនសិស្សដល់អាយុត្រូវចុះឈ្មោះចូលរៀននៅក្នុងសហគមន៍សាលារៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)អត្រាកុមារចុះឈ្មោះចូលរៀន ប្រចាំឆ្នាំរបស់សាលារៀននៅក្នុងសហគមន៍សាលារៀន។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | អត្រាចុះឈ្មោះចូលសិក្សារួម លើសពីថ្នាក់ជាតិ ១៥ភាគរយ |
| ពិន្ទុ ៤ | អត្រាចុះឈ្មោះចូលសិក្សារួម លើសថ្នាក់ជាតិចាប់ពី១១ ដល់ ១៥ ភាគរយ |
| ពិន្ទុ ៣ | អត្រាចុះឈ្មោះចូលសិក្សារួម លើសថ្នាក់ជាតិចាប់ពី៦ ដល់ ១០ ភាគរយ |
| ពិន្ទុ ៥ | អត្រាចុះឈ្មោះចូលសិក្សារួម លើសថ្នាក់ជាតិ |
| ពិន្ទុ ១ | អត្រាចុះឈ្មោះចូលសិក្សារួម ស្មើថ្នាក់ជាតិ |
| ពិន្ទុ ០ | អត្រាចុះឈ្មោះចូលសិក្សារួម ស្ថិតនៅក្រោមថ្នាក់ជាតិ |

➢ អត្រាសិស្សបោះបង់ការសិក្សាទាបជាង ឬស្មើថ្នាក់ជាតិ

- ***សេចក្តីពន្យល់៖*** សំដៅដល់ផលធៀបអត្រាសិស្សបោះបង់ការសិក្សាក្នុងសាលារៀនធៀបទៅនឹងអត្រាបោះបង់ការសិក្សារួមទូទាំងប្រទេសប្រចាំឆ្នាំនៃក្រសួងអប់រំ យុវជន និងកីឡា។ អត្រានៃការបោះបង់ការសិក្សារបស់សិស្សក្នុងសាលារៀនសំដៅដល់ ផលធៀបនៃចំនួនសិស្សបោះបង់ការសិក្សា និងចំនួនសិស្សសរុបប្រចាំឆ្នាំសិក្សារបស់សាលារៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)អត្រាបោះបង់ការសិក្សាប្រចាំឆ្នាំរបស់សាលារៀន និង២)អត្រាបោះបង់ការសិក្សាប្រចាំឆ្នាំនៃក្រសួងអប់រំ យុវជន និងកីឡា។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | អត្រាបោះបង់ការសិក្សារបស់សិស្សទាបជាងថ្នាក់ជាតិ ចាប់ពី ៨ភាគរយ |
| ពិន្ទុ ៤ | អត្រាបោះបង់ការសិក្សារបស់សិស្សទាបជាងថ្នាក់ជាតិ ចាប់ពី ៦ភាគរយ |
| ពិន្ទុ ៣ | អត្រាបោះបង់ការសិក្សារបស់សិស្សទាបជាងថ្នាក់ជាតិ ចាប់ពី ៤ភាគរយ |
| ពិន្ទុ ២ | អត្រាបោះបង់ការសិក្សារបស់សិស្សទាបជាងថ្នាក់ជាតិ ចាប់ពី ២ភាគរយ |
| ពិន្ទុ ១ | អត្រាបោះបង់ការសិក្សារបស់សិស្សស្មើឬទាបជាងថ្នាក់ជាតិ |
| ពិន្ទុ ០ | អត្រាបោះបង់ការសិក្សារបស់សិស្សខ្ពស់ជាងថ្នាក់ជាតិ |

## ➢ អត្រាសិស្សត្រួតថ្នាក់ទាបជាង ឬស្មើថ្នាក់ជាតិ

- ***សេចក្តីពន្យល់៖*** សំដៅដល់ផលធៀបអត្រាសិស្សត្រួតថ្នាក់រួមក្នុងឆ្នាំសិក្សាក្នុងសាលារៀន ធៀបទៅនឹងអត្រាសិស្សត្រួតថ្នាក់រួមទូទាំងប្រទេសប្រចាំឆ្នាំនៃក្រសួងអប់រំ យុវជន និងកីឡានៅមធ្យមសិក្សា។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)អត្រាសិស្សត្រួតថ្នាក់នៅតាមកម្រិតថ្នាក់នីមួយៗ និង២)អត្រាសិស្សត្រួតថ្នាក់ជាតិកំណត់ដោយថ្នាក់ជាតិ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | អត្រាសិស្សត្រួតថ្នាក់ទាបជាងថ្នាក់ជាតិចាប់ពី ៣ភាគរយឡើង |
| ពិន្ទុ ៤ | អត្រាសិស្សត្រួតថ្នាក់ទាបជាងថ្នាក់ជាតិ ៣ភាគរយ |
| ពិន្ទុ ៣ | អត្រាសិស្សត្រួតថ្នាក់ទាបជាងថ្នាក់ជាតិ ២ភាគរយ |
| ពិន្ទុ ២ | អត្រាសិស្សត្រួតថ្នាក់ទាបជាងថ្នាក់ជាតិ ១ភាគរយ |
| ពិន្ទុ ១ | អត្រាសិស្សត្រួតថ្នាក់ស្មើថ្នាក់ជាតិ |
| ពិន្ទុ ០ | អត្រាសិស្សត្រួតថ្នាក់ខ្ពស់ជាងថ្នាក់ជាតិ |

## ➢ អត្រាសិស្សឡើងថ្នាក់ខ្ពស់ជាង ឬស្មើថ្នាក់ជាតិ

- ***សេចក្តីពន្យល់៖*** សំដៅដល់ផលធៀបរវាងអត្រាសិស្សឡើងថ្នាក់ប្រចាំឆ្នាំរបស់សាលារៀន និងអត្រាសិស្សឡើងថ្នាក់រួមទូទាំងប្រទេសប្រចាំឆ្នាំ របស់ក្រសួងអប់រំ យុវជន និងកីឡា។ អត្រាសិស្សឡើងថ្នាក់សំដៅដល់ផលធៀបរវាងចំនួនសិស្សឡើងថ្នាក់ និងចំនួនសិស្សសរុបប្រចាំឆ្នាំសិក្សារបស់សាលារៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)អត្រាសិស្សឡើងថ្នាក់ប្រចាំឆ្នាំរបស់សាលារៀន និង២)អត្រាសិស្សឡើងថ្នាក់ប្រចាំឆ្នាំនៃក្រសួងអប់រំ យុវជន និងកីឡា។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | អត្រាសិស្សឡើងថ្នាក់នៅតាមកម្រិតថ្នាក់នីមួយៗខ្ពស់ជាងថ្នាក់ជាតិ ចាប់ពី១០ភាគរយ |
| ពិន្ទុ ៤ | អត្រាសិស្សឡើងថ្នាក់នៅតាមកម្រិតថ្នាក់នីមួយៗខ្ពស់ជាងថ្នាក់ជាតិ ចាប់ពី៨ភាគរយ |
| ពិន្ទុ ៣ | អត្រាសិស្សឡើងថ្នាក់នៅតាមកម្រិតថ្នាក់នីមួយៗខ្ពស់ជាងថ្នាក់ជាតិ ចាប់ពី៦ភាគរយ |
| ពិន្ទុ ២ | អត្រាសិស្សឡើងថ្នាក់នៅតាមកម្រិតថ្នាក់នីមួយៗខ្ពស់ជាងថ្នាក់ជាតិ ចាប់៤ភាគរយ |
| ពិន្ទុ ១ | អត្រាសិស្សឡើងថ្នាក់នៅតាមកម្រិតថ្នាក់នីមួយៗស្មើឬខ្ពស់ជាងថ្នាក់ជាតិ |
| ពិន្ទុ ០ | អត្រាសិស្សឡើងថ្នាក់នៅតាមកម្រិតថ្នាក់នីមួយៗក្រោមថ្នាក់ជាតិ |

## ➢ សិស្សពូកែថ្នាក់កម្រង ឬក្រុង ស្រុក ខណ្ឌ ឬរាជធានី ខេត្ត/ថ្នាក់ជាតិ/អន្តរជាតិ

- ***សេចក្តីពន្យល់៖*** សំដៅដល់សិស្សដែលទទួលបានចំណាត់ថ្នាក់ជ័យលាភីសិស្សពូកែនៅថ្នាក់កម្រង/ក្រុង ស្រុក ខណ្ឌ ឬថ្នាក់រាជធានី ខេត្ត ដែលត្រូវបានទទួលស្គាល់ដោយមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ថ្នាក់ជាតិដែលត្រូវបានទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា និងថ្នាក់អន្តរជាតិដែលត្រូវបានបញ្ជូន និងទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា និងតាមរូបភាពផ្សេងទៀត។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)បញ្ជីឈ្មោះសិស្សចូលរួមប្រឡងសិស្សពូកែ ២)ពានជ័យលាភីប្រឡងសិស្សពូកែថ្នាក់កម្រង/ក្រុង ស្រុក ខណ្ឌ ឬថ្នាក់រាជធានីខេត្ត ថ្នាក់ជាតិ/ថ្នាក់អន្តរជាតិ ៣)ប្រកាសទទួលស្គាល់សិស្សពូកែ ឬជ័យលាភីសិស្សពូកែ និង៤)វិញ្ញាបនបត្រទទួលស្គាល់សិស្សពូកែ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | មានសិស្សចូលរួមប្រឡង និងជាប់សិស្សពូកែថ្នាក់ជាតិឬអន្តរជាតិ ក្នុងរយៈពេល៣ឆ្នាំចុងក្រោយ |
| ពិន្ទុ ៤ | មានសិស្សចូលរួមប្រឡងសិស្សពូកែថ្នាក់ជាតិ ក្នុងរយៈពេល៣ឆ្នាំចុងក្រោយ |
| ពិន្ទុ ៣ | មានសិស្សចូលរួមប្រឡង និងជាប់សិស្សពូកែថ្នាក់រាជធានី ខេត្ត ក្នុងរយៈពេល៣ឆ្នាំចុងក្រោយ |
| ពិន្ទុ ២ | មានសិស្សចូលរួមប្រឡងសិស្សពូកែថ្នាក់រាជធានី ខេត្ត ក្នុងរយៈពេល៣ឆ្នាំចុងក្រោយ |
| ពិន្ទុ ១ | មានការរៀបចំប្រឡងសិស្សពូកែប្រចាំសាលា ក្នុងរយៈពេល៣ឆ្នាំចុងក្រោយ |
| ពិន្ទុ ០ | មិនមានការរៀបចំប្រឡងសិស្សពូកែប្រចាំសាលា ក្នុងរយៈពេល៣ឆ្នាំចុងក្រោយ |

## ➢ អត្រាសិស្សឆ្លងភូមិសិក្សាខ្ពស់ជាង ឬស្មើថ្នាក់ជាតិ (សម្រាប់តែសាលាបឋមសិក្សា)

- ***សេចក្តីពន្យល់៖*** សំដៅដល់អត្រានៃសិស្សបានប្រឡងជាប់ និងឆ្លងភូមិសិក្សាធៀបជាមួយអត្រានៃសិស្សឆ្លងភូមិសិក្សារួមនៅទូទាំងប្រទេសក្នុងឆ្នាំសិក្សា។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)លទ្ធផលសិស្សប្រឡងជាប់ និងឆ្លងភូមិសិក្សារបស់សាលារៀនក្នុងឆ្នាំសិក្សា និង២)លទ្ធផលសិស្សប្រឡងជាប់ និងឆ្លងភូមិសិក្សាកម្រិតបឋមសិក្សារបស់ថ្នាក់ជាតិ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | អត្រាសិស្សប្រឡងជាប់ និងឆ្លងភូមិសិក្សាខ្ពស់ជាងថ្នាក់ជាតិ២៥ភាគរយ |
| ពិន្ទុ ៤ | អត្រាសិស្សប្រឡងជាប់ និងឆ្លងភូមិសិក្សាខ្ពស់ជាងថ្នាក់ជាតិ២០ភាគរយ |

| | |
|---|---|
| ពិន្ទុ ៣ | អត្រាសិស្សប្រឡងជាប់ និងឆ្លងភូមិសិក្សាខ្ពស់ជាងថ្នាក់ជាតិ១៥ភាគរយ |
| ពិន្ទុ ២ | អត្រាសិស្សប្រឡងជាប់ និងឆ្លងភូមិសិក្សាខ្ពស់ជាងថ្នាក់ជាតិ១០ភាគរយ |
| ពិន្ទុ ១ | អត្រាសិស្សប្រឡងជាប់ និងឆ្លងភូមិសិក្សាខ្ពស់ជាងថ្នាក់ជាតិ៥ភាគរយ |
| ពិន្ទុ ០ | អត្រាសិស្សប្រឡងជាប់ និងឆ្លងភូមិសិក្សាទាបជាងថ្នាក់ជាតិ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** លក្ខណៈវិនិច្ឆ័យលម្អិតនេះ ពុំមាននៅតារាងលក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃអនុវិទ្យាល័យនោះទេ។

> ➢ អត្រាសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិខ្ពស់ជាង ឬស្មើថ្នាក់ជាតិ (សម្រាប់តែអនុវិទ្យាល័យ)

- ***សេចក្តីពន្យល់៖*** សំដៅដល់អត្រានៃការប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិរបស់សាលារៀនធៀបជាមួយអត្រានៃការប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិរួមទូទាំងប្រទេសក្នុងឆ្នាំសិក្សា។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)លទ្ធផលប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិរបស់សាលារៀនក្នុងឆ្នាំសិក្សា និង២)លទ្ធផលប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិរបស់ថ្នាក់ជាតិ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | អត្រាសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិខ្ពស់ជាងថ្នាក់ជាតិ |
| ពិន្ទុ ៤ | អត្រាសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិស្មើថ្នាក់ជាតិ |
| ពិន្ទុ ៣ | អត្រាសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិទាបជាងថ្នាក់ជាតិ ៥ភាគរយ |
| ពិន្ទុ ២ | អត្រាសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិទាបជាងថ្នាក់ជាតិ ១០ភាគរយ |
| ពិន្ទុ ១ | អត្រាសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិទាបជាងថ្នាក់ជាតិ ១៥ភាគរយ |
| ពិន្ទុ ០ | អត្រាសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិទាបជាងថ្នាក់ជាតិ ២០ភាគរយ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** លក្ខណៈវិនិច្ឆ័យលម្អិតនេះ ពុំមាននៅតារាងលក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃបឋមសិក្សានោះទេ។

> ➢ សិស្សមានសមត្ថភាពស្របតាមកម្រិតថ្នាក់(ផ្អែកលើតេស្តស្តង់ដា) (សម្រាប់តែសាលាបឋមសិក្សា)

- ***សេចក្តីពន្យល់៖*** សំដៅដល់សមត្ថភាពក្នុងការសរសេរតែងសេចក្តី និងដោះស្រាយគណិតវិទ្យារបស់សិស្ស ធៀបនឹងកម្រិតថ្នាក់របស់សិស្សម្នាក់ៗ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)សាកសួរព័ត៌មានពីគ្រូបង្រៀនតាមមុខវិជ្ជានីមួយៗ ២)សម្ភាសជាមួយសិស្ស និង៣)តេស្តវាយតម្លៃនៃការសិក្សា(ពិន្ទុប្រចាំខែ និងប្រចាំឆមាស)។

- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖*

| | |
|---|---|
| ពិន្ទុ ៥ | សិស្សលើសពី ៩០ភាគរយមានសមត្ថភាពស្របតាមកម្រិតថ្នាក់ធៀបនឹងតេស្តវង្វាយតម្លៃថ្នាក់ជាតិ/តេស្តស្តង់ដា |
| ពិន្ទុ ៤ | សិស្សលើសពី ៨០ភាគរយមានសមត្ថភាពក្នុងការអាននិងសរសេរភាសាខ្មែរ និងគណនាគណិតវិទ្យា |
| ពិន្ទុ ៣ | សិស្សលើសពី ៨០ភាគរយមានសមត្ថភាពក្នុងការអាននិងសរសេរភាសាខ្មែរ និងគណនាគណិតវិទ្យា |
| ពិន្ទុ ២ | សិស្សលើសពី ៧០ភាគរយមានសមត្ថភាពក្នុងការអាននិងសរសេរភាសាខ្មែរ និងគណនាគណិតវិទ្យា |
| ពិន្ទុ ១ | សិស្សលើសពី ៦០ភាគរយមានសមត្ថភាពក្នុងការអាននិងសរសេរភាសាខ្មែរ និងគណនាគណិតវិទ្យា |
| ពិន្ទុ ០ | សិស្សក្រោម ៦០ភាគរយមានសមត្ថភាពក្នុងការអាននិងសរសេរភាសាខ្មែរ និងគណនាគណិតវិទ្យា |

- *ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖* លក្ខណៈវិនិច្ឆ័យលម្អិតនេះ ពុំមាននៅតារាងលក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃអនុវិទ្យាល័យនោះទេ។

➤ <u>សិស្សមានសមត្ថភាពស្របតាមកម្រិតថ្នាក់ (%និទ្ទេស A, B, C មុខវិជ្ជាអក្សរសាស្ត្រខ្មែរ គណិតវិទ្យា និងរូបវិទ្យា) (សម្រាប់តែអនុវិទ្យាល័យ)</u>

- *សេចក្តីពន្យល់៖* សំដៅដល់សិស្សមានសមត្ថភាពលើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ គណិតវិទ្យា និងរូបវិទ្យា ធៀបនឹងកម្រិតថ្នាក់របស់សិស្សម្នាក់ៗ។
- *ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖* ចំណុចត្រូវពិនិត្យ គឺលទ្ធផលតេស្តវាយតម្លៃនៃការសិក្សារបស់សិស្ស(ពិន្ទុប្រចាំខែ និងប្រចាំឆមាស)។
- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖*

| | |
|---|---|
| ពិន្ទុ ៥ | សិស្សលើសពី៥០ភាគរយ មាននិទ្ទេសA, B និងC ភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យា |
| ពិន្ទុ ៤ | សិស្សលើសពី៤០ភាគរយ មាននិទ្ទេសA, B និងC ភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យា |
| ពិន្ទុ ៣ | សិស្សលើសពី៣០ភាគរយ មាននិទ្ទេសA, B និងC ភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យា |
| ពិន្ទុ ២ | សិស្សលើសពី២០ភាគរយ មាននិទ្ទេសA, B និងC ភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យា |
| ពិន្ទុ ១ | សិស្សលើសពី១០ភាគរយ មាននិទ្ទេសA, B និងC ភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យា |
| ពិន្ទុ ០ | សិស្សក្រោម១០ភាគរយមាននិទ្ទេសA, B និងC ភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យា |

- *ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖* លក្ខណៈវិនិច្ឆ័យលម្អិតនេះ ពុំមាននៅតារាងលក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃបឋមសិក្សានោះទេ។

## ២.២ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាធានាឱ្យមានគុណភាព សមធម៌ និងបរិយាបន្ននៅក្នុងសាលារៀន (៤៥ពិន្ទុ)

### ២.២.១ ហេដ្ឋារចនាសម្ព័ន្ធ និងសកម្មភាពធានាដល់ការបង្រៀននិងរៀនប្រកបដោយគុណភាព (៤៥ពិន្ទុ)

➢ មានកម្មវិធី និងបន្ទប់សម្រាប់បង្រៀនកុំព្យូទ័រ

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនមានបន្ទប់សម្រាប់បង្រៀនកុំព្យូទ័រ (Computer Lab) និងមានកាលវិភាគបង្រៀនកុំព្យូទ័រសម្រាប់សិស្សានុសិស្ស។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)បន្ទប់បង្រៀនកុំព្យូទ័រ និងកុំព្យូទ័រ ២)គ្រូបង្រៀនកុំព្យូទ័រ ៣)កាលវិភាគកម្មវិធីបង្រៀនកុំព្យូទ័រ និង៤)កម្មវិធីសិក្សា និងសៀវភៅសិក្សាគោល។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥(គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | បានអនុវត្តការបង្រៀនកុំព្យូទ័រសម្រាប់គ្រប់ថ្នាក់ និងកម្រិតថ្នាក់ |
| ពិន្ទុ ១ | មានគ្រូបង្រៀនកុំព្យូទ័រដែលមានសញ្ញាបត្រឯកទេសកុំព្យូទ័រ |
| ពិន្ទុ ១ | មានគ្រូបង្រៀនកុំព្យូទ័រនិងកាលវិភាគបង្រៀនកុំព្យូទ័រ |
| ពិន្ទុ ១ | មានកម្មវិធីសិក្សា (MS.Word, Excel, Power Point...) |
| ពិន្ទុ ១ | មានបន្ទប់កុំព្យូទ័រ និងកុំព្យូទ័រ |
| ពិន្ទុ ០ | មិនមានគ្រប់ចំណុចខាងលើ |

➢ មានកម្មវិធី និងបន្ទប់សម្រាប់បង្រៀនភាសាបរទេស

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនមានបន្ទប់បង្រៀនភាសាបរទេសដាច់ដោយឡែក (Language Lab) និងមានឧបករណ៍បម្រើឱ្យការបង្រៀនភាសាបរទេស។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)បន្ទប់បង្រៀនភាសាបរទេស ២)គ្រូបង្រៀនភាសាបរទេស ៣)កាលវិភាគ និងកម្មវិធីបង្រៀនភាសាបរទេស ៤)សៀវភៅសិក្សាគោលភាសាបរទេស។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥(គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | បានអនុវត្តការបង្រៀនភាសាបរទេសសម្រាប់គ្រប់ថ្នាក់ និងកម្រិតថ្នាក់ |
| ពិន្ទុ ១ | មានគ្រូបង្រៀនភាសាបរទេសដែលមានសញ្ញាបត្រឯកទេស |
| ពិន្ទុ ១ | មានកម្មវិធីសិក្សាភាសាបរទេស |
| ពិន្ទុ ២ | មានបន្ទប់បង្រៀនភាសាបរទេស និងសម្ភារៈបម្រើដល់ការបង្រៀនភាសាបរទេស |
| ពិន្ទុ ០ | មិនមានគ្រប់ចំណុចខាងលើ |

## ➢ មានកាលវិភាគ និងបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ (សម្រាប់តែអនុវិទ្យាល័យ)

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនមានបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ (គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីនិងបរិស្ថាន) និងសម្ភារៈពិសោធន៍ ដែលស្ថិតនៅដាច់ដោយឡែកពីថ្នាក់រៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ ២)សម្ភារៈពិសោធន៍វិទ្យាសាស្ត្រ ៣)គ្រូបង្រៀនប្រចាំការ និង៤)កាលវិភាគនិងកម្មវិធីពិសោធន៍វិទ្យាសាស្ត្រ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥(គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានដំណើរការពិសោធន៍វិទ្យាសាស្ត្រទៀងទាត់ស្របតាមកម្មវិធីសិក្សា |
| ពិន្ទុ ១ | មានផែនការពិសោធន៍មុខវិជ្ជានីមួយៗ |
| ពិន្ទុ ១ | មានសម្ភារៈពិសោធន៍ |
| ពិន្ទុ ១ | មានបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ ឬបន្ទប់មុខវិជ្ជា |
| ពិន្ទុ ០ | គ្មានបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** លក្ខណៈវិនិច្ឆ័យលម្អិតនេះ ពុំមាននៅតារាងលក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃបឋមសិក្សានោះទេ។

## ➢ មានបន្ទប់ពេងជាងនិងគេហវិទ្យា ឬ បន្ទប់សិល្បៈ

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនមានបន្ទប់ដាច់ដោយឡែកសម្រាប់បម្រើជាបន្ទប់ពេងជាងគេហវិទ្យាក្នុងការបង្រៀន និងរៀនតាមបែបគម្រោង បំណិន ឬជាបន្ទប់សម្រាប់បង្រៀនមុខវិជ្ជាសិល្បៈ (តន្ត្រី របាំ គំនូរ...) ដែលរៀបចំដាច់ដោយឡែកពីថ្នាក់រៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)បន្ទប់ពេងជាង និងគេហវិទ្យា ឬបន្ទប់សិល្បៈ ២)សម្ភារៈ ៣)គ្រូបង្រៀន ៤)កាលវិភាគ ឬកម្មវិធីសិក្សា និង៥)ស្នាដៃ ឬការសម្តែងសិល្បៈនានារបស់សិស្ស។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥(គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានការតាំងបង្ហាញស្នាដៃរបស់សិស្ស និងកម្មវិធីសម្តែងសិល្បៈ |
| ពិន្ទុ ១ | មាន និងអនុវត្តកម្មវិធីសិក្សាពេងជាង គេហវិទ្យា ឬសិល្បៈជាទៀងទាត់ |
| ពិន្ទុ ១ | មានគ្រូបង្រៀនកម្មវិធីពេងជាង គេហវិទ្យា ឬសិល្បៈ |
| ពិន្ទុ ១ | មានសម្ភារៈបម្រើឱ្យពេងជាង គេហវិទ្យា ឬសិល្បៈ |
| ពិន្ទុ ១ | មានបន្ទប់ពេងជាង និងគេហវិទ្យា ឬបន្ទប់សិល្បៈ |
| ពិន្ទុ ០ | គ្មានបន្ទប់ |

## ➢ មានបណ្ណាល័យ

- ***សេចក្តីពន្យល់៖*** សំដៅដល់ការរៀបចំបន្ទប់ ឬអគារដែលមានការដាក់តាំងបង្ហាញសៀវភៅសម្រាប់ឱ្យបុគ្គលិកអប់រំ គ្រូបង្រៀន និងសិស្សានុសិស្សសិក្សាស្រាវជ្រាវបន្ថែម និងមានការចាត់តាំងបណ្ណារក្សជាអ្នកទទួលខុសត្រូវក្នុងដំណើរការគ្រប់គ្រងការអាន ស្រាវជ្រាវរបស់សិស្សានុសិស្ស បុគ្គលិកអប់រំ និងគ្រូបង្រៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)បន្ទប់ឬអគារ(បណ្ណាល័យ) ២)បណ្ណារក្ស ៣)បញ្ជីចុះឈ្មោះអ្នកចូលអានសៀវភៅ ៤)កាលវិភាគនៃការចូលអាន និង៥)សម្ភាសជាមួយអ្នកពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | សិស្ស បុគ្គលិកអប់រំ និងគ្រូបង្រៀនបានប្រើប្រាស់បណ្ណាល័យជាកន្លែងសិក្សា និងស្រាវជ្រាវរបស់ខ្លួនជាប្រចាំ |
| ពិន្ទុ ៤ | បណ្ណាល័យមានបណ្ណារក្ស មានសៀវភៅអានគ្រប់កម្រិតថ្នាក់ និងគ្រប់ឯកទេស និងមានសិស្សចូលអានគ្រប់ពេល |
| ពិន្ទុ ៣ | បណ្ណាល័យមានបណ្ណារក្ស មានសៀវភៅអានគ្រប់កម្រិតថ្នាក់និងគ្រប់ឯកទេស និងមានសិស្សចូលអានតិចតួច |
| ពិន្ទុ ២ | សាលារៀនមានបណ្ណាល័យ និងមានបណ្ណារក្សទទួលខុសត្រូវ |
| ពិន្ទុ ១ | សាលារៀនមានបណ្ណាល័យ តែគ្មានបណ្ណារក្ស |
| ពិន្ទុ ០ | សាលារៀនគ្មានបណ្ណាល័យ |

## ➢ មានបន្ទប់សម្រាប់គ្រូបង្រៀនធ្វើការ ប្រជុំ និងស្រាវជ្រាវ

- ***សេចក្តីពន្យល់៖*** សំដៅដល់ការរៀបចំឱ្យមានបន្ទប់ ឬអគារដាច់ដោយឡែកសម្រាប់គ្រូបង្រៀនបំពេញការងារ ជួបប្រជុំ និងស្រាវជ្រាវដើម្បីអភិវឌ្ឍចំណេះដឹងលើមុខវិជ្ជាបង្រៀន(ចំណេះដឹងវិជ្ជាជីវៈ) និងវិធីសាស្ត្របង្រៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)បន្ទប់ ឬអគារសម្រាប់គ្រូបង្រៀនបំពេញការងារ ជួបប្រជុំ និងស្រាវជ្រាវ និង២)សម្ភារៈសម្រាប់ដំណើរការការងារ ប្រជុំ និងស្រាវជ្រាវ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | មានបន្ទប់ ឬអគារ ទូទុកដាក់ឯកសារ តុកៅអី កុំព្យូទ័រ ម៉ាស៊ីនបោះពុម្ព និងថតចម្លង ម៉ាស៊ីនបញ្ចាំងស្លាយ(LCD Projector) និងភ្ជាប់អិនធើណែត សម្រាប់គ្រូបង្រៀនបំពេញការងារ ជួបប្រជុំ និងស្រាវជ្រាវ |
| ពិន្ទុ ៤ | មានបន្ទប់ ឬអគារ ទូទុកដាក់ឯកសារ តុកៅអី កុំព្យូទ័រ ម៉ាស៊ីនបោះពុម្ព និងថតចម្លង សម្រាប់គ្រូបង្រៀនបំពេញការងារ ជួបប្រជុំ និងស្រាវជ្រាវ |

| | |
|---|---|
| ពិន្ទុ ៣ | មានបន្ទប់ ឬអគារ ទុទុកដាក់ឯកសារ តុកៅអី និងកុំព្យូទ័រសម្រាប់គ្រូបង្រៀនបំពេញការងារ ជួបប្រជុំ និងស្រាវជ្រាវ |
| ពិន្ទុ ២ | មានបន្ទប់ ឬអគារដែលមានទូទុកដាក់ឯកសារ និងតុកៅអីសម្រាប់គ្រូបង្រៀនបំពេញការងារ ជួបប្រជុំ និងស្រាវជ្រាវ |
| ពិន្ទុ ១ | មានបន្ទប់ ឬអគារដែលមានតុ កៅអីសម្រាប់គ្រូបង្រៀនបំពេញការងារ និងជួបប្រជុំ |
| ពិន្ទុ ០ | គ្មានបន្ទប់ ឬអគារសម្រាប់គ្រូបង្រៀនបំពេញការងារ ជួបប្រជុំ និងស្រាវជ្រាវ |

➢ មានសម្ភារៈបច្ចេកវិទ្យានិងឌីជីថលសម្រាប់គាំទ្រការបង្រៀននិងរៀន

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបបន្ទប់រៀនឌីជីថល ឬបំពាក់សម្ភារៈបច្ចេកវិទ្យា និងឌីជីថលនៅតាមថ្នាក់រៀនដើម្បីជាជំនួយ ឬបម្រើដល់ការបង្រៀន និងរៀនឱ្យកាន់តែមានប្រសិទ្ធភាព និងសក្តិសិទ្ធិភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)បន្ទប់រៀនឌីជីថល ២)សម្ភារៈបច្ចេកវិទ្យាព័ត៌មាន និងឌីជីថល (បណ្តាញអគ្គីសនី កុំព្យូទ័រ ម៉ាស៊ីនបញ្ចាំងស្លាយ អ៊ីនធឺណែត ទូរទស្សន៍ឆ្លាតវៃ...)។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥(គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | គ្រូបង្រៀនបានប្រើប្រាស់កុំព្យូទ័រ ម៉ាស៊ីនបញ្ចាំងស្លាយ ទូរទស្សន៍ឆ្លាតវៃ និងអ៊ីនធើណែត សម្រាប់ការស្រាវជ្រាវ និងការបង្រៀន និងរៀនជាប្រចាំ |
| ពិន្ទុ ២ | គ្រូបង្រៀនចេះប្រើប្រាស់កុំព្យូទ័រ ម៉ាស៊ីនបញ្ចាំងស្លាយ ទូរទស្សន៍ឆ្លាតវៃ និងអ៊ីនធឺណែតសម្រាប់ការស្រាវជ្រាវ និងការបង្រៀននិងរៀន |
| ពិន្ទុ ១ | សាលារៀនបានរៀបចំបន្ទប់រៀនឌីជីថល ឬថ្នាក់រៀនឌីជីថលដោយមានបណ្តាញអគ្គីសនី កុំព្យូទ័រ ម៉ាស៊ីនបញ្ចាំងស្លាយ ទូរទស្សន៍ឆ្លាតវៃ និងអ៊ីនធឺណែត |
| ពិន្ទុ ០ | សាលារៀនគ្មានបន្ទប់រៀនឌីជីថល ឬបំពាក់សម្ភារៈបច្ចេកវិទ្យា និងឌីជីថលនៅតាមថ្នាក់រៀន |

➢ មានបន្ទប់ពហុបំណង ឬមជ្ឈមណ្ឌលសិក្សាសហគមន៍ និងមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត (សម្រាប់តែអនុវិទ្យាល័យ)

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនមានការរៀបចំបន្ទប់ ឬអគារដាច់ដោយឡែងសម្រាប់បង្រៀនមុខវិជ្ជាអភិវឌ្ឍន៍សមត្ថភាពដល់យុវជននៅក្នុងសហគមន៍ និងសិស្សក្នុងសាលារៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ បន្ទប់ ឬ អគារដាច់ដោយឡែក កម្មវិធីសិក្សា គ្រូបង្រៀន វគ្គបណ្តុះបណ្តាល ចំនួនសិស្សបានបញ្ចប់វគ្គបណ្តុះបណ្តាល និង វិញ្ញាបនបត្របញ្ចប់ការសិក្សា ជាដើម។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | សាលារៀនមានអគារ ឬបន្ទប់ដាច់ដោយឡែក មានកម្មវិធីសិក្សា មានគ្រូបង្រៀន និងមានសិស្សទទួលវិញ្ញាបនបត្របញ្ចប់វគ្គបណ្តុះបណ្តាលនីមួយៗ ដែលជាកម្មវិធីអភិវឌ្ឍន៍សមត្ថភាពយុវជននៅក្នុងសហគមន៍របស់សាលារៀននាឆ្នាំកន្លងមក |
| ពិន្ទុ ៤ | មានបន្ទប់ ឬអគារ និងគ្រូបង្រៀនសម្រាប់ដំណើរការកម្មវិធីអភិវឌ្ឍន៍សមត្ថភាពយុវជនពិតប្រាកដ |
| ពិន្ទុ ៣ | សាលារៀនបានដំណើរកម្មវិធីអភិវឌ្ឍន៍សមត្ថភាពយុវជន និងមានគ្រូបណ្តុះបណ្តាល តែពុំមានបន្ទប់ ឬអគារបណ្តុះបណ្តាលច្បាស់លាស់ |
| ពិន្ទុ ២ | សាលារៀនដំណើរការកម្មវិធីអភិវឌ្ឍន៍សមត្ថភាពយុវជន តែគ្មានគ្រូបង្រៀនច្បាស់លាស់ |
| ពិន្ទុ ១ | សាលារៀនមានកម្មវិធីអភិវឌ្ឍន៍សមត្ថភាពយុវជនតែមិនដំណើរការ |
| ពិន្ទុ ០ | សាលារៀនគ្មានកម្មវិធីអភិវឌ្ឍន៍សមត្ថភាពយុវជន |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** លក្ខណៈវិនិច្ឆ័យលម្អិតនេះ ពុំមាននៅតារាងលក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃបឋមសិក្សានោះទេ។

➢ មានអគារ/បន្ទប់ ឬហេដ្ឋារចនាសម្ព័ន្ធសម្រាប់អនុវត្តបំណិនជីវិតមូលដ្ឋាន (សម្រាប់តែអនុវិទ្យាល័យ)

- ***សេចក្តីពន្យល់៖*** សំដៅដល់ការរៀបចំកម្មវិធីសិក្សាបំណិនជីវិតមូលដ្ឋានដែលលើកយកមុខវិជ្ជាបំណិនមកបង្រៀននៅក្នុងសាលារៀន ដើម្បីបន្ត ថែរក្សា និងផ្សព្វផ្សាយបន្ថែម លើបំណិនដែលមានស្រាប់នៅក្នុងសហគមន៍។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ហេដ្ឋារចនាសម្ព័ន្ធ ឬ ទីកន្លែង សម្រាប់ដំណើរការ មានកម្មវិធីសិក្សា មានគ្រូបង្រៀន និងសិស្សរៀនច្បាស់លាស់។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | សាលារៀនមានហេដ្ឋារចនាសម្ព័ន្ធ ឬ ទីកន្លែង មានកម្មវិធីបំណិនជីវិតមូលដ្ឋាន មានគ្រូបង្រៀន និងមានសិស្សចូលរួមរៀន និងបានអនុវត្តបំណិនជីវិតមូលដ្ឋានច្បាស់លាស់ |
| ពិន្ទុ ៤ | សាលារៀនមានហេដ្ឋារចនាសម្ព័ន្ធ ឬ ទីកន្លែងអនុវត្តបំណិន មានកម្មវិធីសិក្សា និងគ្រូបង្រៀន តែមិនដំណើរការ |
| ពិន្ទុ ៣ | សាលារៀនមានកម្មវិធីសិក្សាបំណិន មានគ្រូបង្រៀន តែគ្មានទីតាំងអនុវត្ត |
| ពិន្ទុ ២ | សាលារៀនមានកម្មវិធីសិក្សាបំណិនជីវិតមូលដ្ឋាន តែគ្មានគ្រូបង្រៀនច្បាស់លាស់ |
| ពិន្ទុ ១ | សាលារៀនមានតែកម្មវិធីសិក្សាបំណិនជីវិតមូលដ្ឋាន តែមិនដំណើរការ |
| ពិន្ទុ ០ | សាលារៀនគ្មានកម្មវិធីសិក្សាបំណិនជីវិតមូលដ្ឋាន |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** លក្ខណៈវិនិច្ឆ័យលម្អិតនេះ ពុំមាននៅតារាងលក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃបឋមសិក្សានោះទេ។

## ២.៣ គុណវុឌ្ឍិ និងជំនាញវិជ្ជាជីវៈបុគ្គលិកអប់រំ (៩០ពិន្ទុ)

### ២.៣.១ ចំណេះដឹង និងសមត្ថភាពជំនាញរបស់បុគ្គលិកអប់រំ (៥៥ពិន្ទុ)

➢ ភាគរយបុគ្គលិកអប់រំមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រឡើងទៅ

- ***សេចក្តីពន្យល់៖*** សំដៅដល់ផលធៀបរវាងចំនួននៃបុគ្គលិកអប់រំដែលមានគុណវុឌ្ឍិ និងជំនាញវិជ្ជាជីវៈចាប់ពីបរិញ្ញាបត្រឡើងទៅ និងចំនួនបុគ្គលិកអប់រំសរុបក្នុងសាលារៀនក្នុងឆ្នាំសិក្សា។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ស្ថិតិបុគ្គលិកអប់រំ និង២)គុណវឌ្ឍិ និងជំនាញវិជ្ជាជីវៈរបស់បុគ្គលិកអប់រំក្នុងសាលារៀន។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | បុគ្គលិកអប់រំស្មើ ឬលើសពី ៥០ភាគរយ មានសញ្ញាបត្របរិញ្ញាបត្រ |
| ពិន្ទុ ៤ | បុគ្គលិកអប់រំ ៤០ភាគរយ មានសញ្ញាបត្របរិញ្ញាបត្រ |
| ពិន្ទុ ៣ | បុគ្គលិកអប់រំ ៣០ភាគរយ មានសញ្ញាបត្របរិញ្ញាបត្រ |
| ពិន្ទុ ២ | បុគ្គលិកអប់រំ ២០ភាគរយ មានសញ្ញាបត្របរិញ្ញាបត្រ |
| ពិន្ទុ ១ | បុគ្គលិកអប់រំ ១០ភាគរយ មានសញ្ញាបត្របរិញ្ញាបត្រ |
| ពិន្ទុ ០ | បុគ្គលិកអប់រំទាំងអស់គ្មានសញ្ញាបត្របរិញ្ញាបត្រ |

➢ ភាគរយបុគ្គលិកអប់រំមានសញ្ញាបត្រគ្រូបង្រៀនកម្រិតមូលដ្ឋាន

- ***សេចក្តីពន្យល់៖*** សំដៅដល់ផលធៀបរវាងចំនួននៃបុគ្គលិកអប់រំដែលមានសញ្ញាបត្រគ្រូបង្រៀនកម្រិតមូលដ្ឋាន និងចំនួនបុគ្គលិកអប់រំសរុបក្នុងសាលារៀនក្នុងឆ្នាំសិក្សា។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ស្ថិតិបុគ្គលិកអប់រំ និង២)សញ្ញាបត្រគ្រូបង្រៀនកម្រិតមូលដ្ឋានរបស់បុគ្គលិកអប់រំក្នុងសាលារៀន។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | បុគ្គលិកអប់រំ ២៥ភាគរយ មានសញ្ញាបត្រគ្រូបង្រៀនកម្រិតមូលដ្ឋាន |
| ពិន្ទុ ៤ | បុគ្គលិកអប់រំ ២០ភាគរយ មានសញ្ញាបត្រគ្រូបង្រៀនកម្រិតមូលដ្ឋាន |
| ពិន្ទុ ៣ | បុគ្គលិកអប់រំ ១៥ភាគរយ មានសញ្ញាបត្រគ្រូបង្រៀនកម្រិតមូលដ្ឋាន |
| ពិន្ទុ ២ | បុគ្គលិកអប់រំ ១០ភាគរយ មានសញ្ញាបត្រគ្រូបង្រៀនកម្រិតមូលដ្ឋាន |
| ពិន្ទុ ១ | បុគ្គលិកអប់រំ ៥ភាគរយ មានសញ្ញាបត្រគ្រូបង្រៀនកម្រិតមូលដ្ឋាន |
| ពិន្ទុ ០ | បុគ្គលិកអប់រំទាំងអស់គ្មានសញ្ញាបត្រគ្រូបង្រៀនកម្រិតមូលដ្ឋាន |

➢ ភាគរយបុគ្គលិកអប់រំមានសញ្ញាបត្រគ្រូបង្រៀនកម្រិតបឋមសិក្សា (សម្រាប់តែសាលាបឋមសិក្សា)

- ***សេចក្តីពន្យល់៖*** សំដៅដល់ផលធៀបរវាងចំនួននៃបុគ្គលិកអប់រំដែលមានសញ្ញាបត្រគ្រូបង្រៀនកម្រិតបឋមសិក្សា និងចំនួនបុគ្គលិកអប់រំសរុបក្នុងសាលារៀនក្នុងឆ្នាំសិក្សា។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ស្ថិតិបុគ្គលិកអប់រំ និង២)សញ្ញាបត្រគ្រូបង្រៀនកម្រិតបឋមរបស់បុគ្គលិកអប់រំក្នុងសាលារៀន។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | បុគ្គលិកអប់រំចាប់ពី៩០ភាគរយ មានសញ្ញាបត្រគ្រូបង្រៀនកម្រិតបឋមសិក្សា |
| ពិន្ទុ ៤ | បុគ្គលិកអប់រំចាប់ពី៨០ភាគរយ មានសញ្ញាបត្រគ្រូបង្រៀនកម្រិតបឋមសិក្សា |
| ពិន្ទុ ៣ | បុគ្គលិកអប់រំចាប់ពី៧០ភាគរយ មានសញ្ញាបត្រគ្រូបង្រៀនកម្រិតបឋមសិក្សា |
| ពិន្ទុ ២ | បុគ្គលិកអប់រំចាប់ពី៦០ភាគរយ មានសញ្ញាបត្រគ្រូបង្រៀនកម្រិតបឋមសិក្សា |
| ពិន្ទុ ១ | បុគ្គលិកអប់រំចាប់ពី៥០ភាគរយ មានសញ្ញាបត្រគ្រូបង្រៀនកម្រិតបឋមសិក្សា |
| ពិន្ទុ ០ | បុគ្គលិកអប់រំក្រោម៥០ភាគរយមានសញ្ញាបត្រគ្រូបង្រៀនកម្រិតបឋមសិក្សា |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** លក្ខណៈវិនិច្ឆ័យលម្អិតនេះ ពុំមាននៅតារាងលក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃអនុវិទ្យាល័យនោះទេ។

➢ ភាគរយបុគ្គលិកអប់រំមានសញ្ញាបត្រគ្រូបង្រៀនកម្រិតឧត្តម (សម្រាប់តែអនុវិទ្យាល័យ)

- ***សេចក្តីពន្យល់៖*** សំដៅដល់ផលធៀបរវាងចំនួននៃបុគ្គលិកអប់រំដែលមានសញ្ញាបត្រគ្រូបង្រៀនកម្រិតឧត្តម និងចំនួនបុគ្គលិកអប់រំសរុបក្នុងសាលារៀនក្នុងឆ្នាំសិក្សា។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ស្ថិតិបុគ្គលិកអប់រំ និង២)សញ្ញាបត្រគ្រូបង្រៀនកម្រិតឧត្តមរបស់បុគ្គលិកអប់រំក្នុងសាលារៀន។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | បុគ្គលិកអប់រំចាប់ពី៩០ភាគរយ មានសញ្ញាបត្រគ្រូបង្រៀនកម្រិតឧត្តម |
| ពិន្ទុ ៤ | បុគ្គលិកអប់រំចាប់ពី៨០ភាគរយ មានសញ្ញាបត្រគ្រូបង្រៀនកម្រិតឧត្តម |
| ពិន្ទុ ៣ | បុគ្គលិកអប់រំចាប់ពី៧០ភាគរយ មានសញ្ញាបត្រគ្រូបង្រៀនកម្រិតឧត្តម |
| ពិន្ទុ ២ | បុគ្គលិកអប់រំចាប់ពី៦០ភាគរយ មានសញ្ញាបត្រគ្រូបង្រៀនកម្រិតឧត្តម |
| ពិន្ទុ ១ | បុគ្គលិកអប់រំចាប់ពី៥០ភាគរយ មានសញ្ញាបត្រគ្រូបង្រៀនកម្រិតឧត្តម |
| ពិន្ទុ ០ | បុគ្គលិកអប់រំក្រោម៥០ភាគរយមានសញ្ញាបត្រគ្រូបង្រៀនកម្រិតឧត្តម |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** លក្ខណៈវិនិច្ឆ័យលម្អិតនេះ ពុំមាននៅតារាងលក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃបឋមសិក្សានោះទេ។

## ➢ ភាគរយនៃបុគ្គលិកអប់រំមានការយល់ដឹងគោលនយោបាយអប់រំ/ផែនការយុទ្ធសាស្ត្រវិស័យអប់រំ

- ***សេចក្តីពន្យល់៖*** សំដៅដល់ចំនួននៃបុគ្គលិកអប់រំ ដែលមានការយល់ដឹងអំពីគោលនយោបាយអប់រំនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០២៤-២០២៨ ស្តង់ដាសាលារៀនគំរូ និងកំណែទម្រង់អាទិភាពរបស់ក្រសួងអប់រំ យុវជន និងកីឡាផ្សេងៗទៀត ធៀបនឹងចំនួនបុគ្គលិកអប់រំទាំងអស់នៅក្នុងសាលារៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)មធ្យោបាយផ្សព្វផ្សាយគោលនយោបាយអប់រំដល់បុគ្គលិកអប់រំរបស់សាលារៀន ២)សម្ភាសជាមួយបុគ្គលិកអប់រំ និង៣)ការតម្កល់សៀវភៅផែនការយុទ្ធសាស្ត្រអប់រំ ២០១៩-២០២៣ និងឯកសារស្តីពីកំណែទម្រង់អាទិភាពផ្សេងៗទៀត។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | បុគ្គលិកអប់រំដែលយល់ដឹង និងអាចបកស្រាយពីគោលនយោបាយអប់រំចាប់ពី ៩០ ភាគរយ |
| ពិន្ទុ ៤ | បុគ្គលិកអប់រំដែលយល់ដឹង និងអាចបកស្រាយពីគោលនយោបាយអប់រំចាប់ពី ៨០ ភាគរយ |
| ពិន្ទុ ៣ | បុគ្គលិកអប់រំដែលយល់ដឹង និងអាចបកស្រាយពីគោលនយោបាយអប់រំចាប់ពី ៧០ ភាគរយ |
| ពិន្ទុ ២ | បុគ្គលិកអប់រំដែលយល់ដឹង និងអាចបកស្រាយពីគោលនយោបាយអប់រំចាប់ពី ៦០ ភាគរយ |
| ពិន្ទុ ១ | បុគ្គលិកអប់រំដែលយល់ដឹង និងអាចបកស្រាយពីគោលនយោបាយអប់រំចាប់ពី ៥០ ភាគរយ |
| ពិន្ទុ ០ | បុគ្គលិកអប់រំដែលយល់ដឹង និងអាចបកស្រាយពីគោលនយោបាយអប់រំតិចជាង ៥០ ភាគរយ |

## ➢ ភាគរយនៃការប្រើប្រាស់កម្មវិធីសិក្សាតាមកម្រិតថ្នាក់របស់បុគ្គលិកអប់រំ

- ***សេចក្តីពន្យល់៖*** សំដៅដល់ផលធៀបរវាងចំនួនបុគ្គលិកអប់រំដែលប្រើប្រាស់កម្មវិធីសិក្សានៅតាមមុខវិជ្ជានីមួយៗតាមកម្រិតថ្នាក់ (រៀបចំកិច្ចតែងការបង្រៀន វិធីសាស្ត្របង្រៀន និងវង្វាយតម្លៃដោយផ្អែកលើកម្មវិធីសិក្សា) នឹងចំនួនបុគ្គលិកអប់រំសរុបរបស់សាលាក្នុងឆ្នាំសិក្សា។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ក្របខណ្ឌកម្មវិធីសិក្សា ២)សៀវភៅសិក្សាគោល ៣)កិច្ចតែងការបង្រៀន ៤)បំណែងចែកកាលវិភាគ/កម្មវិធីសិក្សា និង៥)ការសម្ភាសគ្រូបង្រៀនតាមកម្រិតថ្នាក់។

- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖*

| | |
|---|---|
| ពិន្ទុ ៥ | បុគ្គលិកអប់រំចាប់ពី ៩០ភាគរយ បានរៀបចំកិច្ចតែងការបង្រៀន វិធីសាស្ត្របង្រៀន និងវង្វាយតម្លៃដោយផ្អែកលើកម្មវិធីសិក្សា |
| ពិន្ទុ ៤ | បុគ្គលិកអប់រំចាប់ពី ៨០ភាគរយ បានរៀបចំកិច្ចតែងការបង្រៀន វិធីសាស្ត្របង្រៀន និងវង្វាយតម្លៃដោយផ្អែកលើកម្មវិធីសិក្សា |
| ពិន្ទុ ៣ | បុគ្គលិកអប់រំចាប់ពី ៧០ភាគរយ បានរៀបចំកិច្ចតែងការបង្រៀន វិធីសាស្ត្របង្រៀន និងវង្វាយតម្លៃដោយផ្អែកលើកម្មវិធីសិក្សា |
| ពិន្ទុ ២ | បុគ្គលិកអប់រំចាប់ពី ៦០ភាគរយ បានរៀបចំកិច្ចតែងការបង្រៀន វិធីសាស្ត្របង្រៀន និងវង្វាយតម្លៃដោយផ្អែកលើកម្មវិធីសិក្សា |
| ពិន្ទុ ១ | បុគ្គលិកអប់រំចាប់ពី ៥០ភាគរយ បានរៀបចំកិច្ចតែងការបង្រៀន វិធីសាស្ត្របង្រៀន និងវង្វាយតម្លៃដោយផ្អែកលើកម្មវិធីសិក្សា |
| ពិន្ទុ ០ | បុគ្គលិកអប់រំតិចជាង ៥០ភាគរយ បានរៀបចំកិច្ចតែងការបង្រៀន វិធីសាស្ត្របង្រៀន និងវង្វាយតម្លៃដោយផ្អែកលើកម្មវិធីសិក្សា |

➢ ភាគរយគ្រូបង្រៀនបង្រៀនបានត្រឹមត្រូវតាមមុខវិជ្ជាឯកទេស និងតាមកម្រិតថ្នាក់ (សម្រាប់តែអនុវិទ្យាល័យ)

- *សេចក្តីពន្យល់៖* សំដៅដល់ចំនួនគ្រូបង្រៀនបង្រៀនបានត្រឹមត្រូវតាមមុខវិជ្ជាឯកទេស និងតាមកម្រិតថ្នាក់ ធៀបនឹងចំនួនគ្រូបង្រៀនសរុប។
- *ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖* ចំណុចត្រូវពិនិត្យគឺ ១)អង្កេតថ្នាក់រៀន(មុខវិជ្ជាក្នុងម៉ោងបង្រៀន និងឯកទេសបង្រៀនក្នុងម៉ោងបង្រៀន) ២)បំណែងចែកកាលវិភាគគ្រូបង្រៀន និង៣) គុណវុឌ្ឍិគ្រូបង្រៀននៅតាមមុខវិជ្ជាឯកទេសនីមួយៗ។
- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖*

| | |
|---|---|
| ពិន្ទុ ៥ | គ្រូបង្រៀនច្រើនជាង ៩០ភាគរយ បង្រៀនត្រឹមត្រូវតាមមុខវិជ្ជាឯកទេស និងតាមកម្រិតថ្នាក់ |
| ពិន្ទុ ៤ | គ្រូបង្រៀនច្រើនជាង ៨០ភាគរយ បង្រៀនត្រឹមត្រូវតាមមុខវិជ្ជាឯកទេស និងតាមកម្រិតថ្នាក់ |
| ពិន្ទុ ៣ | គ្រូបង្រៀនច្រើនជាង ៧០ភាគរយ បង្រៀនត្រឹមត្រូវតាមមុខវិជ្ជាឯកទេស និងតាមកម្រិតថ្នាក់ |
| ពិន្ទុ ២ | គ្រូបង្រៀនច្រើនជាង ៦០ភាគរយ បង្រៀនត្រឹមត្រូវតាមមុខវិជ្ជាឯកទេស និងតាមកម្រិតថ្នាក់ |

| | |
|---|---|
| ពិន្ទុ ១ | គ្រូបង្រៀនច្រើនជាង ៥០ភាគរយ បង្រៀនត្រឹមត្រូវតាមមុខវិជ្ជាឯកទេស និងតាមកម្រិតថ្នាក់ |
| ពិន្ទុ ០ | គ្រូបង្រៀនតិចជាង ៥០ភាគរយ បង្រៀនត្រឹមត្រូវតាមមុខវិជ្ជាឯកទេស និងតាមកម្រិតថ្នាក់ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** លក្ខណៈវិនិច្ឆ័យលម្អិតនេះ ពុំមាននៅតារាងលក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃបឋមសិក្សានោះទេ។

➢ ***ភាគរយនៃបុគ្គលិកអប់រំមានចំណេះដឹង និងប្រើបច្ចេកវិទ្យាព័ត៌មាន បម្រើឱ្យការស្រាវជ្រាវ ការងាររដ្ឋបាល ការបង្រៀន និងការរៀន***

- ***សេចក្ដីពន្យល់៖*** សំដៅដល់អត្រានៃបុគ្គលិកអប់រំមានចំណេះដឹងក្នុងការប្រើបច្ចេកវិទ្យាព័ត៌មានសម្រាប់ការងាររដ្ឋបាល និងការងារបច្ចេកទេស (ការបង្រៀននិងរៀន) ធៀបនឹងចំនួនបុគ្គលិកអប់រំសរុបរបស់សាលារៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ឯកសាររដ្ឋបាលថ្នាក់រៀន (បំណែងចែកកម្មវិធីសិក្សា កម្មវិធីសិក្សា និងកិច្ចតែងការ...) ២)លិខិតរដ្ឋបាលសម្រាប់ការដឹកនាំ និងគ្រប់គ្រងសាលារៀន និង៣)ការសម្ភាសជាមួយបុគ្គលិកអប់រំអំពីការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានបម្រើឱ្យការងាររដ្ឋបាល ការបង្រៀននិងរៀន។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | បុគ្គលិកអប់រំចាប់ពី ៨០ភាគរយ ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសម្រាប់បម្រើការក្នុងការងាររដ្ឋបាល និងការងារបច្ចេកទេស |
| ពិន្ទុ ៤ | បុគ្គលិកអប់រំចាប់ពី ៧០ភាគរយ ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសម្រាប់បម្រើការក្នុងការងាររដ្ឋបាល និងការងារបច្ចេកទេស |
| ពិន្ទុ ៣ | បុគ្គលិកអប់រំចាប់ពី ៦០ភាគរយ ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសម្រាប់បម្រើការក្នុងការងាររដ្ឋបាល និងការងារបច្ចេកទេស |
| ពិន្ទុ ២ | បុគ្គលិកអប់រំចាប់ពី ៤០ភាគរយ ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសម្រាប់បម្រើការក្នុងការងាររដ្ឋបាល និងការងារបច្ចេកទេស |
| ពិន្ទុ ១ | បុគ្គលិកអប់រំចាប់ពី ២០ភាគរយ ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសម្រាប់បម្រើការក្នុងការងាររដ្ឋបាល និងការងារបច្ចេកទេស |
| ពិន្ទុ ០ | បុគ្គលិកអប់រំតិចជាង ២០ភាគរយ ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសម្រាប់បម្រើការក្នុងការងាររដ្ឋបាល និងការងារបច្ចេកទេស |

## ➢ ភាគរយនៃបុគ្គលិកអប់រំចេះភាសាបរទេស

- ***សេចក្តីពន្យល់៖*** សំដៅដល់ចំនួនបុគ្គលិកអប់រំចេះភាសាបរទេសក្នុងការទំនាក់ទំនង និងការសិក្សាស្រាវជ្រាវដែលបម្រើដល់ការអភិវឌ្ឍសាលារៀន និងការបង្រៀននិងរៀន (ភាសាអង់គ្លេស បារាំង ឬភាសាបរទេសណាមួយ) ធៀបនឹងចំនួនបុគ្គលិកអប់រំសរុប។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)សម្ភាសជាមួយបុគ្គលិកអប់រំ ២)អត្ថបទស្រាវជ្រាវ និងកិច្ចតែងការបង្រៀន ៣)គុណវុឌ្ឍិ(សញ្ញាបត្រ ឬវិញ្ញាបនបត្រ)របស់បុគ្គលិកអប់រំ និង ៤)ស្ថិតិបុគ្គលិកអប់រំ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | បុគ្គលិកអប់រំចាប់ពី ៥០ភាគរយ ចេះភាសាបរទេសសម្រាប់បម្រើការក្នុងការងាររដ្ឋបាលសិក្សា ស្រាវជ្រាវ និងទំនាក់ទំនង |
| ពិន្ទុ ៤ | បុគ្គលិកអប់រំចាប់ពី ៤០ភាគរយ ចេះភាសាបរទេសសម្រាប់បម្រើការក្នុងការងាររដ្ឋបាលសិក្សា ស្រាវជ្រាវ និងទំនាក់ទំនង |
| ពិន្ទុ ៣ | បុគ្គលិកអប់រំចាប់ពី ៣០ភាគរយ ចេះភាសាបរទេសសម្រាប់បម្រើការក្នុងការងាររដ្ឋបាលសិក្សា ស្រាវជ្រាវ និងទំនាក់ទំនង |
| ពិន្ទុ ២ | បុគ្គលិកអប់រំចាប់ពី ២០ភាគរយ ចេះភាសាបរទេសសម្រាប់បម្រើការក្នុងការងាររដ្ឋបាលសិក្សា ស្រាវជ្រាវ និងទំនាក់ទំនង |
| ពិន្ទុ ១ | បុគ្គលិកអប់រំចាប់ពី ១០ភាគរយ ចេះភាសាបរទេសសម្រាប់បម្រើការក្នុងការងាររដ្ឋបាលសិក្សា ស្រាវជ្រាវ និងទំនាក់ទំនង |
| ពិន្ទុ ០ | បុគ្គលិកអប់រំតិចជាង ១០ភាគរយ ចេះភាសាបរទេសសម្រាប់បម្រើការក្នុងការងាររដ្ឋបាលសិក្សា ស្រាវជ្រាវ និងទំនាក់ទំនង |

## ➢ ភាគរយនៃបុគ្គលិកអប់រំមានបទពិសោធការងារចាប់ពី៥ឆ្នាំឡើងទៅ

- ***សេចក្តីពន្យល់៖*** សំដៅដល់ចំនួនបុគ្គលិកអប់រំដែលមានអតីតភាពការងារនៅក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា ចាប់ពីប្រាំឆ្នាំឡើងទៅ ធៀបនឹងចំនួនបុគ្គលិកអប់រំសរុប។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)សំណុំឯកសារគ្រប់គ្រងបុគ្គលិក និង ២)ប្រវត្តិរូបសង្ខេបរបស់បុគ្គលិកអប់រំ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | បុគ្គលិកអប់រំចាប់ពី ៨០ភាគរយ មានបទពិសោធការងារចាប់ពី៥ឆ្នាំឡើង |
| ពិន្ទុ ៤ | បុគ្គលិកអប់រំចាប់ពី ៧០ភាគរយ មានបទពិសោធការងារចាប់ពី៥ឆ្នាំឡើង |
| ពិន្ទុ ៣ | បុគ្គលិកអប់រំចាប់ពី ៦០ភាគរយ មានបទពិសោធការងារចាប់ពី៥ឆ្នាំឡើង |

| | |
|---|---|
| ពិន្ទុ ២ | បុគ្គលិកអប់រំចាប់ពី ៥០ភាគរយ មានបទពិសោធការងារចាប់ពី៥ឆ្នាំឡើង |
| ពិន្ទុ ១ | បុគ្គលិកអប់រំចាប់ពី ៤០ភាគរយ មានបទពិសោធការងារចាប់ពី៥ឆ្នាំឡើង |
| ពិន្ទុ ០ | បុគ្គលិកអប់រំតិចជាង ៤០ភាគរយ មានបទពិសោធការងារចាប់ពី៥ឆ្នាំឡើង |

➢ <u>ភាគរយនៃបុគ្គលិកអប់រំដែលប្រើប្រាស់ទិន្នន័យជាមូលដ្ឋានក្នុងការអនុវត្តការងារ</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ចំនួនបុគ្គលិកអប់រំដែលបានប្រើប្រាស់ទិន្នន័យជាមូលដ្ឋានសម្រាប់ការបំពេញការងារធៀបនឹងចំនួនបុគ្គលិកអប់រំសរុបក្នុងសាលារៀន។ ដំណើរការនៃការរៀបចំនិងប្រើប្រាស់ទិន្នន័យជាមូលដ្ឋានក្នុងការសម្រេចចិត្ត គឺប្រមូល រៀបចំ បង្ហាញ វិភាគ សន្និដ្ឋាន និងសម្រេចចិត្ត។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ឯកសារពាក់ព័ន្ធការងាររដ្ឋបាល និងការបង្រៀន(ផែនការប្រតិបត្តិប្រចាំឆ្នាំ ផែនការអភិវឌ្ឍនិងកែលម្អសាលារៀន ផែនការបង្រៀន បំណែងចែកភារកិច្ចគ្រូបង្រៀន កិច្ចតែងការបង្រៀន...) និង២)ការសម្ភាសជាមួយបុគ្គលិកអប់រំអំពីចំណេះដឹងពាក់ព័ន្ធការប្រមូល និងប្រើប្រាស់ទិន្នន័យ(ប្រមូល រៀបចំ បង្ហាញ វិភាគ សន្និដ្ឋាន និងសម្រេចចិត្ត)។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | បុគ្គលិកអប់រំចាប់ពី ៦០ភាគរយ បានប្រើប្រាស់ទិន្នន័យជាមូលដ្ឋានសម្រាប់ការបំពេញការងារ |
| ពិន្ទុ ៤ | បុគ្គលិកអប់រំចាប់ពី ៥០ភាគរយ បានប្រើប្រាស់ទិន្នន័យជាមូលដ្ឋានសម្រាប់ការបំពេញការងារ |
| ពិន្ទុ ៣ | បុគ្គលិកអប់រំចាប់ពី ៤០ភាគរយ បានប្រើប្រាស់ទិន្នន័យជាមូលដ្ឋានសម្រាប់ការបំពេញការងារ |
| ពិន្ទុ ២ | បុគ្គលិកអប់រំចាប់ពី ៣០ភាគរយ បានប្រើប្រាស់ទិន្នន័យជាមូលដ្ឋានសម្រាប់ការបំពេញការងារ |
| ពិន្ទុ ១ | បុគ្គលិកអប់រំចាប់ពី ២០ភាគរយ បានប្រើប្រាស់ទិន្នន័យជាមូលដ្ឋានសម្រាប់ការបំពេញការងារ |
| ពិន្ទុ ០ | បុគ្គលិកអប់រំតិចជាង ២០ភាគរយ បានប្រើប្រាស់ទិន្នន័យជាមូលដ្ឋានសម្រាប់ការបំពេញការងារ |

➢ <u>ភាគរយបុគ្គលិកអប់រំដែលបានធ្វើទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធការងារ</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ចំនួនបុគ្គលិកអប់រំដែលបានធ្វើទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធការងារជាមួយគ្រឹះស្ថានសិក្សាដទៃទៀត ធៀបនឹងចំនួនបុគ្គលិកអប់រំសរុបរបស់សាលារៀន។

- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ផែនការទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធការងាររបស់សាលារៀន ២)លិខិតឧទ្ទេសនាម ឬលិខិតបញ្ជាបេសកកម្មស្តីពីទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធការងារ ៣)របាយការណ៍លទ្ធផលទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធការងារ និង៤)ការសម្ភាសជាមួយអ្នកពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | សាលារៀនមានបុគ្គលិកអប់រំចាប់ពី ១០ភាគរយ បានទៅធ្វើទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធការងារក្នុងរយៈពេល ១ឆ្នាំចុងក្រោយ |
| ពិន្ទុ ៤ | សាលារៀនមានបុគ្គលិកអប់រំចាប់ពី ៨ភាគរយ បានទៅធ្វើទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធការងារក្នុងរយៈពេល ១ឆ្នាំចុងក្រោយ |
| ពិន្ទុ ៣ | សាលារៀនមានបុគ្គលិកអប់រំចាប់ពី ៦ភាគរយ បានទៅធ្វើទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធការងារក្នុងរយៈពេល ១ឆ្នាំចុងក្រោយ |
| ពិន្ទុ ២ | សាលារៀនមានបុគ្គលិកអប់រំចាប់ពី ៤ភាគរយ បានទៅធ្វើទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធការងារក្នុងរយៈពេល ១ឆ្នាំចុងក្រោយ |
| ពិន្ទុ ១ | សាលារៀនមានបុគ្គលិកអប់រំចាប់ពី ២ភាគរយ បានទៅធ្វើទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធការងារក្នុងរយៈពេល ១ឆ្នាំចុងក្រោយ |
| ពិន្ទុ ០ | សាលារៀនមានបុគ្គលិកអប់រំតិចជាង ២ភាគរយ បានទៅធ្វើទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធការងារក្នុងរយៈពេល ១ឆ្នាំចុងក្រោយ |

### ២.៣.២ ភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់គ្រូបង្រៀន (៣៥ពិន្ទុ)

➢ <u>គ្រូបង្រៀនវិនិច្ឆ័យលទ្ធផលការសិក្សារបស់សិស្សបានត្រឹមត្រូវ និងតម្លាភាព</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់គ្រូបង្រៀនបានវិនិច្ឆ័យការសិក្សា និងវាយតម្លៃលទ្ធផលការសិក្សារបស់សិស្សបានត្រឹមត្រូវ និងតម្លាភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)បញ្ជីស្រង់ពិន្ទុ ២)ប្រធានវិញ្ញាសា និងសន្លឹកកិច្ចការរបស់សិស្ស ៣)បញ្ជីវត្តមានពេលប្រឡង និង៤)ការសម្ភាសជាមួយអ្នកពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥(គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានការប្រកាសលទ្ធផលនៃការប្រឡងជាសាធារណៈ |
| ពិន្ទុ ១ | ការធ្វើអត្រាកំណែនិងកែរួម |
| ពិន្ទុ ១ | ការប្រឡងមានការចូលរួមពីអ្នកពាក់ព័ន្ធ |
| ពិន្ទុ ១ | ការរៀបចំប្រធានវិញ្ញាសាត្រឹមត្រូវតាមតេស្តស្តង់ដា (ស្របតាមកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល) |
| ពិន្ទុ ១ | ការប្រឡងធ្វើតាមប្រតិទិនរបស់ក្រសួងអប់រំ យុវជន និងកីឡា និង/ឬ តាមកាលវិភាគរបស់សាលារៀន |
| ពិន្ទុ ០ | មិនមានគ្រប់ចំណុចខាងលើ |

## ➢ មានផែនការបង្រៀននិងរៀន និងសៀវភៅរដ្ឋបាលថ្នាក់រៀន

- ***សេចក្តីពន្យល់៖*** សំដៅដល់គ្រូបង្រៀនបានរៀបចំផែនការបង្រៀន និងរៀន សៀវភៅ និងបញ្ជីគ្រប់គ្រងរដ្ឋបាលថ្នាក់រៀននៅតាមថ្នាក់រៀននីមួយៗរួមមាន៖ បំណែងចែកកម្មវិធីសិក្សាប្រចាំឆ្នាំ កិច្ចតែងការបង្រៀន បញ្ជីហៅឈ្មោះសិស្ស បញ្ជីពិន្ទុ បញ្ជីសារពើភ័ណ្ឌថ្នាក់រៀន វេនសម្អាតថ្នាក់រៀន សៀវភៅតាមដានការសិក្សា សៀវភៅទំនាក់ទំនងជាមួយមាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស សៀវភៅចូលមើលការបង្រៀន សៀវភៅប្រជុំបច្ចេកទេសនិងប្រជុំការងារ និងសៀវភៅទទួលនិងបែងចែកសម្ភារៈ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ សៀវភៅរដ្ឋបាលថ្នាក់រៀនតាមថ្នាក់រៀននីមួយៗទាំង១០ខាងលើ និងសម្ភាសជាមួយអ្នកពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥(គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | សៀវភៅទំនាក់ទំនងជាមួយមាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស |
| ពិន្ទុ ១ | បញ្ជីសារពើភ័ណ្ឌថ្នាក់រៀន និងវេនសម្អាតថ្នាក់រៀន |
| ពិន្ទុ ១ | បញ្ជីសារពើភ័ណ្ឌថ្នាក់រៀន និងសៀវភៅទទួល និងបែងចែកសម្ភារៈ |
| ពិន្ទុ ១ | មានបញ្ជីហៅឈ្មោះសិស្ស និងពិន្ទុ |
| ពិន្ទុ ១ | មានបំណែងចែកកម្មវិធីសិក្សា កិច្ចតែងការបង្រៀន និងសៀវភៅប្រជុំបច្ចេកទេស |
| ពិន្ទុ ០ | គ្មានចំណុចទាំងអស់ខាងលើ |

## ➢ មានការតាមដាន និងវាយតម្លៃការសិក្សារបស់សិស្សជាប្រចាំ

- ***សេចក្តីពន្យល់៖*** សំដៅដល់គ្រូបង្រៀនបានរៀបចំ និងវាយតម្លៃការសិក្សារបស់សិស្សជាប្រចាំ និងបានប្រើប្រាស់លទ្ធផលនៃការវាយតម្លៃការសិក្សាដើម្បីពង្រឹងគុណភាពការបង្រៀននិងរៀន ជួយដល់សិស្សរៀនលឿន និងបំប៉នសិស្សរៀនយឺត។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)តេស្តវាយតម្លៃការសិក្សាសិស្សដើមឆ្នាំសិក្សា ២)បញ្ជីស្រង់ពិន្ទុសិស្សប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំ ៣)កម្មវិធីជួយសិស្សរៀនលឿន និងបំប៉នសិស្សរៀនយឺត ៤)របាយការណ៍បូកសរុបលទ្ធផលសិក្សារបស់សិស្សប្រចាំខែ និងប្រចាំឆមាស និង៥)សម្ភាសជាមួយអ្នកពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥(គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានការរៀបចំនិងអនុវត្តកម្មវិធីពិសេសសម្រាប់សិស្សរៀនលឿន |
| ពិន្ទុ ១ | មានរបាយការណ៍វាយតម្លៃការសិក្សារបស់សិស្សប្រចាំខែ និងឆមាស |

| | |
|---|---|
| ពិន្ទុ ១ | មានការវាយតម្លៃការសិក្សារបស់សិស្សជាទៀងទាត់ |
| ពិន្ទុ ១ | មានរៀបចំនិងអនុវត្តកម្មវិធីបំប៉នសិស្សរៀនយឺត |
| ពិន្ទុ ១ | មានការវាយតម្លៃវាស់ស្ទង់សមត្ថភាពសិស្សនៅដើមឆ្នាំសិក្សា |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- គ្រប់គ្រងថ្នាក់រៀន (គ្រប់គ្រងសកម្មភាពបង្រៀន និងរៀននៅតាមថ្នាក់រៀន)

- ***សេចក្តីពន្យល់៖*** សំដៅដល់គ្រូបង្រៀនបានគ្រប់គ្រងពេលវេលាបង្រៀន ជំហាននៃការបង្រៀន ការជ្រើសរើសនិងប្រើប្រាស់វិធីសាស្ត្របង្រៀន និងគ្រប់គ្រងសកម្មភាពរបស់សិស្សនៅក្នុងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)អង្កេតដំណើរការបង្រៀនរបស់គ្រូបង្រៀន ២)កិច្ចតែងការបង្រៀន
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥(គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | គ្រប់គ្រងសកម្មភាពរបស់សិស្សក្នុងដំណើរការបង្រៀនបានល្អ |
| ពិន្ទុ ១ | ផ្តល់ឱកាស និងលើកទឹកចិត្តដល់សិស្សស្មើៗគ្នា |
| ពិន្ទុ ១ | ការបង្រៀនស្របតាមជំហាននៅក្នុងកិច្ចតែងការបង្រៀន |
| ពិន្ទុ ១ | គ្រប់គ្រងវេលាបង្រៀនបានល្អ |
| ពិន្ទុ ១ | បង្រៀនដោយមានកិច្ចតែងការបង្រៀន |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- បង្កើត និងជំរុញសកម្មភាពក្លឹបសិក្សា ឬសកម្មភាពក្រៅម៉ោងសិក្សា

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀន ឬគ្រូបង្រៀនបានបង្កើតក្លឹបសិក្សានៅតាមមុខវិជ្ជានីមួយៗ ក្នុងគោលបំណងឱ្យសិស្សបានសិក្សារៀនសូត្រពីគ្នាទៅវិញទៅមក ការធ្វើការជាក្រុម ដើម្បីជួយបំពេញបន្ថែម និងពង្រីកចំណេះដឹងបន្ថែមនៅក្នុងចំណោមសិស្សានុសិស្សនៅក្រៅម៉ោងសិក្សាដែលបានកំណត់ដោយរដ្ឋ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ឯកសារបង្កើតក្លឹបសិក្សា ២)បញ្ជីសមាសភាពគណៈកម្មការតាមក្លឹបសិក្សា ៣)កាលវិភាគរៀនរបស់ក្លឹបសិក្សា ៤)របាយការណ៍វឌ្ឍនភាពនៃក្លឹបសិក្សា និង៥)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ ។

- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥(គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ៣ | ក្លឹបសិក្សាមានរៀបចំផែនការ និងដំណើរការបានច្បាស់លាស់ |
| ពិន្ទុ ១ | មានការបង្កើតក្លឹបសិក្សាគ្រប់កម្រិតថ្នាក់ |
| ពិន្ទុ ១ | មានការបង្កើតក្លឹបសិក្សានៅតាមថ្នាក់រៀន |
| ពិន្ទុ ០ | មិនមានការបង្កើតក្លឹបសិក្សា |

- *ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖* ចំពោះមុខវិជ្ជាវិទ្យាសាស្ត្រ សាលានឹងបានពិន្ទុ១ នៅពេលដែលបានដំណើរការក្លឹបសិក្សាលើមុខវិជ្ជាណាមួយក្នុងចំណោមមុខវិជ្ជាវិទ្យាសាស្ត្រទាំងប្រាំខាងលើ។

## ➢ បណ្តុះស្មារតីគ្រូនិងសិស្សឱ្យសិក្សាពេញមួយជីវិត

- *សេចក្តីពន្យល់៖* សំដៅដល់គ្រូបង្រៀនបានបង្កើត ឬការបណ្តុះនូវវប្បធម៌នៃការអាន ការសរសេរ ការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់ខ្លួន និងដល់សិស្ស។
- *ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖* ចំណុចត្រូវពិនិត្យគឺ ១)កាលវិភាគសិក្សានៅបណ្ណាល័យ ២)កិច្ចការ ឬលំហាត់សម្រាប់កុមារស្រាវជ្រាវ ៣)សៀវភៅពុម្ព ៤)ការចងក្រងស្នាដៃរបស់គ្រូ និងរបស់សិស្ស ៥)កុំព្យូទ័រ និងអ៊ីនធឺណែត និង៦)ផែនការការអភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកអប់រំ។
- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖*

| | |
|---|---|
| ពិន្ទុ ១ | មានរៀបចំកម្មវិធីទិវាជាតិអំណាននៅក្នុងសាលារៀន |
| ពិន្ទុ ១ | មានការតាំងពិព័រណ៍ស្នាដៃរបស់គ្រូបង្រៀននិងសិស្សយ៉ាងតិចមួយដងក្នុងមួយឆ្នាំ |
| ពិន្ទុ ១ | មានការចងក្រងស្នាដៃគ្រូបង្រៀន និងសិស្ស |
| ពិន្ទុ ១ | មានកម្មវិធីលើកទឹកចិត្តចំពោះការចងក្រងស្នាដៃរបស់គ្រូបង្រៀន និងសិស្ស |
| ពិន្ទុ ១ | មានកិច្ចការ ឬលំហាត់សម្រាប់ឱ្យសិស្សស្រាវជ្រាវនៅបណ្ណាល័យ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## ➢ មានទំនាក់ទំនងល្អ ផ្តល់ និងទទួលព័ត៌មានត្រឡប់ពីការសិក្សារបស់សិស្សម្នាក់ៗនៅក្នុងថ្នាក់រៀនដល់គណៈគ្រប់គ្រងសាលារៀន មាតាបិតា និងអ្នកពាក់ព័ន្ធ

- *សេចក្តីពន្យល់៖* សំដៅដល់គ្រូបង្រៀនឈរថ្នាក់បានធ្វើទំនាក់ទំនង និងទទួលព័ត៌មានត្រឡប់ពីមាតាបិតា អ្នកអាណាព្យាបាលពីការសិក្សា និងលទ្ធផលនៃការសិក្សារបស់សិស្ស និងបានជូនដំណឹងជាទៀងទាត់ពីលទ្ធផលនៃសិក្សារបស់សិស្សដល់គណៈគ្រប់គ្រងសាលារៀន។
- *ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖* ចំណុចត្រូវពិនិត្យគឺ ១)មានបញ្ជីលេខទូរសព្ទ ឬអាសយដ្ឋាន

ទំនាក់ទំនងមាតាបិតា អ្នកអាណាព្យាបាលសិស្ស ២)ក្រុមតេឡេក្រាមថ្នាក់រៀន ៣)កម្មវិធីជួបជុំមាតាបិតា អ្នកអាណាព្យាបាលតាមថ្នាក់រៀន ៤)សម្ភាសន៍ជាមួយមាតាបិតា អ្នកអាណាព្យាបាលសិស្ស និងគណៈគ្រប់គ្រងសាលារៀន។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ៣ | មានកម្មវិធីជួបប្រជុំ និងពិភាក្សាជាមួយមាតាបិតា អ្នកអាណាព្យាបាលសិស្សពីលទ្ធផលនៃការសិក្សារបស់សិស្សដោយផ្ទាល់ |
| ពិន្ទុ ១ | មានការកំណត់អត្តសញ្ញាណសិស្សរៀនយឺត និងងាយរងគ្រោះនៅក្នុងថ្នាក់រៀន និងជូនដំណឹងទៅគណៈគ្រប់គ្រងសាលារៀន |
| ពិន្ទុ ១ | មានបញ្ជីលេខទូរសព្ទ ឬមានបង្កើតក្រុមតេឡេក្រាមថ្នាក់រៀន ឬអាសយដ្ឋានទំនាក់ទំនងជាមួយមាតាបិតា អ្នកអាណាព្យាបាលសិស្ស |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

# ផ្នែកទី៣៖ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងអង្គភាព

## ៣. ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងអង្គភាព (១២៥ពិន្ទុ)

ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងអង្គភាពសំដៅការគ្រប់គ្រងហិរញ្ញវត្ថុ និងធនធានក្នុងសាលារៀនដែលបម្រើដល់ការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់អភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិប្រកបដោយសមធម៌ និងបរិយាបន្ន។ ការគ្រប់គ្រងហិរញ្ញវត្ថុនៅក្នុងសាលារៀនសំដៅលើការរៀបចំផែនការថវិកា ការអនុវត្តថវិកា ការត្រួតពិនិត្យ និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនិងសមិទ្ធកម្មបានត្រឹមត្រូវ និងទាន់ពេលវេលា។

លក្ខណៈវិនិច្ឆ័យសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុក្នុងសាលារៀនសាធារណៈ មានអត្ថប្រយោជន៍ដើម្បីពិនិត្យលើការពង្រឹងប្រព័ន្ធគណនេយ្យភាពនៃការគ្រប់គ្រងថវិកា និងធនធាន ក្នុងន័យធានាបាន តម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងការឆ្លើយតបនឹងសមិទ្ធផលសិក្សារបស់សិស្សដែលទទួលបាននូវគុណភាពអប់រំ ប្រកបដោយសមធម៌ និងបរិយាបន្ន។ ការអនុវត្តបានល្អនូវលក្ខណៈវិនិច្ឆ័យនេះនឹងជួយដល់សាលារៀនដូចជា (ទី១)បង្កើនស្វ័យភាពក្នុងការគ្រប់គ្រងសាលារៀនសាធារណៈ (ទី២)ពង្រឹងគណនេយ្យភាពលើការគ្រប់គ្រងថវិកា (ទី៣)អនុវត្តតាមប្រព័ន្ធគ្រប់គ្រងតាមសាលារៀនសាធារណៈ និងប្រើប្រាស់ថវិកាស្របតាមគោលការណ៍សួលអភិបាលកិច្ចល្អ និង(ទី៤)ធានាបានភាពឆ្លើយតបទៅនឹងសមិទ្ធផលសិក្សារបស់សិស្ស។

នៅក្នុងផ្នែកនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងអង្គភាព មានពិន្ទុសរុបចំនួន ១២៥ពិន្ទុ ដែលមានលក្ខណៈវិនិច្ឆ័យរងចំនួន៣ គឺ៖

**១. ភាពជឿទុកចិត្តនៃថវិកា និងការពង្រឹងស្វ័យភាពហិរញ្ញវត្ថុ** (៦០ពិន្ទុ)

**២. ប្រព័ន្ធគ្រប់គ្រងគណនេយ្យ និងទ្រព្យសម្បត្តិរដ្ឋ** (៤០ពិន្ទុ)

**៣. ការតាមដាន និងការត្រួតពិនិត្យ** (២៥ពិន្ទុ)

## ៣.១ ភាពជឿទុកចិត្តនៃថវិកា និងការពង្រឹងស្វ័យភាពហិរញ្ញវត្ថុ (៦០ពិន្ទុ)

### ៣.១.១ ការរៀបចំផែនការថវិកា (១០ពិន្ទុ)

- ***សេចក្តីពន្យល់៖*** សំដៅដល់ការរៀបចំថវិកាមូលនិធិដំណើរការសាលារៀនសាធារណៈឱ្យបានល្អប្រសើរ ដែលត្រូវរៀបចំផែនការថវិកា[១] តាមរូបមន្តនៃការរៀបចំថវិកា ដូចជា ថវិការដ្ឋ ថវិកាដៃគូ ថវិកាសហគមន៍ និងថវិកាផ្សេងៗ រួមមាន ផែនការយុទ្ធសាស្ត្រថវិកា(៣ឆ្នាំ) ផែនការថវិកាប្រចាំឆ្នាំ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន និងផែនការប្រតិបត្តិប្រចាំឆ្នាំ ដោយផ្អែកតាមការវិភាគស្ថានភាពបច្ចុប្បន្ន ការកំណត់ទិន្នន័យសូចនាករសំខាន់ៗជាមូលដ្ឋាន ការកំណត់យុទ្ធសាស្ត្រជាអាទិភាពដើម្បីអភិវឌ្ឍន៍ និងការព្យាករសកម្មភាពរួមជាមួយសមិទ្ធផលជាក់ស្តែង។ ការរៀបចំផែនការថវិកា ត្រូវមានការចូលរួមពីភាគីពាក់ព័ន្ធ និងផ្អែកលើសមាសធាតុដូចខាងក្រោម៖
  - កំណត់សមាសភាពចូលរួមឱ្យបានច្បាស់លាស់ និងគ្រប់ភាគីពាក់ព័ន្ធ
  - វិភាគស្ថានភាពអប់រំជាក់ស្តែងនៅសាលារៀន
  - កំណត់គម្រោង និងសកម្មភាពជាអាទិភាពទៅតាមប្រភពថវិកា
  - កំណត់សូចនាករសមិទ្ធកម្ម និងគោលដៅដែលមានប្រយោជន៍ដល់សាលារៀនសាធារណៈ
  - សូចនាករសមិទ្ធកម្ម និងសូចនាករអនុវត្តន៍ តាមគោលការណ៍"SMART" ដោយកំណត់ជា៖
    - *(ទី១) ឱ្យបានច្បាស់លាស់*
    - *(ទី២) អាចវាស់វែងបាន*
    - *(ទី៣) អាចសម្រេចទៅបានតាមប្រភពថវិកា*
    - *(ទី៤) មានភាពប្រាកដនិយមព្រមទាំងជាកម្មវត្ថុដែលអាចត្រួតពិនិត្យ និងវាយតម្លៃបាន*
    - *(ទី៥) អាចសម្រេចបានក្នុងរយៈពេលកំណត់*
  - តម្រូវការថវិកាសរុបប្រចាំឆ្នាំ ត្រូវស្ថិតក្នុងពិតានថវិកាដែលបានបែងចែកស្របតាមឆ្នាំនីមួយៗរបស់សាលារៀន
  - ក្របខ័ណ្ឌរៀបចំផែនការ ដូចជា
    - ១.ធនធាន
    - ២.សកម្មភាព
    - ៣. លទ្ធផល
    - ៤.ផលសម្រេច និងផលប៉ះពាល់។
- ***បញ្ជីឯកសារភស្តុតាង៖***
  1. លិខិតបង្គាប់ការ / សេចក្តីសម្រេច ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ(គ.ម.ស.)
  2. ផែនការយុទ្ធសាស្ត្រថវិកា(៣ឆ្នាំ) ផែនការថវិកាប្រចាំឆ្នាំ ផែនការអភិវឌ្ឍសាលារៀន ឬផែនការកសាងសាលារៀន
  3. របាយការណ៍នៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា(៣ឆ្នាំ) និងផែនការថវិកាប្រចាំឆ្នាំ
  4. លិខិតបញ្ជូនផែនការយុទ្ធសាស្ត្រថវិកា(៣ឆ្នាំ) និងផែនការថវិកាប្រចាំឆ្នាំ។

---

[១] គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ, ជំពូកទី២, ចំណុច ៤, ៤.១ រូបមន្តនៃការរៀបចំថវិកា, ទំព័រទី៥

➢ ផែនការយុទ្ធសាស្ត្រថវិកា(៣ឆ្នាំ) រំកិល (Y+1, Y+2, Y+3)

- ***សេចក្ដីពន្យល់៖*** សំដៅដល់ផែនការថវិការយៈពេលមធ្យម (៣ឆ្នាំ) ដែលអាចពិនិត្យឡើងវិញនូវពាក់កណ្ដាលអាណត្តិ ហើយត្រូវចាប់ផ្ដើមរៀបចំនៅសប្ដាហ៍ទី១ ខែមីនានៃឆ្នាំ និងត្រូវផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ យ៉ាងយូរត្រឹមដំណាច់ខែមីនានៃឆ្នាំ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)លិខិតបង្គាប់ការ/សេចក្ដីសម្រេចស្ដីពីការបង្កើតគណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ(គ.ម.ស.) ២)ផែនការយុទ្ធសាស្ត្រថវិកា(៣ឆ្នាំ) ៣)របាយការណ៍លើការរៀបចំផែនការយុទ្ធសាស្ត្រថវិកា(៣ឆ្នាំ) និង៤) លិខិតបញ្ជូនផែនការយុទ្ធសាស្ត្រថវិកា(៣ឆ្នាំ)។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | ផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌយ៉ាងយូរត្រឹមដំណាច់ខែមីនានៃឆ្នាំ និងផ្សព្វផ្សាយដល់គ្រប់ភាគីពាក់ព័ន្ធតាមប្រព័ន្ធផ្សព្វផ្សាយ (ប្រព័ន្ធទំនាក់ទំនងសង្គម ឯកសារ កិច្ចប្រជុំ ឬការបិទផ្សាយតាមក្ដារខៀននូវតារាងសង្ខេប) យ៉ាងយូររយៈពេល ១ខែ បញ្ចប់ការរៀបចំជាស្ថាពរ |
| ពិន្ទុ ៤ | ផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ មុនថ្ងៃទី១៥ ខែមេសានៃឆ្នាំ |
| ពិន្ទុ ៣ | ផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ មុនថ្ងៃទី៣១ ខែមេសានៃឆ្នាំ |
| ពិន្ទុ ២ | ផែនការយុទ្ធសាស្ត្រថវិកា(៣ឆ្នាំ) អនុម័តដោយគណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ (គ.ម.ស.) |
| ពិន្ទុ ១ | សេចក្ដីព្រាងបឋមផែនការយុទ្ធសាស្ត្រថវិកា(៣ឆ្នាំ) |
| ពិន្ទុ ០ | ពុំបានរៀបចំផែនការយុទ្ធសាស្ត្រថវិកា(៣ឆ្នាំ) |

➢ ផែនការថវិកាប្រចាំឆ្នាំ (Y+1)

- ***សេចក្ដីពន្យល់៖*** សំដៅដល់ផែនការថវិការយៈពេល១ឆ្នាំ ដែលត្រូវចាប់ផ្ដើមរៀបចំនៅសប្ដាហ៍ទី១ ខែឧសភានៃឆ្នាំ និងត្រូវផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ យ៉ាងយូរត្រឹមដំណាច់ខែឧសភានៃឆ្នាំ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)លិខិតបង្គាប់ការ/សេចក្ដីសម្រេចស្ដីពីការបង្កើតគណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ(គ.ម.ស.) ២)ផែនការថវិកាប្រចាំឆ្នាំ ឬផែនការប្រតិបត្តិ ៣)របាយការណ៍លើការរៀបចំផែនការថវិកាប្រចាំឆ្នាំ និង៤) លិខិតបញ្ជូនផែនការថវិកាប្រចាំឆ្នាំ។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | ផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ យ៉ាងយូរត្រឹមដំណាច់ខែឧសភានៃឆ្នាំ និងផ្សព្វផ្សាយដល់គ្រប់ភាគីពាក់ព័ន្ធតាមប្រព័ន្ធផ្សព្វផ្សាយ (ប្រព័ន្ធទំនាក់ទំនងសង្គម ឯកសារ កិច្ចប្រជុំ ឬការបិទផ្សាយតាមក្តារខៀននូវតារាងសង្ខេប) យ៉ាងយូររយៈពេល ១ខែ បញ្ចប់ការរៀបចំជាស្ថាពរ |
| ពិន្ទុ ៤ | ផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ យ៉ាងយូរត្រឹមដំណាច់ខែឧសភានៃឆ្នាំ |
| ពិន្ទុ ៣ | ផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្រោយថ្ងៃទី៣១ ខែឧសភានៃឆ្នាំ |
| ពិន្ទុ ២ | មានសេចក្តីព្រាងចុងក្រោយផែនការថវិកាប្រចាំឆ្នាំ |
| ពិន្ទុ ១ | សេចក្តីព្រាងបឋមផែនការថវិកាប្រចាំឆ្នាំ |
| ពិន្ទុ ០ | ពុំបានរៀបចំផែនការថវិកាប្រចាំឆ្នាំ |

### ៣.១.២ ការអនុវត្តថវិកា (១៥ពិន្ទុ)

- ***សេចក្តីពន្យល់៖*** សំដៅដល់ការអនុវត្តថវិកាធៀបនឹងផែនការថវិកាប្រចាំឆ្នាំ ដោយធានាបានតម្លាភាព (ផ្សព្វផ្សាយពីផែនការថវិកា ការអនុវត្តចំណូលនិងចំណាយថវិកា) និងគណនេយ្យភាព(ការកត់ត្រាស្របតាមប្លង់គណនេយ្យសាធារណៈ)។
- ***បញ្ជីឯកសារកស្តុតាង៖***
  ១. របាយការណ៍ចំណាយថវិកាប្រចាំត្រីមាស ឆមាស និងឆ្នាំនៃការអនុវត្តថវិកាឆ្នាំ (Y-1)
  ២. របាយការណ៍ទូទាត់។

➢ <u>ការអនុវត្តថវិកាស្របតាមការគ្រោងទុក</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការអនុវត្តថវិកាធៀបទៅនឹងផែនការថវិកាប្រចាំឆ្នាំ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)របាយការណ៍ចំណាយថវិកាប្រចាំត្រីមាស ឆមាស និងឆ្នាំនៃការអនុវត្តថវិកាឆ្នាំ (Y-1) និង២)របាយការណ៍ទូទាត់។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | ការអនុវត្តថវិការដ្ឋ និងថវិកាដទៃទៀត បានលើសពី ៩៨ភាគរយ នៃកញ្ចប់ថវិកាសរុបនៃឆ្នាំ (Y-1) |
| ពិន្ទុ ៤ | ការអនុវត្តថវិការដ្ឋ និងថវិកាដទៃទៀត បាន ៩៦-៩៨ភាគរយ នៃកញ្ចប់ថវិកាសរុបនៃឆ្នាំ (Y-1) |
| ពិន្ទុ ៣ | ការអនុវត្តថវិការដ្ឋ និងថវិកាដទៃទៀត បាន ៩១-៩៥ភាគរយ នៃកញ្ចប់ថវិកាសរុបនៃឆ្នាំ (Y-1) |

| | |
|---|---|
| ពិន្ទុ ២ | ការអនុវត្តថវិការដ្ឋ និងថវិកាដទៃទៀត បាន ៨៦-៩០ភាគរយ នៃកញ្ចប់ថវិកាសរុបនៃឆ្នាំ (Y-1) |
| ពិន្ទុ ១ | ការអនុវត្តថវិការដ្ឋ និងថវិកាដទៃទៀត បាន ៨១-៨៥ភាគរយ នៃកញ្ចប់ថវិកាសរុបនៃឆ្នាំ (Y-1) |
| ពិន្ទុ ០ | ការអនុវត្តថវិការដ្ឋ និងថវិកាដទៃទៀត បានតិចជាង ៨០ភាគរយ នៃកញ្ចប់ថវិកាសរុបនៃឆ្នាំ (Y-1) |

- ការដកសាច់ប្រាក់ពីបេឡាត្រូវមានសំណើសុំចំណាយថវិកា និងបណ្ណចំណាយដោយភ្ជាប់ជាមួយឯកសារគាំទ្រ
  - ***សេចក្តីពន្យល់៖*** សំដៅដល់នីតិវិធីពេលដកសាច់ប្រាក់ពីបេឡារបស់សាលារៀន។ លោកគ្រូ អ្នកគ្រូដែលមានតម្រូវការសម្ភារបង្រៀន និងរៀន ត្រូវបំពេញទម្រង់ពាក្យស្នើសុំបើកសាច់ប្រាក់ដោយភ្ជាប់មកជាមួយនូវបណ្ណចំណាយ និងឯកសារគាំទ្រមកនាយកសាលា។ ពេលទទួលបានការឯកភាពពីនាយកសាលា លោកគ្រូ អ្នកគ្រូនឹងទទួលបានសាច់ប្រាក់ពីហេរញ្ញិក ដើម្បីទៅទិញសម្ភារបង្រៀននិងរៀនដោយខ្លួនឯង ហើយត្រូវប្រគល់វិក្កយបត្រទិញមកវិញ ពេលក្រោយ។
  - ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ សំណើសុំថវិកា បណ្ណចំណាយ ឯកសារគាំទ្រ និងវិក្កយបត្រ។
  - ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | បានរៀបចំបញ្ជីសរុបបណ្ណដកប្រាក់ប្រចាំខែ |
| ពិន្ទុ ៤ | ដកសាច់ប្រាក់មានសំណើសុំថវិកា មានបណ្ណចំណាយ មានឯកសារគាំទ្រ និងមានវិក្កយបត្របង្ហាញក្រោយពេលទិញសម្ភារៈ |
| ពិន្ទុ ៣ | ដកសាច់ប្រាក់មានសំណើសុំថវិកា មានបណ្ណចំណាយ និងមានឯកសារគាំទ្រ |
| ពិន្ទុ ២ | ដកសាច់ប្រាក់មានសំណើសុំថវិកា មានបណ្ណចំណាយ តែមិនមានឯកសារគាំទ្រ |
| ពិន្ទុ ១ | ដកសាច់ប្រាក់មានសំណើសុំចំណាយថវិកា តែមិនមានបណ្ណចំណាយ និងឯកសារគាំទ្រ |
| ពិន្ទុ ០ | ដកសាច់ប្រាក់មិនមានសំណើសុំចំណាយថវិកា បណ្ណចំណាយ និងឯកសារគាំទ្រ |

- ការរៀបចំតារាងតម្លាភាពថវិកា និងគណនេយ្យភាពថវិកាឱ្យបានទៀងទាត់និងទាន់ពេល
  - ***សេចក្តីពន្យល់៖*** សំដៅដល់ការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងផែនការថវិកាប្រចាំឆ្នាំ ការអនុវត្តចំណូលនិងចំណាយថវិកា និងព័ត៌មានពាក់ព័ន្ធផ្សេងៗ។
  - ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ផ្ទាំង ឬក្តារខៀន ២)របាយការណ៍នៃការអនុវត្តថវិកា ៣)របាយការណ៍ និងភស្តុតាងផ្សេងៗនៃកិច្ចប្រជុំរវាងគណៈគ្រប់គ្រងសាលារៀនជាមួយមាតាបិតា អ្នកអាណាព្យាបាលសិស្ស និងសហគមន៍ និង៤)ប្រព័ន្ធផ្សព្វផ្សាយ(បង្ហាញអំពីទិន្នន័យថវិកាទៅសាធារណជន)។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | មានការផ្សព្វផ្សាយក្នុងបរិវេណសាលារៀន ក្នុងសហគមន៍ និងប្រព័ន្ធទំនាក់ទំនងសង្គម ផ្តល់ព័ត៌មានអំពីតម្លាភាពថវិកា និងគណនេយ្យភាពថវិកាដែលមានបច្ចុប្បន្នភាពទៀងទាត់ (លើសពី៤ដងក្នុងបវេសនកាល ដោយយ៉ាងយូរ១៥ថ្ងៃនៃខែបន្ទាប់ក្នុងមួយលើកៗ) |
| ពិន្ទុ ៤ | មានការផ្សព្វផ្សាយក្នុងបរិវេណសាលារៀន និងប្រព័ន្ធទំនាក់ទំនងសង្គម ផ្តល់ព័ត៌មានអំពីតម្លាភាពថវិកា និងគណនេយ្យភាពថវិកានិងជាប្រចាំ (លើសពី៤ដងក្នុងបវេសនកាល) |
| ពិន្ទុ ៣ | មានការផ្សព្វផ្សាយក្នុងបរិវេណសាលារៀនតែមិនបានទៀងទាត់ និងជាប្រចាំ (តិចជាង ៤ដងក្នុងបវេសនកាល) |
| ពិន្ទុ ២ | មានការផ្សព្វផ្សាយក្នុងបរិវេណសាលារៀនតែមិនបានទៀងទាត់ និងជាប្រចាំ |
| ពិន្ទុ ១ | មានការផ្សព្វផ្សាយមិនចំហ និងមិនបានជាសាធារណៈ (ក្នុងបរិវេណការិយាល័យទីចាត់ការ) |
| ពិន្ទុ ០ | ពុំបានផ្សព្វផ្សាយ និងពុំមានឧបករណ៍ផ្សព្វផ្សាយ |

### ៣.១.៣ ការកៀរគរថវិកា/គ្រប់គ្រងថវិកាប្រកបដោយតម្លាភាពសម្រាប់អភិវឌ្ឍសាលារៀន (២៥ពិន្ទុ)

- ***សេចក្តីពន្យល់៖*** សំដៅដល់សកម្មភាពកៀរគរថវិកាបំពេញបន្ថែមក្រៅពីថវិការដ្ឋ របស់គណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ ក្នុងស្មារតីផ្សារភ្ជាប់សាលារៀនទៅនឹងសហគមន៍។ ការកៀរគរថវិកានេះ អាចធ្វើបានតាមរយៈសកម្មភាព ដូចខាងក្រោម៖
  - ការអែអង្គាសពីអតីតសិស្ស សប្បុរសជន សហគមន៍ អាជ្ញាធរ ដៃគូអភិវឌ្ឍ វិស័យឯកជន (ការអែអង្គាសតាមរយៈការផ្សព្វផ្សាយក្នុងបណ្តាញសង្គម បុណ្យផ្កាសាមគ្គី...)
  - ការលក់ផលិតផលផ្សេងៗ និងការលក់ផលិតផលស្នាដៃសិស្ស
  - ការប្រគុំតន្ត្រី និងសម្តែងសិល្បៈសប្បុរសធម៌
  - ភាស៊ីផ្ញើម៉ូតូ កង់ អាហារដ្ឋាន តូបលក់ និងការជួលផ្សេងៗ។

  **សម្គាល់៖** ចំណូលដែលទទួលបានក្នុងសកម្មភាពខាងលើនេះ ត្រូវដាក់ក្នុងគណនីធនាគាររបស់សាលារៀនហើយកត់ត្រាចូលក្នុងបញ្ជីបេឡាមូលនិធិដំណើរការសាលារៀនសាធារណៈនៅពេលដកសាច់ប្រាក់ពីធនាគារ។

- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)បណ្ណទទួលប្រាក់ ២)សក្ខីបណ្ណចំណាយ និង៣)គណនីធនាគាររបស់សាលារៀន។

➢ ការកៀរគរថវិកាពីប្រភពស្របច្បាប់ផ្សេងៗដើម្បីអភិវឌ្ឍសាលារៀន

- ***សេចក្ដីពន្យល់៖*** សំដៅដល់ការប្រមូល និងគ្រប់គ្រងចំណូលដោយគណៈកម្មការគ្រប់គ្រងសាលារៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)បណ្ណទទួលប្រាក់ និង២)សក្ខីបណ្ណចំណាយ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | មានបញ្ជីបេឡាមូលនិធិដំណើរការសាលារៀនសាធារណៈ និងបង់មូលនិធិក្នុងគណនីធនាគាររបស់សាលារៀន ព្រមទាំងមានការផ្សព្វផ្សាយជាសាធារណៈនូវរបាយការណ៍ចំណូលនិងចំណាយថវិកានៃមូលនិធិនេះ តាមរយៈតារាងតម្លាភាពថវិកា និងគណនេយ្យភាពថវិកា( ចាប់ពី ៤ដងក្នុងបវេសនកាល ) |
| ពិន្ទុ ៤ | មានបញ្ជីបេឡាមូលនិធិដំណើរការសាលារៀនសាធារណៈ និងបង់មូលនិធិក្នុងគណនីធនាគាររបស់សាលារៀន ព្រមទាំងមានការផ្សព្វផ្សាយជាសាធារណៈនូវរបាយការណ៍ចំណូលនិងចំណាយថវិកានៃមូលនិធិនេះ តាមរយៈតារាងតម្លាភាពថវិកា និងគណនេយ្យភាពថវិកា ( តិចជាង ៤ដងក្នុងបវេសនកាល ) |
| ពិន្ទុ ៣ | មានរបាយការណ៍ចំណូល និងចំណាយថវិកា ដែលមានការត្រួតពិនិត្យដោយគណៈកម្មការគ្រប់គ្រង ឬសហគមន៍គ្រប់គ្រងជាប្រចាំ មានបញ្ជីបេឡាមូលនិធិដំណើរការសាលារៀនសាធារណៈ និងបង់មូលនិធិក្នុងគណនីធនាគាររបស់សាលារៀន |
| ពិន្ទុ ២ | មានរបាយការណ៍ចំណូល និងចំណាយថវិកា មានបញ្ជីបេឡាមូលនិធិដំណើរការសាលារៀនសាធារណៈ និងបង់មូលនិធិក្នុងគណនីធនាគាររបស់សាលារៀន |
| ពិន្ទុ ១ | មានបញ្ជីបេឡាមូលនិធិដំណើរការសាលារៀនសាធារណៈ តែពុំបានបង់មូលនិធិក្នុងគណនីធនាគាររបស់សាលារៀន |
| ពិន្ទុ ០ | ពុំបានកត់ត្រាក្នុងបញ្ជីបេឡានូវមូលនិធិដំណើរការសាលារៀនសាធារណៈ |

➢ ការរៀបចំព្រឹត្តិការណ៍ផ្សេងៗដើម្បីស្វែងរកចំណូលសម្រាប់ការអភិវឌ្ឍសាលារៀន

- ***សេចក្ដីពន្យល់៖*** សំដៅដល់ការរៀបចំព្រឹត្តិការណ៍វប្បធម៌ ឬបុណ្យផ្សេងៗ ដូចជា៖ បុណ្យផ្កា បុណ្យប្រឹស ឬពិធីផ្សេងៗនៅក្នុងសាលារៀនដើម្បីកៀរគរថវិកាសម្រាប់អភិវឌ្ឍសាលារៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់ (របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ សកម្មភាពព្រឹត្តិការណ៍ របាយការណ៍ចំណូលពីការរៀបចំព្រឹត្តិការណ៍ តារាងតម្លាភាពថវិកា និងរបាយការណ៍ប្រជុំលើការប្រើប្រាស់ចំណូលនេះ។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | ធ្លាប់បានរៀបចំ មានរបាយការណ៍ចំណូល បានដាក់ចូលក្នុងថវិកាសម្រាប់អភិវឌ្ឍសាលារៀន មានបិទផ្សាយលើតារាងតម្លាភាព និងមានការប្រជុំលើការប្រើប្រាស់ថវិកានេះដោយតម្លាភាព |
| ពិន្ទុ ៤ | ធ្លាប់បានរៀបចំ មានរបាយការណ៍ចំណូល បានដាក់ចូលក្នុងថវិកាសម្រាប់អភិវឌ្ឍសាលារៀន មានបិទផ្សាយលើតារាងតម្លាភាព តែមិនមានការប្រជុំលើការប្រើប្រាស់ថវិកានេះដោយតម្លាភាព |
| ពិន្ទុ ៣ | ធ្លាប់បានរៀបចំ មានរបាយការណ៍ចំណូល បានដាក់ចូលក្នុងថវិកាសម្រាប់អភិវឌ្ឍសាលារៀន តែមិនមានបិទផ្សាយលើតារាងតម្លាភាព និងមិនមានការប្រជុំលើការប្រើប្រាស់ថវិកានេះដោយតម្លាភាព |
| ពិន្ទុ ២ | ធ្លាប់បានរៀបចំ មានរបាយការណ៍ចំណូល តែមិនបានដាក់ចូលក្នុងថវិកាសម្រាប់អភិវឌ្ឍសាលារៀន មិនមានបិទផ្សាយលើតារាងតម្លាភាព និងមិនមានការប្រជុំលើការប្រើប្រាស់ថវិកានេះដោយតម្លាភាព |
| ពិន្ទុ ១ | ធ្លាប់បានរៀបចំ តែមិនមានរបាយការណ៍ចំណូល មិនបានដាក់ចូលក្នុងថវិកាសម្រាប់អភិវឌ្ឍសាលារៀន មិនមានបិទផ្សាយលើតារាងតម្លាភាព និងមិនមានការប្រជុំលើការប្រើប្រាស់ថវិកានេះដោយតម្លាភាព |
| ពិន្ទុ ០ | ពុំដែលធ្លាប់បានរៀបចំម្តងណាឡើយ |

## ➢ ការគ្រប់គ្រងចំណូលពីការអនុវត្តបំណិនជីវិតប្រកបដោយនិរន្តរភាព

- ***សេចក្តីពន្យល់៖*** សំដៅដល់ការគ្រប់គ្រងចំណូលដែលបានពីសកម្មភាពបំណិនជីវិត (ដាំបន្លែ ចិញ្ចឹមសត្វ ផ្សេងៗ) ដោយមានរបាយការណ៍កត់ត្រាច្បាស់លាស់ មានការដាក់ចូលក្នុងថវិកាសម្រាប់អភិវឌ្ឍសាលារៀន មានការបិទផ្សាយលើតារាងតម្លាភាព និងមានកិច្ចប្រជុំលើការប្រើប្រាស់ថវិកានេះ ដើម្បីបម្រើដល់ការអភិវឌ្ឍសាលារៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ សួនបំណិនជីវិត របាយការណ៍ចំណូលពីបំណិនជីវិត តារាងតម្លាភាពថវិកា និងរបាយការណ៍ប្រជុំលើការប្រើប្រាស់ចំណូលនេះ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | មានសកម្មភាពបំណិនជីវិត មានរបាយការណ៍ចំណូលពីបំណិនជីវិត បានដាក់ចូលក្នុងថវិកាសម្រាប់អភិវឌ្ឍសាលារៀន មានបិទផ្សាយលើតារាងតម្លាភាព និងមានការប្រជុំលើការប្រើប្រាស់ថវិកានេះដោយតម្លាភាព |
| ពិន្ទុ ៤ | មានសកម្មភាពបំណិនជីវិត មានរបាយការណ៍ចំណូលពីបំណិនជីវិត បានដាក់ចូលក្នុងថវិកាសម្រាប់អភិវឌ្ឍសាលារៀន មានបិទផ្សាយលើតារាងតម្លាភាព ប៉ុន្តែមិនមានការប្រជុំលើការប្រើប្រាស់ថវិកានេះដោយតម្លាភាព |

| | |
|---|---|
| ពិន្ទុ ៣ | មានសកម្មភាពបំណិនជីវិត មានរបាយការណ៍ចំណូលពីបំណិនជីវិត បានដាក់ចូលក្នុងថវិកាសម្រាប់អភិវឌ្ឍសាលារៀន ប៉ុន្តែមិនមានបិទផ្សាយលើតារាងតម្លាភាព និងមិនមានការប្រជុំលើការប្រើប្រាស់ថវិកានេះដោយតម្លាភាព |
| ពិន្ទុ ២ | មានសកម្មភាពបំណិនជីវិត មានរបាយការណ៍ចំណូលពីបំណិនជីវិត ប៉ុន្តែមិនបានដាក់ចូលក្នុងថវិកាសម្រាប់អភិវឌ្ឍសាលារៀន មិនមានបិទផ្សាយលើតារាងតម្លាភាព និងមិនមានការប្រជុំលើការប្រើប្រាស់ថវិកានេះដោយតម្លាភាព |
| ពិន្ទុ ១ | មានសកម្មភាពបំណិនជីវិត តែមិនមានរបាយការណ៍ចំណូលពីបំណិនជីវិត មិនបានដាក់ចូលក្នុងថវិកាសម្រាប់អភិវឌ្ឍសាលារៀន មិនមានបិទផ្សាយលើតារាងតម្លាភាព និងមិនមានការប្រជុំលើការប្រើប្រាស់ថវិកានេះដោយតម្លាភាព |
| ពិន្ទុ ០ | មាន/គ្មានសកម្មភាពបំណិនជីវិត ប៉ុន្តែមិនមានចំណូលពីបំណិនជីវិត |

- ការគ្រប់គ្រងចំណូលពីភាសីកង់ ម៉ូតូ អាហារដ្ឋាន តូបលក់និងការជួលផ្សេងៗប្រកបដោយប្រសិទ្ធភាព

- ***សេចក្តីពន្យល់៖*** សំដៅដល់ការគ្រប់គ្រងចំណូលពីភាសីកង់ ម៉ូតូ អាហារដ្ឋាន តូបលក់និងការជួលផ្សេងៗ ប្រកបដោយប្រសិទ្ធភាព តាមរយៈការមានកុងត្រាជួលច្បាស់លាស់ មានរបាយការណ៍កត់ត្រាច្បាស់លាស់ មានការដាក់ចូលក្នុងថវិកាសម្រាប់អភិវឌ្ឍសាលារៀន មានការបិទផ្សាយលើតារាងតម្លាភាព និងមានកិច្ចប្រជុំលើការប្រើប្រាស់ថវិកានេះ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ កុងត្រាជួល របាយការណ៍កត់ត្រាចំណូលពីភាសី តារាងតម្លាភាពថវិកា និងរបាយការណ៍ប្រជុំលើការប្រើប្រាស់ចំណូលពីភាសី។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | មានកុងត្រាជួល មានរបាយការណ៍ចំណូលពីភាសីកង់ ម៉ូតូ អាហារដ្ឋាន តូបលក់និងការជួលផ្សេងៗ បានដាក់ចូលក្នុងថវិកាសម្រាប់អភិវឌ្ឍសាលារៀន មានបិទផ្សាយលើតារាងតម្លាភាព និងមានការប្រជុំលើការប្រើប្រាស់ថវិកានេះដោយតម្លាភាព |
| ពិន្ទុ ៤ | មានកុងត្រាជួល មានរបាយការណ៍ចំណូលពីភាសីកង់ ម៉ូតូ អាហារដ្ឋាន តូបលក់និងការជួលផ្សេងៗ បានដាក់ចូលក្នុងថវិកាសម្រាប់អភិវឌ្ឍសាលារៀន មានការបិទផ្សាយលើតារាងតម្លាភាព ប៉ុន្តែមិនមានការប្រជុំលើការប្រើប្រាស់ថវិកានេះ |
| ពិន្ទុ ៣ | មានកុងត្រាជួល មានរបាយការណ៍ចំណូលពីភាសីកង់ ម៉ូតូ អាហារដ្ឋាន តូបលក់និងការជួលផ្សេងៗ បានដាក់ចូលក្នុងថវិកាសម្រាប់អភិវឌ្ឍសាលារៀន ប៉ុន្តែមិនមានការបិទផ្សាយលើតារាងតម្លាភាព និងមិនមានការប្រជុំលើការប្រើប្រាស់ថវិកានេះ |
| ពិន្ទុ ២ | មានកុងត្រាជួល និងមានរបាយការណ៍ចំណូលពីភាសីកង់ ម៉ូតូ អាហារដ្ឋាន តូបលក់និងការជួលផ្សេងៗ ប៉ុន្តែមិនបានដាក់ចូលក្នុងថវិកាសម្រាប់អភិវឌ្ឍសាលារៀន |
| ពិន្ទុ ១ | មានកុងត្រាជួល តែមិនមានរបាយការណ៍ចំណូលពីភាសីកង់ ម៉ូតូ អាហារដ្ឋាន តូបលក់និងការជួលផ្សេងៗ |
| ពិន្ទុ ០ | មិនមានកុងត្រា មិនមានរបាយការណ៍ចំណូល ហើយចំណូលពីភាសីកង់ ម៉ូតូ អាហារដ្ឋាន តូបលក់និងការជួលផ្សេងៗ ក៏មិនបានដាក់ចូលក្នុងថវិកាសម្រាប់អភិវឌ្ឍសាលារៀន |

## ➢ ការរៀបចំសមាសភាពនិងមុខងារគណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ

- ***សេចក្តីពន្យល់៖*** សំដៅដល់សមាសភាព និងមុខងារ ដូចខាងក្រោម៖

  សមាសភាព[២]៖ នាយក/នាយិកាសាលា នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេសទាំងអស់ និងតំណាងគ្រូបង្រៀន ហេរញ្ញិក/គណនេយ្យករសាលា និងសមាជិក២រូបរបស់សហគមន៍។

  មុខងារ[៣] ៖ ១.គ្រប់គ្រងមូលនិធិដំណើរការសាលារៀន ២.ទទួលខុសត្រូវក្នុងការអនុវត្តមូលនិធិដំណើរការសាលារៀនឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ៣.បង្កើតហិបតម្លាភាពដើម្បីទទួលបានព័ត៌មាន ឬពាក្យបណ្តឹងផ្សេងៗពីអ្នកពាក់ព័ន្ធ និង ៤.ទទួលថវិកាសម្រាប់ការអនុវត្តមូលនិធិដំណើរការសាលារៀនសាធារណៈ និងទទួលខុសត្រូវក្នុងការគ្រប់គ្រងមូលនិធិ។

- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)លិខិតបង្គាប់ការឬសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ ២)ហិបតម្លាភាព និង៣)បញ្ជីត្រួតពិនិត្យ(Checklist) សមាសភាព និងមុខងារគណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | មានការរៀបចំសមាសភាពនាយក/នាយិកាសាលា នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេសទាំងអស់និងតំណាងគ្រូបង្រៀន ហេរញ្ញិក/គណនេយ្យករសាលា និងតំណាងសហគមន៍ ២រូប ចូលរួមក្នុងសមាសភាព និងបានបំពេញមុខងារបានពេញលេញ |
| ពិន្ទុ ៤ | មានការរៀបចំសមាសភាពនាយក/នាយិកាសាលា នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេសទាំងអស់និងតំណាងគ្រូបង្រៀន ហេរញ្ញិក/គណនេយ្យករសាលា និងតំណាងសហគមន៍ ២រូប ចូលរួមក្នុងសមាសភាព និងបានបំពេញមុខងារ បាន៣/៤នៃចំណុចខាងលើ |
| ពិន្ទុ ៣ | មានការរៀបចំសមាសភាពនាយក/នាយិកាសាលា នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេសទាំងអស់និងតំណាងគ្រូបង្រៀន ហេរញ្ញិក/គណនេយ្យករសាលា និងតំណាងសហគមន៍ ២រូប ចូលរួមក្នុងសមាសភាព និងបានបំពេញមុខងារ បាន២/៤នៃចំណុចខាងលើ |
| ពិន្ទុ ២ | មានការរៀបចំសមាសភាពនាយក/នាយិកាសាលា នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេសទាំងអស់និងតំណាងគ្រូបង្រៀន ហេរញ្ញិក/គណនេយ្យករសាលា និងតំណាងសហគមន៍ ២រូប ចូលរួមក្នុងសមាសភាព |

[២] គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ, ទំព័រទី១៧

[៣] គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ, ទំព័រទី១៦

| | |
|---|---|
| ពិន្ទុ ១ | មានការរៀបចំសមាសភាពនាយក/នាយិកាសាលា នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេសទាំងអស់និងតំណាងគ្រូបង្រៀន ហេរញ្ញិក/គណនេយ្យករសាលា តែពុំមានគ្រប់សមាសភាព |
| ពិន្ទុ ០ | ពុំបានរៀបចំសមាសភាព និងមុខងារគណៈកម្មការគ្រប់គ្រងមូលនិធិសាលារៀន |

### ៣.១.៤ ការពង្រឹងគុណវុឌ្ឍិមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ (១០ពិន្ទុ)

➢ <u>មន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុទទួលបានការបណ្តុះបណ្តាលអំពីនីតិវិធីហិរញ្ញវត្ថុពាក់ព័ន្ធ</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការចូលរួមទទួលការបណ្តុះបណ្តាលពាក់ព័ន្ធនឹងផ្នែកហិរញ្ញវត្ថុ របស់មន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ ពីមន្ទីរ/ការិយាល័យអប់រំ យុវជន និងកីឡា ឬពីស្ថាប័នផ្សេងៗ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ លិខិតអញ្ជើញចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា តែងតែសួរនាំការិយាល័យអប់រំ ពេលមានចម្ងល់។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥(មានតែពិន្ទុ០, ៣ និង៥)៖***

| | |
|---|---|
| ពិន្ទុ ៥ | បានទទួលការបណ្តុះបណ្តាលជាទៀងទាត់ (យ៉ាងហោចណាស់ ២ ដង/ឆ្នាំ) |
| ពិន្ទុ ៣ | ធ្លាប់បានទទួលការបណ្តុះបណ្តាល (១ ដង/ឆ្នាំ) |
| ពិន្ទុ ០ | ពុំដែលធ្លាប់បានទទួលការបណ្តុះបណ្តាល |

➢ <u>ការចែករំលែកបទពិសោធផ្ទៃក្នុងផ្នែកហិរញ្ញវត្ថុ</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការចែករំលែករបស់គណនេយ្យករពីបទពិសោធពាក់ព័ន្ធផ្នែកហិរញ្ញវត្ថុដល់មន្ត្រីក្នុងសាលារៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** របាយការណ៍សមិទ្ធកម្មប្រចាំឆមាស/ឆ្នាំ របស់សាលារៀន។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥(មានតែពិន្ទុ០, ៣ និង៥)៖***

| | |
|---|---|
| ពិន្ទុ ៥ | ចែករំលែកទៀងទាត់ (យ៉ាងហោចណាស់ ២ ដង/ឆ្នាំ) |
| ពិន្ទុ ៣ | បានចែករំលែកខ្លះ (១ ដង/ឆ្នាំ) |
| ពិន្ទុ ០ | មិនដែលបានចែករំលែកសោះ |

## ៣.២ ប្រព័ន្ធគ្រប់គ្រងគណនេយ្យ និងទ្រព្យសម្បត្តិរដ្ឋ (៤០ពិន្ទុ)

សំដៅដល់ការកត់ត្រា កិច្ចបញ្ជិកាគណនេយ្យ និងទ្រព្យសម្បត្តិរដ្ឋ។

### ៣.២.១ ដំណើរការនៃការកត់ត្រា (២០ពិន្ទុ)

- ***សេចក្តីពន្យល់៖*** ការកត់ត្រាតាមទម្រង់ និងប្រព័ន្ធណាមួយ។

- ***បញ្ជីឯកសារកេស្ដុតាង៖***
  ១. បញ្ជីតាមដានសាច់ប្រាក់ក្នុងធនាគារ
  ២. បញ្ជីតាមដានបេឡា។

➢ មានបញ្ជីតាមដានសាច់ប្រាក់ក្នុងធនាគារកត់ត្រាគ្រប់ប្រតិបត្តិការសាច់ប្រាក់ក្នុងគណនីធនាគាររបស់សាលារៀនជាប្រចាំ (គំរូលេខ៤)

- ***សេចក្តីពន្យល់៖*** សំដៅដល់បញ្ជីកត់ត្រាប្រតិបត្តិការសាច់ប្រាក់ក្នុងគណនីធនាគារ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ បញ្ជីតាមដានសាច់ប្រាក់ក្នុងធនាគារកត់ត្រាគ្រប់ប្រតិបត្តិការសាច់ប្រាក់ក្នុងគណនីធនាគាររបស់សាលារៀនជាប្រចាំ (គំរូលេខ៤[៥])។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | មានបញ្ជីតាមដានសាច់ប្រាក់ដូចក្នុងគំរូលេខ៤ និងកត់ត្រាបាន ១០ខែ |
| ពិន្ទុ ៤ | មានបញ្ជីតាមដានសាច់ប្រាក់ដូចក្នុងគំរូលេខ៤ និងកត់ត្រាបាន ៨ខែ |
| ពិន្ទុ ៣ | មានបញ្ជីតាមដានសាច់ប្រាក់ដូចក្នុងគំរូលេខ៤ និងកត់ត្រាបាន ៦ខែ |
| ពិន្ទុ ២ | មានបញ្ជីតាមដានសាច់ប្រាក់ដូចក្នុងគំរូលេខ៤ និងកត់ត្រាបាន ៤ខែ |
| ពិន្ទុ ១ | មានបញ្ជីតាមដានសាច់ប្រាក់ដូចក្នុងគំរូលេខ៤ និងកត់ត្រាបានតិចជាង ៤ខែ |
| ពិន្ទុ ០ | គ្មានបញ្ជីតាមដានសាច់ប្រាក់ |

➢ មានបញ្ជីបេឡាសម្រាប់តាមដានស្ថានភាពចំណូលចំណាយ និងចំនួនសាច់ប្រាក់ ដែលនៅសល់ចុងថ្ងៃ និងចុងខែ (គំរូលេខ៥)

- ***សេចក្តីពន្យល់៖*** សំដៅដល់បញ្ជីកត់ត្រាចំណូល ចំណាយប្រចាំថ្ងៃ និងប្រចាំខែរបស់សាលារៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ បញ្ជីបេឡាសម្រាប់តាមដានស្ថានភាពចំណូលចំណាយ និងចំនួនសាច់ប្រាក់ ដែលនៅសល់ចុងថ្ងៃ ចុងខែ (គំរូលេខ៥[៦])។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | មានបញ្ជីបេឡាតាមគំរូលេខ៥ និងកត់ត្រាបាន ចន្លោះពី៩ ទៅ១០ខែ |
| ពិន្ទុ ៤ | មានបញ្ជីបេឡាតាមគំរូលេខ៥ និងកត់ត្រាបាន ចន្លោះពី៧ ទៅ៨ខែ |
| ពិន្ទុ ៣ | មានបញ្ជីបេឡាតាមគំរូលេខ៥ និងកត់ត្រាបាន ចន្លោះពី៥ ទៅ៦ខែ |

[៥] គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ, ទំព័រទី៤៥

[៦] គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ, ទំព័រទី៤៦

| | |
|---|---|
| ពិន្ទុ ២ | មានបញ្ជីបេឡាតាមគំរូលេខ៥ និងកត់ត្រាបាន ចន្លោះពី៣ ទៅ៤ខែ |
| ពិន្ទុ ១ | មានបញ្ជីបេឡាតាមគំរូលេខ៥ និងកត់ត្រាបានតិចជាង ៣ខែ |
| ពិន្ទុ ០ | គ្មានបញ្ជីបេឡាតាមគំរូលេខ៥ |

- កត់ត្រាកិច្ចបញ្ជិកាគណនេយ្យតាមកុំព្យូទ័រដោយប្រើ Ms.Excel ឬកម្មវិធីផ្សេងទៀត
  - ***សេចក្តីពន្យល់៖*** សំដៅដល់កិច្ចបញ្ជិកាគណនេយ្យ (បូកសរុបទិន្នន័យប្រចាំឆ្នាំ) ដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន (កុំព្យូទ័រ និងសម្ភារៈអេឡិចត្រូនិកផ្សេងទៀត)។
  - ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)កុំព្យូទ័រ ២)កម្មវិធី Ms.Excel សម្រាប់គ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ និង៣)មន្ត្រីទទួលបន្ទុកការងារកត់ត្រា។
  - ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | ប្រើកម្មវិធី Ms. Excel ឬកម្មវិធីផ្សេងទៀត កត់ត្រាគ្រប់កិច្ចបញ្ជិកាគណនេយ្យ ៤ត្រីមាស |
| ពិន្ទុ ៤ | ប្រើកម្មវិធី Ms. Excel សម្រាប់គ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ មានមន្ត្រីទទួលបន្ទុកច្បាស់លាស់ និងបានកត់ត្រាលើកិច្ចបញ្ជិកាគណនេយ្យបានយ៉ាងតិច ៣ត្រីមាស |
| ពិន្ទុ ៣ | ប្រើកម្មវិធី Ms. Excel សម្រាប់គ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ មានមន្ត្រីទទួលបន្ទុកច្បាស់លាស់ និងបានកត់ត្រាលើកិច្ចបញ្ជិកាគណនេយ្យបានយ៉ាងតិច ២ត្រីមាស |
| ពិន្ទុ ២ | មានកុំព្យូទ័រ និងកម្មវិធី Ms. Excel សម្រាប់គ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ និងមានមន្ត្រីទទួលបន្ទុកច្បាស់លាស់ |
| ពិន្ទុ ១ | មានកុំព្យូទ័រនិងកម្មវិធី Ms. Excel សម្រាប់គ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ និងកំពុងទទួលការបណ្តុះបណ្តាលលើការកត់ត្រាតាមកុំព្យូទ័រ |
| ពិន្ទុ ០ | មានកុំព្យូទ័រនិងកម្មវិធី Ms. Excel សម្រាប់គ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ តែមិនដំណើរការ |

- ការគ្រប់គ្រងឯកសារពាក់ព័ន្ធនឹងហិរញ្ញវត្ថុត្រូវបានរក្សាទុកតាមក្រូណូ តាមលំដាប់ និងមានភាពងាយស្រួលសម្រាប់ការប្រើប្រាស់
  - ***សេចក្តីពន្យល់៖*** សំដៅដល់ការរក្សាទុកឯកសារពាក់ព័ន្ធនឹងហិរញ្ញវត្ថុតាមក្រូណូ តាមលំដាប់ និងមានភាពងាយស្រួលសម្រាប់ការប្រើប្រាស់។
  - ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ទូឯកសារ ២)ក្រូណូ ៣)ការបិទស្លាកលើក្រូណូ ៤)សណ្តាប់ធ្នាប់នៃការទុកដាក់ និង៥)សុវត្ថិភាពនៃការទុកដាក់ឯកសារ។

- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖*

| | |
|---|---|
| ពិន្ទុ ៥ | ឯកសារពាក់ព័ន្ធនឹងហិរញ្ញវត្ថុទាំងអស់ត្រូវបានដាក់ក្នុងក្រូណូបានត្រឹមត្រូវ មានរបៀបរៀបរយ ស្អាត ងាយស្រួលរក និងមានសុវត្ថិភាព |
| ពិន្ទុ ៤ | មានទូ និងដាក់ឯកសារតាមក្រូណូមានរបៀបរៀបរយ |
| ពិន្ទុ ៣ | មានទូ ប៉ុន្តែដាក់ឯកសារ មិនទៅតាមប្រភេទឯកសារ |
| ពិន្ទុ ២ | ដាក់ឯកសារមិនទៅតាមក្រូណូ |
| ពិន្ទុ ១ | គ្មានក្រូណូសម្រាប់ដាក់ឯកសារ |
| ពិន្ទុ ០ | គ្មានទូដាក់ឯកសារ និងការទុកដាក់ឯកសារមិនមានសណ្តាប់ធ្នាប់ |

### ៣.២.២ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (២០ពិន្ទុ)

- ***សេចក្តីពន្យល់៖*** សំដៅដល់ការកត់ត្រាបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋផ្ទាំគោល ស្របតាមវិធាន និងទម្រង់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- ***បញ្ជីឯកសារភស្តុតាង៖*** បញ្ជីសារពើភ័ណ្ឌ និងទ្រព្យសម្បត្តិរដ្ឋ។

➢ ការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ និងទ្រព្យសម្បត្តិរដ្ឋឱ្យបានទៀងទាត់និងជាប្រចាំ

- ***សេចក្តីពន្យល់៖*** សំដៅដល់ការគ្រប់គ្រង ការចាត់ចែង និងការរៀបចំបញ្ជីដោយបញ្ជាក់ពីប្រភពនៃការទិញ ការធ្វើបញ្ជីស្នើសុំជម្រុះ ការធ្វើបច្ចុប្បន្នកម្មទៅតាមគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា និងអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)បញ្ជីសារពើភ័ណ្ឌ ២)ស្លាកសម្គាល់ទ្រព្យដែលបញ្ជាក់អំពីប្រភពទិញ និងឆ្នាំទិញ ៣)បញ្ជីជម្រុះ និង៤)បញ្ជីស្នើសុំជម្រុះ(បាត់បង់ ឬខូចខាត) ៥)បញ្ជីតាមដានសម្ភារៈ និង៦)ក្រុមការងារបញ្ជីសារពើភ័ណ្ឌ។
- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ១ | មានរៀបចំក្រុមការងារបញ្ជីសារពើភ័ណ្ឌ |
| ពិន្ទុ ១ | មានបញ្ជីតាមដានសម្ភារៈ |
| ពិន្ទុ ១ | មានបញ្ជីជម្រុះ និងមានបញ្ជីស្នើសុំជម្រុះ(សម្ភារៈបាត់បង់ ឬខូចខាត) |
| ពិន្ទុ ១ | មានបិទស្លាកសម្គាល់ទ្រព្យដែលបញ្ជាក់អំពីប្រភពទិញ និងឆ្នាំទិញ |
| ពិន្ទុ ១ | មានបញ្ជីសារពើភ័ណ្ឌ និងទ្រព្យសម្បត្តិរដ្ឋតែការរៀបចំមិនស្របតាមគោលការណ៍ណែនាំ និងទម្រង់ផ្លូវការ(តាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា) |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## ➢ ការធ្វើបច្ចុប្បន្នកម្មតារាងប្រៀបធៀប(កើន/ថយចុះ) ទ្រព្យសម្បត្តិរដ្ឋឱ្យបានត្រឹមត្រូវ

- ***សេចក្តីពន្យល់៖*** សំដៅដល់ការធ្វើបច្ចុប្បន្នកម្មតារាងប្រៀបធៀប(កើន/ថយចុះ) ទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ និងទាន់ពេលវេលា។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ តារាងប្រៀបធៀប(កើន/ថយចុះ)ទ្រព្យសម្បត្តិរដ្ឋ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | តារាងប្រៀបធៀប(កើន/ថយចុះ) ទ្រព្យសម្បត្តិរដ្ឋ មានការកត់ត្រាបានទាំងអស់ (១០០ភាគរយ) ពេញលេញ (រដ្ឋ ដៃគូអភិវឌ្ឍ និងសហគមន៍) និងរួចរាល់នៅត្រឹមាសទី១នៃឆ្នាំបន្ទាប់ |
| ពិន្ទុ ៤ | តារាងប្រៀបធៀប(កើន/ថយចុះ) ទ្រព្យសម្បត្តិរដ្ឋ មានការកត់ត្រាភាគច្រើន(ត្រឹម ៨៥ភាគរយ) |
| ពិន្ទុ ៣ | តារាងប្រៀបធៀប(កើន/ថយចុះ) ទ្រព្យសម្បត្តិរដ្ឋ មានការកត់ត្រា ជាមធ្យម(ត្រឹម ៦០ភាគរយ) |
| ពិន្ទុ ២ | តារាងប្រៀបធៀប(កើន/ថយចុះ) ទ្រព្យសម្បត្តិរដ្ឋ មានការកត់ត្រាខ្លះ (តិចជាង ៦០ ភាគរយ) |
| ពិន្ទុ ១ | បានធ្វើបច្ចុប្បន្នកម្មតារាងប្រៀបធៀប(កើន/ថយចុះ) ទ្រព្យសម្បត្តិរដ្ឋ ប៉ុន្តែការរៀបចំមិនទៅតាមទម្រង់ផ្លូវការ |
| ពិន្ទុ ០ | ពុំបានរៀបចំបច្ចុប្បន្នកម្មតារាងប្រៀបធៀប(កើន/ថយចុះ) ទ្រព្យសម្បត្តិរដ្ឋ |

## ➢ ការគ្រប់គ្រង និងការប្រើប្រាស់បណ្ណកម្មសិទ្ធិដីធ្លី ឬ/និង អចលនទ្រព្យរបស់សាលារៀន

- ***សេចក្តីពន្យល់៖*** សំដៅដល់ការស្នើនិងរក្សាទុកបណ្ណកម្មសិទ្ធិដីធ្លី និង ការគ្រប់គ្រងនិងការប្រើប្រាស់អចលនទ្រព្យរបស់សាលារៀនដែលជាទ្រព្យសម្បត្តិសាធារណៈបម្រើដល់សកម្មភាពរបស់សាលារៀនដោយធានាបានថាស្ថានភាពទំហំដីជាក់ស្តែង និងទិន្នន័យក្នុងបណ្ណកម្មសិទ្ធិដីធ្លី ឬ/និង អចលនទ្រព្យរបស់សាលារៀនមានសង្គតិភាព និងត្រឹមត្រូវជាមួយអចលនទ្រព្យជាក់ស្តែង។ ចំពោះសាលារៀនដែលស្ថិតក្រោមចំណុះបណ្ណកម្មសិទ្ធិដីធ្លី ឬ/និង អចលនទ្រព្យរបស់ស្ថាប័នដទៃ ឬ ដីសាធារណៈរបស់រដ្ឋ ឬដីឯកជនរបស់រដ្ឋ មិនតម្រូវឱ្យសាលារៀនបំបែកចេញបណ្ណកម្មសិទ្ធិដីធ្លី ឬ/និង អចលនទ្រព្យនោះឡើយ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ
    - ***ករណីសាលារៀនមិនទាន់ទទួលបានបណ្ណកម្មសិទ្ធិដីធ្លី ឬ/និង អចលនទ្រព្យ៖*** ១)សំណើសុំចុះប្លង់កម្មសិទ្ធិពីអាជ្ញាធរមានសមត្ថកិច្ច ឬ ២)ឯកសារបញ្ជាក់ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ឬ ៣)ឯកសារបញ្ជាក់ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ។

- ***ករណីសាលារៀនទទួលបានបណ្ណកម្មសិទ្ធិដីធ្លី ឬ/និង អចលនទ្រព្យ៖*** ១)មានសេចក្តីចម្លងបណ្ណកម្មសិទ្ធិដីធ្លី ឬ/និង អចលនទ្រព្យ ដែលច្បាប់ដើមត្រូវរក្សាទុកនៅមន្ទីរអប់រំ យុវជន និងកីឡា ២)ក្នុងករណីមានបច្ចុប្បន្នភាព (ពង្រីក ផ្ទេរ បំបែក ឬដោះដូរ) ត្រូវមានការស្នើសុំរៀបចំធ្វើបច្ចុប្បន្នភាពបណ្ណកម្មសិទ្ធិដីធ្លី ដោយអនុលោមទៅតាមនីតិវិធីច្បាប់ជាធរមាន។
- ***ករណីសាលារៀនស្ថិតក្នុងដីដែលមានបណ្ណកម្មសិទ្ធិដីធ្លី ឬ/និង អចលនទ្រព្យរបស់ស្ថាប័នដទៃ (វត្តអារាម, ចំណុះសាលារៀនសាធារណៈ, ចំណុះស្ថាប័នរដ្ឋ)៖*** ១)មានសេចក្តីចម្លងបណ្ណកម្មសិទ្ធិដីធ្លី ឬ/និង អចលនទ្រព្យ។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (ករណីពិសេសមានតែពិន្ទុ ០,១, ៣ ឬ ៥)៖***

| | |
|---|---|
| ពិន្ទុ ៥ | – សេចក្តីចម្លងបណ្ណកម្មសិទ្ធិដីធ្លី ឬ/និង អចលនទ្រព្យ ដោយច្បាប់ដើមត្រូវរក្សាទុកនៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ឬ<br>– សេចក្តីចម្លងបណ្ណកម្មសិទ្ធិដីធ្លី ឬ/និង អចលនទ្រព្យ ដែលស្ថិតក្នុងចំណុះបណ្ណកម្មសិទ្ធិដីធ្លី ឬ/និង អចលនទ្រព្យរបស់ស្ថាប័នដទៃ (វត្តអារាម, ចំណុះសាលារៀនសាធារណៈ, ចំណុះស្ថាប័នរដ្ឋ) |
| ពិន្ទុ ៣ | បានស្នើសុំចុះបណ្ណកម្មសិទ្ធិដីធ្លី ឬ/និង អចលនទ្រព្យដែលមានលក្ខណៈសម្បត្តិមិនស្ថិតក្រោមបណ្ណកម្មសិទ្ធិដីធ្លី ឬ/និង អចលនទ្រព្យរបស់ស្ថាប័នដទៃ ឬ ដីសាធារណៈរបស់រដ្ឋ ឬដីឯកជនរបស់រដ្ឋ |
| ពិន្ទុ ១ | បានគិតគូរស្នើសុំចុះបណ្ណកម្មសិទ្ធិដីធ្លី ឬ/និង អចលនទ្រព្យ |
| ពិន្ទុ ០ | ពុំបានគិតគូរ និងគ្មានបណ្ណកម្មសិទ្ធិដីធ្លី ឬ/និង អចលនទ្រព្យ |

➢ <u>ការថែទាំនិងជួសជុលទ្រព្យសម្បត្តិរបស់សាលារៀន</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការថែទាំ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀន សម្ភារៈបង្រៀននិងរៀន ឬសម្ភារៈផ្សេងៗ ដើម្បីបម្រើដល់សកម្មភាពរៀន និងបង្រៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ រោងជាង របាយការណ៍ឬសកម្មភាពជួសជុលរបស់បុគ្គលិកសាលាដែលមានកន្លងមក។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥(ករណីពិសេសមានតែពិន្ទុ ០,១, ៣ ឬ ៥)៖***

| | |
|---|---|
| ពិន្ទុ ៥ | មានរោងជាង និងតែងតែថែទាំ និងជួសជុលទ្រព្យសម្បត្តិដែលខូច |
| ពិន្ទុ ៣ | មានរោងជាង ដំណើរការម្តងម្កាល |
| ពិន្ទុ ១ | មានរោងជាង តែមិនដំណើរការ (ទ្រព្យសម្បត្តិខូចទុកចោល) |
| ពិន្ទុ ០ | ពុំដែលធ្លាប់ជួសជុលទ្រព្យសម្បត្តិម្តងណាឡើយ |

### ៣.៣ ការតាមដាន និងការត្រួតពិនិត្យ (២៥ពិន្ទុ)

សំដៅដល់ការតាមដាន និងត្រួតពិនិត្យលទ្ធផលនៃការអនុវត្តសកម្មភាពរបស់សាលារៀន តាមរយៈការពិនិត្យលើរបាយការណ៍ថវិកា របាយការណ៍ទូទាត់ របាយការណ៍សមិទ្ធកម្ម និងរបាយការណ៍របស់សវនកម្ម ឬអធិការកិច្ច(មានខ្លឹមសារ មានការកត់ត្រាលទ្ធផលច្បាស់លាស់ និងមានការចុះហត្ថលេខាត្រឹមត្រូវ)។

#### ៣.៣.១ ប្រព័ន្ធរបាយការណ៍តាមដាន (២៥ពិន្ទុ)

- ***សេចក្តីពន្យល់៖*** សំដៅដល់របាយការណ៍សមិទ្ធកម្មការងារ ដែលឆ្លុះបញ្ចាំងពីលទ្ធផលដែលសាលាអនុវត្តបានប្រចាំឆមាស និងឆ្នាំ និងផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ បានទាន់ពេលវេលា។
- ***បញ្ជីឯកសារភស្តុតាង៖***
  ១. របាយការណ៍ចំណាយថវិកា(តាមតារាងលេខ ២.១ក និង២.១ខ នៃសៀវភៅគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ[៧])
  ២. របាយការណ៍ទូទាត់(តាមតារាងលេខ ៣.១ នៃសៀវភៅគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ[៨])
  ៣. របាយការណ៍របស់សវនកម្ម ឬអធិការកិច្ច
  ៤. របាយការណ៍សមិទ្ធកម្ម។

➢ <u>មានរបាយការណ៍ចំណាយថវិកាប្រចាំខែ(ជារបាយការណ៍ហិរញ្ញវត្ថុនៃកិច្ចប្រតិបត្តិការរបស់សាលារៀនសាធារណៈប្រចាំខែ និងជារបាយការណ៍ជម្រះបញ្ជីសម្រាប់ថវិកាដែលបានទទួល)</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់របាយការណ៍ហិរញ្ញវត្ថុនៃកិច្ចប្រតិបត្តិការរបស់សាលារៀនសាធារណៈប្រចាំខែ និងរបាយការណ៍ជម្រះបញ្ជីសម្រាប់ថវិកាដែលបានទទួល ដោយត្រូវផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឱ្យបានទាន់ពេលវេលា។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ របាយការណ៍ចំណាយថវិកាប្រចាំខែ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | មានរបាយការណ៍ចំណាយថវិកាប្រចាំខែ គ្រប់ខែ និងផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ បានគ្រប់ខែ និងទាន់ពេលវេលា |
| ពិន្ទុ ៤ | បានរៀបចំរបាយការណ៍ចំណាយថវិកាប្រចាំខែ គ្រប់ខែ និងផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ បានយ៉ាងតិច១០ខែទាន់ពេលវេលា |
| ពិន្ទុ ៣ | បានរៀបចំរបាយការណ៍ចំណាយថវិកាប្រចាំខែ គ្រប់ខែ និងផ្ញើការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ បានយ៉ាងតិច៨ខែទាន់ពេលវេលា |

[៧] គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ, ទំព័រទី៥០-៥១

[៨] គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ, ទំព័រទី៥៦

| | |
|---|---|
| ពិន្ទុ ២ | បានរៀបចំរបាយការណ៍ចំណាយថវិកាប្រចាំខែ តិចជាង៨ខែ និងផ្ញើជូនទៅការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ទាន់ពេល |
| ពិន្ទុ ១ | បានរៀបចំរបាយការណ៍ចំណាយថវិកាប្រចាំខែ តិចជាង៦ខែ និងមិនបានផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ |
| ពិន្ទុ ០ | គ្មានរបាយការណ៍ចំណាយថវិកាប្រចាំខែ |

- មានរបាយការណ៍ចំណាយថវិកាប្រចាំត្រីមាស( ជារបាយការណ៍ហិរញ្ញវត្ថុនៃកិច្ចប្រតិបត្តិការរបស់សាលារៀនសាធារណៈប្រចាំត្រីមាស និងជារបាយការណ៍ជម្រះបញ្ជីសម្រាប់ថវិកាដែលបានទទួល)
  - ***សេចក្តីពន្យល់៖*** សំដៅដល់របាយការណ៍ហិរញ្ញវត្ថុនៃកិច្ចប្រតិបត្តិការរបស់សាលារៀនសាធារណៈប្រចាំត្រីមាស និងរបាយការណ៍ជម្រះបញ្ជីសម្រាប់ថវិកាដែលបានទទួល និងផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ បានទាន់ពេលវេលា។
  - ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ របាយការណ៍ចំណាយថវិកាប្រចាំត្រីមាស។
  - ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | មានរបាយការណ៍ចំណាយថវិកាប្រចាំត្រីមាស គ្រប់ត្រីមាស និងផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ បានទាន់ពេលវេលា |
| ពិន្ទុ ៤ | បានរៀបចំរបាយការណ៍ចំណាយថវិកាប្រចាំត្រីមាស គ្រប់ត្រីមាស និង៣/៤នៃរបាយការណ៍ និងបានផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ បានទាន់ពេលវេលា |
| ពិន្ទុ ៣ | បានរៀបចំរបាយការណ៍ចំណាយថវិកាប្រចាំត្រីមាស គ្រប់ត្រីមាស និង២/៤នៃរបាយការណ៍ និងបានផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ បានទាន់ពេលវេលា |
| ពិន្ទុ ២ | បានរៀបចំរបាយការណ៍ចំណាយថវិកាប្រចាំត្រីមាសតិចជាង ៣ត្រីមាស |
| ពិន្ទុ ១ | បានរៀបចំរបាយការណ៍ចំណាយថវិកាប្រចាំត្រីមាសតិចជាង ២ត្រីមាស |
| ពិន្ទុ ០ | គ្មានរបាយការណ៍ចំណាយថវិកាប្រចាំត្រីមាស |

- មានរបាយការណ៍សមិទ្ធកម្មប្រចាំឆមាស[៩] ដែលឆ្លុះបញ្ចាំងពីព័ត៌មានសមិទ្ធកម្មគ្រប់ជ្រុងជ្រោយ
  - ***សេចក្តីពន្យល់៖*** សំដៅដល់របាយការណ៍ដែលឆ្លុះបញ្ចាំងពីលទ្ធផលដែលសាលារៀនអនុវត្តបានប្រចាំឆមាស និងផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌបានទាន់ពេលវេលា។

[៩] គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ, ទំព័រទី៣២

- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ របាយការណ៍សមិទ្ធកម្មប្រចាំឆមាស។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | បានរៀបចំរបាយការណ៍សមិទ្ធកម្មចំនួន ៤ត្រីមាស និងបានផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ បានទាន់ពេលវេលា ទាំង៤ត្រីមាស |
| ពិន្ទុ ៤ | បានរៀបចំរបាយការណ៍សមិទ្ធកម្មចំនួន ៤ត្រីមាស និងបានផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ បានទាន់ពេលវេលា យ៉ាងតិចចំនួន ២ត្រីមាស |
| ពិន្ទុ ៣ | បានរៀបចំរបាយការណ៍សមិទ្ធកម្ម ចំនួន ៤ត្រីមាស |
| ពិន្ទុ ២ | បានរៀបចំរបាយការណ៍សមិទ្ធកម្ម ចំនួន ៣ត្រីមាស |
| ពិន្ទុ ១ | បានរៀបចំរបាយការណ៍សមិទ្ធកម្ម ចំនួន ២ត្រីមាស |
| ពិន្ទុ ០ | គ្មានរបាយការណ៍សមិទ្ធកម្ម |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ការបញ្ជូនរបាយការណ៍សមិទ្ធកម្មបានទាន់ពេលវេលា សំដៅដល់ការបញ្ជូនរបាយការណ៍សមិទ្ធកម្ម ទៅការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងរយៈពេល១០ថ្ងៃបន្ទាប់ពីដំណាច់ត្រីមាសនីមួយៗ។

➢ <u>មានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់សាលារៀន និងរបាយការណ៍</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការអនុវត្តប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់សាលារៀនសាធារណៈ ដើម្បីធានាថាថវិកាត្រូវបានគ្រប់គ្រង និងប្រើប្រាស់ ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)របាយការណ៍ត្រួតពិនិត្យដែលចុះហត្ថលេខាចុងក្រោយដោយប្រធានគណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ និង២)បញ្ជីវត្តមានប្រជុំ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | មានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធសម្រាប់ការត្រួតពិនិត្យផ្ទៃក្នុង និងរបាយការណ៍ចុះហត្ថលេខាចុងក្រោយដោយប្រធានគណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ |
| ពិន្ទុ ៤ | មានការចូលរួមពីគណៈគ្រប់គ្រងសាលា សហគមន៍ មូលដ្ឋានឃុំ និងការិយាល័យ/មន្ទីរ |
| ពិន្ទុ ៣ | មានការចូលរួមពីគណៈគ្រប់គ្រងសាលា សហគមន៍ និងមូលដ្ឋានឃុំ |
| ពិន្ទុ ២ | មានការចូលរួមពីគណៈគ្រប់គ្រងសាលា និងសហគមន៍ |

| | |
|---|---|
| ពិន្ទុ ១ | មានការចូលរួមត្រឹមតែគណៈគ្រប់គ្រងសាលាដើម្បីត្រួតពិនិត្យប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង |
| ពិន្ទុ ០ | គ្មានការចូលរួមពីគណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ ដើម្បីត្រួតពិនិត្យប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ការចូលរួមក្រៅពីគណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ អាចចូលរួមក្នុងកិច្ចដំណើរការត្រួតពិនិត្យនេះ ក្នុងពេលកំណត់ណាមួយ។

➢ <u>ការអនុវត្តតាមអនុសាសន៍ចុងក្រោយរបស់សវនកម្មផ្ទៃក្នុង ឬអធិការកិច្ច</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការអនុវត្តតាមអនុសាសន៍របស់សវនកម្មផ្ទៃក្នុង ឬអធិការកិច្ច។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)របាយការណ៍សវនកម្ម ឬអធិការកិច្ចចុងក្រោយរបស់សាលារៀន ២)ផែនការប្រតិបត្តិប្រចាំឆ្នាំ និង៣)ផែនការអភិវឌ្ឍសាលារៀន។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | បានស្នើសុំ និងបានទទួលការធ្វើសវនកម្ម/អធិការកិច្ច ព្រមទាំងបានអនុវត្តតាមអនុសាសន៍ លើសពី ៨៥ភាគរយ |
| ពិន្ទុ ៤ | បានស្នើសុំ និងបានទទួលការធ្វើសវនកម្ម/អធិការកិច្ច ព្រមទាំងបានអនុវត្តតាមអនុសាសន៍ តិចជាង៨៥ភាគរយ |
| ពិន្ទុ ៣ | បានស្នើសុំ និងបានទទួលការធ្វើសវនកម្ម/អធិការកិច្ច ព្រមទាំងបានអនុវត្តតាមអនុសាសន៍ តិចជាង៧០ភាគរយ |
| ពិន្ទុ ២ | បានស្នើសុំ និងបានទទួលការធ្វើសវនកម្ម/អធិការកិច្ច ព្រមទាំងបានអនុវត្តតាមអនុសាសន៍ តិចជាង៥០ភាគរយ |
| ពិន្ទុ ១ | បានស្នើសុំ និងបានទទួលការធ្វើសវនកម្ម/អធិការកិច្ច ព្រមទាំងបានអនុវត្តតាមអនុសាសន៍ តិចជាង៣០ភាគរយ |
| ពិន្ទុ ០ | មិនធ្លាប់ត្រូវបានធ្វើសវនកម្ម/អធិការកិច្ច និងមិនធ្លាប់បានស្នើសុំការធ្វើសវនកម្ម/អធិការកិច្ច |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ត្រូវពិនិត្យរបាយការណ៍សវនកម្ម ឬ/និង អធិការកិច្ច ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ។

# ផ្នែកទី៤៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅក្នុងអង្គភាព

## ៤. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅក្នុងអង្គភាព (៨៥ពិន្ទុ)

ការពង្រឹង និងការកែលម្អដំណើរការនៃការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស ជាកិច្ចការអាទិភាព និងចាំបាច់បំផុត ដើម្បីប្រែក្លាយធនធានមនុស្សឱ្យកាន់តែមានសមត្ថភាព វិជ្ជាជីវៈច្បាស់លាស់ និងមានប្រសិទ្ធភាពក្នុងការបំពេញការងារសម្រេចបានតាមលទ្ធផលរំពឹងទុករបស់អង្គភាព ឬស្ថាប័ន ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ ក្នុងន័យនេះ ការគិតគូរលើការពង្រឹងដំណើការនៃការគ្រប់គ្រងធនធានមនុស្សប្រកបដោយប្រសិទ្ធភាព និងការអភិវឌ្ឍសមត្ថភាពធនធានមនុស្សប្រកបដោយភាពត្រឹមត្រូវឆ្លើយតបទៅនឹងតម្រូវការរបស់សាលារៀន ជាកត្តាចាំបាច់បំផុត ដែលរួមចំណែកដល់ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការបង្រៀននិងរៀន។

ក្នុងផ្នែកនៃការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សក្នុងអង្គភាព មានពិន្ទុសរុបចំនួន៨៥ ដែលមានលក្ខណៈវិនិច្ឆ័យរងចំនួន ២ គឺ៖

**១. ការគ្រប់គ្រងធនធានមនុស្ស** (៥៥ពិន្ទុ)

**២. ការអភិវឌ្ឍធនធានមនុស្ស** (៣០ពិន្ទុ)

## ៤.១ ការគ្រប់គ្រងធនធានមនុស្ស (៥៥ពិន្ទុ)

### ៤.១.១ ការរៀបចំផែនការគ្រប់គ្រងធនធានមនុស្ស និងការគ្រប់គ្រងការវិវត្តន៍អាជីពរបស់បុគ្គលិកអប់រំ (២០ពិន្ទុ)

➢ ការរៀបចំផែនការគ្រប់គ្រងធនធានមនុស្ស

- ***សេចក្ដីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបចំផែនការគ្រប់គ្រងបុគ្គលិកប្រចាំឆ្នាំ ដើម្បីឆ្លើយតបនឹងតម្រូវការការងាររបស់សាលារៀន។
- ***ទិន្នន័យ ឯកសារនិងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ផែនការគ្រប់គ្រងធនធានមនុស្សប្រចាំឆ្នាំ ២)របាយការណ៍កិច្ចប្រជុំពិគ្រោះយោបល់ជាមួយបុគ្គលិកអប់រំក្នុងសាលារៀន ៣)សំណើស្ដីពីតម្រូវការធនធានមនុស្សពីសាលារៀនទៅការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និង៤)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានផែនការគ្រប់គ្រងធនធានមនុស្ស |
| ពិន្ទុ ១ | មានការប្រមូលព័ត៌មានតម្រូវការធនធានមនុស្សពីគ្រប់ផ្នែកបច្ចេកទេសក្នុងសាលារៀន |
| ពិន្ទុ ១ | មានកិច្ចប្រជុំពិគ្រោះយោបល់ជាមួយ គណៈគ្រប់គ្រង បុគ្គលិកអប់រំ និងភាគីពាក់ព័ន្ធអំពីតម្រូវការធនធានមនុស្សក្នុងសាលារៀន |
| ពិន្ទុ ១ | បានរៀបចំនិងបញ្ជូនសំណើស្ដីពីតម្រូវការធនធានមនុស្សពីសាលារៀនទៅការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ ការផ្ទេរ ឬការផ្លាស់ប្ដូរកន្លែងធ្វើការរបស់មន្ត្រីផ្អែកតាមតម្រូវការពិតប្រាកដ និងអនុវត្តតាមបទដ្ឋានគតិយុត្តជាធរមាន

- ***សេចក្ដីពន្យល់៖*** ការផ្ទេរកន្លែងធ្វើការសំដៅដល់ការប្ដូរកន្លែងធ្វើការរបស់បុគ្គលិកអប់រំពីសាលារៀនមួយ ទៅសាលារៀនមួយទៀត។ ដោយឡែកការផ្លាស់ប្ដូរកន្លែងធ្វើការ សំដៅដល់ការប្ដូរកន្លែងធ្វើការរបស់បុគ្គលិកអប់រំក្នុងរចនាសម្ព័ន្ធសាលាតែមួយ។ ការផ្ទេរ និងការផ្លាស់ប្ដូរកន្លែងធ្វើការត្រូវធ្វើឡើងដើម្បីបំពេញកន្លែងទំនេរ ឆ្លើយតបនឹងតម្រូវការសមត្ថភាពជំនាញ និងធានាបាននូវប្រសិទ្ធភាពការងាររបស់សាលារៀន ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)របាយការណ៍ឬកំណត់ហេតុប្រជុំពិគ្រោះយោបល់ស្ដីពីការផ្ទេរ ឬការផ្លាស់ប្ដូរកន្លែងធ្វើការរបស់បុគ្គលិកអប់រំ ២)ដីកា/សេចក្ដីសម្រេច/លិខិតបង្គាប់ការស្ដីពីការផ្ទេរ ឬការផ្លាស់ប្ដូរកន្លែងធ្វើការរបស់បុគ្គលិកអប់រំ ៣) លិខិតបង្គាប់/សេចក្ដី

សម្រេច ស្តីពីការប្រគល់ភារកិច្ចជូនបុគ្គលិកអប់រំ ដែលបានផ្លាស់ប្តូរកន្លែងធ្វើការ ឬផ្ទេរចូល។ ដើម្បីផ្ទៀងផ្ទាត់អំពីការឆ្លើយតបនឹងតម្រូវការសមត្ថភាព និងកន្លែងទំនេរ ត្រូវពិនិត្យលើរចនាសម្ព័ន្ធ មន្ត្រីក្នុងមុខតំណែងក្នុងរចនាសម្ព័ន្ធ(អង្គការលេខ) ការពិពណ៌នាមុខតំណែង ប្រវត្តិរូបសង្ខេបរបស់មន្ត្រីដែលបានផ្លាស់ប្តូរកន្លែងធ្វើការ ឬការផ្ទេរចូល ឬផ្ទេរចេញ និងប្រកាសឬដីកាស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់សាលារៀន។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | ការផ្លាល់ប្តូរកន្លែងធ្វើការ ឬផ្ទេរចូល ឬចេញ ធ្វើឡើងដោយផ្អែកលើតម្រូវការជំនាញរបស់សាលារៀន |
| ពិន្ទុ ១ | ការផ្ទេរ ឬការផ្លាស់ប្តូរកន្លែងធ្វើការងារត្រូវបានអនុវត្តដើម្បីបំពេញកន្លែងទំនេរ |
| ពិន្ទុ ១ | ការផ្ទេរ ឬការផ្លាស់ប្តូរកន្លែងធ្វើការមានការពិគ្រោះយោបល់ប្រកបដោយតម្លាភាព (របាយការណ៍ ឬកំណត់ហេតុនៃកិច្ចប្រជុំ) |
| ពិន្ទុ ២ | មានសេចក្តីសម្រេច/ដីកា/លិខិតបង្គាប់ការស្តីពីការប្រគល់ភារកិច្ចជូនបុគ្គលិកអប់រំ ដែលបានផ្លាស់ប្តូរកន្លែងធ្វើការ ឬផ្ទេរចូល |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## ➢ ការដំឡើងថ្នាក់និងឋានន្តរស័ក្តិត្រូវបានរៀបចំជាទៀងទាត់

- ***សេចក្តីពន្យល់៖*** សំដៅដល់ការដំឡើងថ្នាក់ឬឋានន្តរស័ក្តិប្រចាំឆ្នាំជូនមន្ត្រីរាជការនៅសាលារៀនដែលជាគោលការណ៍ ត្រូវធ្វើឡើងតាមវេនជ្រើសរើស តាមអតីតភាពការងារ និងតាមសញ្ញាបត្រ។ ការដំឡើងថ្នាក់ ឬឋានន្តរស័ក្តិ ត្រូវធ្វើឡើងជាទៀងទាត់ ប្រកបដោយតម្លាភាព សុចរិតភាព និងត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំងឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)បញ្ជីឈ្មោះបុគ្គលិកអប់រំសម្រាប់ដំឡើងថ្នាក់ប្រចាំឆ្នាំ(រយៈពេល៣ឆ្នាំជាប់គ្នា) ២)របាយការណ៍ឬកំណត់ហេតុនៃកិច្ចប្រជុំពិគ្រោះយោបល់លើការដំឡើងថ្នាក់ និងឋានន្តរស័ក្តិជូនបុគ្គលិកអប់រំរបស់សាលារៀន ៣)សំណើដំឡើងថ្នាក់ប្រចាំឆ្នាំជូនបុគ្គលិកអប់រំរបស់សាលារៀន និង៤)ភាពទៀងទាត់នៃការដំឡើងថ្នាក់និងឋានន្តរស័ក្តិ។ ដើម្បីពិនិត្យមើលភាពទៀងទាត់នៃការដំឡើងថ្នាក់ និងឋានន្តរស័ក្តិត្រូវពិនិត្យមើលសេចក្តីសម្រេច (ប្រកាស អនុក្រឹត្យ ព្រះរាជក្រឹត្យ)ស្តីពីការដំឡើងជូនបុគ្គលិកអប់រំរយៈពេល ៥ឆ្នាំចុងក្រោយ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានការប្រជុំវាយតម្លៃប្រកបដោយតម្លាភាព ដើម្បីដំឡើងថ្នាក់និងឋានន្តរស័ក្តិប្រចាំឆ្នាំរបស់បុគ្គលិកអប់រំរបស់សាលារៀន |
| ពិន្ទុ ១ | មានការរៀបចំបញ្ជីឈ្មោះបុគ្គលិកអប់រំសម្រាប់ស្នើសុំដំឡើងថ្នាក់និងឋានន្តរស័ក្តិប្រចាំឆ្នាំ |

| | |
|---|---|
| ពិន្ទុ ១ | មានការរៀបចំលិខិតស្នើដើម្បីដំឡើងថ្នាក់និងឋានន្តរស័ក្តិប្រចាំឆ្នាំជូនបុគ្គលិកអប់រំរបស់សាលារៀន |
| ពិន្ទុ ១ | បានរៀបចំដំឡើងថ្នាក់និងឋានន្តរស័ក្តិជាទៀងទាត់ទៅតាមវេន |
| ពិន្ទុ ១ | បានរៀបចំដំឡើងថ្នាក់និងឋានន្តរស័ក្តិតាមកម្រិតសញ្ញាបត្រ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ <u>ការរៀបចំដាក់ឱ្យចូលនិវត្តន៍គោរពតាមគោលការណ៍កំណត់</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការរៀបចំដាក់បុគ្គលិកអប់រំគ្រប់រូប ដែលបានបំពេញគ្រប់លក្ខខណ្ឌឱ្យចូលនិវត្តន៍បានទាន់ពេលវេលា និងការគិតគូរអំពីសុខទុក្ខរបស់និវត្តជនក្រោយពេលដាក់ឱ្យចូលនិវត្តន៍។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)បញ្ជីឈ្មោះបុគ្គលិកអប់រំចូលនិវត្តន៍ប្រចាំឆ្នាំ ២)លិខិតជូនដំណឹងដល់បុគ្គលិកអប់រំដែលត្រៀមចូលនិវត្តន៍ ៣)លិខិតស្នើសុំដាក់បុគ្គលិកអប់រំឱ្យចូលនិវត្តន៍ ៤)លិខិតស្នើសុំប្រាក់ឧបត្ថម្ភសោធនដំបូងម្តងគត់សម្រាប់បុគ្គលិកអប់រំដែលត្រូវចូលនិវត្តន៍ និង៥)ការគិតគូរអំពីសុខទុក្ខនិវត្តជននៅក្រោយពេលដាក់ឱ្យចូលនិវត្តន៍។ ដើម្បីពិនិត្យលើការគិតគូរអំពីសុខទុក្ខនិវត្តជនក្រោយពេលដាក់ឱ្យចូលនិវត្តន៍ ដោយជួបសម្ភាសជាមួយគណៈគ្រប់គ្រងសាលារៀន បុគ្គលិកអប់រំក្នុងសាលារៀន និងភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានបញ្ជីឈ្មោះបុគ្គលិកអប់រំដែលត្រូវចូលនិវត្តន៍ប្រចាំឆ្នាំ |
| ពិន្ទុ ១ | មានលិខិតជូនដំណឹងដល់បុគ្គលិកអប់រំដែលត្រៀមចូលនិវត្តន៍ |
| ពិន្ទុ ១ | មានលិខិតស្នើសុំដាក់បុគ្គលិកអប់រំឱ្យចូលនិវត្តន៍ |
| ពិន្ទុ ១ | មានលិខិតស្នើសុំប្រាក់ឧបត្ថម្ភសោធនដំបូងម្តងគត់សម្រាប់បុគ្គលិកអប់រំដែលត្រូវចូលនិវត្តន៍ |
| ពិន្ទុ ១ | មានការគិតគូរអំពីសុខទុក្ខនិវត្តជននៅក្រោយពេលដាក់ឱ្យចូលនិវត្តន៍ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

### ៤.១.២ ការគ្រប់គ្រងសមិទ្ធកម្ម (ការគ្រប់គ្រងការអនុវត្តការងាររបស់មន្ត្រីក្នុងសាលារៀន) (៣៥ពិន្ទុ)

➢ <u>ការរៀបចំរចនាសម្ព័ន្ធរបស់អង្គភាព</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការបែងចែកមុខតំណែង និងរចនាសម្ព័ន្ធការងារឆ្លើយតបនឹងមុខងាររបស់សាលារៀនដោយតម្រៀបមុខតំណែងទាំងនោះទៅក្នុងទម្រង់ជាអង្គការលេខ។

- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)រចនាសម្ព័ន្ធ(អង្គការលេខ) របស់សាលារៀន ២)បច្ចុប្បន្នភាពនៃរចនាសម្ព័ន្ធរបស់សាលារៀន ៣)ការបិទផ្សាយរចនាសម្ព័ន្ធជាអង្គការលេខ និង៤)លិខិតបង្គាប់ការស្តីពីតួនាទី និងភារកិច្ចរបស់បុគ្គលិកអប់រំ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានរចនាសម្ព័ន្ធជាអង្គការលេខច្បាស់លាស់(មានឈ្មោះ រូបថត មុខតំណែង) |
| ពិន្ទុ ១ | បានធ្វើបច្ចុប្បន្នកម្មរចនាសម្ព័ន្ធអង្គការលេខជាប្រចាំ |
| ពិន្ទុ ១ | មានការបិទផ្សាយអង្គការលេខរបស់សាលារៀន |
| ពិន្ទុ ២ | ការបំពេញតួនាទីនិងភារកិច្ចរបស់បុគ្គលិកអប់រំស្របតាមរចនាសម្ព័ន្ធជាអង្គការលេខ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ ការដាក់ឱ្យអនុវត្តការពិពណ៌នាមុខតំណែងគ្រប់គ្រង និងមុខតំណែងវិជ្ជាជីវៈ

- ***សេចក្តីពន្យល់៖*** សំដៅដល់ការរៀបចំនិងដាក់ឱ្យអនុវត្តការពិពណ៌នាមុខតំណែង ដោយមានការកំណត់តួនាទី ភារកិច្ច ការទទួលខុសត្រូវ បន្ទាត់គណនេយ្យភាព និងគុណវុឌ្ឍិ/លក្ខណសម្បត្តិស័ក្តិសមសម្រាប់កាន់មុខតំណែងនីមួយៗទាំងមុខតំណែងគ្រប់គ្រង (នាយក នាយករង ប្រធានក្រុមបច្ចេកទេស) និងមុខតំណែងវិជ្ជាជីវៈ (មុខវិជ្ជាឯកទេស) របស់សាលារៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)សេចក្តីសម្រេច/ឯកសារស្តីពីការពិពណ៌នាមុខតំណែង ២)របាយការណ៍កិច្ចប្រជុំពិគ្រោះយោបល់លើការរៀបចំការពិពណ៌នាមុខតំណែង ៣)របាយការណ៍លទ្ធផលការងាររបស់បុគ្គលិកអប់រំម្នាក់ៗ ៤)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានសេចក្តីសម្រេច/ឯកសារស្តីពីការពិពណ៌នាមុខតំណែង |
| ពិន្ទុ ១ | មានការរៀបចំការពិពណ៌នាមុខតំណែងស្របតាមទំហំការងារ គុណវុឌ្ឍិ និងជំនាញវិជ្ជាជីវៈរបស់បុគ្គលិកអប់រំម្នាក់ៗ |
| ពិន្ទុ ១ | មានការប្រជុំពិគ្រោះយោបល់ក្នុងការរៀបចំការពិពណ៌នាមុខតំណែងជាមួយគណៈគ្រប់គ្រង បុគ្គលិកអប់រំ និងភាគីពាក់ព័ន្ធ |
| ពិន្ទុ ១ | ការអនុវត្តភារកិច្ចរបស់មន្ត្រីម្នាក់ៗស្របតាមឯកសារស្តីពីការពិពណ៌នាមុខតំណែង |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ ការដាក់ឱ្យអនុវត្តកិច្ចព្រមព្រៀងការងារសម្រាប់មន្ត្រីគ្រប់រូបនៅក្នុងសាលារៀន

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានកំណត់ និងបែងចែកភារកិច្ចនិងការទទួលខុសត្រូវ ដល់បុគ្គលិកអប់រំគ្រប់រូបក្នុងសាលារៀនស្របតាមផែនការប្រចាំឆ្នាំរបស់សាលារៀន ការពិពណ៌នាមុខតំណែង គុណវុឌ្ឍិ ជំនាញវិជ្ជាជីវៈរបស់សាមីបុគ្គលិក និងស្ថានភាពជាក់ស្តែងរបស់សាលារៀន ដើម្បីធានាបាននូវប្រសិទ្ធភាពក្នុងការអនុវត្តការងារ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)សេចក្តីសម្រេច/លិខិតបង្គាប់ការស្តីពីកិច្ចព្រមព្រៀងការងារ ២)របាយការណ៍កិច្ចប្រជុំពិគ្រោះយោបល់ក្នុងការបែងចែកតួនាទីនិងភារកិច្ច ៣)របាយការណ៍លទ្ធផលការងាររបស់បុគ្គលិកអប់រំម្នាក់ៗធៀបទៅនឹងកិច្ចព្រមព្រៀងការងារ ៤)ការពិពណ៌នាមុខតំណែងក្នុងរចនាសម្ព័ន្ធសាលារៀន ៥)ផែនការការងាររបស់សាលារៀន ៦) ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានសេចក្តីសម្រេច/លិខិតបង្គាប់ការស្តីពីកិច្ចព្រមព្រៀងអនុវត្តការងារ |
| ពិន្ទុ ១ | ការរៀបចំកិច្ចព្រមព្រៀងការងារស្របតាមការពិពណ៌នាមុខតំណែង ផែនការការងារប្រចាំឆ្នាំ គុណវុឌ្ឍិ និងជំនាញវិជ្ជាជីវៈរបស់ម្នាក់ៗ |
| ពិន្ទុ ១ | ការរៀបចំកិច្ចព្រមព្រៀងការងារមានការប្រជុំពិគ្រោះយោបល់ជាមួយគណៈគ្រប់គ្រង បុគ្គលិកសាមី និងភាគីពាក់ព័ន្ធ |
| ពិន្ទុ ១ | ការអនុវត្តភារកិច្ចរបស់មន្ត្រីម្នាក់ៗស្របតាមកិច្ចព្រមព្រៀងការងារ |
| ពិន្ទុ ១ | ការរៀបចំនិងការដាក់ឱ្យអនុវត្តកិច្ចព្រមព្រៀងការងារមានការពិគ្រោះយោបល់ និងការឯកភាពពីសាមីបុគ្គលិក |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ ការគ្រប់គ្រងវត្តមានបុគ្គលិកអប់រំរបស់សាលារៀន

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបចំពង្រឹងការគ្រប់គ្រងវត្តមានរបស់បុគ្គលិកអប់រំដែលកំពុងបម្រើការងារក្នុងសាលារៀន តាមមធ្យោបាយផ្សេងៗ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវមនសិការវិជ្ជាជីវៈ និងលទ្ធផលការងារនិងការសិក្សារបស់សិស្សនៅក្នុងសាលារៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)បញ្ជីសម្រង់វត្តមានរបស់បុគ្គលិកអប់រំ ២)របាយការណ៍វត្តមានប្រចាំសប្តាហ៍/ខែ ៣)ទម្រង់ការគ្រប់គ្រងវត្តមានតាមប្រព័ន្ធអេឡិចត្រូនិកដែលបោះពុម្ពចេញពីម៉ាស៊ីនកំព្យូទ័រ និង៤)របាយការណ៍នៃការអនុវត្តការលើកទឹកចិត្ត និងវិធានការវិន័យផ្អែកលើលទ្ធផលនៃការគ្រប់គ្រងវត្តមាន។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានបញ្ជីសម្រង់វត្តមានសម្រាប់បុគ្គលិកអប់រំតាមសៀវភៅ |

| | |
|---|---|
| ពិន្ទុ ១ | មានបញ្ជីសម្រង់វត្តមានសម្រាប់បុគ្គលិកអប់រំតាមប្រព័ន្ធអេឡិចត្រូនិក |
| ពិន្ទុ ១ | មានរបាយការណ៍វត្តមានប្រចាំសប្តាហ៍/ខែ |
| ពិន្ទុ ២ | មានយន្តការលើកទឹកចិត្ត និងមានវិធានការវិន័យផ្អែកលើលទ្ធផលនៃការគ្រប់គ្រងវត្តមាន |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ ការវាយតម្លៃសមិទ្ធកម្ម និងការលើកទឹកចិត្ត

- ***សេចក្តីពន្យល់៖*** សំដៅដល់ការវាយតម្លៃទៅលើការអនុវត្តនិងលទ្ធផលការងារ ធៀបទៅនឹងកិច្ចព្រមព្រៀងការងាររបស់បុគ្គលិកអប់រំម្នាក់ៗ។ ការលើកទឹកចិត្តសំដៅដល់វិធានការអនុវត្ត ដើម្បីលើកទឹកចិត្តបុគ្គលិកអប់រំម្នាក់ៗផ្អែកលើលទ្ធផលនៃការវាយតម្លៃសមិទ្ធកម្ម។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ឯកសារស្តីពីលក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃសមិទ្ធកម្ម និងបានផ្សព្វផ្សាយដល់បុគ្គលិកអប់រំ ២) ឯកសារបញ្ជាក់ពីការបង្កើតគណៈកម្មការវាយតម្លៃសមិទ្ធកម្មបុគ្គលិកអប់រំម្នាក់ៗ ៣)របាយការណ៍សមិទ្ធកម្មរបស់បុគ្គលិកអប់រំម្នាក់ៗ ៤)របាយការណ៍កិច្ចប្រជុំរបស់គណៈកម្មការវាយតម្លៃសមិទ្ធកម្មបុគ្គលិកអប់រំម្នាក់ៗ ៥)របាយការណ៍នៃការវាយតម្លៃសមិទ្ធកម្ម និងការលើកទឹកចិត្តបុគ្គលិកអប់រំនៅក្នុងសាលារៀន ៦)របាយការណ៍ ឬឯកសារដាក់ពិន័យដល់បុគ្គលិកអប់រំរបស់សាលារៀន និង៧)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានការកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃសមិទ្ធកម្ម និងបានផ្សព្វផ្សាយដល់បុគ្គលិកអប់រំ |
| ពិន្ទុ ១ | មានការបង្កើតគណៈកម្មការវាយតម្លៃសមិទ្ធកម្ម |
| ពិន្ទុ ១ | មានការវាយតម្លៃសមិទ្ធកម្មបុគ្គលិកអប់រំម្នាក់ៗ ផ្អែកលើលក្ខខណ្ឌការងារ |
| ពិន្ទុ ១ | មានការលើកទឹកចិត្ត ឬវិធានការកែលម្អផ្អែកលើលទ្ធផលនៃការវាយតម្លៃសមិទ្ធកម្ម |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ ការគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនមានការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីជួយគាំទ្រដល់ការគ្រប់គ្រងធនធានមនុស្ស។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ការពិនិត្យមើលដោយផ្ទាល់លើកម្មវិធីគ្រប់គ្រងធនធានមនុស្សតាមបច្ចេកវិទ្យាព័ត៌មាន ២)ទិន្នន័យមន្ត្រីរាជការអាចបោះពុម្ពចេញពីប្រព័ន្ធព័ត៌មានវិទ្យា និង៣)សម្ភាសជាមួយមន្ត្រីគ្រប់គ្រងបុគ្គលិកអំពីការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងការគ្រប់គ្រងបុគ្គលិក។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានកំព្យូទ័រដែលប្រើប្រាស់ជាប្រចាំនៅក្នុងទីចាត់ការ |
| ពិន្ទុ ១ | មានមន្ត្រីទទួលបន្ទុកគ្រប់គ្រងបុគ្គលិកក្នុងទម្រង់បច្ចេកវិទ្យាព័ត៌មាន |
| ពិន្ទុ ១ | មានការរៀបចំទិន្នន័យនៃការគ្រប់គ្រងបុគ្គលិកក្នុងទម្រង់បច្ចេកវិទ្យាព័ត៌មាន |
| ពិន្ទុ ១ | មានការប្រើប្រាស់ទិន្នន័យក្នុងទម្រង់បច្ចេកវិទ្យាព័ត៌មាន ជាមូលដ្ឋានសម្រាប់គ្រប់គ្រងបុគ្គលិកនៅក្នុងសាលារៀន |
| ពិន្ទុ ១ | បានធ្វើបច្ចុប្បន្នភាពជាប្រចាំ(យ៉ាងតិច១ឆ្នាំម្តង) |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ការរៀបចំទិន្នន័យនៃការគ្រប់គ្រងបុគ្គលិកក្នុងទម្រង់បច្ចេកវិទ្យាព័ត៌មាន មានសមាសធាតុសំខាន់ដូចជា៖ ព័ត៌មានផ្ទាល់ខ្លួន ប្រវត្តិការងារ ប្រវត្តិនៃការបណ្តុះបណ្តាល ប្រវត្តិស្នាដៃការងារ។

## ➢ ការគ្រប់គ្រង និងការដោះស្រាយវិវាទក្នុងសាលារៀន

- ***សេចក្តីពន្យល់៖*** សំដៅដល់ការរៀបចំគោលការណ៍ នីតិវិធី និងការអនុវត្តការដោះស្រាយវិវាទនៅក្នុងសាលារៀនដើម្បីកាត់បន្ថយទំនាស់ រក្សាបានសាមគ្គីភាពផ្ទៃក្នុង និងបង្កើនប្រសិទ្ធភាពការងាររបស់សាលារៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)សេចក្តីសម្រេចឬលិខិតបង្គាប់ការស្តីពីការបង្កើតក្រុមប្រឹក្សាវិន័យនៅពេលដែលមានវិវាទកើតឡើង ២)របាយការណ៍ដោះស្រាយវិវាទ និង ៣)សម្ភាសជាមួយអ្នកគ្រប់គ្រង និងមន្ត្រីពាក់ព័ន្ធនៅក្នុងសាលារៀនអំពីការដោះស្រាយវិវាទក្នុងអង្គភាព។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានសមាជិកគណៈគ្រប់គ្រងសាលារៀនទទួលបានការបណ្តុះបណ្តាល ឬមានចំណេះដឹងផ្នែកការគ្រប់គ្រងវិវាទក្នុងស្ថាប័ន |
| ពិន្ទុ ១ | មានការបង្កើតក្រុមប្រឹក្សាវិន័យនៅពេលមានវិវាទកើតឡើង |
| ពិន្ទុ ១ | មានកិច្ចប្រជុំពង្រឹងសាមគ្គីភាពជាទៀងទាត់ ដើម្បីទប់ស្កាត់និងដោះស្រាយទំនាស់ |
| ពិន្ទុ ២ | មិនដែលមានវិវាទក្នុងសាលារៀនក្នុងរយៈពេលពីរឆ្នាំចុងក្រោយ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## ៤.២ ការអភិវឌ្ឍធនធានមនុស្ស (៣០ពិន្ទុ)

### ៤.២.១ ការរៀបចំផែនការអភិវឌ្ឍធនធានមនុស្ស (៥ពិន្ទុ)

➢ មានផែនការអភិវឌ្ឍធនធានមនុស្ស (ផែនការបណ្តុះបណ្តាលមន្ត្រីរបស់សាលារៀន)

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបចំឱ្យមានផែនការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ និងបង្កលក្ខណៈងាយស្រួលដល់បុគ្គលិកអប់រំក្នុងការចូលរួមអភិវឌ្ឍសមត្ថភាពជំនាញគ្រប់គ្រងដឹកនាំ និងជំនាញវិជ្ជាជីវៈ/ឯកទេស ដើម្បីបង្កើនប្រសិទ្ធភាពការងារឆ្លើយតបទៅនឹងតម្រូវការរបស់សាលារៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ផែនការអភិវឌ្ឍសមត្ថភាព ២)របាយការណ៍ប្រជុំពិគ្រោះយោបល់ និងអនុម័តផែនការអភិវឌ្ឍធនធានមនុស្ស និង៣)របាយការណ៍ស្តីពីកម្មវិធីអភិវឌ្ឍសមត្ថភាព។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានផែនការអភិវឌ្ឍធនធានមនុស្ស |
| ពិន្ទុ ១ | មានការសិក្សាអំពីតម្រូវការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីក្នុងសាលារៀនពីគ្រប់ផ្នែកបច្ចេកទេស |
| ពិន្ទុ ១ | មានការចូលរួមនិងពិគ្រោះយោបល់ជាមួយបុគ្គលិក និងភាគីពាក់ព័ន្ធក្នុងគ្រប់ដំណាក់កាលនៃការរៀបចំផែនការអភិវឌ្ឍធនធានមនុស្ស |
| ពិន្ទុ២ | គណៈគ្រប់គ្រង និងបុគ្គលិកបានចូលរួមអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

### ៤.២.២ ការអភិវឌ្ឍ និងការប្រើធនធានមនុស្សដែលទទួលបានការបណ្តុះបណ្តាល (២៥ពិន្ទុ)

➢ ការគាំទ្រនិងលើកទឹកចិត្តមន្ត្រីឱ្យទទួលបានការបណ្តុះបណ្តាល

- ***សេចក្តីពន្យល់៖*** សំដៅដល់ការខិតខំប្រឹងប្រែងរបស់គណៈគ្រប់គ្រងក្នុងការស្វែងរកមធ្យោបាយ និងកៀរគរធនធាន ដើម្បីផ្តល់ឱកាស លើកទឹកចិត្ត និងគាំទ្រដល់បុគ្គលិកអប់រំរបស់សាលារៀនឱ្យទទួលបានការបណ្តុះបណ្តាល។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការបណ្តុះបណ្តាល ២)ធនធាន(ថវិកា សម្ភារៈ ការផ្តល់ពេលវេលា ទំនាក់ទំនងជាមួយស្ថាប័នដទៃ) គាំទ្រដល់ការបណ្តុះបណ្តាល ៣)របាយការណ៍ស្តីពីការបណ្តុះបណ្តាលទាំងក្នុង និងក្រៅសាលារៀន និង៤)សម្ភាសជាមួយអ្នកគ្រប់គ្រង ឬមន្ត្រីអំពីការគាំទ្រនិងលើកទឹកចិត្តដើម្បីទទួលបានការបណ្តុះបណ្តាល។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | បុគ្គលិកក្នុងសាលារៀនបានចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗទាំងក្នុង និងក្រៅសាលារៀន |
| ពិន្ទុ ២ | បានផ្តល់ឱកាស និងការគាំទ្រដល់បុគ្គលិកអប់រំឱ្យទទួលបានការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាព |
| ពិន្ទុ ២ | មានការស្វែងរកនិងផ្សព្វផ្សាយអាហារូបករណ៍ ឬការកៀរគរធនធានពីដៃគូដើម្បីគាំទ្រដល់ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាព |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## ➢ ការប្រើប្រាស់វិធីសាស្ត្រផ្សេងៗដើម្បីផ្តល់ការបណ្តុះបណ្តាល

- ***សេចក្តីពន្យល់៖*** សំដៅដល់ការរៀបចំ និងអនុវត្តការបណ្តុះបណ្តាលក្នុងទម្រង់ផ្សេងៗដើម្បីផ្តល់ឱកាសឱ្យបុគ្គលិកអប់រំក្នុងសាលារៀនទទួលបានការបណ្តុះបណ្តាលអភិវឌ្ឍសមត្ថភាព។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)របាយការណ៍នៃការបណ្តុះបណ្តាលមន្ត្រីក្នុងសាលារៀន ២)របាយការណ៍នៃការបញ្ជូនមន្ត្រីនិងចំនួនមន្ត្រីទទួលបានការបណ្តុះបណ្តាលនៅក្រៅសាលារៀន ៣)របាយការណ៍នៃការធ្វើទស្សនកិច្ចសិក្សា ៤)កម្រងរូបភាព ឬវីដេអូបញ្ជាក់ពីការបណ្តុះបណ្តាលរបស់សាលារៀន(ការបណ្តុះបណ្តាលក្នុងទម្រង់ផ្សេងៗ និងការធ្វើទស្សនកិច្ចសិក្សា) និង៥)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានការរៀបចំនិងបញ្ជូនមន្ត្រីទៅទទួលការបណ្តុះបណ្តាលនៅក្រៅស្ថាប័ន |
| ពិន្ទុ ១ | មានការបង្វឹកដោយផ្ទាល់ |
| ពិន្ទុ ២ | មានការចែករំលែកចំណេះដឹងនិងបទពិសោធពីបុគ្គលិកអប់រំទាំងក្នុងទាំងក្រៅស្ថាប័ន |
| ពិន្ទុ ១ | មានការរៀបចំទស្សនកិច្ចសិក្សាក្នុង និងក្រៅប្រទេស |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## ➢ មានកម្មវិធីណែនាំគ្រូបង្រៀនដែលទើបចេញមកបង្រៀនថ្មី ឬផ្ទេរចូល

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនមានការរៀបចំកម្មវិធី និងចាត់តាំងគ្រូបង្គោលសម្រាប់ណែនាំដល់គ្រូបង្រៀនដែលទើបចេញមកបង្រៀនថ្មី ឬផ្ទេរចូលទៅលើវប្បធម៌ការងាររបស់សាលា វិធីសាស្ត្របង្រៀន ខ្លឹមសារមេរៀនបង្រៀន ការរៀបចំផែនការបង្រៀននិងរៀន និងការអនុវត្តការងារនៅសាលារៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)កម្មវិធី/ផែនការណែនាំគ្រូបង្រៀនដែលទើបចេញថ្មី ២)លិខិតបង្គាប់ការចាត់តាំងគ្រូបង្គោល ៣)របាយការណ៍ណែនាំគ្រូបង្រៀនចេញថ្មី ឬផ្ទេរចូល និង ៤)ការសម្ភាសជាមួយនឹងគ្រូបង្រៀនទើបចេញថ្មី។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥(គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | ការរៀបចំកម្មវិធីណែនាំ ឬតម្រង់ទិសដល់លោកគ្រូ អ្នកគ្រូក្របខណ្ឌថ្មី ឬផ្ទេរចូល |
| ពិន្ទុ ១ | លិខិតបង្គាប់ការចាត់តាំងគ្រូបង្គោល |
| ពិន្ទុ ១ | ការអនុញ្ញាតឱ្យលោកគ្រូ អ្នកគ្រូក្របខណ្ឌថ្មី ឬផ្ទេរចូលបញ្ចេញសមត្ថភាពតាមជំនាញ |
| ពិន្ទុ ១ | របាយការណ៍ណែនាំគ្រូបង្រៀនចេញថ្មី ឬផ្ទេរចូល |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

### ➢ ការវាយតម្លៃលទ្ធផលទទួលបានពីការបណ្តុះបណ្តាល

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនមានការសិក្សា និងវាយតម្លៃលទ្ធផលទទួលបានពីការបណ្តុះបណ្តាល និងការបញ្ជូនមន្ត្រីទៅទទួលបានការបណ្តុះបណ្តាល និងបានប្រើប្រាស់លទ្ធផលនៃការវាយតម្លៃទាំងនោះសម្រាប់ការរៀបចំនិងកែលម្អផែនការ និងការអនុវត្តការបណ្តុះបណ្តាល។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)របាយការណ៍ស្តីពីការវាយតម្លៃលទ្ធផលនៃការបណ្តុះបណ្តាល និង២)ការសម្ភាសជាមួយអ្នកគ្រប់គ្រង និងមន្ត្រីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ៣ | មានការសិក្សាវាយតម្លៃពីលទ្ធផលទទួលបានពីការបណ្តុះបណ្តាល |
| ពិន្ទុ ១ | បានប្រើប្រាស់លទ្ធផលនៃការវាយតម្លៃលទ្ធផលទទួលបានពីការបណ្តុះបណ្តាល សម្រាប់រៀបចំនិងកែលម្អផែនការបណ្តុះបណ្តាល |
| ពិន្ទុ ១ | បានប្រើប្រាស់លទ្ធផលនៃការវាយតម្លៃលទ្ធផលទទួលបានពីការបណ្តុះបណ្តាល សម្រាប់កែលម្អវិធីសាស្ត្រនៃការបណ្តុះបណ្តាល |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

### ➢ ការអភិវឌ្ឍសមត្ថភាពភាពជាអ្នកដឹកនាំ និងអ្នកបន្តវេន

- ***សេចក្តីពន្យល់៖*** ការអភិវឌ្ឍសមត្ថភាពភាពជាអ្នកដឹកនាំសំដៅដល់ការពង្រឹង និងការលើកកម្ពស់សមត្ថភាពភាពជាអ្នកដឹកនាំនិងគ្រប់គ្រងក្នុងការបំពេញការងាររបស់គណៈគ្រប់គ្រង និងបុគ្គលិកអប់រំនៅក្នុងសាលារៀន។ ការអភិវឌ្ឍសមត្ថភាពអ្នកបន្តវេន សំដៅដល់សាលាបានគិតគូរបណ្តុះបណ្តាល និងតម្រង់ទិសដល់បុគ្គលិកអប់រំក្នុងសាលាដែលមានសក្តានុពល ដើម្បីត្រៀមកាន់មុខតំណែងក្នុងរចនាសម្ព័ន្ធរបស់សាលារៀននាពេលខាងមុខ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)របាយការណ៍ស្តីពីការបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ ២)របាយការណ៍ស្តីពីលទ្ធផលកម្មវិធីចែករំលែកចំណេះដឹងអំពីភាពជាអ្នកដឹកនាំ និង៣)ការសម្ភាសជាមួយគណៈគ្រប់គ្រង និងមន្ត្រីពាក់ព័ន្ធ។

- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ១ | គណៈគ្រប់គ្រងបានចូលរួមវគ្គបណ្តុះបណ្តាលសមត្ថភាពភាពជាអ្នកដឹកនាំនិងគ្រប់គ្រង |
| ពិន្ទុ ១ | មន្ត្រីបានចូលរួមវគ្គបណ្តុះបណ្តាលសមត្ថភាពភាពជាអ្នកដឹកនាំនិងគ្រប់គ្រង |
| ពិន្ទុ ១ | មានការចែករំលែកចំណេះដឹងអំពីភាពជាអ្នកដឹកនាំនិងគ្រប់គ្រងដល់មន្ត្រីក្នុងសាលារៀន |
| ពិន្ទុ ១ | មានការបែងចែកតួនាទីភារកិច្ចនិងការទទួលខុសត្រូវ និងផ្តល់សិទ្ធិក្នុងការសម្រេចចិត្តដល់បុគ្គលិកអប់រំលើកិច្ចការនានាសមស្របទៅនឹងស្ថានភាពរបស់សាលារៀន |
| ពិន្ទុ ១ | មានរៀបចំផែនការអភិវឌ្ឍសមត្ថភាពដល់អ្នកបន្តវេន |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

# ផ្នែកទី៥៖ ការរៀបចំ និងកែលម្អបរិស្ថានអង្គភាព

## ៥. ការរៀបចំ និងកែលម្អបរិស្ថានអង្គភាព (១២០ពិន្ទុ)

ការរៀបចំនិងកែលម្អបរិស្ថានអង្គភាពសំដៅដល់ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ការបញ្ជ្រាបការយល់ដឹង និងសកម្មភាពបរិស្ថាន ដើម្បីប្រែក្លាយសាលារៀន និងសហគមន៍ជាមេត្រីបរិស្ថានរបស់សិស្សនិងសហគមន៍។

ការកំណត់ឱ្យមានលក្ខណៈវិនិច្ឆ័យគោលមួយនេះសម្រាប់ការវាយតម្លៃសាលារៀនគំរូ គឺក្នុងគោលបំណងជំរុញឱ្យសាលារៀនបញ្ជ្រាបការយល់ដឹងពីបរិស្ថាន ការប្រែប្រួលអាកាសធាតុ រៀបចំផែនការអភិវឌ្ឍបរិស្ថាន និងសកម្មភាពកិច្ចគាំពារបរិស្ថាន ចូលរួមអនុវត្តគោលការណ៍ ៤R (ការបដិសេធ ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ) (៤R: Reject, Reduce, Reuse, Recycle) រៀបចំសណ្តាប់ធ្នាប់ អនាម័យឱ្យមានភាពស្អាតនៅក្នុងសាលារៀន ទីធ្លា សួនច្បារ បន្លែ ដីរៈចម្រុះនិងដើមឈើឬដាំដើមឈើបន្ថែមមានភាពបៃតងស្រស់ មានបង្គន់ប្រកបដោយភាពស្អាត អនាម័យនិងសមាមាត្រទៅនឹងចំនួនសិស្សនិងលោកគ្រូ អ្នកគ្រូ មានការគ្រប់គ្រងនិងសម្អាតសំណល់រឹងជាពិសេសប្លាស្ទិកឱ្យបានត្រឹមត្រូវ មានប្រព័ន្ធគ្រប់គ្រងសំណល់រាវ ប្រព័ន្ធលូទឹកសំអុយ ប្រព័ន្ធរំដោះទឹកភ្លៀងព្រមទាំងមានការត្រួតពិនិត្យនិងថែទាំជាប្រចាំ។ ការលក់ដូរចំណីអាហារណាដែលមិនប៉ះពាល់ដល់សុខភាពសិស្សនិងមានការត្រួតពិនិត្យជាប្រចាំ។

នៅក្នុងផ្នែកនៃការរៀបចំនិងកែលម្អបរិស្ថានអង្គភាព មានពិន្ទុសរុបចំនួន១២០ ដែលមានលក្ខណៈវិនិច្ឆ័យរងចំនួន៤ គឺ ៖

១. ការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន ភាពស្អាត ភាពបៃតង និងសុខភាពអនាម័យ (១៥ពិន្ទុ)

២. ការអនុវត្តដើម្បីសោភណភាពក្នុងបរិវេណសាលារៀន (៥០ពិន្ទុ)

៣. ទីតាំងលេងកំសាន្ត និងគ្រប់គ្រងកាកសំណល់ (៣៥ពិន្ទុ)

៤. ការប្រើប្រាស់ទឹកស្អាត និងអនាម័យចំណីអាហារដែលលក់ដូរក្នុងបរិវេណសាលារៀន (២០ពិន្ទុ)

## ៥.១ ការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន ភាពស្អាត សុខភាពនិងអនាម័យ (១៥ពិន្ទុ)

### ៥.១.១ ការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន និងភាពស្អាត (១៥ពិន្ទុ)

➢ បានបញ្ចូលផែនការបរិស្ថានទៅក្នុងផែនការអភិវឌ្ឍសាលារៀន/កែលម្អសាលារៀន/ផែនការប្រតិបត្តិប្រចាំឆ្នាំ

- ***សេចក្តីពន្យល់៖*** សំដៅដល់ការបញ្ចូលបញ្ជ្រាបការយល់ដឹងពីបរិស្ថាន និងសកម្មភាពកែលម្អបរិស្ថាន មានដូចជា ការសម្អាតអនាម័យទីធ្លា ការពិនិត្យសុខភាព ការចូលរួមយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ការចូលរួមទិវាបរិស្ថានជាតិនិងអន្តរជាតិ ការបង្កើតគណៈកម្មការគ្រប់គ្រងបរិស្ថាន/ក្រុមយុវជន/ក្រុមកុមារបរិស្ថានទៅក្នុងផែនការអភិវឌ្ឍសាលារៀន/ផែនការកែលម្អសាលារៀន និងមានផែនការប្រតិបត្តិប្រចាំឆ្នាំ និងមានអ្នកទទួលខុសត្រូវនិងថវិកា។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ផែនការអភិវឌ្ឍសាលារៀន/ផែនការកែលម្អសាលារៀន ២)ផែនការមានការកំណត់អំពីអ្នកទទួលខុសត្រូវអនុវត្តនិងប្រភពធនធានសម្រាប់គាំទ្រ ៣)ផែនការកែលម្អបរិស្ថានសាលារៀនប្រចាំខែ/ប្រចាំត្រីមាស/ប្រចាំឆមាស/ប្រចាំឆ្នាំរបស់គណៈកម្មការគ្រប់គ្រង/ក្រុមយុវជន/ក្រុមកុមារបរិស្ថាន ៤)ទិន្នន័យឯកសារបញ្ជាក់ពីការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក និង៥)ការលើកទឹកចិត្តដូចជាតារាងកិត្តិយស/លិខិតសរសើរក្រុម/ថ្នាក់/សិស្សដែលទទួលបានជ័យលាភីក្នុងការកែលម្អបរិស្ថាន(តារាងផែនការសកម្មភាពប្រចាំឆ្នាំ)។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | បានបញ្ចូលផែនការកែលម្អបរិស្ថាន ភាពស្អាត សុខភាពនិងអនាម័យ ទៅក្នុងផែនការអភិវឌ្ឍសាលារៀន/កែលម្អសាលារៀន |
| ពិន្ទុ ១ | ផែនការកែលម្អបរិស្ថានមានការកំណត់អំពីសកម្មភាពអាទិភាព (ការសម្អាតអនាម័យទីធ្លា ការចូលរួមយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ការចូលរួមទិវាបរិស្ថានជាតិនិងអន្តរជាតិ គោលការណ៍៤R ការប្រែប្រួលអាកាសធាតុ ការពិនិត្យសុខភាព ការបង្កើតក្រុមយុវជន/កុមារបរិស្ថានទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំនីមួយៗ |
| ពិន្ទុ ១ | ផែនការកែលម្អបរិស្ថានមានការកំណត់អំពីអ្នកទទួលខុសត្រូវអនុវត្ត |
| ពិន្ទុ ១ | ផែនការកែលម្អបរិស្ថានមានការកំណត់អំពីប្រភពធនធានសម្រាប់គាំទ្រការអនុវត្ត |
| ពិន្ទុ ០ | គ្មានផែនការកែលម្អបរិស្ថាននៅក្នុងផែនការអភិវឌ្ឍសាលារៀន |

➢ មានការបញ្ជ្រាបការយល់ដឹងពីបរិស្ថានរួមទាំងគោលការណ៍៤R (ការបដិសេធ ការកាត់បន្ថយ ការ ប្រើប្រាស់ឡើងវិញ និងការកែច្នៃឡើងវិញ) និងការប្រែប្រួលអាកាសធាតុ ដល់បុគ្គលិកអប់រំ និងសិស្សានុសិស្ស

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានអនុវត្តសកម្មភាពបញ្ជ្រាបការយល់ដឹងពីបរិស្ថាន មានដូចជាគោលការណ៍៤Rសម្រាប់ការគ្រប់គ្រងកាកសំណល់រឹង(ការបដិសេធ ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ) ៤R:(Reject, Reduce, Reuse, Recycle)និងការកាត់

បន្ថយការប្រើប្រាស់ប្លាស្ទិក ផលប៉ះពាល់ពីសំរាមប្លាស្ទិក ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុជាប្រចាំដល់បុគ្គលិកអប់រំក្នុងកិច្ចប្រជុំប្រចាំខែនិងសិស្សានុសិស្សនៅរៀងរាល់ពេលគោរពទង់ជាតិ នៅតាមថ្នាក់រៀន ការផ្សព្វផ្សាយខិត្តប័ណ្ណឬពាក្យស្លោកពាក់ព័ន្ធបរិស្ថានក្នុងបរិវេណសាលា ក្នុងថ្នាក់រៀន រូបភាពពីផលប៉ះពាល់ពីសំរាមប្លាស្ទិក និងការប្រែប្រួលអាកាសធាតុ ការប្រឡងប្រណាំងការតែងកំណាព្យនិងគូរគំនូរស្តីពីបរិស្ថានជាដើម។

- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ផែនការ/កម្មវិធីពីការបញ្ជ្រាបការយល់ដឹងអំពីបរិស្ថានដូចជាផលប៉ះពាល់ពីសំរាមប្លាស្ទិកនិងការប្រែប្រួលអាកាសធាតុ និងគោលការណ៍4R សម្រាប់ការគ្រប់គ្រងកាកសំណល់រឹង ២)របាយការណ៍/រូបភាពស្តីពីការអនុវត្តសកម្មភាពបញ្ជ្រាបការយល់ដឹងពីបរិស្ថាន ដូចជាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ៣)ការផ្សព្វផ្សាយខិត្តប័ណ្ណឬពាក្យស្លោកពាក់ព័ន្ធបរិស្ថានដូចជាផលប៉ះពាល់ពីសំរាមប្លាស្ទិក និងការប្រែប្រួលអាកាសធាតុ ៤)កម្មវិធីប្រឡងប្រណាំង/ជជែកពិភាក្សាអំពីបរិស្ថាន ការតែងកំណាព្យនិងគូរគំនូរ ៥)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ និង៦)រូបភាពពីការអប់រំផ្សព្វផ្សាយបរិស្ថាន។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | កម្មវិធីប្រឡងប្រណាំង/ជជែកពិភាក្សាអំពីបរិស្ថានប្រចាំខែ/ប្រចាំឆមាស/ប្រចាំឆ្នាំ (ការតែងកំណាព្យ ការគូរគំនូរ ការគ្រប់គ្រង និងកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ផលប៉ះពាល់ពីសំរាមប្លាស្ទិក និងការប្រែប្រួលអាកាសធាតុ) |
| ពិន្ទុ ១ | មានការបញ្ជ្រាបការយល់ដឹងពីបរិស្ថានដល់បុគ្គលិកអប់រំក្នុងកិច្ចប្រជុំប្រចាំខែនិងសិស្សរៀងរាល់ពេលគោរពទង់ជាតិ និងនៅតាមថ្នាក់រៀន |
| ពិន្ទុ ១ | មានការបញ្ជ្រាបការយល់ដឹងពីបរិស្ថានដល់គណៈកម្មការគ្រប់គ្រងបរិស្ថាន ក្រុមប្រឹក្សាកុមារ/ក្រុមបរិស្ថាន និងអាណាព្យាបាលសិស្សរៀងរាល់កិច្ចប្រជុំប្រចាំខែ |
| ពិន្ទុ ១ | មានការផ្សព្វផ្សាយខិត្តប័ណ្ណ/រូបភាពឬពាក្យស្លោកពាក់ព័ន្ធបរិស្ថានក្នុងទីធ្លាសាលានិងតាមថ្នាក់រៀន |
| ពិន្ទុ ០ | មិនមានការបញ្ជ្រាបការយល់ដឹងពីបរិស្ថានដល់សិស្សានុសិស្ស |

➢ <u>មានការបញ្ជ្រាបការយល់ដឹងអំពីការអប់រំសុខភាព អនាម័យ ដល់បុគ្គលិកអប់រំនិងសិស្សានុសិស្ស</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានអនុវត្តសកម្មភាពបញ្ជ្រាបការយល់ដឹងពីកម្មវិធីការអប់រំសុខភាពអនាម័យដល់បុគ្គលិកអប់រំនិងសិស្សានុសិស្សមានដូចជា ការគិតគូរអំពីសុខភាពរបស់សិស្សនិងបុគ្គលិកអប់រំ និងការថែរក្សាអនាម័យក្នុងបរិវេណសាលារៀន បន្ទប់រៀន បន្ទប់ទឹក ដោយមានកម្មវិធីការអប់រំអនាម័យនិង កម្មវិធីត្រួតពិនិត្យសុខភាព និងគុណភាពចំណីអាហារដោយសហការជាមួយមណ្ឌលសុខភាពនិងអង្គភាពជំនាញ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១) ផែនការអភិវឌ្ឍ/គេលម្អសាលារៀន

ដែលមានការបញ្ជ្រាបការយល់ដឹងអំពីសុខភាព អនាម័យ ២)កាលវិភាគបែងចែកវេនសម្រាប់ការអប់រំសុខភាព អនាម័យដល់បុគ្គលិកអប់រំនិងសិស្ស ៣)របាយការណ៍ស្តីពីការអនុវត្តសកម្មភាពបញ្ជ្រាបការយល់ដឹងពីការអប់រំសុខភាព អនាម័យ ៤)លិខិត/កិច្ចព្រមព្រៀងសហការរវាងសាលារៀននិងមណ្ឌលសុខភាព/អង្គភាពជំនាញ ៥)សៀវភៅតាមដានសុខភាពរបស់បុគ្គលិកអប់រំនិងសិស្ស និង៦)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានកាលវិភាគ/កម្មវិធីសម្រាប់ការអប់រំ/ត្រួតពិនិត្យសុខភាពអនាម័យដល់បុគ្គលិកអប់រំ និងសិស្ស ដោយសហការជាមួយស្ថាប័នជំនាញ |
| ពិន្ទុ ១ | មានលិខិត/កិច្ចព្រមព្រៀងសហការរវាងសាលារៀននិងមណ្ឌលសុខភាព/អង្គភាពជំនាញ និងរបាយការណ៍/រូបភាពស្តីពីការអនុវត្តសកម្មភាពបញ្ជ្រាបការយល់ដឹងពីការអប់រំសុខភាព អនាម័យ |
| ពិន្ទុ ១ | មានការបញ្ជ្រាបការយល់ដឹងពីការអប់រំ/ពិនិត្យសុខភាព អនាម័យដល់បុគ្គលិកអប់រំក្នុងកិច្ចប្រជុំប្រចាំខែ/ត្រីមាស/ឆមាសនិងសិស្សរៀងរាល់ពេលគោរពទង់ជាតិនិងតាមថ្នាក់រៀន |
| ពិន្ទុ ១ | មានសៀវភៅត្រួតពិនិត្យនិងតាមដានសុខភាពរបស់បុគ្គលិកអប់រំនិងសិស្ស |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## ៥.២ ការអនុវត្តដើម្បីសោភណភាពក្នុងបរិវេណសាលារៀន (៥០ពិន្ទុ)

### ៥.២.១ ការអនុវត្តដើម្បីភាពស្អាត និងភាពបៃតងក្នុងបរិវេណសាលារៀន (៥០ពិន្ទុ)

➢ មានរចនាសម្ព័ន្ធដឹកនាំគ្រប់គ្រងភាពស្អាត បៃតង អនាម័យ និងគុណភាពចំណីអាហារនៅក្នុងសាលារៀន

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានបង្កើត និងដំណើរការរៀបចំរចនាសម្ព័ន្ធដឹកនាំគ្រប់គ្រងបរិស្ថាននិងត្រួតពិនិត្យចំណីអាហារក្នុងសាលារៀនដើម្បីឱ្យមានភាពស្អាត បៃតង អនាម័យនិងគុណភាពចំណីអាហារត្រឹមត្រូវមានដូចជា ការបង្កើតគណៈកម្មការគ្រប់គ្រងបរិស្ថាន/ក្រុមយុវជន/ក្រុមកុមារបរិស្ថាន ក្រុមបរិស្ថានតាមថ្នាក់រៀន គណៈកម្មការត្រួតពិនិត្យចំណីអាហារ និងបរិស្ថានសាលារៀនដើម្បីដឹកនាំគ្រប់គ្រង និងត្រួតពិនិត្យភាពស្អាត បៃតង គុណភាពនិងអនាម័យចំណីអាហារ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)មានរចនាសម្ព័ន្ធដឹកនាំគ្រប់គ្រង បរិស្ថាននិងត្រួតពិនិត្យចំណីអាហារដោយមានទំនួលខុសត្រូវ ២)មានគណៈកម្មការគ្រប់គ្រងនិងកែលម្អបរិស្ថាន ៣)មានក្រុមយុវជន/ក្រុមកុមារបរិស្ថាន/ក្រុមកុមារបរិស្ថានតាមថ្នាក់រៀន ៤)មានកាលវិភាគប្រជុំប្រចាំខែ/ប្រចាំត្រីមាស/ប្រចាំឆមាស/ប្រចាំឆ្នាំរបស់គណៈកម្មការគ្រប់គ្រង/ក្រុមយុវជន/ក្រុមកុមារបរិស្ថាន ៥)របាយការណ៍/រូបភាពសកម្មភាពកិច្ចប្រជុំនីមួយៗ និង៦)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានរចនាសម្ព័ន្ធដឹកនាំគ្រប់គ្រង បរិស្ថាននិងត្រួតពិនិត្យចំណីអាហារដោយមានអ្នកទំនួលខុសត្រូវសម្រាប់ការអនុវត្តដូចជាគណៈកម្មការគ្រប់គ្រង កែលម្អ និងត្រួតពិនិត្យបរិស្ថាន |
| ពិន្ទុ ១ | មានការបង្កើតក្រុមយុវជន/ក្រុមកុមារបរិស្ថាន/ក្រុមកុមារបរិស្ថានតាមថ្នាក់រៀនមានអ្នកទំនួលខុសត្រូវសម្រាប់ការអនុវត្ត |
| ពិន្ទុ ១ | មានកាលវិភាគប្រជុំប្រចាំខែ/ប្រចាំត្រីមាស/ប្រចាំឆមាស/ប្រចាំឆ្នាំរបស់គណៈកម្មការគ្រប់គ្រង/ក្រុមយុវជន/ក្រុមកុមារបរិស្ថាន |
| ពិន្ទុ ១ | មានរបាយការណ៍/រូបភាពសកម្មភាពកិច្ចប្រជុំនីមួយៗ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ <u>មានកាលវិភាគនិងអនុវត្តការសម្អាតបរិវេណសាលារៀនជាប្រចាំ</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានបង្កើត និងដំណើរការរៀបចំយន្តការសម្អាតបរិស្ថាននិងត្រួតពិនិត្យភាពស្អាត បៃតង អនាម័យក្នុងសាលារៀន ដើម្បីឱ្យមានបរិស្ថានស្អាត និងសោភណភាពនៃភាពស្អាត បៃតង និងអនាម័យ(គ្មានភាពកខ្វក់ ភក់ជ្រាំ គ្មានក្លិនស្អុយ) មានការទុកដាក់សំរាមឱ្យបានត្រឹមត្រូវស្អាតល្អ(សំរាមប្លាស្ទិក)ក្នុងបរិវេណសាលារៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)តារាង/កាលវិភាគបែងចែកវេនសម្អាតក្នុងបរិវេណសាលារៀន ២)តារាង/កាលវិភាគបែងចែកវេនត្រួតពិនិត្យភាពស្អាតក្នុងបរិវេណសាលារៀនរបស់គណៈកម្មការគ្រប់គ្រងបរិស្ថាន/ក្រុមបរិស្ថាន ៣)តារាង/កាលវិភាគបែងចែកវេនសម្អាតរបស់ក្រុមបរិស្ថានតាមថ្នាក់រៀន ៤)ទីធ្លាសាលារៀនគ្មានភាពកខ្វក់ ភក់ជ្រាំ គ្មានក្លិនស្អុយ មានការទុកដាក់សំរាមឱ្យបានត្រឹមត្រូវស្អាតល្អ(សំរាមប្លាស្ទិក) ៥)របាយការណ៍/រូបភាពសកម្មភាពចូលរួមការសម្អាតបរិស្ថានក្នុងសាលារៀន និង៦)ការសម្អាសជាមួយភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានតារាង/កាលវិភាគបែងចែកវេនត្រួតពិនិត្យភាពស្អាតក្នុងថ្នាក់រៀននិងបរិវេណសាលារៀនរបស់គណៈកម្មការគ្រប់គ្រងបរិស្ថាន/ក្រុមបរិស្ថាន |
| ពិន្ទុ ១ | មានប្លង់/តារាង/កាលវិភាគបែងចែកវេនសម្អាតក្នុងបរិវេណសាលារៀនដោយមានក្រុមនីមួយៗទទួលខុសត្រូវ |
| ពិន្ទុ ១ | តារាង/កាលវិភាគបែងចែកវេនសម្អាតតាមថ្នាក់រៀន |
| ពិន្ទុ ១ | ទីធ្លាសាលារៀនគ្មានភាពកខ្វក់ ភក់ជ្រាំ គ្មានក្លិនស្អុយ និងមានរបាយការណ៍/រូបភាពសកម្មភាពចូលរួមការសម្អាតបរិស្ថានក្នុងសាលារៀន |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ទីធ្លាសាលារៀនមានសណ្តាប់ធ្នាប់ល្អ និងគ្មានសំរាមគ្រប់ប្រភេទ

  - ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនមានការរៀបចំហេដ្ឋារចនាសម្ព័ន្ធទីធ្លាសាលារៀនប្រកបដោយរចនាបទ(រូប និងសណ្តាប់ធ្នាប់ល្អ មានដូចជាផ្លូវចូល សួនច្បារ ដើមឈើដាំជាជួរ ដាំដើមឈើជារបងរស់តាមរបងសាលារៀន ទីចំណត កន្លែងលក់ចំណី។ល។ និងមានប្លង់គោល/គំនូសព្រួញបង្ហាញទិសដៅ(អគារសិក្សា សាលប្រជុំ ទីចំណត ទីចាត់ការ កន្លែងផ្តល់សេវា/ព័ត៌មាន បន្ទប់អនាម័យ) ឈ្មោះអគារសិក្សានីមួយៗ និងក្នុងបរិវេណសាលារៀនមានបំពាក់ដោយពាក្យស្លោកសុភាសិតដើម្បីអប់រំសិស្ស ក្តារខៀនផ្តល់ព័ត៌មាន មានភ្លើងបំភ្លឺទីធ្លា(អំពូលសូឡា) និងគ្មានសំរាមនិងមានការទុកដាក់សំរាមឱ្យបានត្រឹមត្រូវស្អាតល្អ(សំរាមប្លាស្ទិក)។
  - ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ប្លង់គោលរបស់សាលារៀនបង្ហាញពីទីតាំងអគារ ២)ការអង្កេតរចនាបទ និងសណ្តាប់ធ្នាប់ហេដ្ឋារចនាសម្ព័ន្ធទីធ្លាសាលារៀនរួមមានពាក្យស្លោក ផ្ទាំងរូបភាព រូបចម្លាក់មនុស្សល្បីៗ ៣)ផ្លូវចូល សួនច្បារ សួនជីវៈចម្រុះមានភាពបៃតងជាប្រចាំ ដើមឈើដាំជាជួរ ដាំដើមឈើជារបងរស់តាមរបងសាលារៀន ទីចំណត កន្លែងលក់ចំណី។ល។ និងមានគំនូសព្រួញបង្ហាញទិសដៅ ៤)ភ្លើងបំភ្លឺទីធ្លា(អំពូលសូឡា) ៥)ក្តារខៀនផ្តល់ព័ត៌មាន ៦)ការអង្កេតពីភាពស្អាតរបស់សាលារៀន(គ្មានសំរាម គ្មានទឹកដក់ និងភាពបៃតង)។
  - ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានប្លង់គោលរបស់សាលារៀនបង្ហាញពីទីតាំងអគារ |
| ពិន្ទុ ១ | មានការរៀបចំរចនាបទ និងសណ្តាប់ធ្នាប់ហេដ្ឋារចនាសម្ព័ន្ធទីធ្លាសាលារៀនមានសោភណភាពបរិស្ថានបានល្អរួមមានពាក្យស្លោក ផ្ទាំងរូបភាព រូបចម្លាក់មនុស្សល្បីៗ |
| ពិន្ទុ ១ | មានការរៀបចំនូវផ្លូវចូល សួនច្បារ ដើមឈើដាំជាជួរ ដាំដើមឈើជារបងរស់តាមរបងសាលារៀន ទីចំណត កន្លែងលក់ចំណី។ល។ និងមានគំនូសព្រួញបង្ហាញទិសដៅ |
| ពិន្ទុ ១ | មានភ្លើងបំភ្លឺទីធ្លា (អំពូលសូឡា) និងក្តារខៀនផ្តល់ព័ត៌មាន |
| ពិន្ទុ ១ | ទីធ្លាសាលារៀនគ្មានសំរាម និងមានភាពបៃតងជាប្រចាំ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- បន្ទប់រៀនមានសោភណភាព និងរៀបចំតុបតែងបានល្អ និងមានការសម្អាតជាប្រចាំ

  - ***សេចក្តីពន្យល់៖*** សំដៅដល់បន្ទប់រៀនមានការរៀបចំសោភណភាព ដោយមានបិទតុបតែងដោយផ្ទាំងរូបភាពដែលទាក់ទងនឹងមេរៀនឬរូបមន្តផ្សេងៗដែលបង្កើតឡើងដោយស្នាដៃសិស្ស កាលវិភាគនៃការសម្អាតថ្នាក់រៀននិងក្រុមសម្អាតប្រចាំថ្នាក់រៀន មានបិទលេខសំគាល់សិស្ស ឬលេខទូរសព្ទមាតាបិតាក្រុមតេឡេក្រាមរបស់សិស្ស និងអាណាព្យាបាលសិស្ស(Telegram Group) ឬអ្នកអាណាព្យាបាលសិស្សនៅតាមតុសិស្សងាយស្រួលក្នុងការទាក់ទង មានតុបតែងដាកម្រាល ចូ ឬផើងកូនឈើ ផ្កា... ក្នុងបន្ទប់រៀន និងតុគ្រូ និងមានកាលវិភាគបែងចែកវេនសម្អាតតាមថ្ងៃ។

- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ការអង្កេតពីសោភណភាព និងការតុបតែងថ្នាក់រៀននីមួយៗគ្រប់អគារ ២)កាលវិភាគនៃការសម្អាតថ្នាក់រៀន និងក្រុមសម្អាតប្រចាំថ្នាក់រៀន និង៣)បញ្ជីលេខទូរសព្ទសិស្សនិងអ្នកអាណាព្យាបាលសិស្ស បញ្ជីក្រុមតេឡេក្រាមរបស់សិស្ស និងអ្នកអាណាព្យាបាលសិស្ស។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានការបិទផ្ទាំងរូបភាពដែលទាក់ទងនឹងមេរៀនឬរូបមន្តផ្សេងៗនៅក្នុងបន្ទប់រៀន |
| ពិន្ទុ ១ | មានក្រុមសម្អាតនៅតាមថ្នាក់រៀន និងមានកាលវិភាគបែងចែកវេនសម្អាត |
| ពិន្ទុ ១ | មានតុបតែងជាកម្រាល ថូឬផើងកូនឈើ/ផ្កានៅលើតុគ្រូ ឬ ថូឬផើងកូនឈើ/ផ្កាក្នុងបន្ទប់រៀន |
| ពិន្ទុ ១ | មានបិទលេខសំគាល់សិស្ស ឬលេខទូរសព្ទមាតាបិតា ឬអ្នកអាណាព្យាបាលសិស្សនៅតាមតុសិស្ស និងបញ្ជីលេខទូរសព្ទសិស្សនិងអ្នកអាណាព្យាបាលសិស្ស បញ្ជីក្រុមតេឡេក្រាមរបស់សិស្ស និងអ្នកអាណាព្យាបាលសិស្ស |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ <u>មានការបែងចែកបង្គន់សម្រាប់សិស្សស្រី សិស្សប្រុស អ្នកដែលមានពិការភាព និងបុគ្គលិកអប់រំ និងចំនួនបង្គន់សមាមាត្រទៅនឹងចំនួនសិស្ស និងបុគ្គលិកអប់រំ</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនមានការបែងចែកបង្គន់ទៅតាមភេទស្រី និងប្រុស សម្រាប់សិស្ស/អ្នកដែលមានពិការភាព និងបុគ្គលិកអប់រំ និងរៀបចំបង្គន់អនាម័យសមាមាត្រទៅនឹងចំនួនសិស្សប្រុស សិស្សស្រី និងបុគ្គលិកអប់រំដោយកំណត់ទីតាំងដាច់ដោយឡែកពីគ្នាឬមានវត្ថុអ្វីបាំងមិនអាចមើលគ្នាឃើញ។ ចំនួនបង្គន់អនាម័យសិស្សស្រី១០០នាក់ ត្រូវមានបង្គន់ចំនួន៣ និងសិស្សប្រុស១០០នាក់ត្រូវមានបង្គន់ចំនួន២ និងបន្ទប់នោម៣ (អនុក្រឹត្យលេខ ២៥ អនក្រ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ ស្តីពីអនាម័យសិក្សា)។ ចំនួនបង្គន់អនាម័យសម្រាប់បុគ្គលិកអប់រំមានបិទផ្លាកសញ្ញាសម្គាល់។ ផ្នែកខាងក្នុងនិងខាងក្រៅបង្គន់មានការសម្អាតនិងអនាម័យជានិច្ច ដោយផ្នែកខាងក្នុងបង្គន់បំពាក់សម្ភារៈគ្រប់គ្រាន់ប្រកបដោយអនាម័យល្អ មានការរចនាលម្អសោភណភាពល្អ និងក្រៅបរិវេណឬទីធ្លាបង្គន់ត្រូវរៀបចំឱ្យមានសោភណភាពល្អ បរិស្ថានបៃតងដូចជាមានដាំកូនឈើ ឬផើងផ្កាជុំវិញដើម្បីលើកសោភណភាពល្អ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ការអង្កេតការបែងចែកបង្គន់អនាម័យសម្រាប់សិស្ស អ្នកដែលមានពិការភាព និងបុគ្គលិកអប់រំ និងភ្ញៀវ ។ ១)ស្ថិតិនិងទីតាំងអគារបង្គន់អនាម័យសមស្របទៅតាមចំនួនសិស្ស និងបុគ្គលិកអប់រំ ២)ហេដ្ឋារចនាសម្ព័ន្ធបង្គន់អនាម័យរបស់សាលារៀនមានការរចនាលម្អ សោភណភាពល្អ បរិស្ថាននិងភាពស្អាតជានិច្ច និង៣)ស្ថិតិសិស្សស្រី សិស្សប្រុស និងបុគ្គលិកអប់រំ។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | ចំនួនបង្គន់អនាម័យសមាមាត្រទៅនឹងចំនួនសិស្សស្រី សិស្សប្រុស និងបុគ្គលិកអប់រំ និងមានទីតាំងដាច់ដោយឡែកពីគ្នា ឬមានវត្ថុអ្វីបាំងមិនអាចមើលគ្នាឃើញ |
| ពិន្ទុ ១ | មានការបែងចែកបង្គន់រវាងសិស្សប្រុស និងសិស្សស្រី និងបុគ្គលិកអប់រំ និងភ្ញៀវ |
| ពិន្ទុ ១ | ហេដ្ឋារចនាសម្ព័ន្ធបង្គន់អនាម័យរបស់សាលារៀនមានការរចនាលម្អ សោភណភាពល្អ និងបរិស្ថានផ្នែកខាងក្នុងនិងខាងក្រៅបង្គន់មានការសម្អាតនិងអនាម័យជានិច្ចព្រមទាំងបំពាក់សម្ភារៈគ្រប់គ្រាន់ប្រកបដោយអនាម័យល្អ |
| ពិន្ទុ ១ | មានការបែងចែកបង្គន់សម្រាប់អ្នកដែលមានពិការភាព |
| ពិន្ទុ ០ | នៅក្នុងបរិវេណសាលារៀនមិនមានបង្គន់អនាម័យ ឬមានបង្គន់អនាម័យ តែមិនបានប្រើប្រាស់ ឬមិនបានបែងចែកបង្គន់អនាម័យសម្រាប់ស្រី និងប្រុស និងបុគ្គលិកអប់រំដាច់ពីគ្នា |

## ➢ បង្គន់ប្រកបដោយអនាម័យ សោភណភាព និងសុវត្ថិភាព

- ***សេចក្តីពន្យល់៖*** សំដៅដល់គ្រប់បង្គន់ និងបរិវេណបង្គន់មានភាពស្អាតនិងសុវត្ថិភាព(បង្គន់មានទ្វារនិងគន្លឹះទ្វារ មានដំបូល មានស្លាបព្រិល មានពន្លឺ មានខ្យល់ចេញចូល និងមានទីតាំងសមស្រប) មានអនាម័យស្អាតជាប្រចាំ(គ្មានសំរាមគ្រប់ប្រភេទជាពិសេសប្លាស្ទិក ការដក់ទឹក ស្នាមប្រលាក់ ភក់ជ្រាំ និងក្លិនស្អុយ) មានសម្ភារៈប្រើប្រាស់គ្រប់គ្រាន់(ធ្នឹលទឹក សាប៊ូ កន្សែងជូតដៃ ឬធុងទឹក និងក្រណាត់ ឬប្រដាប់ជូតជើង និងមានទឹកប្រើប្រាស់គ្រប់គ្រាន់) និងមានការតាំងលម្អផើងកូនឈើ ឬផ្កា។ មានការរចនាលម្អសោភណភាពល្អ និងក្រៅបរិវេណឬទីធ្លាបង្គន់ត្រូវរៀបចំឱ្យមានសោភណភាពល្អ បរិស្ថានបៃតងដូចជាមានដាំកូនឈើ ឬផើងផ្កាជុំវិញដើម្បីលើកសោភណភាពល្អ
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ការអង្កេតទៅលើទីតាំង សម្ភារៈប្រើប្រាស់មានភាពស្អាត(គ្មានសំរាមប្លាស្ទិក ការដក់ទឹក កាន់ស្លែ ស្នាមប្រលាក់ ភក់ជ្រាំ និងក្លិនស្អុយ) និងសុវត្ថិភាពនៃបង្គន់ និងបរិវេណជុំវិញបង្គន់មានភាពស្អាត និងសោភណភាពដូចជាមានការតាំងលម្អផើងកូនឈើ/ផ្កា ឬវត្ថុលម្អផ្សេងៗ ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានសុវត្ថិភាព(បង្គន់មានទ្វារនិងគន្លឹះទ្វារ មានដំបូល មានស្លាបព្រិល មានពន្លឺ មានខ្យល់ចេញចូល និងមានទីតាំងសមស្រប) |
| ពិន្ទុ ១ | មានអនាម័យស្អាតជាប្រចាំ(គ្មានសំរាមប្លាស្ទិក ការដក់ទឹក កាន់ស្លែ ស្នាមប្រលាក់ ភក់ជ្រាំ និងក្លិនស្អុយ) |
| ពិន្ទុ ១ | មានសម្ភារៈប្រើប្រាស់គ្រប់គ្រាន់ប្រកបដោយភាពស្អាតនិងអនាម័យ(ធ្នឹលទឹក សាប៊ូ កន្សែងជូតដៃ ឬក្រមា ធុងទឹក និងក្រណាត់ ឬប្រដាប់ជូតជើង និងមានទឹកប្រើប្រាស់គ្រប់គ្រាន់) |
| ពិន្ទុ ១ | មានការតាំងលម្អផើងកូនឈើ/ផ្កា ឬវត្ថុលម្អផ្សេងៗ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- **មានកន្លែងលាងសម្អាតដៃប្រកបដោយអនាម័យ និងសុវត្ថិភាព**
  - ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបចំឱ្យមានកន្លែងនិងសម្ភារៈលាងដៃសមរម្យសម្រាប់សិស្ស និងបុគ្គលិកអប់រំ ព្រមទាំងបានរក្សានូវភាពស្អាត អនាម័យ សុវត្ថិភាព និងសោភណភាពនៅក្នុងបរិវេណកន្លែងលាងដៃជាប្រចាំដោយគ្មានការដក់ទឹក ស្នាមប្រលាក់ ភក់ជ្រាំ និងក្លិនស្អុយ និងមានសម្ភារៈប្រើប្រាស់គ្រប់គ្រាន់(សាប៊ូ កន្សែងជូតដៃ និងមានទឹកប្រើប្រាស់គ្រប់គ្រាន់) និងមានការតាំងលម្អផើងកូនឈើ ឬផ្កា។
  - ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ការអង្កេតទៅលើទីកន្លែងលាងដៃមានភាពស្អាត និងអនាម័យ(គ្មានសំរាមប្លាស្ទិក ការដក់ទឹក ភក់ជ្រាំ និងក្លិនស្អុយ) ២)ទីតាំងនិងចំនួនកន្លែងលាងដៃសមស្របទៅនឹងបរិវេណសាលារៀន ៣)កន្លែងលាងដៃមានសុវត្ថិភាព សោភណភាព និងសម្ភារៈគ្រប់គ្រាន់ និង៤)ការអង្កេតទៅលើទីកន្លែង សម្ភារៈ អនាម័យ សុវត្ថិភាព និងសោភណភាពនៃកន្លែងលាងដៃ។
  - ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | សាលារៀនមានទីតាំងនិងចំនួនកន្លែងលាងដៃសមស្របទៅនឹងបរិវេណសាលារៀន |
| ពិន្ទុ ១ | មានសម្ភារៈលាងដៃ(ទឹកប្រើប្រាស់ សាប៊ូ/ផេះ កន្សែងជូតដៃ) |
| ពិន្ទុ ១ | កន្លែងលាងដៃមានភាពស្អាតនិងអនាម័យ |
| ពិន្ទុ ១ | កន្លែងលាងដៃមានសោភណភាព |
| ពិន្ទុ ១ | កន្លែងលាងដៃមានសុវត្ថិភាព |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- **មានសួនច្បារ/ផ្កា សួនបន្លែ និងសួនជីវៈចម្រុះ និងមានការដាំដើមឈើក្នុងបរិវេណសាលា ដើម្បីឱ្យកាន់តែមានសោភណភាព និងមានភាពទាក់ទាញ**
  - ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនរៀបចំឱ្យមានសួនផ្កា (កូនឈើលម្អ) សួនបន្លែ និងសួនជីវៈចម្រុះ (ថ្នាល រង ដាំដំណាំ រោងទ្រើង រុក្ខជាតិប្រទាល ឱសថ កេសរកូល ...) ឱ្យសមស្របតាមទំហំនៃសាលារៀន ព្រមទាំងមានការដាំដុះជាប្រចាំ មានកាលវិភាគការដាំដុះ និងថែទាំឱ្យមានភាពបៃតងជាប្រចាំដោយមានអ្នកទទួលខុសត្រូវ។ មានការដាំដើមឈើជាជួរក្នុងបរិវេណសាលារៀន ដាំដើមឈើជារបងរស់តាមរបងសាលារៀន ជាច្រើនប្រភេទរួមមានប្រភេទដើមឈើ លម្អ ផ្តល់ម្លប់ និងសោភណភាពព្រមទាំងមានការថែទាំដើមឈើទាំងនោះជាប្រចាំ និងមានដាក់ផ្លាកឈ្មោះដើមឈើជាភាសាខ្មែរ/ភាសាជាតិ ឬឈ្មោះវិទ្យាសាស្ត្រ និងមានភាពបៃតង។
  - ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ការអង្កេតទៅលើសួនផ្កា សួនបន្លែ និង

សួនជីវៈចម្រុះដែលមានការដាំដុះជាប្រចាំ មានភាពបៃតង ២)មានកាលវិភាគការដាំដុះនិងថែទាំដោយមានអ្នកទទួលខុសត្រូវ ៣)មានការដាំឈើបន្ថែមនិងអង្កេតទៅលើដើមឈើមានដាក់ឈ្មោះរុក្ខជាតិ(ជាភាសាជាតិ និងភាសាវិទ្យាសាស្ត្រ) និង៤)សៀវភៅកត់ត្រាពីការបញ្ជ្រាបការយល់ដឹងដល់សិស្ស និងរបាយការណ៍។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានសួនច្បារ/ផ្កា |
| ពិន្ទុ ១ | មានសួនបន្លែ |
| ពិន្ទុ ១ | មានសួនជីវៈចម្រុះ |
| ពិន្ទុ ១ | មានការដាំដុះបន្លែជាប្រចាំ សួនច្បារ/ផ្កា និងសួនជីវៈចម្រុះមានភាពបៃតងជាប្រចាំ មានដាក់ឈ្មោះរុក្ខជាតិ(ជាភាសាជាតិ និងភាសាវិទ្យាសាស្ត្រ) មានរបាយការណ៍ ឬសៀវភៅកត់ត្រាពីសកម្មភាពនិងការបញ្ជ្រាបការយល់ដឹងជីវៈចម្រុះដល់សិស្ស |
| ពិន្ទុ ១ | មានកាលវិភាគការដាំដុះនិងថែទាំដោយមានអ្នកទទួលខុសត្រូវ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ <u>គ្មានការបំពុលបរិស្ថាន(ផ្សែង សំឡេង ក្លិន..) និងគ្មានផ្សែងបារីនៅក្នុងបរិវេណសាលារៀន</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានអនុវត្តវិធានការដើម្បីការពារការបំពុលដោយផ្សែង សំឡេង ក្លិន និងផ្សែងបារី ឬសារធាតុញៀននៅក្នុងបរិវេណសាលា(មានផ្លាកហាមជក់បារីបិទតាមអគារ ឬទីធ្លាសួនឬតាមផ្លូវដើរក្នុងបរិវេណសាលានិងថ្នាក់រៀន ការប្រជុំជាមួយភាគីពាក់ព័ន្ធដើម្បីបង្ការការរំខានដោយផ្សែង សំឡេង និងក្លិនដល់សាលារៀន)។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ផែនការ ឬរបាយការណ៍អនុវត្តន៍សកម្មភាពនៃការការពារការបំពុលបរិស្ថាន ២)ផ្លាកផ្សព្វផ្សាយ«សាលារៀនគ្មានផ្សែងបារី» ៣)ការអង្កេតនៅក្នុងនិងក្រៅបរិវេណសាលា និងសម្ភាសជាមួយភាគីពាក់ព័ន្ធ និង៤)របាយការណ៍ប្រជុំគណៈកម្មការគ្រប់គ្រងសាលា និងភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានការបិទ ឬផ្សព្វផ្សាយអប់រំអំពីការបំពុលបរិស្ថានក្នុងថ្នាក់រៀន និងបរិវេណសាលារៀន |
| ពិន្ទុ ១ | មានការបិទ ឬផ្សព្វផ្សាយអប់រំអំពីពាក្យស្លោក "សាលារៀនគ្មានផ្សែងបារី" |
| ពិន្ទុ ១ | ផែនការ ឬរបាយការណ៍អនុវត្តន៍សកម្មភាពនៃការការពារការបំពុលបរិស្ថាន |
| ពិន្ទុ ២ | សាលារៀនគ្មានការបំពុលដោយផ្សែង សំឡេង និងក្លិន |
| ពិន្ទុ ០ | សាលារៀនមានការបំពុលដោយផ្សែង សំឡេង ក្លិន និងមានអ្នកជក់បារីក្នុងសាលារៀន |

➢ មានប្រអប់សង្គ្រោះបឋម និងបរិក្ខារជំនួយ

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបចំឱ្យមានបន្ទប់សង្គ្រោះបឋម ឬប្រអប់ ឬទូសង្គ្រោះសម្រាប់ដាក់ថ្នាំនិងសម្ភារៈព្យាបាលបឋមមួយចំនួន ដូចជា ថ្នាំលាងរបួស បង់រុំរបួស សំឡី ស្កុតបិទរបួស កន្ត្រៃ អាល់កុល ។ល។ និងមានកត់ត្រាទុកលេខទូរសព្ទទំនាក់ទំនងជាមួយមន្ទីរពេទ្យ ឬមណ្ឌលសុខភាព ឬគិលានុបដ្ឋានដែលនៅជិតសាលាបំផុត។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)បន្ទប់សង្គ្រោះបឋម ឬទូដាក់សម្ភារៈសង្គ្រោះបឋម ឬប្រអប់សម្រាប់ដាក់ថ្នាំនិងសម្ភារៈពេទ្យ ២)លេខទូរសព្ទទំនាក់ទំនងជាមួយមន្ទីរពេទ្យ ឬមណ្ឌលសុខភាព ឬគិលានដ្ឋាន ៣)មានបុគ្គលិកទទួលខុសត្រូវផ្នែកសង្គ្រោះបឋម និង៤)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានបន្ទប់ ឬប្រអប់ ឬទូសម្រាប់សង្គ្រោះបឋម |
| ពិន្ទុ ១ | មានសម្ភារៈសម្រាប់សង្គ្រោះបឋម |
| ពិន្ទុ ១ | មានកត់ត្រាទុកលេខទូរសព្ទទំនាក់ទំនងជាមួយមន្ទីរពេទ្យ ឬមណ្ឌលសុខភាព ឬគិលានុបដ្ឋាន |
| ពិន្ទុ ១ | មានបុគ្គលិកទទួលខុសត្រូវផ្នែកសង្គ្រោះបឋម |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## ៥.៣ ទីតាំងលេងកំសាន្ត និងគ្រប់គ្រងកាកសំណល់ (៣៥ពិន្ទុ)

### ៥.៣.១ ទីតាំងលេងកំសាន្ត និង អប់រំកាយនិងកីឡា (១៥ពិន្ទុ)

➢ មានកន្លែងសម្រាប់សិស្សានុសិស្សនិងបុគ្គលិកអប់រំអង្គុយលេងប្រកបដោយអនាម័យល្អ និងបរិស្ថានស្អាតជានិច្ច

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនរៀបចំឱ្យមានកន្លែងសម្រាប់សិស្សានុសិស្ស និងបុគ្គលិកអប់រំអង្គុយលេង ពិភាក្សា អានសៀវភៅនិងស្វ័យសិក្សាប្រកបដោយភាពស្អាត អនាម័យល្អ បរិស្ថានស្អាតជានិច្ចនិងមានផាសុកភាពដូចជា កៅអីអង្គុយមានអនាម័យ គ្មានសំរាម ភក់ជ្រាំ ទឹកដក់ មានម្លប់ដើមឈើ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ការអង្កេតកន្លែងអង្គុយលេង ពិភាក្សា អានសៀវភៅនិងស្វ័យសិក្សារបស់សិស្ស និងបុគ្គលិកអប់រំមានចំនួនសមស្របតាមបរិវេណសាលារៀន និងបរិវេណជុំវិញ ប្រកបដោយផាសុកភាព ២)វេនសម្អាតនិងក្រុមសម្អាតដោយមានការទទួលខុសត្រូវ និង៣)របាយការណ៍និងការសម្ភាសជាមួយភាគីពាក់ព័ន្ធអំពីការថែទាំកន្លែងអង្គុយលេង។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានចំនួនកន្លែងអង្គុយលេង ពិភាក្សា អានសៀវភៅនិងស្វ័យសិក្សាសម្រាប់សិស្ស និងបុគ្គលិកអប់រំសមស្របតាមបរិវេណសាលារៀននិងមានផាសុកភាព |
| ពិន្ទុ ២ | កន្លែងអង្គុយលេង ពិភាក្សា អានសៀវភៅនិងស្វ័យសិក្សាសម្រាប់សិស្ស និងបុគ្គលិកអប់រំមានភាពស្អាត បរិស្ថាននិងអនាម័យជាប្រចាំ |
| ពិន្ទុ ១ | មានវេនសម្អាតនិងក្រុមសម្អាតដោយមានការទទួលខុសត្រូវ និងរបាយការណ៍ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ <u>មានទីលានលេងកីឡាស្របតាមនិយាម និងតាមកម្រិតភូមិសិក្សា</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនមានទីលានលេងកីឡា( បាល់ទាត់ បាល់បោះ បាល់ទះ កន្លែងលោតកម្ពស់ លោតចម្ងាយ វាយសី...)ប្រកបដោយអនាម័យ និងបរិស្ថានល្អស្របតាមលទ្ធភាពអាចធ្វើបាន ហើយទីលានទាំងនោះមានសិស្សចូលហាត់ និងលេងជាប្រចាំ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ការអង្កេតលើទីលានលេងកីឡា និងបរិវេណ ២)កាលវិភាគហាត់កីឡាសម្រាប់ថ្នាក់នីមួយៗ និង៣)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានទីលានលេងកីឡា(កីឡាចម្រុះ) |
| ពិន្ទុ ១ | មានកាលវិភាគហាត់កីឡាសម្រាប់សិស្ស |
| ពិន្ទុ ១ | ទីលានលេងកីឡាមានអនាម័យជានិច្ច |
| ពិន្ទុ ១ | ទីលានលេងកីឡាមានផ្លាកសញ្ញាបង្ហាញពីប្រភេទកីឡានិងបរិស្ថានល្អ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ <u>មានសម្ភារៈសម្រាប់លេងកីឡាគ្រប់គ្រាន់</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនរៀបចំឱ្យមានសម្ភារៈសម្រាប់ឱ្យសិស្សហាត់ និងលេងកីឡាច្រើនប្រភេទ(បាល់ទាត់ បាល់បោះ បាល់ទះ លោតកម្ពស់ លោតចម្ងាយ សំលៀកបំពាក់កីឡាសម្រាប់សិស្ស បន្ទប់ផ្លាស់សំលៀកបំពាក់សម្រាប់សិស្សប្រុស និងសិស្សស្រីដាច់ពីគ្នា...) ហើយមានគ្រូបង្គោល ឬក្រុមដឹកនាំការហាត់ និងលេងកីឡា ព្រមទាំងគ្រប់គ្រងសម្ភារៈកីឡា។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)គ្រូបង្គោលឬក្រុមដឹកនាំការហាត់ និងលេងកីឡា ២)បន្ទប់ឬកន្លែងដាក់សម្ភារៈកីឡា ៣)ឯកសណ្ឋានកីឡារបស់សាលារៀន ៤)សម្ភារៈកីឡា និង៥)បន្ទប់ផ្លាស់សំលៀកបំពាក់សម្រាប់សិស្សប្រុស និងសិស្សស្រីដាច់ពីគ្នាដោយសុវត្ថិភាព។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានគ្រូបង្គោលឬក្រុមដឹកនាំការហាត់និងលេងកីឡា |
| ពិន្ទុ ១ | មានបន្ទប់ឬកន្លែងដាក់សម្ភារៈកីឡា និងសម្ភារៈកីឡាច្រើនប្រភេទ |
| ពិន្ទុ ១ | មានឯកសណ្ឋានកីឡារបស់សាលារៀន |
| ពិន្ទុ ២ | មានបន្ទប់ផ្លាស់សំលៀកបំពាក់សម្រាប់សិស្សប្រុសនិងសិស្សស្រីដាច់ពីគ្នាប្រកបដោយសុវត្ថិភាព |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

### ៥.៣.២ ការគ្រប់គ្រងកាកសំណល់ និងប្រព័ន្ធលូ (២០ពិន្ទុ)

➢ <u>មានការអនុវត្តគោលការណ៍៤R( ការបដិសេធ ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃឡើងវិញ )</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនមានការអនុវត្តគោលការណ៍ ៤R សម្រាប់ការគ្រប់គ្រងកាកសំណល់ (ការបដិសេធ ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃឡើងវិញ) ៤R: Reject, Reduce, Reuse, Recycle) ឧទាហរណ៍៖ មានការផ្សព្វផ្សាយដល់សិស្សានុសិស្ស និងបុគ្គលិកអប់រំឱ្យអនុវត្តគោលការណ៍អនុវត្តន៍ ៤R ដូចជា**ការបដិសេធ**ក្នុងការប្រើប្រាស់ថង់ប្លាស្ទិក **ការកាត់បន្ថយ** ដូចជាប្រើប្រាស់កែវទឹកក្រដាស ប្រើប្រាស់ថង់បរិស្ថាន និងតំឡើងម៉ាស៊ីនចម្រោះទឹក **ការប្រើប្រាស់ឡើងវិញ**ដូចជាប្រើប្រាស់ដបទឹក កែវ ប្រអប់អាហារ ចានស្រាកដែលអាចប្រើប្រាស់ឡើងវិញបាន និង**ការកែច្នៃឡើងវិញ**ដូចជាចោលសំរាមប្លាស្ទិកឬកាកសំណល់ចំណីអាហារក្នុងធុងសំរាមកែច្នៃឡើងវិញ។ មានកន្លែងទុកដាក់សំរាមសមស្របតាមដែលអាចធ្វើបាន មានការញែកកាកសំណល់ មានឡសម្រាប់ដុតសំរាម មានការកែច្នៃធ្វើជីកំប៉ុស និងប្រើប្រាស់សម្រាប់ដាំដំណាំនៅក្នុងសាលារៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)កន្លែងទុកដាក់សំរាម និងញែកសំរាម ២)អនុវត្តការញែកសំរាម ៣)កន្លែងធ្វើនិងប្រើប្រាស់ជីកំប៉ុស ៤)ផលិតផលដែលបានមកពីការកែច្នៃនិងការប្រើប្រាស់ឡើងវិញពីកាកសំណល់ និង៥)អង្កេតមើលបរិវេណសាលារៀនមានការរៀបរយទុកដាក់សំរាមមានសណ្តាប់ធ្នាប់ មានការបែងចែកប្រភេទសំណល់ ទីកន្លែងស្តុកសំរាមមានអានាម័យល្អ គ្មានក្លិនស្អុយដែលរំខានដល់ថ្នាក់រៀន ពេលវេលានៃការដឹកជញ្ជូនចេញពីសាលា។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | សាលារៀនបានអនុវត្តការបដិសេធ(Reject)ជាពិសេសកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ឬបដិសេធការទទួលយកថង់ប្លាស្ទិក ទង្វើដែលធ្វើឱ្យមានផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន អនាម័យ និងសុខភាព (អ្វីដែលមានកំណត់ក្នុងកិច្ចសន្យារវាងសាលារៀន និងអ្នកលក់ដូរ បទបញ្ជាផ្ទៃក្នុងរបស់សាលា និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ) |

| | |
|---|---|
| ពិន្ទុ ១ | សាលារៀនបានអនុវត្តការកាត់បន្ថយ(Reduce)កាកសំណល់ជាពិសេសប្លាស្ទិក |
| ពិន្ទុ ១ | សាលារៀនបានអនុវត្តការប្រើប្រាស់ដបទឹក កែវ ប្រអប់អាហារ ចានស្រាកឡើងវិញ (Reuse) |
| ពិន្ទុ ១ | សាលារៀនបានអនុវត្តការកែច្នៃ(Recycle)កាកសំណល់ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ក្នុងករណីគ្មានធុងសំរាម និងគ្មានសំរាមនៅក្នុងបរិវេណសាលារៀន ត្រូវផ្តល់ពិន្ទុពេញ។

## ➢ មានធុងសំរាម ការញែកប្រភេទសំរាម និងមានការសម្អាតជាប្រចាំ

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនរៀបចំឱ្យមានធុងសំរាមនៅក្នុងបរិវេណ និងនៅតាមអគារសិក្សា ព្រមទាំងបានសម្អាតអនាម័យជាប្រចាំ និងរៀបចំបែងចែកធុងទៅតាមប្រភេទសំរាម(ប្លាស្ទិក ក្រដាស និងសំរាមដែលអាចកែច្នៃធ្វើជីកំប៉ុស) ដើម្បីងាយទុកដាក់ និងកែច្នៃ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ការអង្កេតលើធុងសំរាម(សណ្តាប់ធ្នាប់ និងអនាម័យនៃធុងសំរាម) ២)ការអង្កេតពីប្រភេទធុងសំរាម ៣)កន្លែងទុកដាក់និងកែច្នៃសំរាម ៤) បរិវេណជុំវិញធុងសំរាមមានភាពស្អាតនិងអនាម័យ និង៥)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានធុងសំរាមនៅក្នុងបរិវេណសាលារៀន និងនៅតាមអគារសិក្សា និងមានការបែងចែកធុងសំរាមទៅតាមប្រភេទសំរាម(ប្លាស្ទិក ក្រដាស និងសំរាមដែលអាចកែច្នៃធ្វើជីកំប៉ុស) |
| ពិន្ទុ ១ | មានការញែកសំរាមនៅកន្លែងទុកដាក់សំរាម |
| ពិន្ទុ ១ | ធុងសំរាមត្រូវបានសម្អាត និងរក្សាអនាម័យជាប្រចាំ |
| ពិន្ទុ ១ | ធុងសំរាមត្រូវបានរៀបចំប្រកបដោយសណ្តាប់ធ្នាប់ល្អ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** គណៈកម្មការមិនលើកទឹកចិត្តឱ្យសាលារៀនរៀបចំឱ្យមានធុងសំរាមនៅក្នុងថ្នាក់រៀនឡើយ។ ធុងសំរាមអាចមានច្រើនប្រភេទទៅតាមលទ្ធភាពរបស់សាលារៀន ដូចជា ធុង ដាល កញ្ជើ កន្ត្រក...។

## ➢ មានទីតាំងសម្រាប់ស្តុកសំរាមប្រកបដោយអនាម័យស្អាត

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបចំឱ្យមានទីតាំងសម្រាប់ស្តុកសំរាមច្បាស់លាស់មានអនាម័យស្អាត(គ្មានដក់ទឹកនិងភក់ជ្រាំ និង មិនបំភាយក្លិនស្អុយដល់អគារសិក្សា សួនច្បារ កន្លែងលក់ចំណីអាហារ...)និងមានឡសម្រាប់ដុតសំរាម ពេលវេលានៃការដឹកជញ្ជូនចេញពីសាលា មានទីតាំងសម្រាប់កែច្នៃធ្វើជាជីកុំប៉ុស។

- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ការអង្កេតកន្លែងស្តុកសំរាម ២)ការអង្កេតការដក់ទឹកនិងភក់ជ្រាំ និងមិនបំភាយក្លិនស្អុយដល់បរិវេណសាលារៀន និង៣)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានកន្លែងស្តុកសំរាម |
| ពិន្ទុ ១ | កន្លែងស្តុកសំរាមគ្មានដក់ទឹកនិងភក់ជ្រាំ |
| ពិន្ទុ ២ | កន្លែងស្តុកសំរាមមិនបំភាយក្លិនស្អុយដល់បរិវេណសាលារៀន |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ <u>មានប្រព័ន្ធគ្រប់គ្រងសំណល់រាវ ដើម្បីរំដោះទឹកភ្លៀង ទឹកសំអុយ និងមានការថែទាំជាប្រចាំ</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនរៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងសំណល់រាវ ដើម្បីគ្រប់គ្រងសំណល់រាវចេញពីបន្ទប់ទឹក បង្គន់ កន្លែងលាងដៃ ប្រព័ន្ធលូទឹកសំអុយ និង រំដោះទឹកភ្លៀង ព្រមទាំងមានការពិនិត្យនិងថែទាំជាប្រចាំ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ការអង្កេតពីប្រព័ន្ធគ្រប់គ្រងសំណល់រាវ ២)ការអង្កេតពីប្រព័ន្ធស្តុក និងរំដោះទឹកភ្លៀង ៣)កាលវិភាគ/ផែនការសម្រាប់ការជួសជុល និងរបាយការណ៍ស្តីពីការជួសជុល ស្តារកែលម្អ និងថែទាំប្រព័ន្ធគ្រប់គ្រងសំណល់រាវ និង៤)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានប្រព័ន្ធគ្រប់គ្រងសំណល់រាវចេញពីបន្ទប់ទឹក បង្គន់ កន្លែងលាងដៃ ប្រព័ន្ធលូទឹកសំអុយផ្សេងគ្នាពីប្រព័ន្ធរំដោះទឹកភ្លៀង |
| ពិន្ទុ ២ | មានប្រព័ន្ធស្តុកទឹកសំអុយ និងរំដោះទឹកភ្លៀង |
| ពិន្ទុ ១ | មានកាលវិភាគ/ផែនការសម្រាប់ការជួសជុល ស្តារកែលម្អនិងថែទាំប្រព័ន្ធគ្រប់គ្រងសំណល់រាវជាប្រចាំ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## ៥.៤ ការប្រើប្រាស់ទឹកស្អាត និងអនាម័យចំណីអាហារដែលលក់ដូរក្នុងបរិវេណសាលារៀន (២០ពិន្ទុ)

### ៥.៤.១ ការប្រើប្រាស់ទឹកស្អាត (១០ពិន្ទុ)

➢ <u>មានទឹកស្អាតប្រើប្រាស់នៅក្នុងសាលារៀន</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនមានទឹកស្អាតប្រើប្រាស់សម្រាប់បុគ្គលិកអប់រំ និងសិស្សានុសិស្ស តាមរយៈការរៀបចំឱ្យមានការតបណ្តាញទឹកស្អាត(រដ្ឋាករទឹក) ឬអណ្តូង ឬស្រះ ឬអាងស្តុកទឹក ឬម៉ាស៊ីនចម្រោះទឹក...។

- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ការអង្កេតពីប្រភពទឹកសម្រាប់ការប្រើប្រាស់នៅក្នុងសាលារៀន ២)ការអង្កេតពីទឹកនៅក្នុងបន្ទប់ទឹក កន្លែងលាងដៃ និងធុងសម្រាប់ដាក់ទឹកស្អាតបរិភោគ ៣)បណ្ដាញផ្គត់ផ្គង់ទឹកក្នុងបរិវេណសាលារៀន និង៤)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានប្រភពទឹកសម្រាប់ការប្រើប្រាស់នៅក្នុងសាលារៀនជាប្រចាំ |
| ពិន្ទុ ១ | មានបណ្ដាញផ្គត់ផ្គង់ទឹក និងទឹកនៅក្នុងបន្ទប់ទឹក កន្លែងលាងដៃ |
| ពិន្ទុ ១ | មានធុងសម្រាប់ដាក់ទឹកស្អាតបរិភោគ |
| ពិន្ទុ ១ | មានការថែទាំប្រភព និងបណ្ដាញផ្គត់ផ្គង់ទឹកក្នុងបរិវេណសាលារៀន |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## ➢ ទឹកប្រើប្រាស់ជាទឹកដែលមានគុណភាព និងអនាម័យល្អ

- ***សេចក្ដីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបចំឱ្យមានទឹកប្រើប្រាស់ជាទឹកដែលមានគុណភាព និងអនាម័យល្អ(បណ្ដាញទឹកស្អាតរបស់រដ្ឋឬឯកជន ឬអណ្ដូងក្នុងសាលារៀនទទួលបានការត្រួតពិនិត្យបានត្រឹមត្រូវ ឬទឹកចម្រោះ) និងមានការសហការជាមួយអ្នកជំនាញត្រួតពិនិត្យគុណភាពទឹកប្រើប្រាស់ និងរបាយការណ៍ពីគុណភាពទឹក។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖***ចំណុចត្រូវពិនិត្យគឺ ១)ការអង្កេតប្រភពផ្គត់ផ្គង់ទឹក បណ្ដាញទឹក និងទឹកប្រើប្រាស់ក្នុងសាលារៀន ២)ធុងចម្រោះទឹកសម្រាប់បរិភោគ ៣)របាយការណ៍និងកាលវិភាគលាងសម្អាតម៉ាស៊ីនចម្រោះទឹក និង៤)មានការសហការជាមួយអ្នកជំនាញត្រួតពិនិត្យគុណភាពទឹកប្រើប្រាស់និងការសម្ភាសជាមួយភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានការតបណ្ដាញទឹកស្អាតពីរដ្ឋឬឯកជន ឬសម្ភារៈសម្រាប់ចម្រោះទឹក |
| ពិន្ទុ ២ | មានការត្រួតពិនិត្យនិងថែទាំបណ្ដាញទឹក និងទឹកប្រើប្រាស់ជាប្រចាំ និងរបាយការណ៍ និងកាលវិភាគលាងសម្អាតម៉ាស៊ីនចម្រោះទឹក អាងស្តុកទឹក |
| ពិន្ទុ ១ | មានការសហការជាមួយអ្នកជំនាញត្រួតពិនិត្យគុណភាពទឹកប្រើប្រាស់ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

### ៥.៤.២ ការលក់ចំណីអាហារ (១០ពិន្ទុ)

➢ ទីតាំងលក់ចំណីអាហារមិនរំខានដល់ការសិក្សា មានអនាម័យ និងបរិស្ថានស្អាត

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបចំទីតាំងលក់ចំណីអាហារមានចម្ងាយសមស្របពីអគារសិក្សា(មិនរំខានដល់ការសិក្សា) ហើយមានអនាម័យល្អ បរិស្ថានស្អាតនិងសោភណភាព (ទីតាំងឬរោងលក់ចំណីអាហារគ្មានភាពកខ្វក់ ភក់ជ្រាំ មានការទុកដាក់សំរាមឱ្យបានត្រឹមត្រូវស្អាតល្អ(សំរាមប្លាស្ទិក) គ្មានក្លិនស្អុយ ផ្សែង សំឡេង ដែលជាហេតុនាំឱ្យរំខានដល់ការសិក្សា ទីតាំងឬរោងលក់ចំណីអាហារនីមួយៗត្រូវមានការឯកភាពពីគណៈគ្រប់គ្រងសាលារៀន ឬគណៈកម្មការគ្រប់គ្រងសាលារៀន)។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ការអង្កេតទីកន្លែងលក់ចំណីអាហារ ២)កិច្ចសន្យាលក់ដូរ ៣)មានការទុកដាក់សំរាមឱ្យបានត្រឹមត្រូវស្អាតល្អ ៤)ទីកន្លែងលក់ចំណីអាហារមានអនាម័យល្អ និង៥)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | ទីកន្លែងលក់ចំណីអាហារមានចម្ងាយសមស្របពីអគារសិក្សាដែលមិនរំខានដល់ការសិក្សា |
| ពិន្ទុ ១ | ទីកន្លែងលក់ចំណីអាហារមានអនាម័យល្អ(ទីតាំងឬរោងលក់ចំណីអាហារគ្មានភាពកខ្វក់ ភក់ជ្រាំ ទូដាក់ចំណីអាហារ) |
| ពិន្ទុ ១ | ទីកន្លែងលក់ចំណីអាហារមានបរិស្ថានស្អាត(គ្មានក្លិនស្អុយ ការទុកដាក់សំរាម(ប្លាស្ទិក) ផ្សែង សំឡេង ដែលជាហេតុនាំឱ្យរំខានដល់ការសិក្សា) និងមានសោភណភាព |
| ពិន្ទុ ១ | មានកិច្ចសន្យាលក់ដូររវាងគណៈគ្រប់គ្រងសាលារៀន ឬគណៈកម្មការគ្រប់គ្រងសាលារៀនជាមួយនឹងអ្នកលក់ដូរ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ មានការត្រួតពិនិត្យ និងផ្តល់ការណែនាំជាប្រចាំអំពីគុណភាពចំណីអាហារ

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានបង្កើត និងដំណើរការគណៈកម្មការត្រួតពិនិត្យចំណីអាហារ និងបរិស្ថានសាលារៀន ដើម្បីដឹកនាំគ្រប់គ្រង និងត្រួតពិនិត្យគុណភាព និងអនាម័យចំណីអាហារ(ការទុកដាក់ចំណីអាហារ ការវេចខ្ចប់ចំណីអាហារ ប្រភេទអាហារដែលហាមឃាត់ក្នុងសាលារៀន ការប្រើប្រាស់សារធាតុគីមីដែលត្រូវបានហាមឃាត់ក្នុងចំណីអាហារ) និងសហការជាមួយមន្ទីរជំនាញ ឬអង្គភាពជំនាញក្នុងការត្រួតពិនិត្យចំណីអាហារ។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖***ចំណុចត្រូវពិនិត្យគឺ១)លិខិតបង្គាប់ការស្តីពីបង្កើតគណៈកម្មការត្រួតពិនិត្យចំណីអាហារ និងបរិស្ថានសាលារៀន ២)លិខិតកិច្ចសហការរវាងគណៈគ្រប់គ្រងសាលារៀនជាមួយស្ថាប័នជំនាញ ៣)កាលវិភាគ និងរបាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាព និងអនាម័យចំណីអាហារជាមួយស្ថាប័នជំនាញ ៤)ការអង្កេតចំណីអាហារ ៥)បម្រាមប្រភេទអាហារដែលហាមឃាត់ក្នុងសាលារៀន និង៦)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានលិខិតបង្គាប់ការស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យចំណីអាហារ និងបរិស្ថានសាលារៀន |
| ពិន្ទុ ១ | បានត្រួតពិនិត្យ និងផ្តល់ការណែនាំជាប្រចាំ(មួយខែម្តង)ដល់អ្នកលក់ដូរអំពីគុណភាព និងអនាម័យចំណីអាហារ |
| ពិន្ទុ ៣ | ចំណីអាហារមានគុណភាព និងអនាម័យ(ការទុកដាក់ចំណីអាហារ ការវេចខ្ចប់ចំណីអាហារ ប្រភេទអាហារដែលហាមឃាត់ក្នុងសាលារៀន ការប្រើប្រាស់សារធាតុគីមីដែលត្រូវបានហាមឃាត់ក្នុងចំណីអាហារ)និងរបាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាព និងអនាម័យចំណីអាហារ និងមានការសហការជាមួយស្ថាប័នជំនាញ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

# ផ្នែកទី៦៖ ទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍ ព្រមទាំងការចូលរួមវាយតម្លៃពីអ្នកប្រើប្រាស់សេវាសាធារណៈ

## ៦. ទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍ ព្រមទាំងការចូលរួមវាយតម្លៃពីអ្នកប្រើប្រាស់សេវាសាធារណៈ (៧០ពិន្ទុ)

ការកំណត់និងវាយតម្លៃលក្ខណៈវិនិច្ឆ័យស្តីពីទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍ ព្រមទាំងការចូលរួមវាយតម្លៃពីអ្នកប្រើប្រាស់សេវាសាធារណៈ គឺដើម្បីជំរុញឱ្យសាលារៀនមានទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍ។ ទំនាក់ទំនងល្អរវាងសាលារៀនជាមួយអ្នកពាក់ព័ន្ធនានានៅក្នុងសហគមន៍ធ្វើឡើងតាមរយៈការផ្សារភ្ជាប់កម្មវិធីសិក្សា ការបង្រៀននិងរៀនទៅនឹងតម្រូវការនិងការអនុវត្តជាក់ស្តែងនៅក្នុងសហគមន៍ ការចូលរួមគាំទ្រ និងការកៀរគរធនធាននៅក្នុងសហគមន៍ ដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធនានាក្នុងការអភិវឌ្ឍសាលារៀន និងពង្រឹងគុណភាពនៃការសិក្សារបស់សិស្ស។ ការផ្សារភ្ជាប់សាលារៀនទៅនឹងប្រជាពលរដ្ឋ សហគមន៍ អាជ្ញាធរ និងដៃគូអភិវឌ្ឍ នឹងផ្តល់លទ្ធភាពឱ្យសាលារៀនកៀរគរធនធានគាំទ្រដល់ការលើកកម្ពស់គុណភាពបង្រៀននិងរៀន និងការអភិវឌ្ឍសាលារៀន កំណត់តម្រូវការនិងផ្តល់សេវាប្រកបដោយភាពឆ្លើយតប ព្រមទាំងធ្វើឱ្យសាលារៀនកែលម្អចំណុចខ្វះខាតនានាដែលបានកើតឡើង និងទប់ស្កាត់និងដោះស្រាយភាពមិនប្រក្រតីដែលកើតមានក្នុង និងក្រៅបរិវេណសាលារៀន។

នៅក្នុងផ្នែកនៃទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍ ព្រមទាំងការចូលរួមវាយតម្លៃពីអ្នកប្រើប្រាស់សេវាសាធារណៈ មានពិន្ទុសរុបចំនួន៧០ ដែលមានលក្ខណៈវិនិច្ឆ័យរងចំនួន២ គឺ៖

១. ការពង្រឹងទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ អាជ្ញាធរ និងដៃគូអភិវឌ្ឍ (៥៥ពិន្ទុ)

២. ការអភិវឌ្ឍកុមារ/យុវជន (១៥ពិន្ទុ)

## ៦.១ ការពង្រឹងទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ អាជ្ញាធរ និងដៃគូអភិវឌ្ឍ (៥៥ពិន្ទុ)

### ៦.១.១ ការពង្រឹងទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ (២៥ពិន្ទុ)

➢ ការផ្សារភ្ជាប់កម្មវិធីបំណិនជីវិតមូលដ្ឋានទៅនឹងតម្រូវការសហគមន៍(ការផ្សារភ្ជាប់សាលារៀននិងសហគមន៍)

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបចំ និងអនុវត្តកម្មវិធីសិក្សាបំណិនជីវិត ដោយផ្សារភ្ជាប់ទៅនឹងតម្រូវការជាក់ស្តែងរបស់សហគមន៍មូលដ្ឋាន (បណ្តុះបណ្តាលទ្រឹស្តីនៃបំណិនជីវិតផ្សារភ្ជាប់ទៅនឹងការអនុវត្តជាក់ស្តែងដែលជាប្រយោជន៍ដល់ជីវភាពគ្រួសាររបស់សិស្ស និងតម្រូវរបស់សហគមន៍មូលដ្ឋាន)។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)កម្មវិធីសិក្សាបំណិនជីវិត ២)ការអង្កេតពីមុខរបររបស់ប្រជាជនក្នុងសហគមន៍ ៣)ការអង្កេតពីការប្រើប្រាស់ទ្រឹស្តីបំណិនជីវិតក្នុងជីវភាពរស់នៅរបស់សិស្ស ៤)គ្រូទទួលបន្ទុកកម្មវិធីសិក្សាបំណិនជីវិត និង៥)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានកម្មវិធីសិក្សាបំណិនជីវិត |
| ពិន្ទុ ១ | មានគ្រូទទួលបន្ទុកកម្មវិធីសិក្សាបំណិនជីវិត |
| ពិន្ទុ ១ | កម្មវិធីសិក្សាបំណិនជីវិតត្រូវបានរៀបចំឡើងស្របតាមធនធានសាលារៀន និងមានពិគ្រោះយោបល់ជាមួយសហគមន៍ |
| ពិន្ទុ ២ | មានការអនុវត្តកម្មវិធីសិក្សាបំណិនជីវិតជាក់ស្តែងក្នុងសហគមន៍ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ កម្មវិធីដឹកនាំសិស្សជួយការងារសង្គម និងសហគមន៍

- ***សេចក្តីពន្យល់៖*** សំដៅដល់សកម្មភាពទាំងឡាយដែលគ្រូបង្រៀន គ្រូទទួលបន្ទុកថ្នាក់ ឬគណៈគ្រប់គ្រងសាលារៀន បានដឹកនាំសិស្សទៅចូលរួមសកម្មភាពនានានៅក្នុងសហគមន៍ (ជួយសម្អាតដាំដើមឈើ និងចូលរួមកម្មវិធីផ្សេងៗក្នុងសហគមន៍)។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ក្រុមប្រឹក្សាកុមារ/យុវជន ២)ក្រុមកាយរិទ្ធិ ៣)ក្រុមយុវជនកាកបាទក្រហម ៤)សកម្មភាពការងារនៅក្នុងសហគមន៍(រូបថត...) ៥)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ និងលិខិតស្នើសុំរបស់សហគមន៍ ឬអាជ្ញាធរដែនដី។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖***

| | |
|---|---|
| ពិន្ទុ ៥ | សាលារៀនមានការរៀបចំផែនការដឹកនាំជួយការងារសង្គម តាមរយៈការផ្សារភ្ជាប់កម្មវិធីសិក្សាទៅនឹងការងារសង្គម និងបានអនុវត្តបានយ៉ាងទៀងទាត់ |
| ពិន្ទុ ៤ | សាលារៀនមានការរៀបចំផែនការដឹកនាំជួយការងារសង្គម តែអនុវត្តការងារសង្គមមិនបានទៀងទាត់ |

| | |
|---|---|
| ពិន្ទុ ៣ | សាលារៀនបានចូលរួមជួយការងារសង្គមជាមួយសហគមន៍ និងអាជ្ញាធរដែនដី យ៉ាងសកម្ម |
| ពិន្ទុ ២ | សាលារៀនបានចូលរួមជួយការងារសង្គម និងសហគមន៍ជាប្រចាំតាមការស្នើសុំរបស់សហគមន៍ និងអាជ្ញាធរដែនដី |
| ពិន្ទុ ១ | សាលារៀនមានការសហការជាមួយសហគមន៍ និងអាជ្ញាធរដែនដី |
| ពិន្ទុ ០ | សាលារៀនពុំមានទំនាក់ទំនងល្អជាមួយសហគមន៍ |

➢ **ការជំរុញការបង្កើត ការរក្សា និងការតាំងបង្ហាញស្នាដៃសិស្ស**

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានជំរុញការបង្កើត ការរក្សា និងការតាំងបង្ហាញស្នាដៃសិស្ស ដើម្បីបំផុសចលនានៃការបង្កើតស្នាដៃរបស់សិស្ស និងទាក់ទាញសមានចិត្តរបស់មាតាបិតាអ្នកអាណាព្យាបាលសិស្ស អ្នកពាក់ព័ន្ធ និងសប្បុរសជននានា។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)កម្មវិធីប្រឡងប្រណាំងបង្កើតស្នាដៃសិស្ស ២)ការអង្កេតលើសមិទ្ធផលនិងស្នាដៃសិស្ស ៣)កន្លែងរក្សាទុក និងតាំងបង្ហាញស្នាដៃសិស្ស ៤)កម្មវិធីតាំងបង្ហាញស្នាដៃសិស្សជូនសហគមន៍ និងអ្នកពាក់ព័ន្ធ និង៥)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានការរៀបចំកម្មវិធីប្រឡងប្រណាំងបង្កើតស្នាដៃសិស្ស |
| ពិន្ទុ ២ | មានកន្លែងសម្រាប់រក្សា និងតាំងបង្ហាញស្នាដៃសិស្ស |
| ពិន្ទុ ១ | មានការរៀបចំកម្មវិធីតាំងបង្ហាញស្នាដៃសិស្សជូនសហគមន៍ និងអ្នកពាក់ព័ន្ធ |
| ពិន្ទុ ១ | មានការតាំងបង្ហាញស្នាដៃសិស្សនៅតាមបន្ទប់រៀន |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ **ការចូលរួមវាយតម្លៃពីមាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស និងអ្នកពាក់ព័ន្ធ**

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានបង្កលក្ខណៈងាយស្រួល និងទទួលយកការចូលរួមវាយតម្លៃ(ការផ្តល់សេវា និងសមិទ្ធផលរបស់សាលារៀន) និងផ្តល់មតិយោបល់ពីមាតាបិតាឬអ្នកអាណាព្យាបាល និងអ្នកពាក់ព័ន្ធ ដើម្បីអភិវឌ្ឍសាលារៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)របាយការណ៍កិច្ចប្រជុំរវាងគណៈកម្មការគ្រប់គ្រងសាលារៀនជាមួយមាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស និងអ្នកពាក់ព័ន្ធ ២)របាយការណ៍កែលម្អគុណភាពនៃការផ្តល់សេវារបស់សាលារៀន ៣)ប្រអប់សំបុត្រ ៤)កម្មវិធីទូរសព្ទ ឬបណ្តាញទំនាក់ទំនងសង្គមដើម្បីទទួលយកការចូលរួមមតិយោបល់ពីអ្នកពាក់ព័ន្ធ និង៥)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ និងចុះជួបប្រជាពលរដ្ឋក្នុងសហគមន៍។

- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ១ | មានការរៀបចំជាប្រអប់សំបុត្រ ឬកម្មវិធីទូរសព្ទ បណ្តាញទំនាក់ទំនងសង្គមដើម្បីទទួលមតិយោបល់ និងការវាយតម្លៃរបស់មាតាបិតា អ្នកអាណាព្យាបាល និងអ្នកពាក់ព័ន្ធ |
| ពិន្ទុ ១ | មានការរៀបចំកិច្ចប្រជុំដើម្បីទទួលយកការវាយតម្លៃ និងមតិយោបល់លើការផ្តល់សេវា និងលទ្ធផលការងាររបស់សាលារៀន យ៉ាងតិចម្តងក្នុងមួយត្រីមាស |
| ពិន្ទុ ១ | មានការចុះជួប ឬស្ទង់មតិពីមាតាបិតា អ្នកអាណាព្យាបាល និងអ្នកពាក់ព័ន្ធលើការផ្តល់សេវា និងលទ្ធផលការងាររបស់សាលារៀន |
| ពិន្ទុ ២ | បានយកមតិយោបល់ចេញពីការវាយតម្លៃរបស់មាតាបិតា អ្នកអាណាព្យាបាល និងអ្នកពាក់ព័ន្ធ ដើម្បីកែលម្អ និងអភិវឌ្ឍសាលារៀន |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ <u>កម្រិតនៃការពេញចិត្តរបស់អ្នកប្រើសេវា និងសហគមន៍ចំពោះគុណភាពសេវារបស់សាលារៀន</u>

- *សេចក្តីពន្យល់៖* សំដៅដល់កម្រិតនៃការពេញចិត្តរបស់សិស្ស មាតាបិតា អ្នកអាណាព្យាបាល សហគមន៍ និងដៃគូអភិវឌ្ឍផ្សេងៗចំពោះគុណភាពនៃការផ្តល់សេវានានារបស់សាលារៀន។ សាលារៀនដែលទទួលបានការពេញចិត្តពីសិស្ស មាតាបិតា អ្នកអាណាព្យាបាល សហគមន៍ និងដៃគូអភិវឌ្ឍផ្សេងៗនឹងបង្កើតទំនាក់ទំនងល្អរវាងសាលារៀននិងសហគមន៍ និងទាក់ទាញយកសមានចិត្តចូលរួមអភិវឌ្ឍសាលារៀនតាមគ្រប់រូបភាព។
- *ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖* ចំណុចត្រូវពិនិត្យគឺ ១)លទ្ធផលនៃការសិក្សាលើកម្រិតពេញចិត្តរបស់អ្នកប្រើប្រាស់សេវា និងដៃគូអភិវឌ្ឍ ២)របាយការណ៍ វត្តមាន និងកម្រងរូបភាពនៃការទំនាក់ទំនង ៣)លិខិតថ្លែងអំណរគុណ និង៤)ការសម្ភាសជាមួយអ្នកប្រើប្រាស់ សហគមន៍ និងភាគីពាក់ព័ន្ធ។
- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥៖*

| | |
|---|---|
| ពិន្ទុ ៥ | កម្រិតនៃការពេញចិត្តចាប់ពី ៨០ភាគរយ |
| ពិន្ទុ ៤ | កម្រិតនៃការពេញចិត្តចាប់ពី ៧៥ភាគរយ |
| ពិន្ទុ ៣ | កម្រិតនៃការពេញចិត្តចាប់ពី ៥៥ភាគរយ |
| ពិន្ទុ ២ | កម្រិតនៃការពេញចិត្តចាប់ពី ៣៥ភាគរយ |
| ពិន្ទុ ១ | កម្រិតនៃការពេញចិត្តចាប់ពី ១៥ភាគរយ |
| ពិន្ទុ ០ | កម្រិតនៃការពេញចិត្តតិចជាង ១៥ភាគរយ |

- *ចំណុចបញ្ជាក់បន្ថែមដើម្បីឱ្យអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖* ចំណុចខាងក្រោមជាជំនួយស្មារតីសម្រាប់ការអង្កេត និងការសម្ភាសជាមួយអ្នកប្រើប្រាស់ សហគមន៍ និងភាគីពាក់ព័ន្ធ៖

- ការចុះតាមខ្នងផ្ទះ៖ អាចសម្ភាសជាគំរូ ដោយចាប់ផ្តើមពីផ្នែកខ្លះនៃដើមភូមិ កណ្តាលភូមិ និងចុងភូមិ។ ម្យ៉ាងទៀត យើងក៏អាចសំដៅទៅរកសហគមន៍ និងអង្គការសង្គមនានា (រួមទាំងវត្តអារាមផង)
- កម្រងសំណួរសម្រាប់ពលរដ្ឋសហគមន៍ដូចជា តើគាត់មានបុត្រាបុត្រី ឬកូនក្មួយរៀននៅទីនោះឬទេ? តើមានការតម្រូវ ឬចាប់បង្ខិតបង្ខំ ឬដាក់បន្ទុកលើសិស្សានុសិស្សក្នុងការចំណាយលើអ្វីមួយឬទេ (ឧ. បង្ខំឱ្យរៀនគួរ បង្ខំឱ្យបង់សេវាផ្សេងៗ ផ្តល់ពិន្ទុឬពិន័យមិនយុត្តិធម៌...)?
- បង្កើតកម្រងសំណួរសម្រាប់សហគមន៍មូលដ្ឋាន៖ តើអស់លោកធ្លាប់បានចូលរួមក្នុងវេទិកានានា ដែលសាលារៀនបានរៀបចំឬទេ? តើអស់លោកមានចំណាប់អារម្មណ៍ដូចម្តេចទៅលើការផ្តល់សេវា ការចាត់ចែងកិច្ចការនានា និងតម្លាភាព?
- តើអស់លោកធ្លាប់បានចូលរួមផ្តល់អំណោយផ្សេងៗ ជូនសាលារៀនដែរឬទេ?

### ៦.១.២ ការបង្កើតមូលនិធិសមធម៌អប់រំ និងការសហការជាមួយដៃគូអភិវឌ្ឍ (១០ពិន្ទុ)

➢ <u>ការបង្កើតនិងដំណើរការមូលនិធិសមធម៌អប់រំ តាមរយៈភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន និងភាពជាដៃគូអភិវឌ្ឍ</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបចំគម្រោង សំណើ និង/ឬព្រឹត្តិការណ៍កៀរគរថវិកា និងសម្ភារៈតាមរយៈភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន ដើម្បីបង្កើតនូវមូលនិធិសមធម៌ សម្រាប់ជួយសិស្សងាយរងគ្រោះ(សិស្សក្រីក្រ សិស្សដែលគ្រួសារជួបការលំបាក និងសិស្សដែលមានពិការភាព) និងអភិវឌ្ឍសាលារៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងមូលនិធិសមធម៌ ២)ឯកសារស្តីពីសំណើគម្រោង លិខិតអំពាវនាវ(សំណើ) និង/ឬព្រឹត្តិការណ៍នានា ដើម្បីកៀរគរថវិកា និងសម្ភារៈពីសប្បុរសជន ៣)ឯកសារបញ្ជាក់ពីដំណើរការ និងសមិទ្ធផលនៃមូលនិធិសមធម៌ និង៤)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងមូលនិធិសមធម៌ |
| ពិន្ទុ ១ | មានការរៀបចំឯកសារស្តីពីសំណើគម្រោង លិខិតអំពាវនាវ(សំណើ) |
| ពិន្ទុ ១ | មានការរៀបចំព្រឹត្តិការណ៍នានា ដើម្បីកៀរគរថវិកា និងសម្ភារៈពីសប្បុរសជន |
| ពិន្ទុ ២ | បានដំណើរការ និងបង្ហាញសមិទ្ធផលនៃមូលនិធិសមធម៌ជួយដល់សិស្សងាយរងគ្រោះ និងអភិវឌ្ឍសាលារៀន |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ ការសហការជាមួយដៃគូអភិវឌ្ឍ ជាអង្គការជាតិ អន្តរជាតិ និងសប្បុរសជន

- *សេចក្តីពន្យល់៖* សំដៅដល់សាលារៀនបានធ្វើកិច្ចសហការជាមួយដៃគូអភិវឌ្ឍ ជាអង្គការជាតិ អន្តរជាតិ និងសប្បុរសជន តាមរយៈការជួយផ្តល់ការគាំទ្រដល់គ្នាទៅវិញទៅមក(សម្ភារៈ ថវិកា បច្ចេកទេស) ក្នុងគោលបំណងពង្រឹងគុណភាពសេវារបស់សាលារៀន និងលើកស្ទួយវិស័យអប់រំ។
- *ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖* ចំណុចត្រូវពិនិត្យគឺ ១)ឯកសារបញ្ជាក់ពីកិច្ចសហការរបស់សាលារៀនជាមួយដៃគូអភិវឌ្ឍ ជាអង្គការជាតិ អន្តរជាតិ និងសប្បុរសជន(អនុស្សារណៈយោគយល់គ្នា កម្រងរូបភាព ស្លាក/ផ្លាកពណ៌នាអំពីកិច្ចសហការ) ២)សមិទ្ធផលដែលបានមកពីកិច្ចសហការ និង៣)ការសម្ភាសជាមួយដៃគូអភិវឌ្ឍ និងភាគីពាក់ព័ន្ធ។
- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ១ | មានគំនិតផ្តួចផ្តើម និងបានទាក់ទងសុំការសហការជាមួយដៃគូអភិវឌ្ឍ ជាអង្គការជាតិ អន្តរជាតិ និងសប្បុរសជន |
| ពិន្ទុ ២ | បានអនុវត្តសកម្មភាពសហការជាមួយដៃគូអភិវឌ្ឍ ជាអង្គការជាតិ អន្តរជាតិ និងសប្បុរសជន ដើម្បីពង្រឹងគុណភាពសេវារបស់សាលារៀន និងលើកស្ទួយវិស័យអប់រំ |
| ពិន្ទុ ២ | បានកសាងសមិទ្ធផលក្រោមកិច្ចសហការជាមួយដៃគូអភិវឌ្ឍ ជាអង្គការជាតិ អន្តរជាតិ និងសប្បុរសជន |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

### ៦.១.៣ ទំនាក់ទំនងជាមួយនឹងអាជ្ញាធរ (២០ពិន្ទុ)

➢ ការសហការ និងកៀរគរការគាំទ្រពីអាជ្ញាធរដែនដីក្នុងការអប់រំនិងទប់ស្កាត់ និងដោះស្រាយបញ្ហាគ្រឿងញៀន គ្រឿងស្រវឹង ល្បែងស៊ីសង និងបទល្មើសផ្សេងៗ

- *សេចក្តីពន្យល់៖* សំដៅដល់សាលារៀនបានធ្វើកិច្ចសហការ និងកៀរគរការគាំទ្រពីអាជ្ញាធរដែនដីធ្វើការអប់រំផ្សព្វផ្សាយ ទប់ស្កាត់ និងដោះស្រាយបញ្ហាគ្រឿងញៀន គ្រឿងស្រវឹង ល្បែងស៊ីសង និងបទល្មើសផ្សេងៗ ដើម្បីគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយក្នុងសាលារៀន/សហគមន៍ និងបង្កើនភាពទុកចិត្តពីមាតាបិតាសិស្ស សហគមន៍ និងអ្នកពាក់ព័ន្ធ។
- *ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖* ចំណុចត្រូវពិនិត្យគឺ ១)របាយការណ៍ផ្សព្វផ្សាយពាក់ព័ន្ធនឹងការទប់ស្កាត់និងដោះស្រាយបញ្ហា គ្រឿងញៀន គ្រឿងស្រវឹង ល្បែងស៊ីសង និងបទល្មើសផ្សេងៗ ២)របាយការណ៍សុំកិច្ចសហការទៅអាជ្ញាធរ ៣)ការរក្សាទុកលេខទូរសព្ទ ឬមធ្យោបាយទំនាក់ទំនងជាមួយអាជ្ញាធរ និង៤)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។
- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ១ | មានការរក្សាទុកលេខទូរសព្ទ ឬមធ្យោបាយទំនាក់ទំនងជាមួយអាជ្ញាធរ |
| ពិន្ទុ ២ | មានកិច្ចសហការជាមួយអាជ្ញាធរដែនដីធ្វើការផ្សព្វផ្សាយអប់រំពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀន គ្រឿងស្រវឹង ល្បែងស៊ីសង និងបទល្មើសផ្សេងៗ |

| | |
|---|---|
| ពិន្ទុ ២ | មានកិច្ចសហការជាមួយអាជ្ញាធរដែនដី ដើម្បីអនុវត្តវិធានការផ្សេងៗក្នុងការទប់ស្កាត់ និងដោះស្រាយបញ្ហាពាក់ព័ន្ធនឹងសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយក្នុងសាលារៀន/សហគមន៍ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ <u>ការសហការ និងកៀរគរការគាំទ្រពីអាជ្ញាធរដែនដីក្នុងការអប់រំនិងទប់ស្កាត់ និងដោះស្រាយសុវត្ថិភាពចរាចរណ៍</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានអនុវត្តកិច្ចសហការជាមួយអាជ្ញាធរដែនដីក្នុងការចូលរួមផ្សព្វផ្សាយអប់រំ ទប់ស្កាត់ បង្ការគ្រោះថ្នាក់ផ្សេងៗ និងដោះស្រាយការកកស្ទះបណ្តាលមកពីបញ្ហាចរាចរណ៍។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)របាយការណ៍ កម្រងរូបភាព ឬឯកសារនៃកិច្ចសហការផ្សព្វផ្សាយអប់រំ និងអនុវត្តវិធានការបង្ការពាក់ព័ន្ធនឹងបញ្ហាចរាចរណ៍ និង២)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានបិទផ្សាយខិត្តប័ណ្ណ ឬរូបភាពអប់រំពាក់ព័ន្ធនឹងបញ្ហាចរាចរណ៍ក្នុងបរិវេណសាលារៀន |
| ពិន្ទុ ២ | មានកិច្ចសហការជាមួយអាជ្ញាធរដែនដីក្នុងការផ្សព្វផ្សាយអប់រំពាក់ព័ន្ធនឹងបញ្ហាចរាចរណ៍នៅក្នុងសាលារៀនយ៉ាងតិច ២ដង ក្នុងមួយឆ្នាំសិក្សា |
| ពិន្ទុ ២ | មានកិច្ចសហការជាមួយអាជ្ញាធរដែនដីក្នុងការផ្សព្វផ្សាយអប់រំ និងដោះស្រាយបញ្ហាពាក់ព័ន្ធនឹងគ្រោះថ្នាក់ និងការកកស្ទះចរាចរណ៍យ៉ាងតិច ២ដង ក្នុងមួយឆ្នាំសិក្សា |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ <u>ការសហការជាមួយអាជ្ញាធរដែនដីក្នុងការទប់ស្កាត់ និងដោះស្រាយបញ្ហាក្មេងទំនើង និងសិស្សគេចសាលា</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានសហការជាមួយអាជ្ញាធរដែនដីអនុវត្តការផ្សព្វផ្សាយអប់រំនិងវិធានការទប់ស្កាត់ និងដោះស្រាយបញ្ហាក្មេងទំនើង និងសិស្សគេចសាលាទៅប្រព្រឹត្តអំពើអសកម្មនានាក្នុងសង្គម(ល្បែងស៊ីសង វាយតប់...)។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)បទបញ្ជាផ្ទៃក្នុងស្តីពីការពិន័យ និងវិធានការទប់ស្កាត់សិស្សគេចសាលា និងក្មេងទំនើង ២)របាយការណ៍ កម្រងរូបភាព ឬឯកសារនៃកិច្ចសហការផ្សព្វផ្សាយអប់រំ និងអនុវត្តវិធានការបង្ការ និងដោះស្រាយបញ្ហាក្មេងទំនើង និងសិស្សគេចសាលា និង៣)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។

- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ១ | មានបទបញ្ជាផ្ទៃក្នុងស្តីពីការពិន័យ និងវិធានការទប់ស្កាត់សិស្សគេចសាលា និងក្មេងទំនើង |
| ពិន្ទុ ២ | មានកិច្ចសហការជាមួយអាជ្ញាធរដែនដីក្នុងការផ្សព្វផ្សាយអប់រំពាក់ព័ន្ធនឹងបញ្ហាក្មេងទំនើង និងសិស្សគេចសាលានៅក្នុងសាលារៀនយ៉ាងតិច ៤ដង ក្នុងមួយឆ្នាំសិក្សា |
| ពិន្ទុ ២ | មានកិច្ចសហការជាមួយអាជ្ញាធរដែនដីក្នុងការផ្សព្វផ្សាយអប់រំ និងដោះស្រាយបញ្ហាពាក់ព័ន្ធនឹងបញ្ហាក្មេងទំនើង និងសិស្សគេចសាលាយ៉ាងតិច ២ដង ក្នុងមួយឆ្នាំសិក្សា |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ <u>ការកៀរគរការគាំទ្ររបស់អាជ្ញាធរក្នុងការអភិវឌ្ឍសាលារៀន</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបចំផែនការ និងធ្វើសំណើជូនទៅអាជ្ញាធរដែនដីដើម្បីកៀរគរការគាំទ្រនានាដូចជាការផ្តួចផ្តើម ផ្សព្វផ្សាយ និងបំផុសឱ្យប្រជាពលរដ្ឋ សហគមន៍ សប្បុរសជន និងដៃគូអភិវឌ្ឍចូលរួមកសាង និងអភិវឌ្ឍសាលារៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ផែនការអភិវឌ្ឍសាលារៀន ២)សំណើសុំការគាំទ្រពីអាជ្ញាធរដើម្បីអភិវឌ្ឍសាលារៀន ៣)ការអង្កេតពីសមិទ្ធផលទទួលបានពីការឧបត្ថម្ភរបស់អាជ្ញាធរដែនដីក្នុងបរិវេណសាលារៀន ៤)របាយការណ៍កិច្ចប្រជុំជាមួយអាជ្ញាធរដែនដី និងភាគីពាក់ព័ន្ធក្នុងការផ្សព្វផ្សាយ និងលើកសំណើដើម្បីដោះស្រាយតម្រូវការនៃការអភិវឌ្ឍសាលារៀន និង៥)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។
- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ១ | បានធ្វើសំណើសុំអាជ្ញាធរដែនដីដើម្បីគាំទ្រការអនុវត្តផែនការអភិវឌ្ឍសាលារៀន |
| ពិន្ទុ ១ | មានកិច្ចប្រជុំជាមួយអាជ្ញាធរដែនដីដើម្បីលើកសំណើសុំការឧបត្ថម្ភគាំទ្រការអនុវត្តផែនការអភិវឌ្ឍសាលារៀន |
| ពិន្ទុ ១ | មានសមិទ្ធផលដែលទទួលបានពីការឧបត្ថម្ភរបស់អាជ្ញាធរដែនដី |
| ពិន្ទុ ២ | មានការថែទាំសមិទ្ធផលដែលទទួលបានពីការឧបត្ថម្ភរបស់អាជ្ញាធរដែនដី |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## ៦.២ ការអភិវឌ្ឍកុមារ/យុវជន (១៥ពិន្ទុ)

### ៦.២.១ ការងារអភិវឌ្ឍកុមារ/យុវជន (១៥ពិន្ទុ)

➢ <u>រចនាសម្ព័ន្ធ និងកិច្ចដំណើរការក្រុមប្រឹក្សាកុមារ/យុវជន</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនរៀបចំឱ្យមានរចនាសម្ព័ន្ធ តួនាទីនិងភារកិច្ច និងកិច្ចដំណើរការរបស់ក្រុមប្រឹក្សាកុមារ/យុវជន ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។

- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)សេចក្តីសម្រេចស្តីពីការបង្កើតក្រុមប្រឹក្សាកុមារ/យុវជន ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ២)អង្គការលេខបញ្ជាក់ពីសមាសភាពជាក់ស្តែងរបស់ក្រុមប្រឹក្សាកុមារ/យុវជន និង៣)ឯកសារស្តីពីបំណែងចែកតួនាទីនិងភារកិច្ចសម្រាប់គ្រប់សមាជិកនៃក្រុមប្រឹក្សាកុមារ/យុវជន។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានសេចក្តីសម្រេចស្តីពីការបង្កើតក្រុមប្រឹក្សាកុមារ/យុវជន ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា |
| ពិន្ទុ ២ | មានអង្គការលេខបញ្ជាក់ពីសមាសភាពជាក់ស្តែងរបស់ក្រុមប្រឹក្សាកុមារ/យុវជន |
| ពិន្ទុ ២ | មានបំណែងចែកតួនាទីនិងភារកិច្ចសម្រាប់គ្រប់សមាជិកនៃក្រុមប្រឹក្សាកុមារ/យុវជន |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## ➢ បណ្តុះបណ្តាលនិងអប់រំភាពជាអ្នកដឹកនាំ សហគ្រិនភាព និងបំណិនជីវិតដល់កុមារនិងយុវជន

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានសិក្សា រៀបចំកម្មវិធីសិក្សាឬវគ្គបណ្តុះបណ្តាល និងបានអនុវត្តសកម្មភាពអប់រំភាពជាអ្នកដឹកនាំ សហគ្រិនភាព និងបំណិនជីវិតដល់សិស្ស ដើម្បីលើកកម្ពស់បំណិនជីវិត។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)របាយការណ៍សិក្សាវាយតម្លៃកម្មវិធីសិក្សាឬវគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ សហគ្រិនភាព និងបំណិនជីវិតដល់សិស្ស ២)កម្មវិធីសិក្សាឬវគ្គបណ្តុះបណ្តាល ៣)សម្ភារៈសិក្សា និង៤)សម្ភាសអ្នកពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | បានសិក្សាដើម្បីរៀបចំកម្មវិធីសិក្សាឬវគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ សហគ្រិនភាព និងបំណិនជីវិតដល់សិស្ស |
| ពិន្ទុ ១ | បានរៀបចំកម្មវិធីសិក្សាឬវគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ សហគ្រិនភាព និងបំណិនជីវិតដល់សិស្ស |
| ពិន្ទុ ១ | បានចាត់តាំងគ្រូ និងរៀបចំសម្ភារៈដើម្បីដំណើរការកម្មវិធីសិក្សាឬវគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ សហគ្រិនភាព និងបំណិនជីវិតដល់សិស្ស |
| ពិន្ទុ ២ | បានអនុវត្តកម្មវិធីសិក្សាឬវគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ សហគ្រិនភាព និងបំណិនជីវិតដល់សិស្ស |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## ➢ ក្លឹបសិក្សា/បន្ទប់ប្រឹក្សាអាជីព/កងកាយរឹទ្ធិ/កាកបាទក្រហម

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនរៀបចំឱ្យមានដំណើរការក្លឹបសិក្សា/កងកាយរឹទ្ធិ/កាកបាទក្រហម ដើម្បីជួយសិស្សរៀនយឺត ជំរុញចលនាមិត្តជួយមិត្ត និងជួយការងារសង្គមផ្សេងៗ...។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ផែនការដំណើរការងាររបស់ក្លឹបសិក្សា/កងកាយរឹទ្ធិ/កាកបាទក្រហម ២)របាយការណ៍ កម្រងរូបភាព ឬឯកសារបញ្ជាក់អំពីការអនុវត្តការងារនៃក្លឹបសិក្សា/កងកាយរឹទ្ធិ/កាកបាទក្រហម ដូចជាបញ្ជីរាយឈ្មោះនិងកម្មវិធីបង្រៀនបន្ថែម ៣)បន្ទប់បម្រុងសម្រាប់ក្លឹបសិក្សា និង៤)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានក្លឹបសិក្សាយ៉ាងតិច១/បន្ទប់ប្រឹក្សាអាជីព |
| ពិន្ទុ ១ | មានកងកាយរឹទ្ធិ/កាកបាទក្រហម |
| ពិន្ទុ ១ | មានផែនការសម្រាប់ដំណើរការក្លឹបសិក្សា/បន្ទប់ប្រឹក្សាអាជីព/កងកាយរឹទ្ធិ/កាកបាទក្រហម |
| ពិន្ទុ ២ | មានការអនុវត្តសកម្មភាពក្លឹបសិក្សា/បន្ទប់ប្រឹក្សាអាជីព/កងកាយរឹទ្ធិ/កាកបាទក្រហម |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

# ផ្នែកទី៧៖ ការដោះស្រាយបញ្ហាប្រឈមជាមួយប្រជាពលរដ្ឋ អាជ្ញាធរ និងសហគមន៍

## ៧. ការដោះស្រាយបញ្ហាប្រឈមជាមួយប្រជាពលរដ្ឋ អាជ្ញាធរ និងសហគមន៍ (៣៥ពិន្ទុ)

ការកំណត់និងវាយតម្លៃលក្ខណៈវិនិច្ឆ័យស្តីពីការដោះស្រាយបញ្ហាប្រឈមជាមួយប្រជាពលរដ្ឋ និងសហគមន៍ គឺដើម្បីជំរុញឱ្យសាលារៀនយកចិត្តទុកដាក់ដោះស្រាយបញ្ហាប្រឈម ព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ារបស់សិស្ស មាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស ប្រជាពលរដ្ឋ សហគមន៍ និងអ្នកពាក់ព័ន្ធនានា ប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា។ ការដោះស្រាយបញ្ហាប្រឈមជាមួយប្រជាពលរដ្ឋនិងសហគមន៍ នឹងធ្វើឱ្យសាលារៀនកាន់តែទទួលបានទំនុកចិត្តនិងឆ្លើយតបតាមតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍរបស់សហគមន៍ ព្រមទាំងលើកកម្ពស់គុណភាពសេវាអប់រំរបស់សាលារៀន។

នៅក្នុងផ្នែកនៃការដោះស្រាយបញ្ហាប្រឈមជាមួយប្រជាពលរដ្ឋ និងសហគមន៍ មានពិន្ទុសរុបចំនួន**៣៥** ដែលមានលក្ខណៈវិនិច្ឆ័យរងចំនួន២ គឺ៖

**១. យន្តការទទួលព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា** (២០ពិន្ទុ)

**២. ការអនុវត្តវិធានការឆ្លើយតបទៅនឹងបញ្ហាប្រឈមនានា ស្របតាមស្ថានភាពជាក់ស្តែង** (១៥ពិន្ទុ)

## ៧.១ យន្តការទទួលព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា (២០ពិន្ទុ)

### ៧.១.១ ការរៀបចំនិងដំណើរការយន្តការទទួលព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា (២០ពិន្ទុ)

➢ ការរៀបចំយន្តការទទួលព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបចំឱ្យមានយន្តការសម្រាប់ទទួលព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ាពីអ្នកប្រើប្រាស់សេវា ប្រជាពលរដ្ឋ និងសហគមន៍ ដូចជាប្រអប់សំបុត្រ ទូរសព្ទ បណ្តាញទំនាក់ទំនងសង្គម និងការជួបផ្ទាល់ជាលក្ខណៈឯកជន ឬការប្រជុំជាមួយអ្នកអាណាព្យាបាលសិស្ស សហគមន៍ ដើម្បីប្រមូលធាតុចូលក្នុងការកែលម្អគុណភាពសេវារបស់សាលារៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)មធ្យោបាយទទួលព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា ដូចជាប្រអប់សំបុត្រ ទូរសព្ទ បណ្តាញទំនាក់ទំនងសង្គម និងការស្ទង់មតិ ២)របាយការណ៍នៃកិច្ចប្រជុំ ជាលក្ខណៈឯកជន ឬការប្រជុំជាមួយអ្នកអាណាព្យាបាលសិស្ស សហគមន៍ពាក់ព័ន្ធនឹងព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ាពីអ្នកប្រើប្រាស់សេវា ប្រជាពលរដ្ឋ និងសហគមន៍ ៣) លិខិតឬពាក្យបណ្តឹងដែលសាលារៀនទទួលបាន ៤)លិខិតបង្គាប់ការ/សេចក្តីសម្រេចស្តីពីការបែងចែកតួនាទីនិងភារកិច្ចទទួលព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ាពីអ្នកប្រើប្រាស់សេវា ប្រជាពលរដ្ឋ និងសហគមន៍ ៥)ទម្រង់បំពេញផ្តល់ព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា និង៦)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានយន្តការទទួលព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ាក្នុងទម្រង់មិនមែនអេឡិចត្រូនិក ដូចជាប្រអប់សំបុត្រ ការជួបផ្ទាល់ជាលក្ខណៈឯកជន... |
| ពិន្ទុ ១ | មានយន្តការទទួលព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ាក្នុងទម្រង់អេឡិចត្រូនិក ដូចជាលេខទូរសព្ទ បណ្តាញទំនាក់ទំនងសង្គម... |
| ពិន្ទុ ១ | មានបែងចែកតួនាទីនិងភារកិច្ចដើម្បីទទួលព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា |
| ពិន្ទុ ១ | មានទម្រង់បំពេញផ្តល់ព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា |
| ពិន្ទុ ១ | មានប្រជុំជាមួយអ្នកប្រើប្រាស់សេវា ប្រជាពលរដ្ឋ និងសហគមន៍ ដើម្បីផ្សព្វផ្សាយពីយន្តការ និងទទួលព័ត៌មានត្រឡប់និងបណ្តឹងតវ៉ា |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ ការផ្សព្វផ្សាយអំពីយន្តការនិងមធ្យោបាយនៃការផ្តល់ និងការទទួលព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ារបស់សាលារៀន

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបចំធ្វើការផ្សព្វផ្សាយទូលំទូលាយតាមគ្រប់រូបភាព ដូចជាកិច្ចប្រជុំនានា វេទិការបស់រដ្ឋបាល បណ្តាញសង្គម គេហទំព័រ ខិត្តប័ណ្ណ ដែលខ្លឹមសារផ្សព្វផ្សាយមានលក្ខណៈសាមញ្ញ ខ្លី ងាយយល់ និងមានភាពទាក់ទាញឱ្យមានការចូលរួម។

- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១) មធ្យោបាយប្រើប្រាស់សម្រាប់ការផ្សព្វផ្សាយ ដូចជា ខិត្តប័ណ្ណ បណ្តាញទំនាក់ទំនងសង្គម គេហទំព័រ កិច្ចប្រជុំឬវេទិកានានា ២) របាយការណ៍អំពីចំនួនចុះផ្សព្វផ្សាយ ទីតាំង ចំនួនខិត្តប័ណ្ណ កិច្ចសហការរវាងអ្នកស្ម័គ្រចិត្ត អ្នកពាក់ព័ន្ធនានា។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ១ | មានសេចក្តីសម្រេចបង្កើតក្រុមការងារផ្សព្វផ្សាយ |
| ពិន្ទុ១ | មានកម្មវិធីកំណត់ពេលវេលា និងមធ្យោបាយផ្សព្វផ្សាយ |
| ពិន្ទុ១ | មានអត្ថបទ ខ្លឹមសារ រូបភាពស្របនឹងមធ្យោបាយផ្សព្វផ្សាយ |
| ពិន្ទុ២ | របាយការណ៍លទ្ធផល រូបភាពនានាក្នុងពេលផ្សព្វផ្សាយ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីឱ្យអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** សូមគិតថាការផ្សព្វផ្សាយអំពីសាលារៀបចំឱ្យមានការទទួលព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ាជាភារកិច្ចរបស់សាលា និងលោកគ្រូ អ្នកគ្រូ បុគ្គលិកសិក្សាសំដៅឱ្យមានទំនុកចិត្ត ផ្តល់ឱកាសឱ្យមាតាបិតាសិស្សចូលរួមមតិយោបល់ និងចូលរួមអភិវឌ្ឍសាលា។ សាលាអាចប្រើប្រាស់មធ្យោបាយផ្សព្វផ្សាយផ្សេងៗទៀតដែលសាលាមាន និងទទួលលទ្ធផលជាទីមោទនៈ។

➢ ការឆ្លើយតបទៅនឹងព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា តាមពេលវេលាសមស្រប និងតាមករណីនីមួយៗ

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានអនុវត្តវិធីសាស្ត្រផ្សេងៗក្នុងការពិនិត្យ ដោះស្រាយ និងឆ្លើយតបចំពោះសំណូមពរ ព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវា ប្រជាពលរដ្ឋ និងសហគមន៍ បានទាន់ពេលវេលា និងគ្រប់ករណី។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)សេចក្តីសម្រេច/លិខិតបង្គាប់ការស្តីពីការបែងចែកតួនាទីនិងភារកិច្ចសម្រាប់ពិនិត្យ ដោះស្រាយ និងឆ្លើយតបចំពោះសំណូមពរ ព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា ២)របាយការណ៍/កំណត់ហេតុប្រជុំស្តីពីការដោះស្រាយសំណូមពរ និងឆ្លើយតបព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា ៣)ឯកសារបញ្ជាក់អំពីការទទួលពិនិត្យ ដោះស្រាយ និងឆ្លើយតបចំពោះសំណូមពរ ព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា ៤)បញ្ជរ/ក្តារខៀនផ្សព្វផ្សាយព័ត៌មានអំពីដំណោះស្រាយចំពោះសំណូមពរ ព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា ៥)កំណត់ហេតុនៃការអញ្ជើញអ្នកផ្តល់ព័ត៌មាន ឬដើមបណ្តឹង ដើម្បីឆ្លើយតបទៅនឹង ករណីនីមួយៗ ៦)ការឆ្លើយតបតាមប្រព័ន្ធបណ្តាញទំនាក់ទំនងសង្គម សារព័ត៌មាន និងសេចក្តីប្រកាសព័ត៌មាន និង៧)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានសេចក្តីសម្រេច/លិខិតបង្គាប់ការស្តីពីការបែងចែកក្រុមការងារសម្រាប់ដោះស្រាយសំណូមពរ ព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា |
| ពិន្ទុ ១ | មានការរៀបចំកិច្ចប្រជុំដោះស្រាយសំណូមពរ ព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា តាមករណីនីមួយៗ |
| ពិន្ទុ ១ | មានកន្លែងសម្រាប់ឆ្លើយតបចំពោះសំណូមពរ ព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា |
| ពិន្ទុ ២ | មានការផ្សព្វផ្សាយអំពីដំណោះស្រាយរបស់សាលារៀនចំពោះសំណូមពរ ព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា តាមមធ្យោបាយផ្សេងៗ ដូចជាលិខិត ក្តារខៀន/បញ្ជរព័ត៌មាន បណ្តាញទំនាក់ទំនងសង្គម សារព័ត៌មាន និងសេចក្តីប្រកាសព័ត៌មាន |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីឱ្យអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** រាល់ព័ត៌មានដែលជាសំណូមពរក្តី បណ្តឹងក្តី មតិរិះគន់ក្តី ត្រូវតែចុះបញ្ជីក្នុងសៀវភៅរដ្ឋឱ្យបានត្រឹមត្រូវ ហើយករណីនីមួយៗត្រូវបញ្ជាក់ពីអ្នកឬក្រុមការងារដែលត្រូវទទួលដោះស្រាយ និងបញ្ជាក់ពីការបិទបញ្ចប់នៃករណីនីមួយៗ ឬបញ្ជាក់ពីនីតិវិធីសម្រាប់ដោះស្រាយបន្ត...។ល។

### ➢ ការផ្សព្វផ្សាយជាសាធារណៈនូវការឆ្លើយតបព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា

- ***សេចក្តីពន្យល់៖*** សំដៅដល់ការឆ្លើយតបជាវិជ្ជមាន និងជាលាយលក្ខណ៍អក្សរជូនមាតាបិតា អ្នកអាណាព្យាបាល និងអ្នកពាក់ព័ន្ធនានា ទោះបីមតិយោបល់ ព័ត៌មាន ឬបណ្តឹងតវ៉ានោះទទួលបានដោយផ្ទាល់ ប្រយោល ឬជាលក្ខណៈអនាមិក។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១) សេចក្តីសម្រេចបង្កើតក្រុមការងារដោះស្រាយទំនាស់ដោយមានចែងច្បាស់លាស់អំពីការកត់ត្រាមតិយោបល់ នីតិវិធីការងារ និងកាលបរិច្ឆេទផ្សព្វផ្សាយ។ ២) កំណត់ហេតុ របាយការណ៍ សម្រាំងមតិយោបល់ ៣) សេចក្តីសម្រេច លិខិតជូនដំណឹង ត្រូវបានផ្សព្វផ្សាយជាសាធារណៈតាមរយៈមធ្យោបាយ ឧបករណ៍ដែលសាលាមាន។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ១ | បញ្ជីកត់ត្រាមតិយោបល់ ឬបណ្តឹងតវ៉ា |
| ពិន្ទុ១ | សេចក្តីសម្រេចបង្កើតគណៈកម្មាធិការ ឬក្រុមការងារដោះស្រាយទំនាស់ |
| ពិន្ទុ១ | កិច្ចប្រជុំ កំណត់ហេតុ របាយការណ៍ សម្រាំងមតិយោបល់ ឬបណ្តឹងតវ៉ា |
| ពិន្ទុ២ | សេចក្តីសម្រេច លិខិតជូនដំណឹងលទ្ធផលចុងក្រោយ និងបានបិទបង្ហាញ ឬបានផ្សព្វផ្សាយជាសាធារណៈ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីឱ្យអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ការរៀបចំសៀវភៅកត់ត្រាដោយមានបែងចែកតាមប្រភេទមតិយោបល់ ឧទាហរណ៍ ផ្ទាល់មាត់ តាមទូរសព្ទ chat តាម telegram គេហទំព័រ តាមវេទិកានានា តាមការផ្ញើផ្ញើ ឬប្រអប់សំបុត្រ ដោយរំលេចអំពីប្រភេទមតិយោបល់ ឬបណ្តឹងតវ៉ាដែលលាក់អាសយដ្ឋាន(អនាមិក)។

## ៧.២ ការអនុវត្តវិធានការឆ្លើយតបទៅនឹងបញ្ហាប្រឈមនានា ស្របតាមស្ថានភាពជាក់ស្តែង (១៥ពិន្ទុ)

### ៧.២.១ កិច្ចសហការជាមួយមាតាបិតា អ្នកអាណាព្យាបាល និងអាជ្ញាធរដែនដី ដើម្បីដោះស្រាយបញ្ហាប្រឈម (១៥ពិន្ទុ)

➢ មានការប្រជុំក្រុមប្រឹក្សាភិបាល(ក.ប.ស)/គណៈកម្មការគ្រប់គ្រងសាលារៀន(គ.គ.ស)/គណៈកម្មការទ្រទ្រង់សាលារៀន(គ.ទ.ស)

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនមានការរៀបចំកិច្ចប្រជុំ**ក.ប.ស** ឬ **គ.គ.ស** ឬ **គ.ទ.ស** ជាទៀងទាត់ ដើម្បីពិភាក្សាស្វែងរកគំនិតល្អៗ ក្នុងការចូលរួមចំណែករកដំណោះស្រាយចំពោះបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងដំណើរការ និងការអភិវឌ្ឍសាលារៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)សេចក្តីសម្រេចបង្កើត ក.ប.ស/គ.គ.ស/គ.ទ.ស ២)ផែនការប្រជុំ ៣)ឯកសារបញ្ជាក់អំពីការរៀបចំកិច្ចប្រជុំ(លិខិតអញ្ជើញ របៀបវារៈ បញ្ជីវត្តមាន កម្រងរូបភាពនៃកិច្ចប្រជុំ...) ៤)របាយការណ៍/កំណត់ហេតុលទ្ធផលនៃកិច្ចប្រជុំ និង៥)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានសេចក្តីសម្រេចបង្កើត ក.ប.ស/គ.គ.ស/គ.ទ.ស |
| ពិន្ទុ ១ | មានផែនការប្រជុំរបស់ **ក.ប.ស** ឬ **គ.គ.ស** ឬ **គ.ទ.ស** (ប្រជុំប្រចាំត្រីមាស ឆមាស និងឆ្នាំ ឬតាមការចាំបាច់) |
| ពិន្ទុ ១ | មានការរៀបចំកិច្ចប្រជុំរបស់ **ក.ប.ស** ឬ **គ.គ.ស** ឬ **គ.ទ.ស** តាមផែនការដែលបានកំណត់ |
| ពិន្ទុ ២ | មានការផ្សព្វផ្សាយរបាយការណ៍/កំណត់ហេតុ/លទ្ធផលនៃកិច្ចប្រជុំរបស់ **ក.ប.ស** ឬ **គ.គ.ស** ឬ **គ.ទ.ស** ជាសាធារណៈ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីឱ្យអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ការប្រជុំរបស់ **ក.ប.ស** ឬ **គ.គ.ស** ឬ **គ.ទ.ស** ត្រូវមាននៅក្នុងផែនការប្រជុំប្រចាំត្រីមាស ឆមាស និងឆ្នាំ ឬតាមការចាំបាច់ សំដៅប្រមូលគ្រប់ព័ត៌មាន ដើម្បីចូលរួមកែលម្អនិងអភិវឌ្ឍសាលារៀន។

➢ មានការកែលម្អការផ្តល់សេវាផ្អែកលើព័ត៌មានត្រឡប់របស់អ្នកប្រើប្រាស់សេវា សហគមន៍ និងអាជ្ញាធរដែនដី

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានទទួលយក និងអនុវត្តវិធានការកែលម្អការផ្តល់សេវារបស់សាលារៀន ដោយផ្អែកតាមព័ត៌មានត្រឡប់របស់អ្នកប្រើប្រាស់សេវា សហគមន៍ និងអាជ្ញាធរដែនដី ដើម្បីធ្វើឱ្យអ្នកប្រើប្រាស់សេវាកាន់តែមានលក្ខណៈងាយស្រួល រហ័សទាន់ចិត្ត និងភាពទុកចិត្តបាន។

- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)របាយការណ៍កិច្ចប្រជុំពិភាក្សាអំពីគុណភាពនៃការផ្តល់សេវារបស់សាលារៀន ២)របាយការណ៍ស្តីពីការចុះស្ទង់មតិអំពីការផ្តល់សេវារបស់សាលារៀន(សម្ភាសផ្ទាល់ ឬកម្រងសំណួរ) ៣)របាយការណ៍ ឬកម្រងរូបភាពស្តីពីទស្សនកិច្ចសិក្សារបស់សាលារៀន ដើម្បីស្រង់បទពិសោធ និងការចូលរួមសិក្ខាសាលា និង៤)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានការរៀបចំកិច្ចប្រជុំពិភាក្សាអំពីគុណភាពនៃការផ្តល់សេវារបស់សាលារៀន ជាមួយអ្នកប្រើប្រាស់សេវា ប្រជាពលរដ្ឋ សហគមន៍ និងអាជ្ញាធរដែនដី |
| ពិន្ទុ ១ | មានការចុះស្ទង់មតិអំពីការផ្តល់សេវារបស់សាលារៀន(សម្ភាសផ្ទាល់ ឬកម្រងសំណួរ) |
| ពិន្ទុ ១ | មានការរៀបចំឬបញ្ជូនបុគ្គលិកអប់រំទៅចូលរួមទស្សនកិច្ចសិក្សា ឬសិក្ខាសាលាផ្លាស់ប្តូរបទពិសោធនានា |
| ពិន្ទុ ២ | មានការប្រើប្រាស់មតិយោបល់ដែលទទួលបានពីអ្នកប្រើប្រាស់សេវា ប្រជាពលរដ្ឋ សហគមន៍ និងអាជ្ញាធរដែនដី ដើម្បីកែលម្អគុណភាពនៃការផ្តល់សេវារបស់សាលារៀន |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីឱ្យអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** ការផ្តល់សេវាដល់អ្នកប្រើប្រាស់ត្រូវគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយ និងត្រូវប្រមូលព័ត៌មានត្រឡប់ពីអ្នកប្រើប្រាស់សេវា (អនុវត្តការកែលម្អផ្អែកលើព័ត៌មានត្រឡប់ រួចជម្រាបជូនដំណឹងដល់អ្នកប្រើប្រាស់សេវាវិញ)។

➢ <u>មានការគាំទ្រ និងជំរុញដល់មាតាបិតា ឬអ្នកអាណាព្យាបាលសិស្សជួយសិស្សរៀនយឺត និងសិស្សរៀនពូកែ/សិស្សដែលមានបញ្ហាខ្ពស់</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់សាលារៀនបានរៀបចំយន្តការតាមដានការសិក្សារបស់សិស្ស ផែនការ/កម្មវិធីបំប៉ន ដោយសហការជាមួយមាតាបិតា និងអ្នកអាណាព្យាបាលសិស្ស ក្នុងការជាស់តឿនជំរុញ និងផ្តល់ឱកាសដល់សិស្សរៀនយឺត សិស្សពូកែ/សិស្សដែលមានបញ្ហាខ្ពស់ ដើម្បីលើកកម្ពស់គុណភាពនៃការសិក្សាស្របតាមកម្រិតថ្នាក់ និងតាមទេពកោសល្យរបស់សិស្ស។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)សេចក្តីសម្រេច/លិខិតបង្គាប់ការស្តីពីការបង្កើតក្រុមការងារពិនិត្យតាមដានការសិក្សារបស់សិស្ស ២)ពិនិត្យតារាងពិន្ទុប្រចាំខែ ប្រចាំត្រីមាស និងឆមាសរបស់សិស្សតាមថ្នាក់ ៣)ផែនការ/កម្មវិធីបំប៉ន ៤)របាយការណ៍វឌ្ឍនភាពនៃផែនការ/កម្មវិធីបំប៉ន និង៥)ការសម្ភាសជាមួយភាគីពាក់ព័ន្ធ។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | មានសេចក្តីសម្រេច/លិខិតបង្គាប់ការស្តីពីការបង្កើតក្រុមការងារពិនិត្យតាមដានការសិក្សារបស់សិស្ស |
| ពិន្ទុ ១ | មានផែនការ/កម្មវិធីបំប៉នសិស្សរៀនយឺត សិស្សពូកែ និងសិស្សដែលមានបញ្ហាខ្ពស់ |
| ពិន្ទុ ១ | មានកាលវិភាគបែងចែកគ្រូសម្រាប់បំប៉នសិស្សរៀនយឺត សិស្សពូកែ និងសិស្សដែលមានបញ្ហាខ្ពស់ |
| ពិន្ទុ ១ | មានការរៀបចំកិច្ចប្រជុំ ឬការធ្វើការទំនាក់ទំនងជាមួយមាតាបិតា ឬអ្នកអាណាព្យាបាលរបស់សិស្សរៀនយឺត សិស្សពូកែ និងសិស្សដែលមានបញ្ហាខ្ពស់ |
| ពិន្ទុ ១ | មានរង្វាន់លើកទឹកចិត្តដល់លោកគ្រូ អ្នកគ្រូ ដែលបង្រៀនបំប៉នសិស្សរៀនយឺត សិស្សពូកែ និងសិស្សដែលមានបញ្ហាខ្ពស់ |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- ***ចំណុចបញ្ជាក់បន្ថែមដើម្បីឱ្យអ្នកអានយល់កាន់តែច្បាស់អំពីលក្ខណៈវិនិច្ឆ័យ៖*** យើងត្រូវពិនិត្យមើលទៅលើផែនការសកម្មភាពប្រចាំឆ្នាំរបស់សាលារៀន ទៅតាមកម្រិតថ្នាក់នីមួយៗ ថាតើក្នុងករណីមានសិស្សរៀនយឺត សាលាចាត់វិធានការដូចម្តេចខ្លះ? (ពិនិត្យលើឯកសារដែលមាន ឬសម្ភាសអ្នកពាក់ព័ន្ធ)។

# ផ្នែកទី៨៖ ការផ្តួចផ្តើមគំនិតថ្មីៗ និងនវានុវត្តន៍ដើម្បីធ្វើឱ្យអង្គភាពមានដំណើរការកាន់តែប្រសើរឡើង

## ៨. ការផ្តួចផ្តើមគំនិតថ្មីៗ និងនវានុវត្តន៍ ដើម្បីធ្វើឱ្យអង្គភាពមានដំណើរការកាន់តែប្រសើរ (៤៥ពិន្ទុ)

ការកំណត់យក “***ការផ្តួចផ្តើមគំនិតថ្មីៗនិងនវានុវត្តន៍ ដើម្បីធ្វើឱ្យអង្គភាពមានដំណើរការកាន់តែប្រសើរ***” ជាលក្ខណៈវិនិច្ឆ័យគោលក្នុងការវាយតម្លៃសាលារៀនគឺក្នុងគោលបំណងជំរុញឱ្យសាលារៀនយកចិត្តទុកដាក់ គិតគូរ និងផ្តល់តម្លៃទៅលើការផ្តួចផ្តើមនិងការអនុវត្តគំនិតនវានុវត្តន៍និងការច្នៃប្រឌិត ដើម្បីរួមចំណែកក្នុងការកែលម្អគុណភាពសេវានានារបស់សាលារៀនឆ្លើយតបទៅនឹងតម្រូវការនិងការវិវត្តន៍ថ្មីៗនៃបច្ចេកវិទ្យា សេដ្ឋកិច្ច និងសង្គម។

ពាក្យ “**នវានុវត្តន៍និងការច្នៃប្រឌិត**” សំដៅដល់ការរិះរកនូវគំនិតថ្មីៗក្នុងការកែសម្រួលឬធ្វើឱ្យប្រសើរឡើងនូវនីតិវិធី វិធីសាស្ត្រ ឬមធ្យោបាយ ដែលកំពុងអនុវត្តក្នុងការផ្តល់សេវាសាធារណៈរបស់អង្គភាព ដើម្បីធ្វើឱ្យការផ្តល់សេវារបស់អង្គភាពបានរហ័ស សាមញ្ញ និងប្រកបដោយប្រសិទ្ធផលខ្ពស់ជាងមុន។

នៅក្នុងផ្នែកនៃការផ្តួចផ្តើមគំនិតថ្មីៗ និងនវានុវត្តន៍ដើម្បីធ្វើឱ្យអង្គភាពមានដំណើរការកាន់តែប្រសើរ មានពិន្ទុសរុបចំនួន៤៥ ដែលមានលក្ខណៈវិនិច្ឆ័យរងចំនួន២ គឺ៖

**១. ការបញ្ច្រាបការយល់ដឹងនិងការបំផុសគំនិតនវានុវត្តន៍និងការច្នៃប្រឌិតក្នុងអង្គភាពផ្តល់សេវា** (៣៥ពិន្ទុ)

**២.ការធ្វើឱ្យមាននិរន្តរភាពការអនុវត្តគំនិតនវានុវត្តន៍ដែលទទួលបានជោគជ័យ និងចែករំលែកជាមួយអង្គភាពដទៃ** (១០ពិន្ទុ)

## ៨.១.ការបញ្ជ្រាបការយល់ដឹងនិងការអនុវត្តគំនិតនវានុវត្តន៍និងការច្នៃប្រឌិតក្នុងអង្គភាពផ្តល់សេវា (៣៥ពិន្ទុ)

### ៨.១.១ ការបញ្ជ្រាបការយល់ដឹងពីនវានុវត្តន៍និងការច្នៃប្រឌិតដល់បុគ្គលិកអប់រំរបស់សាលារៀន(៥ពិន្ទុ)

➢ មានការផ្សព្វផ្សាយ ការបណ្តុះបណ្តាល ឬការចែករំលែកចំណេះដឹងពាក់ព័ន្ធនឹងនវានុវត្តន៍និងការច្នៃប្រឌិតដល់មន្ត្រីក្នុងអង្គភាពសាលារៀន

- ***សេចក្តីពន្យល់៖*** សំដៅដល់សកម្មភាពរបស់សាលារៀនក្នុងការផ្តល់ព័ត៌មាន ការរៀបចំឬបញ្ជូនមន្ត្រីរបស់សាលារៀន ឱ្យចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលចែករំលែកចំណេះដឹងពាក់ព័ន្ធនឹងនវានុវត្តន៍ និងការច្នៃប្រឌិត ដែលនាំឱ្យមន្ត្រីបានយល់ដឹងអំពីទស្សនទានថ្មីនេះ ហើយអាចគិតគូរវិធីសាស្ត្រថ្មីៗរួមចំណែកបង្កើនគុណភាពនិងប្រសិទ្ធភាពនៃការផ្តល់សេវារបស់សាលារៀន។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)របាយការណ៍នៃការបណ្តុះបណ្តាល ការផ្សព្វផ្សាយ និងការបញ្ជ្រាបការយល់ដឹងអំពីនវានុវត្តន៍និងការច្នៃប្រឌិតរបស់សាលារៀន ២)ឯកសារ ឬឧបករណ៍ដែលបានប្រើប្រាស់ក្នុងការផ្សព្វផ្សាយ និង៣)ការសម្ភាសជាមួយគណៈគ្រប់គ្រង និងបុគ្គលិកដែលធ្លាប់ទទួលបានការបណ្តុះបណ្តាល។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥(គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | បានបញ្ជូនមន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាល ឬកម្មវិធីចែករំលែកចំណេះដឹងស្តីពីនវានុវត្តន៍ និងការច្នៃប្រឌិត |
| ពិន្ទុ ១ | បានរៀបចំកម្មវិធី ឬវគ្គចែករំលែកចំណេះដឹងស្តីពីនវានុវត្តន៍ និងការច្នៃប្រឌិតក្នុងអង្គភាពសាលារៀន |
| ពិន្ទុ ៣ | មន្ត្រីចាប់ពី៥០ភាគរយឡើង យល់ដឹងពីនវានុវត្តន៍ និងការច្នៃប្រឌិត |
| ពិន្ទុ ០ | មិនមានគ្រប់បណ្តាចំណុចខាងលើ |

### ៨.១.២ ការផ្តួចផ្តើមនិងអនុវត្តនវានុវត្តន៍ និងការច្នៃប្រឌិតក្នុងការគ្រប់គ្រងនិងការផ្តល់សេវារបស់សាលារៀន (៣០ពិន្ទុ)

➢ មានការផ្តួចផ្តើមនិងអនុវត្តគំនិតនវានុវត្តន៍និងការច្នៃប្រឌិតក្នុងការផ្តល់សេវារដ្ឋបាលរបស់សាលារៀន

- ***សេចក្តីពន្យល់៖*** សំដៅដល់ការអនុវត្តគំនិតឬវិធីសាស្ត្រឬមធ្យោបាយថ្មីៗដែលពុំធ្លាប់បានអនុវត្តក្នុងអង្គភាព ដែលបាននាំឱ្យគុណភាពសេវារដ្ឋបាលរបស់សាលាកាន់តែប្រសើរ ពិសេសគឺ ឆាប់រហ័សឬកាត់បន្ថយការរង់ចាំ កាត់បន្ថយភាពស្មុគស្មាញក្នុងការបំពេញបែបបទ និងឯកសារតម្រូវ និងការយកចិត្តទុកដាក់បម្រើសេវា ជាដើម។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)របាយការណ៍សកម្មភាពនៃការរៀបចំនិងការអនុវត្តនវានុវត្តន៍ និងការច្នៃប្រឌិតកែលម្អការផ្តល់សេវារដ្ឋបាលរបស់សាលារៀន ២)ការប្រែប្រួលនៃការផ្តល់សេវារដ្ឋបាលរបស់សាលារៀន និង ៣)ការសម្ភាសជាមួយអ្នកពាក់ព័ន្ធ។

- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | បានផ្តួចផ្តើមនិងមានការរៀបចំអនុវត្តនវានុវត្តន៍ និងការច្នៃប្រឌិតកែលម្អការផ្តល់សេវារដ្ឋបាលរបស់សាលារៀន |
| ពិន្ទុ ៣ | បានអនុវត្តនវានុវត្តន៍និងការច្នៃប្រឌិតធ្វើឱ្យការផ្តល់សេវារដ្ឋបាលសាលារៀនប្រសើរឡើង |
| ពិន្ទុ ១ | បានត្រួតពិនិត្យវាយតម្លៃនិងកែលម្អការអនុវត្តនវានុវត្តន៍និងការច្នៃប្រឌិតធ្វើឱ្យការផ្តល់សេវារដ្ឋបាលសាលារៀនប្រសើរឡើង |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ **<u>មានផ្តួចផ្តើមនិងអនុវត្តគំនិតនវានុវត្តន៍និងការច្នៃប្រឌិតលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការបង្រៀននិងរៀន</u>**

- ***សេចក្តីពន្យល់៖*** សំដៅដល់ការអនុវត្តគំនិតផ្តួចផ្តើម នីតិវិធី វិធីសាស្ត្រ ឬមធ្យោបាយបង្រៀនថ្មីៗ ដែលនាំឱ្យការបង្រៀននិងរៀនមានភាពប្រសើរឡើង។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)របាយការណ៍សកម្មភាពនៃការរៀបចំនិងការអនុវត្តនវានុវត្តន៍និងការច្នៃប្រឌិតកែលម្អការបង្រៀននិងរៀន ២)ការប្រែប្រួលនៃការអនុវត្តវិធីសាស្ត្រនិងលទ្ធផលនៃការបង្រៀននិងរៀន និង៣)ការសម្ភាសជាមួយអ្នកពាក់ព័ន្ធ។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | បានផ្តួចផ្តើមនិងមានការរៀបចំអនុវត្តនវានុវត្តន៍និងការច្នៃប្រឌិតលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការរៀន និងបង្រៀន |
| ពិន្ទុ ៣ | បានអនុវត្តនវានុវត្តន៍ និងការច្នៃប្រឌិតលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការរៀននិងបង្រៀន |
| ពិន្ទុ ១ | បានត្រួតពិនិត្យ វាយតម្លៃ និងកែលម្អការអនុវត្តនវានុវត្តន៍និងការច្នៃប្រឌិតលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការរៀននិងបង្រៀន |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ **<u>មានការផ្តួចផ្តើមនិងអនុវត្តគំនិតនវានុវត្តន៍ និងការច្នៃប្រឌិតក្នុងការកៀរគរធនធានសម្រាប់គាំទ្រដល់ដំណើរការនិងការអភិវឌ្ឍសាលារៀន</u>**

- ***សេចក្តីពន្យល់៖*** សំដៅដល់ការរិះរកនូវវិធីសាស្ត្រឬមធ្យោបាយថ្មីៗ ដែលអាចទាក់ទាញឱ្យមានការចាប់អារម្មណ៍ និងការចូលរួមដោយស្ម័គ្រចិត្តរបស់សហគមន៍ អាជ្ញាធរ និងដៃគូអភិវឌ្ឍនានា ផ្តល់ការគាំទ្រដល់ដំណើរការនិងការអភិវឌ្ឍសាលារៀនក្នុងគ្រប់រូបភាព ដូចជា ការជួយជាការផ្តល់គំនិតយោបល់ ការចូលរួមជួយជាកម្លាំងពលកម្ម និងធនធានជាដើម។

- *ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖* ចំណុចត្រូវពិនិត្យគឺ ១)របាយការណ៍សកម្មភាពនៃការរៀបចំ និងការអនុវត្តនវានុវត្តន៍និងការច្នៃប្រឌិតលើការកៀរគរធនធានគាំទ្រដំណើរការ និងការអភិវឌ្ឍសាលារៀន ២)របាយការណ៍និង/ឬបញ្ជីវិភាគទានរបស់សប្បុរសជនគាំទ្រសាលារៀន និង៣)ការសម្ភាសជាមួយអ្នកពាក់ព័ន្ធ។
- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ១ | បានផ្តួចផ្តើមនិងមានការរៀបចំអនុវត្តនវានុវត្តន៍និងការច្នៃប្រឌិតលើការកៀរគរធនធានគាំទ្រដំណើរការ និងការអភិវឌ្ឍសាលារៀន |
| ពិន្ទុ ៣ | បានអនុវត្តនវានុវត្តន៍និងការច្នៃប្រឌិតលើការកៀរគរធនធានគាំទ្រដំណើរការនិងការអភិវឌ្ឍសាលារៀន |
| ពិន្ទុ ១ | បានត្រួតពិនិត្យវាយតម្លៃនិងកែលម្អការអនុវត្តនវានុវត្តន៍និងការច្នៃប្រឌិតលើការកៀរគរធនធានគាំទ្រដំណើរការនិងការអភិវឌ្ឍសាលារៀន |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

➢ **មានការផ្តួចផ្តើមនិងអនុវត្តគំនិតនវានុវត្តន៍និងការច្នៃប្រឌិតក្នុងការគ្រប់គ្រងហិរញ្ញវត្ថុដែលទទួលបានពីសហគមន៍និងសប្បុរសជនប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព**

- *សេចក្តីពន្យល់៖* សំដៅដល់ការប្រើប្រាស់វិធីសាស្ត្រឬរបៀបថ្មីក្នុងការគ្រប់គ្រងហិរញ្ញវត្ថុរបស់អង្គភាពដែលទទួលបានពីសហគមន៍និងសប្បុរសជន ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។
- *ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖* ចំណុចត្រូវពិនិត្យគឺ ១)របាយការណ៍សកម្មភាពនៃការរៀបចំ និងការអនុវត្តនវានុវត្តន៍និងការច្នៃប្រឌិតលើការគ្រប់គ្រងហិរញ្ញវត្ថុ ២)របាយការណ៍ឬភស្តុតាងដែលបង្ហាញពីប្រសិទ្ធភាពនៃការអនុវត្តនវានុវត្តន៍និងការច្នៃប្រឌិតក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និង៣)ការសម្ភាសជាមួយអ្នកពាក់ព័ន្ធ។
- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ១ | បានផ្តួចផ្តើមនិងមានការរៀបចំអនុវត្តនវានុវត្តន៍ និងការច្នៃប្រឌិតលើការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាព |
| ពិន្ទុ ៣ | បានអនុវត្តនវានុវត្តន៍ និងការច្នៃប្រឌិតលើការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព |
| ពិន្ទុ ១ | បានត្រួតពិនិត្យវាយតម្លៃ និងកែលម្អការអនុវត្តនវានុវត្តន៍និងការច្នៃប្រឌិតលើការកៀរគរធនធានគាំទ្រដំណើរការនិងការអភិវឌ្ឍសាលារៀន |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- <u>មានការផ្តួចផ្តើមនិងអនុវត្តគំនិតនវានុវត្តន៍ និងការច្នៃប្រឌិតក្នុងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស</u>

  - ***សេចក្តីពន្យល់៖*** សំដៅដល់គណៈគ្រប់គ្រងនិងបុគ្គលិកសាលារៀនមានការវិភាគ ពិភាក្សា កំណត់ និងអនុវត្តគំនិតនិងវិធីសាស្ត្រ ឬមធ្យោបាយថ្មីៗក្នុងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្ស ដើម្បីធ្វើឱ្យមានការកើនឡើងនូវសមិទ្ធកម្មរបស់មន្ត្រី និងអង្គភាព។
  - ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)របាយការណ៍សកម្មភាពនៃការរៀបចំ និងការអនុវត្តនវានុវត្តន៍និងការច្នៃប្រឌិតលើការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្ស ២)របាយការណ៍ ឬភស្តុតាងដែលបង្ហាញពីប្រសិទ្ធភាពនៃការអនុវត្តនវានុវត្តន៍ និងការច្នៃប្រឌិតលើការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស និង៣)ការសម្ភាសជាមួយអ្នកពាក់ព័ន្ធ។
  - ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | បានផ្តួចផ្តើមនិងមានការរៀបចំអនុវត្តនវានុវត្តន៍និងការច្នៃប្រឌិតលើការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សរបស់សាលារៀន |
| ពិន្ទុ ៣ | បានអនុវត្តនវានុវត្តន៍និងការច្នៃប្រឌិតលើការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សរបស់សាលារៀន |
| ពិន្ទុ ១ | បានត្រួតពិនិត្យវាយតម្លៃនិងកែលម្អការអនុវត្តនវានុវត្តន៍និងការច្នៃប្រឌិតលើការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សរបស់សាលារៀន |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

- <u>មានការផ្តួចផ្តើមនិងអនុវត្តគំនិតនវានុវត្តន៍និងការច្នៃប្រឌិតក្នុងការរៀបចំ និងកែលម្អបរិស្ថានអង្គភាព</u>

  - ***សេចក្តីពន្យល់៖*** សំដៅដល់ការប្រើប្រាស់វិធីសាស្ត្រ (មធ្យោបាយ ឧបករណ៍ ឬបច្ចេកវិទ្យាថ្មីៗ) ក្នុងការរៀបចំនិងធ្វើឱ្យប្រសើរឡើងនូវបរិស្ថាន សោភណភាព និងបរិយាកាសក្នុងសាលារៀន(ទីធ្លា កន្លែងលេងកីឡា សួនច្បារ ប្រព័ន្ធលូ ផ្លូវដើរ អគារ និងបន្ទប់ផ្សេងៗរបស់សាលារៀនជាដើម)។
  - ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យ គឺ ១)របាយការណ៍សកម្មភាពនៃការរៀបចំ និងការអនុវត្តនវានុវត្តន៍និងការច្នៃប្រឌិតលើការរៀបចំនិងកែលម្អបរិស្ថានសាលារៀន ២)របាយការណ៍ ឬភស្តុតាងដែលបង្ហាញពីប្រសិទ្ធភាពនៃការអនុវត្តនវានុវត្តន៍ និងការច្នៃប្រឌិតលើការរៀបចំ និងកែលម្អបរិស្ថានសាលារៀន និង៣)ការសម្ភាសជាមួយអ្នកពាក់ព័ន្ធ។
  - ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ១ | បានផ្តួចផ្តើមនិងមានការរៀបចំអនុវត្តនវានុវត្តន៍និងការច្នៃប្រឌិតលើការរៀបចំ និងកែលម្អបរិស្ថានសាលារៀន |
| ពិន្ទុ ៣ | បានអនុវត្តនវានុវត្តន៍និងការច្នៃប្រឌិតលើការរៀបចំ និងកែលម្អបរិស្ថានសាលារៀន |

| | |
|---|---|
| ពិន្ទុ ១ | បានត្រួតពិនិត្យ វាយតម្លៃ និងកែលម្អការអនុវត្តនវានុវត្តន៍និងការច្នៃប្រឌិតលើការរៀបចំ និងកែលម្អបរិស្ថានសាលារៀន |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## ៨.២. ការធ្វើឱ្យមាននិរន្តរភាពការអនុវត្ត គំនិតនវានុវត្តន៍ដែលទទួលបានជោគជ័យ និងចែករំលែកជាមួយ អង្គភាពដទៃ (១០ពិន្ទុ)

### ៨.២.១ ការគាំទ្រនិងការលើកទឹកចិត្តចំពោះគំនិតនវានុវត្តន៍និងការច្នៃប្រឌិត (៥ពិន្ទុ)

➢ បានកំណត់គោលការណ៍និងអនុវត្តការគាំទ្រ និងលើកទឹកចិត្តចំពោះការផ្តួចផ្តើម និងការអនុវត្តគំនិតនវានុវត្តន៍និងការច្នៃប្រឌិតក្នុងអង្គភាព

- *សេចក្តីពន្យល់៖* សំដៅដល់ការរៀបចំគោលការណ៍និងការអនុវត្តការគាំទ្រនិងការលើកទឹកចិត្តចំពោះថ្នាក់ដឹកនាំ គ្រូបង្រៀន និងបុគ្គលិកក្នុងអង្គភាព ដែលបង្កលក្ខណៈឱ្យពួកគាត់មានកម្លាំងចិត្តក្នុងការរិះរកនូវវិធីសាស្ត្រ ឬមធ្យោបាយថ្មីៗ ដើម្បីធ្វើឱ្យការផ្តល់សេវារបស់អង្គភាពមានភាពប្រសើរជាងមុន។
- *ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖* ចំណុចត្រូវពិនិត្យគឺ ១)គោលការណ៍ដែលបានរៀបចំ ២)គំនិតនវានុវត្តន៍និងការច្នៃប្រឌិតដែលបានកើតឡើង និង៣)ការសម្ភាសជាមួយថ្នាក់ដឹកនាំ គ្រូបង្រៀន និងបុគ្គលិកក្នុងសាលារៀន។
- *របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖*

| | |
|---|---|
| ពិន្ទុ ១ | មានគោលការណ៍សម្រាប់គាំទ្រនិងលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ គ្រូបង្រៀននិងបុគ្គលិកក្នុងសាលារៀន |
| ពិន្ទុ ១ | បានផ្សព្វផ្សាយគោលការណ៍សម្រាប់គាំទ្រនិងលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ គ្រូបង្រៀន និងបុគ្គលិកក្នុងសាលារៀន |
| ពិន្ទុ ១ | បានអនុវត្តគោលការណ៍សម្រាប់គាំទ្រនិងលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ គ្រូបង្រៀន និងបុគ្គលិកក្នុងសាលារៀន |
| ពិន្ទុ ១ | មានវប្បធម៌ទទួលយកនិងលើកទឹកចិត្តអ្នកដែលមានគំនិតនវានុវត្តន៍ និងការច្នៃប្រឌិត |
| ពិន្ទុ ១ | មានមធ្យោបាយគាំទ្រឱ្យការអនុវត្តគំនិតនវានុវត្តន៍ និងការច្នៃប្រឌិត ដំណើរការល្អនិងមាននិរន្តរភាព |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

### ៨.២.២ ការចងក្រង និងចែករំលែកគំនិតនវានុវត្តន៍និងការច្នៃប្រឌិតរបស់អង្គភាព (៥ពិន្ទុ)

➢ <u>បានចងក្រងនិងផ្សព្វផ្សាយ ឬចែករំលែកគំនិតនវានុវត្តន៍ និងការច្នៃប្រឌិតដែលបានអនុវត្តនិងទទួលបានលទ្ធផលល្អដល់អង្គភាពផ្តល់សេវាដទៃ</u>

- ***សេចក្តីពន្យល់៖*** សំដៅដល់ការចងក្រងជាឯកសារដែលពន្យល់អំពីគំនិតនវានុវត្តន៍និងការច្នៃប្រឌិតដែលអង្គភាពបានអនុវត្តនិងទទួលបានជោគជ័យ ដោយពន្យល់បានច្បាស់លាស់អំពីរបៀបនៃការអនុវត្ត ព្រមទាំងធ្វើការផ្សព្វផ្សាយ ឬចែករំលែកដល់អង្គភាពផ្តល់សេវាដទៃទៀត ដើម្បីជំរុញឱ្យមានការអនុវត្តបែបថ្មីនោះ បានទូលំទូលាយក្នុងគោលបំណងធ្វើឱ្យមានចលនាក្នុងការកែលម្អការផ្តល់សេវាប្រកបដោយនវានុវត្តន៍និងការច្នៃប្រឌិត។
- ***ទិន្នន័យ ឯកសារ និងមធ្យោបាយដែលត្រូវប្រើសម្រាប់ផ្ទៀងផ្ទាត់(របាយការណ៍ ឧបករណ៍ សម្ភារៈ ទីតាំង ឬការសួរសំណួរផ្ទាល់មាត់)៖*** ចំណុចត្រូវពិនិត្យគឺ ១)ឯកសារដែលបានចងក្រងពាក់ព័ន្ធនឹងការអនុវត្តនវានុវត្តន៍និងការច្នៃប្រឌិតរបស់សាលារៀន ២)ភស្តុតាងដែលបង្ហាញពីការផ្សព្វផ្សាយ ឬការចែករំលែកនូវឯកសារដែលបានចងក្រងនោះដល់អង្គភាពដទៃ និង៣)ការសម្ភាសជាមួយថ្នាក់ដឹកនាំ គ្រូបង្រៀន បុគ្គលិកក្នុងសាលារៀន និងអង្គភាពដែលទទួលបានការផ្សព្វផ្សាយឬការចែករំលែក។
- ***របៀបនៃការដាក់ពិន្ទុពី០ ដល់៥ (គណនាពិន្ទុដោយបូកបញ្ចូលគ្នា)៖***

| | |
|---|---|
| ពិន្ទុ ២ | មានការចងក្រងជាឯកសារអំពីការអនុវត្តនវានុវត្តន៍ និងការច្នៃប្រឌិតដែលសាលារៀនទទួលបានជោគជ័យ |
| ពិន្ទុ ២ | បានផ្សព្វផ្សាយឬចែករំលែកបទពិសោធនៃការអនុវត្តនវានុវត្តន៍ និងការច្នៃប្រឌិតដល់អង្គភាពដទៃ |
| ពិន្ទុ ១ | មានការប្រមូលព័ត៌មានត្រឡប់(ការសរសើរនិងមតិស្ថាបនា)ពីអង្គភាពទទួលបានការចែករំលែកសម្រាប់ជាធាតុចូលក្នុងការកែលម្អ ឬពង្រីកការអនុវត្តក្នុងសាលារៀន |
| ពិន្ទុ ០ | គ្មានគ្រប់ចំណុចខាងលើ |

## សេចក្តីសន្និដ្ឋាន

ឯកសារណែនាំស្តីពីវិធីសាស្ត្រនៃការវាយតម្លៃនិងការទទួលស្គាល់សាលាបឋមសិក្សានិងអនុវិទ្យាល័យគំរូ ជាឯកសារមួយក្នុងចំណោមឯកសារសំខាន់ៗជាច្រើន សម្រាប់គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈគំរូគ្រប់កម្រិត ប្រើប្រាស់ជាមធ្យោបាយក្នុងការអនុវត្តការងារវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ប្រកបដោយតម្លាភាព សុក្រឹតភាព និងយុត្តិធម៌។ ឯកសារណែនាំនេះ មិនត្រឹមតែជួយដល់គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈគំរូប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងបាន ជួយដល់អង្គភាពសាលាបឋមសិក្សានិងអនុវិទ្យាល័យទូទាំងប្រទេស ក្នុងការប្រើប្រាស់ជាមធ្យោបាយសម្រាប់ ត្រៀមលក្ខណៈក្នុងការរៀបចំអង្គភាពរបស់ខ្លួន ដើម្បីចូលរួមប្រកួតប្រជែងការផ្តល់សេវាសាធារណៈគំរូដោយ ស្មើភាព ក្នុងគោលដៅបម្រើសេវាសាធារណៈជូនដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានរបស់ខ្លួន ប្រកបដោយ ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈគំរូទាំងអស់ គួរសិក្សាពីខ្លឹមសារនៃអត្ថបទឯកសារ ណែនាំនេះ និងត្រូវប្រកាន់ខ្ជាប់នូវវិធីសាស្ត្រនៃការវាយតម្លៃដែលផ្តល់ជូនក្នុងការអនុវត្តតួនាទីវាយតម្លៃរបស់ ខ្លួន ព្រមទាំងចូលរួមផ្សព្វផ្សាយខ្លឹមសារនៃឯកសារណែនាំនេះឱ្យជ្រាបដល់គណៈគ្រប់គ្រងសាលា និងភាគី ពាក់ព័ន្ធឱ្យចូលរួមរៀបចំ និងអភិវឌ្ឍសាលារបស់ខ្លួនតាមគន្លងនៃអង្គភាពផ្តល់សេវាអប់រំគំរូនេះ។ គណៈគ្រប់ គ្រងសាលាបឋមសិក្សា និងអនុវិទ្យាល័យ ត្រូវយកចិត្តទុកដាក់ស្វែងយល់ ផ្សព្វផ្សាយ ជូនដល់បុគ្គលិកអប់រំ សាលា ព្រមទាំងកៀរគរការចូលរួមពីលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស សហគមន៍ និងដៃគូអភិវឌ្ឍ ប្រឹងប្រែង អនុវត្តគោលគំនិតនៃការកសាងសាលារៀនគំរូដូចមានក្នុងឯកសារណែនាំនេះ។

សាលាបឋមសិក្សា និងអនុវិទ្យាល័យរដ្ឋ ផ្តល់សេវាប្រកបដោយគុណភាព នឹងរួមចំណែកធ្វើឱ្យយុវជន កម្ពុជាក្លាយជាពលរដ្ឋវិបុលដោយបញ្ញា និងជាទំពាំងបន្តវេនក្នុងការនាំកម្ពុជាឆ្ពោះទៅកាន់ឋានៈជាប្រទេស អភិវឌ្ឍន៍នៅឆ្នាំ២០៥០ តាមបំណងដ៏ពិសិដ្ឋរបស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ជូនដល់ប្រជាជនកម្ពុជា។

# គន្ថនិទ្ទេស

| ល.រ | ឈ្មោះឯកសារ |
|---|---|
| ១ | ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ |
| ២ | អនុក្រឹត្យលេខ ២៥ អនក្រ. ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ ស្តីពីអនាម័យសិក្សា |
| ៣ | អនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រងសំណល់រឹង |
| ៤ | អនុក្រឹត្យលេខ ៤៥៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិវាយតម្លៃសេវាសាធារណៈ និងឧបសម្ព័ន្ធ៖ ឯកសារណែនាំស្តីពីស្តង់ដាសេវាសាធារណៈ |
| ៥ | អនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន |
| ៦ | អនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ |
| ៧ | អនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧ ស្តីពីការកម្រិតរបបម៉ោងកំណត់ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែមសម្រាប់ការបង្រៀនក្នុងគ្រឹះស្ថានសិក្សាសាធារណៈ |
| ៨ | អនុក្រឹត្យលេខ ១៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧ ស្តីពីការគ្រប់គ្រងថង់ប្លាស្ទិក |
| ៩ | អនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ស្តីពីការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល |
| ១០ | រាជរដ្ឋាភិបាលកម្ពុជា, ឆ្នាំ២០០៦ គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ |
| ១១ | រាជរដ្ឋាភិបាលកម្ពុជា, ឆ្នាំ២០០៧ ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន |
| ១២ | រាជរដ្ឋាភិបាលកម្ពុជា, ឆ្នាំ២០១៣ គោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ |
| ១៣ | រាជរដ្ឋាភិបាលកម្ពុជា, ឆ្នាំ២០២៣ យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ |
| ១៤ | ឯកសារគោលការណ៍ណែនាំស្តីពីសាលាមេត្រីបរិស្ថាននៅកម្ពុជា ឆ្នាំ២០១៦ |
| ១៥ | ក្រសួងអប់រំ យុវជន និងកីឡា, សេចក្តីណែនាំលេខ២៥៦ អយក.សរណន ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០២ ស្តីពីការកំណត់និយាមប្រើប្រាស់មន្ត្រីរាជការសម្រាប់សាលាមត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាចំណេះទូទៅ និងសាលាគរុកោសល្យ |
| ១៦ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ឆ្នាំ២០១៤ គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធី |
| ១៧ | Ministry of Environment, Ministry of Education Youth and Sport, 2016 National Guidelines on Eco-Schools in Cambodia |

| | |
|---|---|
| ១៨ | ក្រសួងអប់រំ យុវជន និងកីឡា, ឆ្នាំ២០១៦ ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន |
| ១៩ | ក្រសួងអប់រំ យុវជន និងកីឡា, ឆ្នាំ២០១៧ ស្តង់ដានាយកសាលារៀន |
| ២០ | ក្រសួងអប់រំ យុវជន និងកីឡា, ឆ្នាំ២០១៨ ស្តង់ដាសាលាមធ្យមសិក្សាចំណេះទូទៅ |
| ២១ | ក្រសួងអប់រំ យុវជន និងកីឡា, ខែមីនា ឆ្នាំ២០១៨ សមិទ្ធិផលការអនុវត្តគោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា(ស្ទែម) |
| ២២ | ក្រសួងអប់រំ យុវជន និងកីឡា, ឆ្នាំ២០១៨ សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន |
| ២៣ | ក្រសួងអប់រំ យុវជន និងកីឡា, ឆ្នាំ២០១៨ គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ |
| ២៤ | ក្រសួងអប់រំ យុវជន និងកីឡា, ឆ្នាំ២០១៨ សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀនគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា |
| ២៥ | ក្រសួងមុខងារសាធារណៈ, សេចក្តីសម្រេចលេខ ៣១៣៦មស.សសរ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨ ស្តីពីការដាក់ឱ្យអនុវត្តតារាងលក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃនិងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល |
| ២៦ | ក្រសួងអប់រំ យុវជន និងកីឡា, ខែវិច្ឆិកា ឆ្នាំ២០១៨ យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ២០១៨-២០២៣ |
| ២៧ | ក្រសួងអប់រំ យុវជន និងកីឡា, ខែមិថុនា ឆ្នាំ២០១៩ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-២០២៣ |
| ២៨ | ក្រសួងអប់រំ យុវជន និងកីឡា, ឆ្នាំ២០១៩ ផែនទីបង្ហាញផ្លូវការអប់រំនៅកម្ពុជាឆ្នាំ២០៣០ |
| ២៩ | សាលាគរុកោសល្យនិងវិក្រឹត្យការខេត្ត និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ឆ្នាំ២០១៩, លិខិតលេខ ៨០១៥ សហវ.អថ ស្តីពីការកែសម្រួលគោលការណ៍ចំណាយមួយចំនួនសម្រាប់អនុវត្តមូលនិធិដំណើរការសាលារៀនសាធារណៈ |
| ៣០ | ក្រសួងអប់រំ យុវជន និងកីឡា, សេចក្តីណែនាំស្តីពីដំណើរការគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈតាមឆ្នាំសិក្សានីមួយៗ(សេចក្តីណែនាំលេខ ៦០ អយក.សណន ឆ្នាំ២០២០ ស្តីពីដំណើរការគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈឆ្នាំសិក្សា ២០២០-២០២១) |
| ៣១ | បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន, ឆ្នាំ២០២៣ បរិវត្តកម្មនៃវិស័យអប់រំ |
| ៣២ | ក្រសួងអប់រំ យុវជន និងកីឡា, ឆ្នាំ២០២៣ ស្តង់ដាសាលាបឋមសិក្សាគំរូ |
| ៣៣ | ក្រសួង អប់រំ យុវជន និងកីឡា, ឆ្នាំ២០២៣ ស្តង់ដាសាលាមធ្យមសិក្សាគំរូ |
| ៣៤ | ក្រសួងអប់រំ យុវជន និងកីឡា, ខែមិថុនា ឆ្នាំ២០២៤ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០២៤-២០២៨ |
| ៣៥ | John W, Santrock (2018). Educational Psychology, New York, USA, 6th Edition. |

**សហការរៀបចំដោយ**


**ក្រសួងមុខងារសាធារណៈ**

ផ្លូវអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរសព្ទ/ទូរសារ៖ +៨៥៥ ២៣ ៨៦៦ ៥០១

គេហទំព័រ៖ http//www.mcs.gov.kh

បណ្តាញទំនាក់ទំនងសង្គម៖ http//www.facebook.com/CivilServiceCambodia